# កិច្ចព្រមព្រៀងភាពជាដៃគូ

# សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ

# រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួម

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលតទៅនេះហៅថា "កម្ពុជា")និងរដ្ឋាភិបាលនៃអេមីរ៉ាត អារ៉ាប់រួម (ដែលតទៅនេះហៅថា "អេមីរ៉ាតអារ៉ាប់រួម")

ចាប់ពីពេលនេះតទៅ ហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"

**ដោយទទួលស្គាល់ថា** ចំណងសេដ្ឋកិច្ចនិងនយោបាយដ៏រឹងមាំរវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម ហើយបំណងធ្វើការពង្រឹងទំនាក់ទំនងទាំងនេះ តាមរយៈការបង្កើតតំបន់ពាណិជ្ជកម្មសេរី ដែលហេតុដូចនេះបង្កើតបាននូវទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងយូរអង្វែង

**ដោយប្តេជ្ញា** កសាងបន្ថែមលើសិទ្ធិនិងកាតព្វកិច្ចនានារបស់គូភាគីរៀងៗខ្លួន ក្រោមកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក

**ដោយយល់ដឹងថា** ការផ្លាស់ប្តូរបរិយាកាសសកលប្រកបដោយភាពស្មុគស្មាញនិងឆាប់រហ័សបាននាំមកដោយសកលភាវូបនីយកម្មនិងវឌ្ឍនភាពបច្ចេកវិទ្យា ដែលបង្ហាញពីបញ្ហាប្រឈមនិងឱកាសផ្នែកសេដ្ឋកិច្ចនិងយុទ្ធសាស្ត្រផ្សេងៗដល់គូភាគី

**ដោយប្តេជ្ញា** អភិវឌ្ឍនិងពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្មរបស់គូភាគី តាមរយៈសេរីភាវូបនីយកម្ម កិច្ចសម្រួលនិងការពង្រីកពាណិជ្ជកម្មលើទំនិញនិងសេវាកម្ម និងវិនិយោគនៅក្នុងផលប្រយោជន៍រួមនិងប្រយោជន៍ទៅវិញទៅមករបស់គូភាគី

**ដោយមានគោលបំណង** ជំរុញការផ្ទេរបច្ចេកវិទ្យានិងពង្រីកពាណិជ្ជកម្ម

**ដោយជឿជាក់ថា** ការបង្កើតតំបន់ពាណិជ្ជកម្មសេរីនឹងផ្តល់នូវបរិយាកាសអំណោយផល សុវត្ថិភាព និងភាពអាចប៉ាន់ប្រមាណទុកជាមុនបានបន្ថែមទៀត សម្រាប់ការជំរុញនិងការអភិវឌ្ឍ ទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងគូភាគី

**ដោយមានគោលបំណង** សម្រួលពាណិជ្ជកម្មដោយជំរុញនូវនីតិវិធីគយប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ដែលកាត់បន្ថយការចំណាយនិងធានាភាពអាចប៉ាន់ប្រមាណទុកជាមុនបាន សម្រាប់អ្នកនាំចូលនិងអ្នកនាំចេញរបស់គូភាគី

**ដោយប្តេជ្ញា** ដើម្បីគាំទ្រដល់កំណើននិងការអភិវឌ្ឍនៃមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យមដោយបង្កើនសមត្ថភាពនិងលទ្ធភាពរបស់គូភាគី ដើម្បីចូលរួមនិងទទួលបានផលប្រយោជន៍ពីឱកាសដែលបង្កើតដោយកិច្ចព្រមព្រៀងនេះ:

**ដោយមានគោលបំណង** បង្កើតក្របខណ្ឌច្បាប់និងពាណិជ្ជកម្មច្បាស់លាស់ ប្រកបដោយតម្លាភាព និង អាចប៉ាន់ប្រមាណទុកជាមុនបាន សម្រាប់ការធ្វើផែនការអាជីវកម្ម ដែលគាំទ្រដល់ការពង្រីកនៃពាណិជ្ជកម្ម និងការវិនិយោគបន្ថែមទៀត និង

**ដោយទទួលស្គាល់ថា** សិទ្ធិរបស់គូភាគីធ្វើការបញ្ញត្តិនិងដោះស្រាយ ដើម្បីក្បាបាននូវភោពបត់បែននៃគូភាគី ក្នុងការកំណត់អាទិភាពនៃច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងការពារគោលបំណងសុខុមាលភាពសាធារណៈ ស្របច្បាប់ ដូចជាសុខភាព សុវត្ថិភាព ការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិមានជីវិតឬមិនមាន ជីវិតដែលអាចបាត់បង់ទាំងស្រុង សុចរិតភាពនិងស្ថិរភោពនៃប្រព័ន្ធហិរញ្ញវត្ថុ សីលធម៌សាធារណៈ ជាដើម ដោយអនុលោមតាមសិទ្ធិនិងកាតព្វកិច្ចដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ

**បានព្រមព្រៀង** ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ធ្វើការចុះកិច្ចព្រមព្រៀងខាងក្រោម (ដែលតទៅនេះហៅថា "កិច្ចព្រមព្រៀងនេះ")៖

# ជំពូកទី១
# បទប្បញ្ញត្តិដើមនិងនិយមន័យទូទៅ

## មាត្រា១.១ _ ការបង្កើតតំបន់ពាណិជ្ជកម្មសេរី

គូភាគីបង្កើតតំបន់ពាណិជ្ជកម្មសេរីដោយអនុលោមទៅតាមសេចក្តីសម្រេចចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៩ ស្តីពីប្រព្រឹត្តកម្មដាច់ដោយឡែកនិងអនុគ្រោះបំផុត បដិភាព និងការចូលរួមយ៉ាងពេញលេញនៃប្រទេសកំពុងអភិវឌ្ឍ(ខបើកអំណាច)និងមាត្រា៥នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ("GATS") និងដើម្បីដំរុញឱកាសសម្រាប់ការចូលទីផ្សារនិងសេរីភាវូបនីយកម្មពាណិជ្ជកម្មចំពោះទំនិញ សេវាកម្ម និងវិនិយោគ ពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចនីជីថលនិងធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែស៊ីជម្រៅរវាងគូភាគី។

## មាត្រា១.២ _ និយមន័យទូទៅ

គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

**កិច្ចព្រមព្រៀងស្តីពីកសិកម្ម** សំដៅដល់កិច្ចព្រមព្រៀងស្តីពីកសិកម្មនៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ហូចថ្លៃ** សំដៅដល់កិច្ចព្រមព្រៀង ស្តីពីការអនុវត្តមាត្រាVI នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ១កនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**រដ្ឋបាលគយ** មានន័យថាអាជ្ញាធរសហព័ន្ធនៃអត្តសញ្ញាណ សញ្ជាតិ គយ និងសន្តិសុខកំពង់ផែសម្រាប់អេមីរ៉ាតអារ៉ាប់រួមនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រាប់កម្ពុជា

**កិច្ចព្រមព្រៀងស្តីពីការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រាVII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**ថ្ងៃ** សំដៅដល់ថ្ងៃប្រតិទិន រាប់បញ្ចូលទាំងថ្ងៃចុងសប្តាហ៍និងថ្ងៃឈប់សម្រាកផងដែរ

DSU សំដៅដល់ការព្រមព្រៀងស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងការដោះស្រាយវិវាទ នៅក្នុងឧបសម្ព័ន្ធ២ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

GATS សំដៅដល់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម នៅក្នុងឧបសម្ព័ន្ធ១ខ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

GATT ១៩៩៤ សំដៅដល់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ

១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

GPA សំដៅដល់កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈនៅក្នុងឧបសម្ព័ន្ធ៤ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**ប្រព័ន្ធសុខដុមនីយកម្ម** ឬ HS សំដៅដល់ប្រព័ន្ធសុខដុមនីយកម្មសម្រាប់បរិយាយមុខទំនិញនិងប្រព័ន្ធលេខកូដ រួមបញ្ចូលទាំងវិធានទូទៅនៃការបកស្រាយ កំណត់សម្គាល់ផ្នែក កំណត់សម្គាល់ដំពូក និងកំណត់សម្គាល់អនុចំណងជើង

**កិច្ចព្រមព្រៀងស្តីពីការផ្តល់អាជ្ញាបណ្ណនាំចូល** សំដៅដល់កិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាបណ្ណនាំចូលនៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**គណៈកម្មាធិការចម្រុះ** សំដៅដល់គណៈកម្មាធិការចម្រុះ ដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា ១៦.១ នៃកិច្ចព្រមព្រៀងនេះ

**វិធានការ** សំដៅដល់វិធានការណាក៏ដោយ ទោះបីជាក្នុងទម្រង់ច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសម្រេច ចំណាត់ការរដ្ឋបាល ឬទម្រង់ផ្សេងៗទៀត

**កិច្ចព្រមព្រៀងការការពារ** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការការពារក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀង SCM** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការទប់ទល់ក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀង SPS** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ ក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀង TBT** សំដៅដល់កិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្មក្នុងឧបសម្ព័ន១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀង TRIPS** សំដៅដល់កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ក្នុងឧបសម្ព័ន្ធ១គ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

**WTO** សំដៅដល់អង្គការពាណិជ្ជកម្មពិភពលោក និង

**កិច្ចព្រមព្រៀង WTO** សំដៅដល់កិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានចុះហត្ថលេខានៅទីក្រុងម៉ារ៉ាកេស នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤។

**មាត្រា១.៣ _ គោលបំណង**

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីធ្វើសេរីភាវូបនីយកម្មនិងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងវិនិយោគរវាងគូភាគី ដោយអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា១.៤ _ វិសាលភាពភូមិសាស្ត្រ**

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តៈ

(ក) សម្រាប់អេមីរ៉ាតអារ៉ាប់រួម ដែនដីគោករបស់ខ្លួន ដែនទឹកខាងផ្ទៃក្នុង រួមបញ្ចូលទាំងតំបន់សេរីរបស់ខ្លួន ដែនសមុទ្រ រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រទាំងនោះ និងដែនអាកាសពីលើដែនដីនិងដែនទឹក ព្រមទាំងតំបន់តភ្ជាប់ តំបន់ខ្ពង់រាបបាតសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលអេមីរ៉ាតអារ៉ាប់រួមមានអធិបតេយ្យភាព សិទ្ធិអធិបតេយ្យ ឬ យុត្តាធិការ ដូចដែលបានកំណត់ក្នុងច្បាប់របស់ខ្លួន ហើយដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។

(ខ) សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតំបន់សមុទ្រដែលរួមមានខ្ពង់រាបបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងផ្នែកខាងក្រៅនៃដែនសមុទ្រនិងដែនអាកាសដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យ ឬ យុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

**មាត្រា១.៥ _ ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត**

១- គូភាគីអះអាងអំពីសិទ្ធិនិងកាតព្វកិច្ចដែលមានស្រាប់របស់ខ្លួន ពាក់ព័ន្ធនឹងគ្នាទៅវិញទៅមកក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលគូភាគីជា ភាគី។

២- ក្នុងករណីមានអសង្គតិភាពណាមួយរវាងកិច្ចព្រមព្រៀងនេះនិងកិច្ចព្រមព្រៀងផ្សេងទៀតដែលគូភាគីទាំងពីរជាភាគី គូភាគីត្រូវពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមកភ្លាម ក្នុងគោលបំណងដើម្បីស្វែងរកដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាង។

**មាត្រា១.៦ _ រដ្ឋាភិបាលថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន**

១- ភាគីនីមួយៗត្រូវចាត់វិធានការសមស្របទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីធានាឱ្យបាននូវអនុលោមភាពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដោយថ្នាក់កណ្តាលនិងទឹកន្លែងដែលអាចអនុវត្តបានដោយរដ្ឋាភិបាលថ្នាក់មូលដ្ឋាននិងអាជ្ញាធរ និងចំពោះស្ថាប័នមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តអំណាចរដ្ឋាភិបាល ដែលត្រូវបានធ្វើប្រតិភូកម្មដោយរដ្ឋាភិបាលថ្នាក់កណ្តាល រដ្ឋាភិបាលថ្នាក់មូលដ្ឋាននិងអាជ្ញាធរក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២- បទប្បញ្ញត្តិនេះត្រូវបានបកស្រាយនិងអនុវត្ត ដោយអនុលោមតាមគោលការណ៍ដែលមានចែងក្នុងកថាខណ្ឌទី១២ នៃមាត្រាXXIV នៃកិច្ចព្រមព្រៀង GATT ១៩៩៤ និងកថាខណ្ឌទី៣ នៃមាត្រា នៃកិច្ចព្រមព្រៀង GATS។

**មាត្រា១.៧ _ តម្លាភាព**

១- ភាគីនីមួយៗត្រូវបោះពុម្ពផ្សាយឬធ្វើឱ្យអាចរកបានជាសាធារណៈនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត របស់ខ្លួនក៏ដូចជាកិច្ចព្រមព្រៀងអន្តរជាតិរៀងៗខ្លួន ដែលអាចមានឥទ្ធិពលដល់ដំណើរការនៃកិច្ច ព្រមព្រៀងនេះ។

២- ដោយមិនប៉ះពាល់ដល់មាត្រា១.៨ ភាគីនីមួយៗត្រូវឆ្លើយតបក្នុងរយៈពេលសមរម្យចំពោះសំណួរ ជាក់លាក់នានានិងផ្តល់តាមការស្នើសុំនូវព័ត៌មានដល់គ្នាទៅវិញទៅមកលើបញ្ហានានាដែលមាន ចែងក្នុងកថាខណ្ឌទី១។

**មាត្រា១.៨ _ ព័ត៌មានសម្ងាត់**

១- ភាគីនីមួយៗត្រូវរក្សាការសម្ងាត់នៃព័ត៌មាន ដែលត្រូវបានកំណត់ថាសម្ងាត់ដោយភាគីម្ខាងទៀត ដោយអនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួន។

២- ពុំមានបញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតម្រូវឱ្យភាគីម្ខាងលាតត្រដាងនូវព័ត៌មាន សម្ងាត់ ដែលការលាតត្រដាងព័ត៌មាននោះនឹងរារាំងដល់ការអនុវត្តច្បាប់របស់ភាគី ឬផ្ទុយទៅនឹង ផលប្រយោជន៍សាធារណៈ ឬដែលនឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ នៃប្រតិបត្តិករសេដ្ឋកិច្ចណាមួយនោះឡើយ។

# ជំពូកទី២
# ពាណិជ្ជកម្មទំនិញ

## មាត្រា២.១ _ និយមន័យ

គោលបំណងនៃជំពូកនេះ៖

**ពន្ធគយ** សំដៅលើពន្ធឬបន្ទុកដែលពាក់ព័ន្ធនឹងការនាំចូលផលិតផល រួមទាំងទម្រង់នៃពន្ធបន្ថែមឬការគិតថ្លៃបន្ថែមទាក់ទងនឹងការនាំចូលនេះ ប៉ុន្តែមិនរាប់បញ្ចូលនូវ៖

(ក) បន្ទុកផ្សេងៗ ដែលសមមូលនឹងពន្ធក្នុងស្រុកដែលត្រូវបង់ស្របនឹងមាត្រាIII នៃGATT ឆ្នាំ ១៩៩៤

(ខ) ពន្ធប្រឆាំងនឹងការលក់បង្ហូចថ្លៃឬពន្ធប៉ះប៉ូវដែលត្រូវបានអនុវត្តស្របជាមួយនឹងមាត្រាVI នៃGATT ឆ្នាំ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ហូចថ្លៃ និងកិច្ចព្រមព្រៀងSCM ឬ

(គ) កម្រៃឬបន្ទុកផ្សេងទៀតពាក់ព័ន្ធនឹងការនាំចូលដែលមានតម្លៃសមមាត្រនឹងថ្លៃសេវាបានប្រើប្រាស់ ហើយដែលមិនតំណាងឱ្យការការពារដោយផ្ទាល់ឬដោយប្រយោលសម្រាប់ទំនិញក្នុងស្រុក ឬការយកពន្ធលើការនាំចូលសម្រាប់គោលបំណងសារពើពន្ធ។

**ការផ្តល់អាជ្ញាបណ្ណនាំចូល** សំដៅដល់នីតិវិធីរដ្ឋបាលដែលតម្រូវឱ្យមានការដាក់ស្នើពាក្យសុំឬឯកសារផ្សេងទៀត(ក្រៅពីតម្រូវការជាទូទៅសម្រាប់គោលបំណងបញ្ជូនទំនិញ) ទៅស្ថាប័នរដ្ឋបាលពាក់ព័ន្ធដែលជាលក្ខខណ្ឌតម្រូវជាមុនសម្រាប់ការនាំចូលទៅក្នុងដែនដីនៃភាគីនាំចូល។

**ដំណើរការខាងក្នុង** សំដៅដល់នីតិវិធីគយដែលទំនិញមួយចំនួនអាចនាំចូលទៅក្នុងដែនដីគយដោយមានលក្ខខណ្ឌបន្ទុបន្ថយពីការបង់អាករនិងពន្ធនាំចូល ដោយឈរលើមូលដ្ឋានថាទំនិញទាំងនោះត្រូវបានបម្រុងទុកសម្រាប់ការផលិត ការកែច្នៃ ឬការជួសជុល និងការនាំចេញជាបន្តបន្ទាប់។

## មាត្រា២.២ _ វិសាលភាព

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តលើពាណិជ្ជកម្មទំនិញរវាងគូភាគី។

## មាត្រា២.៣ _ ប្រព្រឹត្តកម្មជាតិ

គូភាគីត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិលើទំនិញនៃភាគីសមាជិកម្ខាងទៀត ស្របតាមមាត្រាIII នៃGATT ឆ្នាំ ១៩៩៤ រាប់បញ្ចូលទាំងកំណត់បកស្រាយ។ ក្នុងគោលបំណងនេះ មាត្រាIII នៃGATT ឆ្នាំ១៩៩៤ និងកំណត់បកស្រាយត្រូវបានដាក់បញ្ចូលនិងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះនិង*ត្រូវយកមកអនុវត្តដូចគ្នា*។

## មាត្រា២.៤ _ ការកាត់បន្ថយឬលុបបំបាត់អត្រាពន្ធគយ

១- លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ រួមទាំងដូចដែលបានកំណត់យ៉ាងច្បាស់នៅក្នុងតារាងសន្យាពន្ធគយរបស់ភាគីសមាជិកនីមួយៗ ដូចមាននៅក្នុងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ) ភាគីសមាជិកមិនត្រូវបង្កើនអត្រាពន្ធគយដែលមានស្រាប់ឬអនុម័តពន្ធគយថ្មីណាមួយលើទំនិញមានដើមកំណើតរបស់ភាគីសមាជិកម្ខាងទៀតឡើយ។

២- នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីកម្ពុជាត្រូវលុបបំបាត់ឬកាត់បន្ថយពន្ធគយរបស់ខ្លួនលើទំនិញដែលមានដើមកំណើតមកពីភាគីអេមីរ៉ាតអារ៉ាប់រួម ស្របតាមឧបសម្ព័ន្ធ២ក (តារាងសន្យាពន្ធគយរបស់កម្ពុជា) ហើយភាគីអេមីរ៉ាតអារ៉ាប់រួមត្រូវលុបបំបាត់ឬកាត់បន្ថយពន្ធគយរបស់ខ្លួនលើទំនិញដែលមានដើមកំណើតមកពីភាគីកម្ពុជាស្របតាមឧបសម្ព័ន្ធ២ខ (តារាងសន្យាពន្ធគយរបស់អេមីរ៉ាតអារ៉ាប់រួម)។

៣- នៅពេលភាគីសមាជិកមួយកាត់បន្ថយនូវអត្រាពន្ធគយអនុវត្តសម្រាប់ប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត(តទៅនេះហៅថា "MFN") អត្រាពន្ធនោះនឹងត្រូវអនុវត្តចំពោះទំនិញដែលមានដើមកំណើតរបស់ភាគីសមាជិកម្ខាងទៀត ដរាបណាវាទាបជាងអត្រាពន្ធគយលើទំនិញដូចគ្នាដែលគណនាដោយអនុលោមតាមឧបសម្ព័ន្ធ២ក(តារាងសន្យាពន្ធគយរបស់កម្ពុជា) ក្នុងករណីរបស់ភាគីកម្ពុជាឬឧបសម្ព័ន្ធ២ខ(តារាងសន្យាពន្ធគយរបស់អេមីរ៉ាតអារ៉ាប់រួម) ក្នុងករណីរបស់ភាគីអេមីរ៉ាតអារ៉ាប់រួម។

## មាត្រា២.៥ _ ការពន្លឿនឬធ្វើឱ្យប្រសើរឡើងនូវការសន្យាពន្ធគយ

១- តាមការស្នើរបស់ភាគីសមាជិកមួយ ភាគីសមាជិកម្ខាងទៀតត្រូវពិគ្រោះជាមួយភាគីសមាជិកដែលស្នើសុំដើម្បីពិចារណាលើការពន្លឿនឬធ្វើឱ្យប្រសើរឡើងលើវិសាលភាពនៃការលុបបំបាត់ពន្ធគយដូចមានចែងក្នុងតារាងសន្យាពន្ធគយនៅក្នុងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ)។

២- ការប្តេជ្ញាចិត្តបន្ថែមទៀតរវាងគូភាគី ក្នុងការពន្លឿនឬធ្វើឱ្យប្រសើរឡើងវិសាលភាពនៃការលុបបំបាត់ពន្ធគយលើទំនិញមួយ(ឬរមបញ្ចូលទំនិញមួយទៅក្នុងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ)) ត្រូវយកមកជំនួសអត្រាពន្ធគយឬប្រភេទដំណាក់កាលកាត់បន្ថយពន្ធគយដែលបានកំណត់នៅក្នុងតារាងសន្យារបស់ភាគីនីមួយៗ លើការបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ។

៣- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវហាមឃាត់ភាគីសមាជិកណាមួយពីការពន្លឿនជាឯកតោភាគីឬធ្វើឱ្យប្រសើរឡើងនូវវិសាលភាពនៃការលុបបំបាត់ពន្ធគយដែលមានចែងក្នុងតារាងសន្យាពន្ធគយរបស់ខ្លួនក្នុងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ) លើទំនិញមានដើមកំណើតនោះទេ។ ការពន្លឿនជាឯកតោភាគីឬធ្វើឱ្យប្រសើរឡើងនូវវិសាលភាពនៃការលុបបំបាត់ពន្ធគយបែបនេះ នឹងមិនជំនួសជាអចិន្ត្រៃយ៍នូវអត្រាពន្ធគយឬប្រភេទដំណាក់កាលកាត់បន្ថយពន្ធគយដែលបានកំណត់នៅក្នុងតារាងសន្យាពន្ធគយរបស់ខ្លួន ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីសមាជិកនោះ ក្នុងការដំឡើងពន្ធគយត្រឡប់ទៅកម្រិតដែលបានកំណត់ក្នុងតារាងសន្យាពន្ធគយដែលមានក្នុងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ) បន្ទាប់ពីការកាត់បន្ថយជាឯកតោភាគីវិញដែរ។

## មាត្រា២.៦ _ ការធ្វើចំណាត់ថ្នាក់ទំនិញនិងការផ្នែរតារាងសន្យាពន្ធគយ

១- ការធ្វើចំណាត់ថ្នាក់ទំនិញនៅក្នុងពាណិជ្ជកម្មរវាងគូភាគី ត្រូវមានកំណត់ក្នុងតារាងនាមវលីរបស់ភាគីនីមួយៗ ដោយអនុលោមតាមប្រព័ន្ធសុខដុម ព្រមទាំងកំណត់សម្គាល់គតិយុត្តនិងវិសោធនកម្មរបស់ភាគីនីមួយៗ។

២- ភាគីសមាជិកនីមួយៗត្រូវបានាថា ការផ្នែរតារាងសន្យាពន្ធគយរបស់ខ្លួនមិនផ្តល់ប្រព្រឹត្តកម្មដែលមានអំណោយផលចំពោះទំនិញ ដែលមានដើមកំណើតរបស់ភាគីសមាជិកម្ខាងទៀតតិចជាងអ្វីដែលមានចែងក្នុងតារាងសន្យាពន្ធគយរបស់ខ្លួនដូចនៅក្នុងឧបសម្ព័ន្ធ២ក(តារាងសន្យាពន្ធគយរបស់កម្ពុជា) ឬឧបសម្ព័ន្ធ២ខ(តារាងសន្យាពន្ធគយរបស់អេមីរ៉ាតអារ៉ាប់រួម) នោះទេ។

៣- ការផ្នែរតារាងសន្យាពន្ធគយត្រូវធ្វើឡើងដោយអនុលោមតាមវិធីសាស្ត្រនិងគោលការណ៍ណែនាំដែលត្រូវអនុម័តដោយអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញ។

៤- ភាគីសមាជិកអាចដាក់ចេញនូវការបំបែកបន្ទាត់ពន្ធគយថ្មី លុះត្រាតែលក្ខខណ្ឌអនុគ្រោះដែលអនុវត្តនៅក្នុងការបំបែកបន្ទាត់ពន្ធគយថ្មី មិនមានការអនុគ្រោះតិចជាងអ្វីដែលបានអនុវត្តដំបូង។

## មាត្រា២.៧ _ ការរឹតត្បិតការនាំចេញនិងនាំចូល

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីសមាជិកមិនអាចដាក់ចេញ ឬរក្សាការហាមឃាត់ ឬការរឹតត្បិតលើការនាំចូលទំនិញណាមួយរបស់ភាគីសមាជិកម្ខាងទៀត ឬលើការនាំចេញ ឬការលក់សម្រាប់ការនាំចេញទំនិញទៅកាន់ដែនដីនៃភាគីសមាជិកម្ខាងទៀត លើកលែងតែអនុលោមតាមមាត្រាXI នៃGATT ឆ្នាំ១៩៩៤ និងកំណត់បកស្រាយ។ ក្នុងន័យនេះ មាត្រាXI នៃGATT ឆ្នាំ១៩៩៤ និងកំណត់ បកស្រាយ ត្រូវបញ្ចូលជាផ្នែកនៃកិច្ចព្រមព្រៀងនេះ និង*ត្រូវយកមកអនុវត្តដូចគ្នា*។

## មាត្រា២.៨ _ ការផ្តល់អាជ្ញាបណ្ណនាំចូល

១- ភាគីសមាជិកមិនត្រូវអនុម័តឬរក្សាវិធានការដែលមានអសង្គតិភាពទៅនឹងកិច្ចព្រមព្រៀងស្តីពីការផ្តល់អាជ្ញាបណ្ណនាំចូល[1] ដែលត្រូវបានដាក់បញ្ចូលក្នុងនិងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ និង*ត្រូវយកមកអនុវត្តដូចគ្នា*។

២- មុននឹងអនុវត្តនីតិវិធីផ្តល់អាជ្ញាបណ្ណនាំចូលថ្មីឬការកែប្រែនីតិវិធីផ្តល់អាជ្ញាបណ្ណនាំចូលណាមួយ ភាគីសមាជិកត្រូវផ្សព្វផ្សាយនៅក្នុងលក្ខណៈដែលអនុញ្ញាតឱ្យរដ្ឋាភិបាលនិងពាណិជ្ជករដឹងពីនីតិវិធី រួមទាំងតាមរយៈការបោះពុម្ពផ្សាយនៅលើគេហទំព័រផ្លូវការរបស់រដ្ឋាភិបាលផងដែរ។ តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ភាគីសមាជិកត្រូវផ្តាស់ប្តូរព័ត៌មានទាក់ទងនឹងការអនុវត្តរបស់ខ្លួនក្នុងរយៈពេលសមស្របមួយ។

---

[1] សម្រាប់គោលបំណងនៃកថាខណ្ឌ១ និងសម្រាប់ភាពច្បាស់លាស់ ក្នុងការកំណត់ថាតើវិធានការមួយមិនស្របនឹងកិច្ចព្រមព្រៀងស្តីពីការផ្តល់អាជ្ញាបណ្ណនាំចូល ភាគីទាំងពីរត្រូវប្រើប្រាស់និយមន័យនៃ "ការផ្តល់អាជ្ញាបណ្ណនាំចូល" ដែលមាននៅក្នុងកិច្ចព្រមព្រៀងនោះ។

**មាត្រា២.៩ – ការខាយតម្លៃពន្ធគយ**

ភាគីទាំងពីរត្រូវកំណត់តម្លៃពន្ធគយនៃទំនិញដែលធ្វើពាណិជ្ជកម្មរវាងគ្នា ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាVII នៃGATT ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និង*ត្រូវយកមកអនុវត្តដូចគ្នា*។

**មាត្រា២.១០ – ការឧបត្ថម្ភធនលើការនាំចេញ**

ភាគីសមាជិកមិនត្រូវអនុម័តឬរក្សាទុកការឧបត្ថម្ភធនលើការនាំចេញចំពោះទំនិញណាមួយដែលត្រូវនាំចេញទៅកាន់ដែនដីនៃភាគីសមាជិកម្ខាងទៀត អនុលោមតាមកិច្ចព្រមព្រៀង SCM និងកិច្ចព្រមព្រៀងស្តីពីកសិកម្មនោះទេ។

**មាត្រា២.១១ – ការពិគ្រោះការពារជញ្ជីងទូទាត់**

១- គូភាគីត្រូវជៀសវាងការដាក់វិធានការពិគ្រោះសម្រាប់គោលបំណងជញ្ជីងទូទាត់។

២- វិធានការបែបនេះដែលធ្វើឡើងសម្រាប់ពាណិជ្ជកម្មទំនិញត្រូវអនុវត្តអនុលោមតាមមាត្រាXII នៃGATT ឆ្នាំ១៩៩៤ និងការពន្យល់ស្តីពីបទប្បញ្ញត្តិស្តីពីជញ្ជីងទូទាត់នៃGATT ឆ្នាំ១៩៩៤ ដែលជាបទប្បញ្ញត្តិដែលត្រូវបានដាក់បញ្ចូលក្នុងនិងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ និង*ត្រូវយកមកអនុវត្តដូចគ្នា*។

**មាត្រា២.១២ – តម្រូវនិតិវិធីបរិបាលរដ្ឋបាល**

១- អនុលោមតាមមាត្រាVIII:1 នៃGATT ឆ្នាំ១៩៩៤ កំណត់បកស្រាយនិងមាត្រា៦ នៃកិច្ចព្រមព្រៀងWTO ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ភាគីសមាជិកនីមួយៗត្រូវធានាថាកម្រៃនិងបន្ទុកផ្សេងៗគ្រប់ប្រភេទ(ក្រៅពីពន្ធគយលើការនាំចូលនិងការនាំចេញ បន្ទុកផ្សេងដែលសមមូលនឹងពន្ធក្នុងស្រុកឬបន្ទុកក្នុងស្រុកផ្សេងទៀតត្រូវបានអនុវត្តដោយសង្គតិភាពទៅតាមមាត្រាIII:2 នៃGATT ឆ្នាំ១៩៩៤ និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃនិងពន្ធប៉ះប៉ូវ) ដែលដាក់បន្ទុកលើឬពាក់ព័ន្ធនឹងការនាំចូលឬការនាំចេញ ត្រូវបានកំណត់ត្រឹមចំនួនប្រហាក់ប្រហែលទៅនឹងថ្លៃសេវាដែលបានប្រើ ដែលមិនត្រូវបានគណនាដោយផ្អែកលើការគិតពន្ធតាមតម្លៃនិងមិនត្រូវធ្វើឡើងក្នុងន័យការពារទំនិញក្នុងស្រុកដោយប្រយោលឬការយកពន្ធលើការនាំចូលឬនាំចេញសម្រាប់គោលបំណងសារពើពន្ធឡើយ។

២- ភាគីសមាជិកនីមួយៗត្រូវបោះពុម្ពផ្សាយភ្លាមៗ និងត្រូវផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតនូវរាល់ព័ត៌មានលម្អិតនៃកម្រៃនិងថ្លៃសេវាដែលភាគីសមាជិកបានដាក់បន្ទុកលើការនាំចូលនិងនាំចេញ។

**មាត្រា២.១៣ – និទានការមិនរើសអើង**

១- លើកលែងតែមានចែងផ្សេងពីនេះ ភាគីសមាជិកមិនត្រូវអនុម័តឬរក្សាវិធានការមិនរើសអើងលើការនាំចូលទំនិញណាមួយរបស់ភាគីសមាជិកម្ខាងទៀតឬលើការនាំចេញទំនិញដែលត្រូវនាំចេញទៅកាន់ដែនដីនៃភាគីសមាជិកម្ខាងទៀតនោះទេ លើកលែងតែអនុលោមតាមសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោម WTO ឬកិច្ចព្រមព្រៀងនេះ។

២- ភាគីសមាជិកនីមួយៗត្រូវធានាថា ច្បាប់ បញ្ញត្តិ នីតិវិធី និងសេចក្តីវិនិច្ឆ័យរដ្ឋបាលរបស់ខ្លួនពាក់ព័ន្ធនឹងវិធានការមិនមែនពន្ធមិនត្រូវបានរៀបចំ អនុម័តឬអនុវត្ត ដោយមានបំណងឬផលប៉ះពាល់ក្នុងការបង្កជាឧបសគ្គដែលមិនចាំបាច់ក្នុងពាណិជ្ជកម្មជាមួយភាគីសមាជិកម្ខាងទៀតឡើយ។

៣- ប្រសិនបើភាគីសមាជិកណាមួយពិចារណាថា វិធានការមិនមែនពន្ធរបស់ភាគីសមាជិកម្ខាងទៀតកំពុងបង្កជាឧបសគ្គដែលមិនចាំបាច់ចំពោះពាណិជ្ជកម្ម ភាគីសមាជិកនោះអាចលើកយកវិធានការមិនមែនពន្ធនោះទៅឱ្យអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញធ្វើការត្រួតពិនិត្យ ដោយជូនដំណឹងតាមរយៈលិខិតស្នើសុំជាលាយលក្ខណ៍អក្សរយ៉ាងតិច៣០ថ្ងៃ មុនកាលបរិច្ឆេទនៃការរៀបចំកិច្ចប្រជុំនៃអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញ។ ការលើកឡើងពីវិធានការមិនមែនពន្ធសម្រាប់ការពិនិត្យត្រូវរួមបញ្ចូលហេតុផលសម្រាប់ការលើកឡើងរបស់ខ្លួន របៀបដែលវិធានការនោះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ពាណិជ្ជកម្មរវាងគូភាគី ហើយប្រសិនបើអាចធ្វើទៅបាន ភ្ជាប់មកជាមួយនូវសំណើនៃដំណោះស្រាយផងដែរ។ អនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញត្រូវពិនិត្យមើលវិធានការនេះភ្លាម ក្នុងគោលបំណងធានាឱ្យបាននូវដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាងចំពោះបញ្ហានេះ។ ការត្រួតពិនិត្យដោយអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញគឺពុំមានប៉ះពាល់ដល់សិទ្ធិនៃភាគីសមាជិកណាមួយនៅក្រោមជំពូកទី១៤(ការដោះស្រាយវិវាទ) ឡើយ។

## មាត្រា២.១៤ _ សហគ្រាសពាណិជ្ជកម្មរបស់រដ្ឋ

មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីរារាំងភាគីសមាជិកណាមួយពីការរក្សាឬបង្កើតសហគ្រាសពាណិជ្ជកម្មរបស់រដ្ឋ ដោយអនុលោមតាមមាត្រាXVII នៃGATT ឆ្នាំ ១៩៩៤ និងការពន្យល់ស្តីពីការបកស្រាយមាត្រាXVII នៃGATT ឆ្នាំ១៩៩៤ និង*ត្រូវយកមកអនុវត្តដូចគ្នា*។

## មាត្រា២.១៥ _ ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិក

១- អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យការនាំចូលតាមរបបប្រវេសន៍កាលិកដោយមិនមានការបង់ពន្ធគយ សម្រាប់មុខទំនិញនាំចូលពីភាគីសមាជិកម្ខាងទៀតដោយមិនគិតពីប្រភពដើម ដូចជា៖

(ក) ឧបករណ៍វិជ្ជាជីវៈនិងវិទ្យាសាស្ត្រ រួមទាំងគ្រឿងបន្លាស់ ឧបករណ៍សម្រាប់សារព័ត៌មានឬទូរទស្សន៍ កម្មវិធី និងឧបករណ៍សម្រាប់ការផ្សព្វផ្សាយនិងកាពយន្ត ដែលចាំបាច់សម្រាប់អនុវត្តសកម្មភាពធុរកិច្ច ពាណិជ្ជកម្ម ឬវិជ្ជាជីវៈរបស់បុគ្គលដែលមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ការនាំចូលបណ្តោះអាសន្នដោយអនុលោមតាមច្បាប់នៃភាគីនាំចូល

(ខ) ទំនិញដែលប្រើប្រាស់សម្រាប់ការដាក់តាំង ការបង្ហាញ ឬការប្រើប្រាស់នៅរោងមហោស្រពការតាំងពិព័រណ៍ ឬព្រឹត្តិការណ៍ស្រដៀងគ្នាផ្សេងទៀត

(គ) គំរូពាណិជ្ជកម្ម ភាពយន្តផ្សាយពាណិជ្ជកម្ម និងការថតសំឡេង

(ឃ) ទំនិញដែលត្រូវបានអនុញ្ញាតសម្រាប់គោលបំណងកីឡា

(ង) កុងតឺន័រនិងប៉ាឡែតដែលប្រើសម្រាប់ដឹកជញ្ជូនគ្រឿងបរិក្ខារឬប្រើសម្រាប់បំពេញបន្ថែម និង

(ច) ទំនិញដែលបានបញ្ចូលសម្រាប់ដំណើរការខាងក្នុង។

๒- ភាគីសមាជិកនីមួយៗត្រូវពន្យារពេលកំណត់ សម្រាប់ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិក លើសពីរយៈពេលដែលបានកំណត់ដំបូង ផ្អែកតាមការស្នើសុំរបស់អ្នកនាំចូលនិងសម្រាប់ហេតុផលដែលអាជ្ញាធរគយរបស់ខ្លួនចាត់ទុកថាមានសុពលភាព។

๓- ភាគីសមាជិកមិនត្រូវដាក់លក្ខខណ្ឌ ក្នុងការនាំចូលទំនិញតាមរបបប្រវេសន៍កាលិកនូវទំនិញដូចដែលមានចែងនៅក្នុងកថាខណ្ឌ១ ឡើយ ក្រៅតែពីតម្រូវឱ្យទំនិញនោះ៖

(ក) មិនត្រូវបានលក់ឬជួលនៅលើដែនដីរបស់ខ្លួន

(ខ) ត្រូវតម្កល់និមុត្តិធានា ក្នុងចំនួនមួយដែលមិនលើសពីពន្ធគយនិងអាករផ្សេងទៀត ដែលនឹងត្រូវដាក់តម្កល់នៅពេលនាំចូលឬការនាំចូលចុងក្រោយ ដែលអាចនឹងបង្វែរសងវិញបាននៅពេលធ្វើការនាំចេញទំនិញទៅវិញ

(គ) អាចកំណត់អត្តសញ្ញាណបាន នៅពេលនាំចេញ

(ឃ) ត្រូវនាំចេញទៅវិញ ស្របតាមរយៈពេលដែលបានផ្តល់ឱ្យសម្រាប់ការនាំចូលជាបណ្តោះអាសន្នអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ពាក់ព័ន្ធនឹងគោលបំណងនៃការនាំចូលតាមរបបប្រវេសន៍កាលិក

(ង) ត្រូវបានអនុញ្ញាតក្នុងបរិមាណមិនលើសពីបរិមាណសមស្របសម្រាប់ការប្រើប្រាស់ណាមួយ

(ច) បើមិនដូច្នេះទេ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងដែនដីរបស់ភាគីសមាជិកនាំចូល តាមច្បាប់របស់ខ្លួន។

๔- ប្រសិនបើមានលក្ខខណ្ឌណាមួយដែលភាគីសមាជិកមួយដាក់ចេញក្រោមកថាខណ្ឌ៣ មិនត្រូវបានបំពេញ ភាគីសមាជិកនោះអាចអនុវត្តពន្ធគយនិងអាករ ឬបន្ទុកផ្សេងៗ ដែលជាធម្មតាត្រូវបានដាក់បន្ថែមពីលើការនាំចេញទំនិញនិងបន្ទុកផ្សេងៗទៀត ឬការដាកពិន័យដែលមានចែងនៅក្នុងច្បាប់របស់ខ្លួន។

๕- តាមរយៈអាជ្ញាធរគយរបស់ខ្លួន ភាគីសមាជិកនីមួយៗត្រូវអនុម័តនិងរក្សានីតិវិធីដែលផ្តល់សម្រាប់ការដោះលែងឱ្យបានហ័សនូវទំនិញដែលបាននាំចូលក្រោមមាត្រានេះ។ នីតិវិធីបែបនេះត្រូវចែងថា នៅពេលដែលទំនិញអមមកជាមួយជនជាតិឬនិវេសនជនរបស់ភាគីសមាជិកម្ខាងទៀតដែលកំពុងស្វែងរកការចូលបណ្តោះអាសន្ន នោះទំនិញនឹងត្រូវដោះលែងក្នុងពេលដំណាលគ្នាជាមួយនឹងការចូលរបស់ជនជាតិឬនិវេសនជននោះ តាមលទ្ធភាពដែលអាចធ្វើបាន។

๖- ភាគីសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យទំនិញ ដែលត្រូវបាននាំចូលដោយរបបប្រវេសន៍កាលិកដូចមានចែងក្នុងមាត្រានេះ អាចនាំចេញទៅវិញតាមកំពង់ផែគយណាមួយក្រៅពីកំពង់ផែគយដែលទំនិញនោះត្រូវបានអនុញ្ញាតឱ្យនាំចូល អនុលោមតាមនីតិវិធីគយរបស់ខ្លួន។

๗- ភាគីសមាជិកនីមួយៗត្រូវផ្តល់ថាអ្នកនាំចូលទំនិញដែលទទួលស្គាល់តាមមាត្រានេះ មិនត្រូវទទួលខុសត្រូវចំពោះការខកខានក្នុងការនាំចេញទំនិញ ដែលមានការបង្ហាញជាភស្តុតាងសមស្របដល់ភាគីនាំចូលថា ទំនិញត្រូវបានបំផ្លាញក្នុងរយៈពេលដែលបានកំណត់សម្រាប់ការនាំចូលតាមរបបប្រវេសន៍កាលិកឬការពន្យារដែលស្របច្បាប់ណាមួយ។ ភាគីសមាជិកអាចដាក់លក្ខខណ្ឌបន្ទុរបន្ថយការទទួលខុសត្រូវក្រោមកថាខណ្ឌនេះ ដោយតម្រូវឱ្យអ្នកនាំចូលទទួលបានការយល់ព្រមជាមុនពីអាជ្ញាធរគយនៃភាគីនាំចូល មុនពេលទំនិញអាចត្រូវបានបំផ្លាញ។

**មាត្រា២.១៦ _ ការនាំចូលទំនិញឡើងវិញក្រោយពេលជួសជុលឬផ្លាស់ប្តូរ**

១- ដោយមិនគិតពីប្រភពដើមនៃទំនិញ ភាគីសមាជិកមិនត្រូវអនុវត្តពន្ធគយចំពោះទំនិញដែលចូលទឹកដីរបស់ខ្លួនឡើងវិញ ស្របតាមច្បាប់និងនីតិវិធីរបស់ខ្លួន បន្ទាប់ពីទំនិញនោះត្រូវបាននាំចេញបណ្តោះអាសន្នពីទឹកដីរបស់ខ្លួនទៅកាន់ទឹកដីភាគីសមាជិកម្ខាងទៀត ដើម្បីជួសជុលឬផ្លាស់ប្តូរ ដោយមិនគិតថាការជួសជុលឬការផ្លាស់ប្តូរនោះអាចត្រូវបានអនុវត្តនៅក្នុងដែនដីដែលទំនិញត្រូវបាននាំចេញនោះទេ លើកលែងតែពន្ធគយឬអាករផ្សេងទៀតអាចត្រូវបានអនុវត្តចំពោះការបន្ថែមដែលជាលទ្ធផលនៃការជួសជុល ឬការផ្លាស់ប្តូរដែលត្រូវបានអនុវត្តនៅក្នុងដែនដីភាគីសមាជិកម្ខាងទៀត។

២- ដោយមិនគិតពីប្រភពដើមនៃទំនិញ ភាគីសមាជិកមិនត្រូវអនុវត្តពន្ធគយចំពោះទំនិញនាំចូលបណ្តោះអាសន្នពីដែនដីនៃភាគីសមាជិកម្ខាងទៀត ដើម្បីជួសជុលឬផ្លាស់ប្តូរឡើយ។

៣- សម្រាប់គោលបំណងនៃមាត្រានេះ "ការជួសជុល" ឬ "ការផ្លាស់ប្តូរ" មិនរួមបញ្ចូលប្រតិបត្តិការ ឬដំណើរការដែល៖

(ក) បំផ្លាញលក្ខណៈសំខាន់ៗរបស់ទំនិញ ឬបង្កើតទំនិញថ្មី ឬទំនិញដែលអាចធ្វើការជួញដូរផ្សេងទៀត

(ខ) បំប្លែងផលិតផលដែលមិនទាន់សម្រេចទៅជាផលិតផលសម្រេច ឬ

(គ) នាំឱ្យមានការផ្លាស់ប្តូរចំណាត់ថ្នាក់នៅកម្រិតប្រាំមួយខ្ទង់នៃប្រព័ន្ធសុខដុម។

**មាត្រា២.១៧ _ ការនាំចូលដោយមិនបង់ពន្ធលើគំរូពាណិជ្ជកម្មដែលមានតម្លៃតិចតួច និងសម្ភារៈសម្រាប់ការផ្សព្វផ្សាយដែលព្រីនចេញ**

អនុលោមតាមច្បាប់ក្នុងស្រុករៀងៗខ្លួន ភាគីសមាជិកនីមួយៗត្រូវផ្តល់ការលើកលែងពន្ធចំពោះការនាំចូលគំរូពាណិជ្ជកម្មដែលមានតម្លៃតិចតួចនិងសម្ភារៈសម្រាប់ការផ្សព្វផ្សាយដែលព្រីនចេញ ពីដែនដីនៃភាគីម្ខាងទៀត ដោយមិនគិតពីប្រភពដើមរបស់ពួកគេ ប៉ុន្តែអាចតម្រូវឱ្យ៖

(ក) គំរូទាំងនោះត្រូវបាននាំចូលសម្រាប់តែជាព័ត៌មានក្នុងការបញ្ជាទិញទំនិញឬសេវាកម្មដែលផ្តល់ពីដែនដីនៃភាគីម្ខាងទៀត ឬមិនមែនជាភាគី ឬ

(ខ) សម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្មទាំងនោះត្រូវបាននាំចូលជាកញ្ចប់ ដែលកញ្ចប់នីមួយៗមានមិនលើសពីមួយច្បាប់នៃសម្ភារៈទាំងនោះ ហើយសម្ភារៈឬកញ្ចប់នោះមិនបង្កជាផ្នែកនៃការដឹកជញ្ជូនទ្រង់ទ្រាយធំ។

**មាត្រា២.១៨ _ អនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញ**

១- គូភាគីយល់ព្រមបង្កើតអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញ ក្រោមគណៈកម្មាធិការចម្រុះដែលមានតំណាងនៃភាគីសមាជិកនីមួយៗ។

២- អនុគណៈកម្មាធិការត្រូវប្រជុំរៀងរាល់មួយឆ្នាំម្តង ឬតាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀតតាមពេលវេលា ទីកន្លែង និងមធ្យោបាយដែលបានឯកភាពគ្នា ដើម្បីពិចារណាលើបញ្ហាណាមួយ

ដែលកើតឡើងក្រោមដំពូកនេះ។ អនុគណៈកម្មាធិការអាចអនុវត្តការងាររបស់ខ្លួនតាមមធ្យោបាយណាក៏ដោយដែលសមស្រប រាប់បញ្ចូលទាំងសារអេឡិចត្រូនិក ការប្រជុំតាមទម្រង់និមិត្ត ឬមធ្យោបាយផ្សេងទៀត។

៣- មុខងាររបស់អនុគណៈកម្មាធិការ រួមមាន៖

(ក) តាមដាននិងពិនិត្យការអនុវត្តនិងការគ្រប់គ្រងដំពូកនេះ និងរៀបចំរបាយការណ៍និងអនុសាសន៍ តាមការគួរ

(ខ) លើកកម្ពស់ពាណិជ្ជកម្មទំនិញរវាងភាគីទាំងពីរ រួមទាំងតាមរយៈការពិគ្រោះយោបល់លើការពន្លឿនឬកែលម្អវិសាលភាពនៃការអនុគ្រោះពន្ធ ឬការលុបបំបាត់ពន្ធក្រោមកិច្ចព្រមព្រៀងនេះនិងបញ្ហាផ្សេងទៀតតាមការគួរ

(គ) ដោះស្រាយរបាំងពាណិជ្ជកម្មទំនិញរវាងគូភាគី រួមទាំងរបាំងពាណិជ្ជកម្មពាក់ព័ន្ធទៅនឹងការអនុវត្តវិធានការមិនមែនពន្ធ ដែលអាចជាក់កម្រិតលើពាណិជ្ជកម្មទំនិញរវាងគូភាគី ហើយបញ្ជូនបញ្ហាទាំងនោះទៅគណៈកម្មាធិការចម្រុះដើម្បីពិចារណា តាមការគួរ

(ឃ) ផ្តល់ដំបូន្មាននិងអនុសាសន៍ជូនគណៈកម្មាធិការចម្រុះស្តីពីតម្រូវការកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងបញ្ហាពាណិជ្ជកម្មទំនិញ;

(ង) ពិនិត្យឡើងវិញលើវិសោធនកម្មនៃប្រព័ន្ធសុខដុម ដើម្បីធានាថាភាគីកិច្ចរបស់ភាគីនីមួយៗនៅក្រោមកិច្ចព្រមព្រៀងនេះមិនត្រូវបានផ្លាស់ប្តូរ និងពិគ្រោះយោបល់ដើម្បីដោះស្រាយជម្លោះណាមួយរវាងវិសោធនកម្មប្រព័ន្ធសុខដុម ព្រមទាំងឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ) និងនាមវលីជាតិ

(ច) ពិគ្រោះយោបល់និងព្យាយាមដោះស្រាយភាពខុសគ្នា ដែលអាចកើតឡើងក្នុងចំណោមគូភាគីលើបញ្ហាពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់ទំនិញនៅក្រោមប្រព័ន្ធសុខដុម រួមទាំងការអនុម័តនិងពិនិត្យឡើងវិញនូវវិធីសាស្ត្រនិងគោលការណ៍ណែនាំអំពីការផ្ទេរបន្ទាត់ពន្ធគយ

(ឆ) ពិនិត្យទិន្នន័យស្តីពីពាណិជ្ជកម្មទំនិញពាក់ព័ន្ធនឹងការអនុវត្តជំពូកនេះ

(ជ) វាយតម្លៃលើបញ្ហាដែលទាក់ទងនឹងពាណិជ្ជកម្មទំនិញនិងបំពេញការងារបន្ថែមណាមួយដែលគណៈកម្មាធិការចម្រុះអាចប្រគល់ឱ្យ និង

(ឈ) ពិនិត្យនិងតាមដានលើបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តជំពូកនេះ។

# ជំពូកទី៣
# វិធានដើមកំណើតទំនិញ

## មាត្រា៣.១ _ និយមន័យ

គោលបំណងនៃជំពូកនេះ៖

**វារីវប្បកម្ម** សំដៅដល់ការធ្វើកសិកម្មនៃសរីរាង្គរស់នៅក្នុងទឹក រួមមានត្រី សិប្បីសត្វ សត្វមានសម្បក និងនិប្បិដ្ឋាជីវសត្វដែលឥតឆ្អឹងខ្នង និងរុក្ខជាតិជុះក្នុងទឹកផ្សេងទៀត ចេញពីការចម្រាញ់ពូជ ដូចជាស៊ុត កូនត្រីទើបញាស់ កូនត្រីនិងកូនញាស់ ដែលចូលរួមក្នុងដំណើរការចិញ្ចឹមឬលូតលាស់ ដើម្បីបង្កើនផលិតកម្ម ដូចជាការស្កុកទុកជាប្រចាំ ការចិញ្ចឹម ការឱ្យចំណី ឬការការពារពីសត្វដែលស៊ីសាច់សត្វជាដើម។ល។

**អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់៖

(ក) សម្រាប់ព្រះរាជាណាចក្រកម្ពុជា មានក្រសួងពាណិជ្ជកម្ម ឬអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬភ្នាក់ងារណាមួយផ្សេងទៀតដែលជូនដំណឹងបន្តបន្ទាប់ និង

(ខ) សម្រាប់អេមីរ៉ាតអារ៉ាប់រួម មានក្រសួងសេដ្ឋកិច្ច ឬភ្នាក់ងារណាមួយផ្សេងទៀតដែលជូនដំណឹងបន្តបន្ទាប់

**ការដឹកជញ្ជូន** មានន័យថា ផលិតផលដែលត្រូវបានបញ្ជូនចេញស្របពេលដំណាលគ្នានោះពីអ្នកនាំចេញម្នាក់ទៅអ្នកទទួលទំនិញម្នាក់ ឬរាប់បញ្ចូលផលិតផលនោះក្នុងឯកសារដឹកជញ្ជូនតែមួយ សម្រាប់ការដឹកជញ្ជូនពីអ្នកនាំចេញទៅកាន់អ្នកទទួល

**អាជ្ញាធរគយ** សំដៅដល់៖

(ក) សម្រាប់ព្រះរាជាណាចក្រកម្ពុជា មានអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង

(ខ) សម្រាប់អេមីរ៉ាតអារ៉ាប់រួម មានអាជ្ញាធរសហព័ន្ធអត្តសញ្ញាណ សញ្ជាតិ គយ និងសន្តិសុខកំពង់ផែ

**តម្លៃគិតពន្ធគយ** សំដៅដល់តម្លៃដែលបានបង់ពិតប្រាកដឬត្រូវបង់ទៅឱ្យអ្នកនាំចេញផលិតផលមួយ នៅពេលដែលផលិតផលត្រូវបានផ្ទេរចេញពីយានយន្តដឹកជញ្ជូននៅកំពង់ផែនៃការនាំចូល ក្នុងនោះរួមមានទាំងតម្លៃនៃផលិតផល ការធានារ៉ាប់រង និងការដឹកជញ្ជូនទំនិញដែលចាំបាច់សម្រាប់ការដឹកជញ្ជូនផលិតផលនោះទៅកាន់ច្រកកំពង់ផែគោលដៅ។ ការវាយតម្លៃត្រូវធ្វើឡើងដោយអនុលោមតាមមាត្រាទី VII នៃGATT ១៩៩៤ ដោយត្រូវមានការកត់ត្រា ភ្ជាប់ជាមួយនឹងគម្រោងត្រូវចំណាយបន្ថែម និងកិច្ចព្រមព្រៀងស្តីពីការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ

**គោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP)** សំដៅដល់ការទទួលស្គាល់ជាទូទៅ ឬការទទួលស្គាល់ដោយភាគីសមាជិកណាមួយ (ក្រុមប្រឹក្សាគោលការណ៍គណនេយ្យ) ដែលស្ថិតក្នុងដែនដីនៃភាគីនោះ ទាក់ទងនឹងការកត់ត្រាប្រាក់ចំណូល ការចំណាយ ថ្លៃដើម ទ្រព្យសកម្ម និងបំណុល ការលាតត្រដាងព័ត៌មាននិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ស្តង់ដាទាំងនេះអាចរាប់បញ្ចូលទាំងគោលការណ៍ណែនាំទូលំទូលាយនៃការអនុវត្តទូទៅ រួមទាំងស្តង់ដាលម្អិត ការអនុវត្ត និងនីតិវិធី

**ទំនិញ** សំដៅដល់ទំនិញ ផលិតផល របស់របរ ឬវត្ថុធាតុនានា

**ប្រព័ន្ធសុខដុម** សំដៅដល់នាមវលីប្រព័ន្ធបរិយាយមុខទំនិញនិងកំណត់លេខកូដសុខដុម រួមបញ្ចូលនូវក្បួនច្បាប់ទូទៅនិងកំណត់សម្គាល់គតិយុត្តិផ្សេងៗ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាអន្តរជាតិស្តីពីនាមវលីនៃប្រព័ន្ធបរិយាយមុខទំនិញនិងកំណត់លេខកូដសុខដុម

**កម្មន្តសាល** សំដៅដល់ដំណើរការការងារឬការកែច្នៃណាមួយ ក្នុងនោះរួមមានការផ្គុំតម្លើងឬប្រតិបត្តិការជាក់លាក់ណាមួយ

**វត្ថុធាតុ** សំដៅដល់ធាតុផ្សំ វត្ថុធាតុដើម សមាសធាតុឬផ្នែក សម្រាប់ប្រើប្រាស់នៅក្នុងផលិតកម្មទំនិញ

**ទំនិញមិនមានដើមកំណើត** សំដៅដល់ទំនិញដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថាមានដើមកំណើតអនុលោមតាមដំពូកនេះ

**វត្ថុធាតុគ្មានដើមកំណើត** សំដៅដល់វត្ថុធាតុទាំងឡាយណាដែលមានប្រទេសដើមកំណើតជាប្រទេសក្រៅពីគូភាគី(នាំចូលគ្មានដើមកំណើត) វត្ថុធាតុទាំងឡាយណាដែលប្រភពដើមមិនអាចកំណត់បាន(មិនអាចកំណត់ដើមកំណើត) ឬវត្ថុធាតុដែលមិនមានលក្ខណៈគ្រប់គ្រាន់ថាមានដើមកំណើតអនុលោមតាមដំពូកនេះ

**ទំនិញមានដើមកំណើតឬវត្ថុធាតុមានដើមកំណើត** សំដៅដល់ទំនិញឬវត្ថុធាតុណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថាមានដើមកំណើតអនុលោមតាមដំពូកនេះ

**ផលិតផល** សំដៅដល់អ្វីដែលទទួលបានពីការដាំដុះ ការចិញ្ចឹម ការដើកយកវើ ការប្រមូលផល ការរេនសាទ វារីវប្បកម្ម ការដាក់អន្ទាក់ ការបរបាញ់ ការទាញយក ឬកម្មន្តសាល ទោះបីជាវាត្រូវបម្រុងទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយក្នុងប្រតិបត្តិការផលិតកម្មណាផ្សេងទៀតក៏ដោយ

**ផលិតកម្ម** សំដៅដល់ការដាំដុះ ការចិញ្ចឹម ការដើកយកវើ ការប្រមូលផល ការរេនសាទ កសិកម្ម ការបង្កាត់ពូជ ការចម្រាញ់ចេញ ការប្រមូលយក ការប្រមូលផ្តុំ ការចាប់យក វារីវប្បកម្ម ការដាក់អន្ទាក់ ការបរបាញ់ កម្មន្តសាល ការផលិត ការកែច្នៃ ឬផ្គុំ ឬតម្លើងទំនិញ។

## ផ្នែក ក៖ ការកំណត់ដើមកំណើត

### មាត្រា៣.២ _ ទំនិញមានដើមកំណើត

គោលបំណងនៃការអនុវត្តកិច្ចព្រមព្រៀងនេះ ទំនិញត្រូវបានចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដីនៃភាគីសមាជិក ប្រសិនបើ៖

(ក) ទំនិញទាំងនោះទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅទីនោះ ដូចមានចែងក្នុងមាត្រា ៣.៣ ឬ

(ខ) ទំនិញទាំងនោះមិនទទួលបានទាំងស្រុងឬមិនបានផលិតទាំងស្រុងនៅទីនោះ ដោយឡែកទំនិញនោះបានឆ្លងកាត់ការផ្លាស់ប្តូរមានលក្ខណៈគ្រប់គ្រាន់ ដូចមានចែងក្នុងមាត្រា ៣.៤ ឬ

(គ) ទំនិញនោះត្រូវបានផលិតទាំងស្រុងនៅទីនោះ ចេញទាំងស្រុងពីវត្ថុធាតុមានដើមកំណើតនៃភាគីសមាជិកណាមួយ ឬ

(ឃ) ទំនិញទាំងនោះបានបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងទៀតទាំងអស់នៃដំពូកនេះ។

### មាត្រា៣.៣ _ ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុង

សម្រាប់គោលបំណងនៃកថាខណ្ឌ(ក) នៃមាត្រា៣.២ ទំនិញខាងក្រោម ត្រូវបានចាត់ទុកថាទទួលបានទាំងស្រុងឬផលិតទាំងស្រុង នៅក្នុងដែនដីនៃភាគីសមាជិក៖

(ក) រុក្ខជាតិនិងផលិតផលពីរុក្ខជាតិ ដែលត្រូវបានដាំដុះ ប្រមូលយក ឬប្រមូលផលនៅទីនោះ

(ខ) សត្វរស់ ដែលបានកើត និងចិញ្ចឹមនៅទីនោះ

(គ) ទំនិញដែលទទួលបានពីសត្វរស់នៅទីនោះ

(ឃ) ផលិតផលរ៉ែនិងធនធានធម្មជាតិដែលបានមកពីការទាញយក ឬយកចេញពីដី ដីក្រោមទឹក ទឹក បាតសមុទ្រ ឬនៅក្រោមបាតសមុទ្រ

(ង) ទំនិញដែលទទួលបានពីការប្រមាញ់ ការដាក់អន្ទាក់ ការប្រមូលយក ការចាប់យក ការនេសាទ ឬវារីវប្បកម្មដែលបានធ្វើឡើងនៅទីនោះ

(ច) ត្រី សំបកខ្យង និងបណ្តាសត្វឬរុក្ខជាតិសមុទ្រដែលមានជីវិតដទៃទៀត ដែលត្រូវបានយកចេញដោយនាវាដែលបានចុះបញ្ជីជាមួយភាគីសមាជិកនោះ ហើយមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីសមាជិកនោះ និងផលិតផលផ្សេងទៀតដែលយកដោយភាគីសមាជិកនោះ ឬប្រជាជននៃភាគីសមាជិកនោះ ពីក្នុងទឹក បាតសមុទ្រ ឬក្រោមបាតសមុទ្រ នៅខាងក្រៅដែនទឹកនៃភាគីសមាជិកនោះ ក្នុងលក្ខខណ្ឌដែលភាគីសមាជិកនោះមានសិទ្ធិទាញយកផលប្រយោជន៍ ពីធនធានធម្មជាតិ ដែលស្ថិតលើទឹក ក្នុងបាតសមុទ្រ និងក្រោមបាតសមុទ្រនោះ ដោយអនុលោមតាមច្បាប់អន្តរជាតិ

(ឆ) ត្រី សំបកខ្យង និងសត្វឬរុក្ខជាតិសមុទ្រដែលមានជីវិតដទៃទៀត ដែលត្រូវបានយកចេញពីសមុទ្រអន្តរជាតិដោយនាវាដែលបានចុះបញ្ជីជាមួយភាគីសមាជិកនោះ និងមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីសមាជិកនោះ

(ជ) ទំនិញដែលត្រូវបានផលិតឬបង្កើតទាំងស្រុងចេញពីផលិតផលដែលមានចែងក្នុងកថាខណ្ឌ (ច) ឬ (ឆ) នៅលើបណ្តានាវារោងចក្រដែលបានចុះបញ្ជីជាមួយភាគីសមាជិក ឬមានសិទ្ធិជាក់ទង់ជាតិរបស់ភាគីសមាជិកនោះ;

(ឈ) វត្ថុធាតុដើមទាញយកមកពីទំនិញប្រើប្រាស់រួចដែលបានប្រមូលនៅទីនោះ;

(ញ) កាកសំណល់ឬកម្ទេចកម្ទីដែលបានមកពីការទាញយក ការប្រើប្រាស់ ឬដំណើរការផលិតកម្មដែលបានធ្វើឡើងនៅទីនោះ គួរធ្វើឡើងសម្រាប់តែការទាញយកមកវិញនៃវត្ថុធាតុដើមតែប៉ុណ្ណោះ និង

(ដ) ទំនិញដែលបានផលិតឬទទួលបានទាំងស្រុងនៅទីនោះ ចេញពីទំនិញដែលមានចែងក្នុងកថាខណ្ឌ(ក)ដល់(ញ) ឬបានមកពីការកែច្នៃចេញពីទំនិញដែលផលិតនៅដំណាក់កាលនៃការផលិតណាមួយ។

**មាត្រា៣.៤ _ ការផលិតឬប្រតិបត្តិការមានលក្ខណៈគ្រប់គ្រាន់**

១- សម្រាប់គោលបំណងនៃកថាខណ្ឌ(ខ) នៃមាត្រា៣.២ ទំនិញមួយត្រូវចាត់ទុកថាមានដើមកំណើត ប្រសិនបើទំនិញនោះបំពេញនូវតម្រូវការណាមួយ ដូចខាងក្រោម៖

(ក) ការផ្លាស់ប្តូរលេខបួនខ្ទង់ដំបូងនៃលេខចំណាត់ថ្នាក់ពន្ធគយ (CTH) ដែលសំដៅដល់គ្រប់វត្ថុធាតុដែលមិនមានដើមកំណើត ដែលបានប្រើក្នុងការផលិតទំនិញបានឆ្លងកាត់ការផ្លាស់ប្តូរនៅក្នុងចំណាត់ថ្នាក់បន្ទាត់ពន្ធគយប្រព័ន្ធសុខដុម នៅកម្រិត៤ខ្ទង់

(ខ) សមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QVC) មិនតិចជាង៤០% នៃតម្លៃទំនិញដឹកជញ្ជូនដល់លើនាវា (FOB) ឬ

(គ) សមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QVC) មិនតិចជាង៣៥% នៃតម្លៃផលិតក្នុងរោងចក្រ(Ex-Works Value)។

២- បើទោះជាមានចែងក្នុងកថាខណ្ឌ១ក៏ដោយ ប្រសិនបើទំនិញនោះ មានក្នុងចំណាត់ថ្នាក់ដែលរាប់បញ្ចូលក្នុងបញ្ជីលើកលែងនៅក្នុងឧបសម្ព័ន្ធ៣ក(វិធានជាក់លាក់សម្រាប់ផលិតផល តទៅនេះហៅថា PSR) ទំនិញនោះត្រូវបំពេញនូវវិធានជាក់លាក់ដែលមានលម្អិតនៅក្នុងនោះ។

៣- សម្រាប់គោលបំណងនៃកថាខណ្ឌ១ នៃមាត្រានេះ QVC ត្រូវបានគណនាដោយប្រើវិធីណាមួយខាងក្រោម៖

(ក) $QVC = \frac{\text{តម្លៃExWorks ឬ តម្លៃFOB} - \text{V.N.M}}{\text{តម្លៃExWorks ឬ តម្លៃFOB}} \times 900$ ឬ

(ខ) $QVC = \frac{\text{V.O.M+ថ្លៃពលកម្មផ្ទាល់+ថ្លៃចំណាយសរុប+ប្រាក់ចំណេញ+ថ្លៃចំណាយផ្សេងៗ}}{\text{តម្លៃExWorks ឬ តម្លៃFOB}} \times 900$

ដែល៖

(i) QVC គឺជាសមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃទំនិញមួយ ដែលគិតជាភាគរយ

(ii) **FOB** គឺជាតម្លៃនៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវា រួមបញ្ចូលទាំងចំណាយនៃការដើរកជញ្ជូនទំនិញ(ដោយមិនគិតពីមធ្យោបាយនៃការដើរកជញ្ជូន) ទៅកាន់កំពង់ផែឬទីកន្លែងដឹកជញ្ជូនចុងក្រោយនៅក្រៅប្រទេស

(iii) **តម្លៃ Ex-Works** គឺជាថ្លៃដែលបានបង់សម្រាប់ការផលិតទំនិញទៅឱ្យអ្នកផលិតនៅក្នុងប្រទេសគូភាគីដែលប្រតិបត្តិការឬការច្នៃចុងក្រោយត្រូវបានធ្វើឡើង ដោយរួមបញ្ចូលទាំងតម្លៃនៃវត្ថុធាតុដែលបានប្រើទាំងអស់ ដកចេញនូវពន្ធអាករណាមួយដែលត្រូវឬអាចសងមកវិញនៅពេលដែលទំនិញទទួលបានត្រូវបាននាំចេញ

(iv) **V.N.M** គឺជាតម្លៃ CIF/ពន្ធគយ នៃវត្ថុធាតុមិនមានដើមកំណើតនៅពេលនាំចូល ឬជាតម្លៃបញ្ជាក់ដែលបានទូទាត់ដំបូងបំផុត ឬត្រូវទូទាត់នៅខាងភាគីសមាជិកនោះ: ខណៈពេលនៃការផលិតធ្វើឡើងសម្រាប់គ្រប់វត្ថុធាតុគ្មានដើមកំណើត គ្រឿងបន្លាស់ ឬផលិតផលដែលមិនមានដើមកំណើត ដែលត្រូវបានទទួលដោយអ្នកផលិតនៅក្នុងការផលិតផលិតផលនោះ។ នៅពេលអ្នកផលិតនៃផលិតផលនោះទទួលបានវត្ថុធាតុមិនមានដើមកំណើតនៅក្នុងភាគីសមាជិកនោះ តម្លៃនៃវត្ថុធាតុទាំងនោះមិនត្រូវរួមបញ្ចូលថ្លៃដឹកជញ្ជូន ថ្លៃធានារ៉ាប់រង ថ្លៃវេចខ្ចប់ និងថ្លៃផ្សេងទៀតដែលបានចំណាយក្នុងការដើរកជញ្ជូនវត្ថុធាតុពីឃ្លាំងរបស់អ្នកផ្គត់ផ្គង់ ទៅកាន់ទីតាំងរបស់អ្នកផលិតឡើយ

(v) **VOM** គឺជាតម្លៃនៃវត្ថុធាតុមានដើមកំណើត បំណែក ឬផលិតផល ដែលបានទទួលដោយអ្នកផលិតឬផលិតដោយខ្លួនឯង និងត្រូវប្រើប្រាស់ក្នុងការផលិតទំនិញនោះ

(vi) **ថ្លៃពលកម្មផ្ទាល់** រួមមានប្រាក់ឈ្នួល សំណង និងអត្ថប្រយោជន៍ផ្សេងទៀតរបស់និយោជិត

(vii) **ថ្លៃចំណាយសរុបផ្ទាល់** គឺជាការចំណាយសរុប និង

(viii) **ថ្លៃចំណាយផ្សេងៗ** គឺជាថ្លៃចំណាយក្នុងការដាក់ទំនិញនៅក្នុងកប៉ាល់ ឬមធ្យោបាយដឹកជញ្ជូនផ្សេងទៀតសម្រាប់ការនាំចេញ រួមបញ្ចូលតែមិនកំណត់ចំពោះថ្លៃចំណាយដឹកជញ្ជូនក្នុងស្រុក ការស្កុកទុកនិងការដាក់ក្នុងឃ្លាំង ការលើកដាក់នៅកំពង់ផែ កម្រៃជើងសារ និងថ្លៃសេវាកម្ម។ *តម្លៃនេះអាចអនុវត្តបានតែនៅពេលដែលមានការគណនា QVC លើមូលដ្ឋាន FOB ប៉ុណ្ណោះ។*

**មាត្រា៣.៥ – ទំនិញសម្រាប់ផលិតបន្ត**

សម្រាប់វត្ថុធាតុមិនមានដើមកំណើតមួយ ដែលត្រូវឆ្លងកាត់ការផលិតមានលក្ខណៈគ្រប់គ្រាន់នៅក្នុងដែនដីនៃភាគីសមាជិកដូចមានចែងក្នុងមាត្រា៣.៤ ទំនិញសម្រេចបាននោះត្រូវបានចាត់ទុកថាមានដើមកំណើត ហើយសមាសភាគនៃវត្ថុធាតុមិនមានដើមកំណើតដែលមានផ្ទុកក្នុងទំនិញនោះមិនត្រូវបានរាប់បញ្ចូលនោះទេ នៅពេលដែលផលិតផលនោះត្រូវបានប្រើប្រាស់នៅក្នុងការផលិតបន្តជាទំនិញមួយផ្សេងទៀត។

**មាត្រា៣.៦ _ វិធានបូកបន្ថែម**

១- ទំនិញមានដើមកំណើតនៃភាគីសមាជិកដែលត្រូវបានយកទៅប្រើប្រាស់ក្នុងការកែច្នៃ ឬការផលិតក្នុងដែនដីនៃភាគីសមាជិកម្ខាងទៀតជាវត្ថុធាតុសម្រាប់ទំនិញសម្រេច ត្រូវបានចាត់ទុកជាវត្ថុធាតុមានដើមកំណើតនៅក្នុងដែនដីនៃភាគីសមាជិកម្ខាងទៀតនោះ ដែលការកែច្នៃឬប្រតិបត្តិការនៃទំនិញសម្រេច ត្រូវបានធ្វើឡើង។

២- បើទោះមានចែងដូចក្នុងកថាខណ្ឌ១ក៏ដោយ វត្ថុធាតុដែលមានដើមកំណើតពីភាគីសមាជិក ដែលមិនបានឆ្លងកាត់ការកែច្នៃលើសពីប្រតិបត្តិការអប្បបរមាឬមានលក្ខណៈមិនគ្រប់គ្រាន់ ដូចមានរៀបរាប់ក្នុងមាត្រា៣.៨នៅក្នុងដែនដីភាគីសមាជិកម្ខាងទៀតនោះ ត្រូវតែរក្សាស្ថានភាពដើមកំណើតនៃភាគីសមាជិកដើមនៃវត្ថុធាតុនោះ។

៣- គណៈកម្មាធិការចម្រុះដែលបង្កើតឡើងដោយអនុលោមតាមមាត្រា១៦.១(គណៈកម្មាធិការចម្រុះ) អាចយល់ព្រមក្នុងការពិនិត្យមាត្រានេះក្នុងទស្សនៈមួយដើម្បីផ្តល់ទម្រង់ផ្សេងទៀតនៃវិធានបូកបន្ថែម សម្រាប់គោលបំណងឱ្យទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញមានដើមកំណើតក្រោមកិច្ចព្រមព្រៀងនេះ។

**មាត្រា៣.៧ _ វិធានអប្បបរមា** ( De Minimis )

១- បើទោះជាមានចែងក្នុងមាត្រា៣.៤ក៏ដោយ ទំនិញមួយនឹងត្រូវបានចាត់ទុកថាបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ប្រសិនបើតម្លៃនៃវត្ថុធាតុមិនមានដើមកំណើតទាំងអស់ដែលបានប្រើក្នុងផលិតកម្មទំនិញ ហើយដែលមិនឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយមានតម្លៃមិនលើសពី១០% នៃតម្លៃFOB ឬ១៥% នៃតម្លៃផលិតក្នុងរោងចក្រ (Ex-Works) នៃទំនិញនោះទេ។

២- តម្លៃនៃវត្ថុធាតុមិនមានដើមកំណត់ដែលមានចែងក្នុងកថាខណ្ឌ១ ត្រូវរាប់បញ្ចូលក្នុងតម្លៃនៃវត្ថុធាតុមិនមានដើមកំណើតសម្រាប់ជាតម្លៃបន្ថែមទៅលើតម្រូវការមាតិកាណាមួយសមស្រប។

**មាត្រា៣.៨ _ ប្រតិបត្តិការនិងដំណើរការអប្បបរមា/មានលក្ខណៈមិនគ្រប់គ្រាន់**

១- ទោះបីជាតម្រូវការនៃមាត្រា៣.៤ ត្រូវបានបំពេញហើយក៏ដោយ ទំនិញមួយមិនត្រូវចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដីនៃភាគីសមាជិកទេ ប្រសិនបើប្រតិបត្តិការដូចខាងក្រោម ត្រូវបានប្រព្រឹត្តឡើងផ្តាច់មុខដោយខ្លួនឯង ឬរួមបញ្ចូលគ្នា នៅក្នុងដែនដីនៃភាគីសមាជិកនោះ៖

(ក) ការសម្លាប់សត្វ

(ខ) ប្រតិបត្តិការដើម្បីធានាការរក្សាទុកផលិតផលនៅក្នុងស្ថានភាពល្អ កំឡុងពេលដឹកជញ្ជូននិងស្តុកទុកដូចជាការសម្ងួត ការបង្កក ការបញ្ចូលខ្យល់ ការធ្វើឱ្យត្រជាក់ និង ប្រតិបត្តិការប្រហាក់ប្រហែលផ្សេងៗ

(គ) ដំណើរការសាមញ្ញ ដែលរួមមានការរែង ការចម្រាញ់ ការបែងចែកតាមប្រភេទ ការលាងសម្អាត ការបែងចែកតាមចំណាត់ថ្នាក់ ការសម្រួច ការកាត់ ការ: ការកិន ការបត់/ពត់ ការរមូរចូល ការរមូរចេញ ឬការចិតជាចំណិត

(ឃ) ការលាងសម្អាត រួមបញ្ចូលទាំងការដេកអុកស៊ីត ប្រេង ថ្នាំលាប ឬគម្របផ្សេងទៀត

(ង) ប្រតិបត្តិការសោមញ្ញលើការដាក់ពណ៌និងខាត់ឱ្យរលោង

(ច) ការធ្វើតេស្តឬការក្រិតតាមមុំ សាមញ្ញ

(ឆ) ការដាក់បែបសាមញ្ញក្នុងដប កំប៉ុង ដបទឹក ថង់ ប្រអប់ ការបន្ថែមលើក្រដាស ឬក្តារ និងប្រតិបត្តិការវេចខ្ចប់សាមញ្ញផ្សេងទៀតទាំងអស់

(ជ) ការលាយផលិតផលបញ្ចូលគ្នាបែបសាមញ្ញ ទោះបីជាប្រភេទដូចឬផ្សេងគ្នាក៏ដោយ

(ឈ) ការផ្តុំបែបសាមញ្ញនូវបំណែកផលិតផល ដើម្បីបង្កើតជាផលិតផលពេញលេញល្អមួយ ឬការបំបែកផលិតផលទៅជាបំណែក

(ញ) ការផ្លាស់ប្តូរប្រតិបត្តិការនៃការវេចខ្ចប់ ការស្រាយចេញ ឬការវេចខ្ចប់ឡើងវិញ និងការបំបែកនិងការផ្តុំទំនិញសម្រាប់ការដឹកជញ្ជូន

(ដ) ការបិទឬបោះពុម្ពម៉ាក ស្លាកសញ្ញា រូបសញ្ញា ឬសញ្ញាសម្គាល់ផ្សេងទៀតលើទំនិញ ឬកញ្ចប់ទំនិញនោះ

(ឋ) ការបកសំបក ការធ្វើឱ្យសដោយផ្នែកឬទាំងស្រុង ការដុសខាត់និងធ្វើឱ្យរលោងលើធញ្ញជាតិនិងអង្ករ

(ឌ) ការលាយជាមួយទឹកឬសារធាតុផ្សេងទៀតដែលមិនផ្លាស់ប្តូរធំដុំដល់លក្ខណៈរបស់ទំនិញ។

២- សម្រាប់គោលបំណងនៃកថាខណ្ឌ១ ៣ក្យ "សាមញ្ញ" នឹងត្រូវបានកំណត់ដូចខាងក្រោម៖

(ក) "សាមញ្ញ" ជាទូទៅពិពណ៌នាអំពីសកម្មភាពដែលមិនត្រូវការជំនាញពិសេស គ្រឿងម៉ាស៊ីន គ្រឿងបរិក្ខារ ឬឧបករណ៍ ដែលជាពិសេសត្រូវបានផលិតឬដំឡើងសម្រាប់ធ្វើសកម្មភាព

(ខ) "ការលាយបែបសាមញ្ញ" ជាទូទៅពិពណ៌នាអំពីសកម្មភាពដែលមិនត្រូវការជំនាញពិសេស គ្រឿងម៉ាស៊ីន គ្រឿងបរិក្ខារ ឬឧបករណ៍ ដែលជាពិសេសត្រូវបានផលិតឬដំឡើងសម្រាប់ធ្វើសកម្មភាព។ ទោះជាយ៉ាងណាក៏ដោយ ការលាយបែបសាមញ្ញមិនរួមបញ្ចូលប្រតិកម្មគីមីនោះទេ។ ប្រតិកម្មគីមីសំដៅដល់ដំណើរការមួយ(រួមបញ្ចូលទាំងដំណើរការជីវគីមី) ដែលបណ្តាលឱ្យម៉ូលេគុលមួយមានរចនាសម្ព័ន្ធថ្មី ដោយការបំបែកចំណងម៉ូលេគុលខាងក្នុងនិងដោយការបង្កើតចំណងម៉ូលេគុលខាងក្នុងថ្មី ឬដោយការផ្លាស់ប្តូរការរៀបចំលំហនៃអាតូមនៅក្នុងម៉ូលេគុលមួយ។

**មាត្រា៣.៩ _ វត្ថុធាតុមិនផ្លាស់**

ដើម្បីកំណត់ថាទំនិញមួយមានដើមកំណើត វត្ថុធាតុខាងក្រោមដែលត្រូវបានប្រើប្រាស់ក្នុងការផលិតទំនិញមួយត្រូវចាត់ទុកជាវត្ថុធាតុមានដើមកំណើត ដោយមិនគិតថាវត្ថុធាតុទាំងនោះមានដើមកំណើតពី៖

(ក) ថាមពលនិងប្រេងឥន្ធនៈ

(ខ) រោងចក្រនិងគ្រឿងបរិក្ខារ

(គ) គ្រឿងម៉ាស៊ីននិងឧបករណ៍

(ឃ) គ្រឿងបន្លាស់និងវត្ថុធាតុដែលប្រើប្រាស់ក្នុងការថែទាំគ្រឿងបរិក្ខារ

(ង) គ្រឿងបរិក្ខារ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ ដែលត្រូវបានប្រើសម្រាប់ការធ្វើតេស្ត ឬការត្រួតពិនិត្យទំនិញ និង

(ច) វត្ថុធាតុផ្សេងទៀតដែលត្រូវបានប្រើក្នុងការផលិត ការធ្វើតេស្ត ឬការត្រួតពិនិត្យនៃទំនិញមួយ ហើយមិនចូល និងមិនមានបំណងចូលក្នុងសមាសភាពចុងក្រោយនៃផលិតផល។

**មាត្រា៣.១០ _ គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍**

១- គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀតដែលត្រូវបានផ្តល់ជាមួយទំនិញមួយក្នុងការបង្កើតជាផ្នែកស្តង់ដានៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀតរបស់ទំនិញដែលត្រូវបានភ្ជាប់ជាមួយទំនិញនោះ ត្រូវចាត់ទុកជាចំណែកមួយនៃទំនិញនោះ និងមិនត្រូវបានរាប់បញ្ចូលក្នុងការកំណត់ថាតើរាល់វត្ថុជាតុមិនមានដើមកំណើតទាំងអស់ ដែលត្រូវបានប្រើក្នុងផលិតកម្មនៃទំនិញនោះ បានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ឬប្រតិបត្តិការផលិត ឬកែច្នៃជាក់លាក់ ដូចមានចែងក្នុងឧបសម្ព័ន្ធ៣ក(វិធានជាក់លាក់សម្រាប់ផលិតផល) នោះឡើយប្រសិនបើ៖

(ក) គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀត ត្រូវបានបែងចែកចំណាត់ថ្នាក់និងមិនត្រូវបានដាក់ក្នុងវិក្កយបត្រដាច់ដោយឡែកពីទំនិញ ហើយ

(ខ) បរិមាណនិងតម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀតដែលភ្ជាប់មកជាមួយទំនិញនោះ មានលក្ខណៈទូទៅសម្រាប់ទំនិញនោះ។

២- ទោះបីជាមានចែងក្នុងកថាខណ្ឌ១ ប្រសិនបើទំនិញនោះស្ថិតក្រោមលក្ខខណ្ឌតម្រូវសមាសភាពតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀត ត្រូវយកមកពិចារណាថាជាវត្ថុជាតុមានដើមកំណើតឬមិនមានដើមកំណើត ក្នុងការគណនាសមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃទំនិញនោះ តាមករណីនីមួយៗ។

**មាត្រា៣.១១ _ វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការលក់រាយ**

១- វត្ថុធាតុវេចខ្ចប់និងកុងតឺន័រដែលត្រូវបានប្រើវេចខ្ចប់ទំនិញសម្រាប់ការលក់រាយ ដែលត្រូវបានបែងចែកចំណាត់ថ្នាក់រួមជាមួយទំនិញនោះ ដូចមានចែងក្នុងវិធាន៥ នៃវិធានទូទៅសម្រាប់ការបកប្រែប្រព័ន្ធសុខដុម មិនត្រូវយកមកពិចារណាសម្រាប់ការកំណត់ដើមកំណើតទំនិញឡើយ ប្រសិនបើ៖

(ក) ទំនិញនោះត្រូវទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅក្នុងប្រទេសភាគីសមាជិក ដូចមានចែងក្នុងកថាខណ្ឌ(ក) នៃមាត្រា៣.២

(ខ) ទំនិញនោះ ត្រូវបានផលិតនៅក្នុងភាគីសមាជិកទាំងស្រុងពីវត្ថុជាតុមានដើមកំណើតរបស់ភាគីសមាជិកណាមួយ ដូចមានចែងក្នុងកថាខណ្ឌ(គ) នៃមាត្រា៣.២ ឬ

(គ) ទំនិញនោះគឺស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការផ្លាស់ប្តូរចំណាត់ថ្នាក់តាមតារាងពន្ធគយ ឬលក្ខខណ្ឌតម្រូវនៃប្រតិបត្តិការផលិត ឬកែច្នៃជាក់លាក់។

២- ប្រសិនបើទំនិញនោះស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃសមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តម្លៃនៃវត្ថុធាតុវេចខ្ចប់និងកុងតឺន័រ ត្រូវបានចាត់ទុកថាជាវត្ថុធាតុមានដើមកំណើត ឬមិនមានដើមកំណើត ក្នុងការគណនាសមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃទំនិញនោះតាមករណីនីមួយៗ។

**មាត្រា៣.១២ _ វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការដឹកជញ្ជូននិងការដឹកតាមកប៉ាល់**

ភាគីសមាជិកនីមួយៗត្រូវផ្តល់ថា វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការដឹកជញ្ជូននិងការដឹកតាមកប៉ាល់ មិនត្រូវយកមកពិចារណាក្នុងការកំណត់ថាទំនិញមួយមានដើមកំណើតឡើយ។

**មាត្រា៣.១៣ _ វត្ថុធាតុឬធាតុទំនិញដែលអាចដំនួសគ្នាបាន**

១- ភាគីសមាជិកនីមួយៗត្រូវផ្តល់ថា ការកំណត់ថាតើវត្ថុធាតុឬទំនិញដែលអាចដំនួសគ្នាបានមានដើមកំណើតឬទេត្រូវធ្វើឡើងតាមរយៈការបែងចែកដោយរូបវន្តនៃទំនិញឬវត្ថុធាតុនីមួយៗឬតាមរយៈការប្រើវិធីគ្រប់គ្រងបញ្ជីសារពើកណ្តា ឬក្នុងករណីពិបាកណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងគោលការណ៍គណនេយ្យទូទៅនៃភាគីសមាជិកដែលការផលិតត្រូវបានអនុវត្តឬវិធីសាស្ត្រផ្សេងៗណាមួយទទួលស្គាល់ដោយភាគីសមាជិកទាំងពីរ។

២- ភាគីសមាជិកនីមួយៗ ត្រូវផ្តល់ថាវិធីគ្រប់គ្រងបញ្ជីសារពើកណ្តាដែលបានជ្រើសរើសក្រោមកថាខណ្ឌ១ នៃមាត្រានេះ សម្រាប់អនុវត្តវត្ថុធាតុឬទំនិញដែលអាចដំនួសគ្នាបាន ត្រូវបន្តប្រើសម្រាប់វត្ថុធាតុ ឬទំនិញដែលអាចដំនួសគ្នាទាំងនោះពេញមួយឆ្នាំសារពើពន្ធនៃភាគីដែលបានជ្រើសរើសវិធីសាស្ត្រគ្រប់គ្រងបញ្ជីសារពើកណ្តា។

## ផ្នែក ខ៖ ដែនដី និងការឆ្លងកាត់

**មាត្រា៣.១៤ _ ការឆ្លងកាត់និងការផ្ទេរមធ្យោបាយដឹកជញ្ជូន**

១- ភាគីសមាជិកនីមួយៗ ត្រូវរក្សាឱ្យបាននូវស្ថានភាពដើមនូវទំនិញដែលមានដើមកំណើត ប្រសិនបើទំនិញនោះត្រូវបានដឹកជញ្ជូនចេញទៅភាគីនាំចូលដោយផ្ទាល់ ដោយមិនឆ្លងកាត់ដែនដីដែលមិនមែនជារបស់ភាគីសមាជិកណាម្នាក់។

២- ទោះបីមានចែងក្នុងកថាខណ្ឌ១ខាងលើក៏ដោយ ភាគីសមាជិកនីមួយៗត្រូវរក្សាអោយបាននូវស្ថានភាពដើមនៃទំនិញដែលមានដើមកំណើត ទោះក្នុងករណីទំនិញនោះបានឆ្លងកាត់ ឬតាមរយៈមួយឬច្រើននូវទីតាំងអន្តរការីដែលមិនមែនជាភាគីសមាជិកក៏ដោយ ទំនិញនោះត្រូវ៖

(ក) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គយ ក្នុងដែនដីមិនមែនជារបស់ភាគីសមាជិក

(ខ) មិនបានឆ្លងកាត់ប្រតិបត្តិការណាមួយ ក្រៅតែពីការទម្លាក់ទំនិញចុះ ការលើកឡើងវិញ ការបំបែកចេញពីដុំធំៗ ការរក្សាទុក ឬប្រតិបត្តិការណាមួយធ្វើឡើងដើម្បីរក្សាទំនិញឱ្យស្ថិតក្នុងស្ថានភាពល្អប្រសើរ។

៣- ផ្អែកតាមការស្នើសុំ អ្នកនាំចូលត្រូវផ្តល់នូវកេស្តុតាងឱ្យបានសមស្របជូនអាជ្ញាធរគយនៃភាគីនាំចូលអំពីអនុលោមភាពដែលខ្លួនបានបំពេញដូចមានចែងក្នុងកថាខណ្ឌ២។

**មាត្រា៣.១៥ _ តំបន់សេដ្ឋកិច្ចសេរីឬតំបន់សេរី**

១- ភាគីទាំងពីរត្រូវចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថាទំនិញដើមដែលត្រូវបានជួញដូរក្រោមរូបភាពសំអាងដើមកំណើតដែលក្នុងកំឡុងពេលនៃការដឹកជញ្ជូននៅក្នុងតំបន់សេរីស្ថិតនៅក្នុងដែនដីរបស់ខ្លួន មិនត្រូវបានជំនួសដោយទំនិញផ្សេងឡើយ និងមិនត្រូវឆ្លងកាត់សកម្មភាពណាមួយក្រៅពីប្រតិបត្តិការទូទៅដែលត្រូវធ្វើឡើងដើម្បីការពារការខូចខាតតែប៉ុណ្ណោះ។

២- ទំនិញដែលផលិតឬត្រូវបានបង្កើតឡើងនៅក្នុងតំបន់សេរី ដែលស្ថិតនៅក្នុងភាគីសមាជិកណាមួយនោះនឹងត្រូវចាត់ទុកថាជាទំនិញមានដើមកំណើតនៅក្នុងភាគីនោះនៅពេលនាំចេញទៅភាគីម្ខាងទៀត ដោយសំអាងលើការប្រព្រឹត្តកម្មឬការកែច្នៃ អនុលោមទៅតាមបទប្បញ្ញត្តិនៃជំពូកនេះ និងផ្អែកលើសំអាងដើមកំណើត។

**មាត្រា៣.១៦ _ និក្ខេបបត្រចេញដោយភាគីទីបី**

១- អាជ្ញាធរគយនៃភាគីនាំចូលមិនត្រូវបដិសេធវិញ្ញាបនបត្រដើមកំណើតទំនិញ ដោយក្រោមមូលហេតុថានិក្ខេបបត្រមិនត្រូវបានចេញដោយអ្នកនាំចេញឬអ្នកផលិតទំនិញ ស្របពេលដែលទំនិញនោះបានអនុលោមទៅតាមតម្រូវការនានាក្នុងជំពូកនេះ។

២- អ្នកនាំចេញទំនិញត្រូវបង្ហាញ "និក្ខេបបត្រចេញដោយភាគីទីបី" និងព័ត៌មានដូចជា ឈ្មោះនិងប្រទេសនៃក្រុមហ៊ុនដែលចេញនិក្ខេបបត្រត្រូវបង្ហាញឱ្យបានសមស្របទៅតាមប្រឡង់ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ៣ខ (វិញ្ញាបនបត្រដើមកំណើត)។

## ផ្នែក គ៖ ការបញ្ជាក់ដើមកំណើត

**មាត្រា៣.១៧ _ សំអាងដើមកំណើត**

១- ទំនិញដែលមានប្រភពមកពីភាគីសមាជិកមួយ ក្នុងការនាំចូលទៅភាគីម្ខាងទៀតត្រូវទទួលបានអត្ថប្រយោជន៍ពីការអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើសំអាងដើមកំណើត។

២- ខាងក្រោមនេះអាចចាត់ទុកបានជាសំអាងដើមកំណើត៖

(ក) វិញ្ញាបនបត្រដើមកំណើតក្នុងទម្រង់ក្រដាសមានលក្ខណៈជាច្បាប់ចម្លងទន់ឬរឹង ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងនៅក្នុងមាត្រា៣.១៨

(ខ) វិញ្ញាបនបត្របញ្ជាក់ដើមកំណត់ក្នុងទម្រង់អេឡិចត្រូនិក(E-Certificate) ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច និងត្រូវធ្វើការផ្លាស់ប្តូរគ្នាទៅវិញទៅមកតាមប្រព័ន្ធអេឡិចត្រូនិកដែលកសាងឡើងរួមគ្នា ដោយយោងទៅតាមមាត្រា៣.១៩ និង

(គ) ប្រតិវេទន៍ដើមកំណើតដែលបានអនុម័តដោយអ្នកនាំចេញស្របតាមមាត្រា៣.២០។

៣- ភាគីនីមួយៗត្រូវផ្តល់សំអាងដើមកំណើត ដែលត្រូវធ្វើឡើងជាភាសាអង់គ្លេសនិងត្រូវមានសុពលភាពរយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលចេញលិខិតនោះ។

## មាត្រា៣.១៨ _ វិញ្ញាបនបត្រដើមកំណើតក្នុងទម្រង់ក្រដាស

១- វិញ្ញាបនបត្រដើមកំណើតក្នុងទម្រង់ក្រដាសត្រូវ៖

(ក) ស្ថិតក្នុងទម្រង់ស្តង់ដាA4 ក្រដាសពណ៌ស ដូចដែលមានជូបភ្ជាប់ក្នុងឧបសម្ព័ន្ធ៣ខ (វិញ្ញាបនបត្របញ្ជាក់ដើមកំណើត)

(ខ) ភ្ជាប់មកនូវច្បាប់ដើមមួយច្បាប់និងច្បាប់ចម្លងពីរច្បាប់។ ចំពោះច្បាប់ដើមត្រូវបញ្ជូនទៅអ្នកនាំចូលដោយអ្នកនាំចេញឬអ្នកផលិត ដើម្បីដាក់ជូនអាជ្ញាធរគយនៃភាគីអ្នកនាំចូល។ ច្បាប់ចម្លងទី២ ត្រូវរក្សាទុកនៅអាជ្ញាធរមានសមត្ថកិច្ចនៃភាគីអ្នកនាំចេញ ហើយច្បាប់ចម្លងទី៣ ត្រូវរក្សាទុកនៅអ្នកផលិតឬអ្នកនាំចេញ។

(គ) អាចផ្ទុកទំនិញមួយឬច្រើនក្រោមការដឹកជញ្ជូនម្តង និង

(ឃ) ត្រូវរក្សាក្នុងទម្រង់បោះពុម្ព(Printed Format) ឬមធ្យោបាយផ្សេងទៀតរួមមាន ទម្រង់អេឡិចត្រូនិក។

២- វិញ្ញាបនបត្រដើមកំណើតនីមួយៗ ត្រូវមានលេខឯកសារយោង(Serial Reference Number) ជាប់ដោយឡែកពីគ្នា ដែលត្រូវផ្តល់ឱ្យដោយទីតាំងឬការិយាល័យចេញវិញ្ញាបនបត្រនីមួយៗ។

៣- វិញ្ញាបនបត្របញ្ជាក់ដើមកំណើតមួយ ត្រូវមានហត្ថលេខា និងត្រាផ្លូវការរបស់អាជ្ញាធរមានសមត្ថកិច្ច។ ការបោះត្រាផ្លូវការ អាចត្រូវបានធ្វើឡើងតាមរយៈអេឡិចត្រូនិក។

៤- ក្នុងករណីការបោះត្រាផ្លូវការត្រូវបានអនុវត្តតាមរយៈអេឡិចត្រូនិក យន្តការផ្ទៀងផ្ទាត់ ដូចជា QRកូដឬគេហទំព័រដែលមានសុវត្ថិភាពត្រូវបញ្ចូលក្នុងវិញ្ញាបនបត្រនោះ ដើម្បីឱ្យវិញ្ញាបនបត្រនោះអាចចាត់ទុកបានជាច្បាប់ចម្លងដើម។

## មាត្រា៣.១៩ _ ប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការផ្លាស់ប្តូរព័ត៌មានដើមកំណើត

សម្រាប់គោលបំណងនៃមាត្រា៣.១៧ កថាខណ្ឌ២(ខ) គូភាគីត្រូវខិតខំព្យាយាមបង្កើតប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការផ្លាស់ប្តូរព័ត៌មានដើមកំណើត ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធិភាពនិងស័ក្តិសិទ្ធិភាពនៃជំពូកនេះ ជាពិសេសលើការបញ្ជូនវិញ្ញាបនបត្រដើមកំណើតអេឡិចត្រូនិក។

## មាត្រា៣.២០ _ ប្រតិវេទន៍ដើមកំណើត

១- សម្រាប់គោលបំណងនៃមាត្រា៣.១៧ កថាខណ្ឌ២ (គ) ក្នុងរយៈពេល១ឆ្នាំ ចាប់ពីថ្ងៃកិច្ចព្រមព្រៀងនេះចូលជាធរមាន បណ្តាភាគីត្រូវអនុវត្តបញ្ញត្តិដែលអនុញ្ញាតឱ្យអាជ្ញាធរគយឬអាជ្ញាធរ

មានសមត្ថកិច្ចទទួលស្គាល់ប្រតិវេទន៍ដើមកំណើតដែលចេញដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត។

២- អាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ អាចផ្តល់សិទ្ធិឱ្យអ្នកនាំចេញ (ចាប់ពីនេះតទៅហៅថា "អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត" ដែលនាំចេញទំនិញក្រោមកិច្ចព្រមព្រៀងនេះ ឱ្យចេញប្រតិវេទន៍ដើមកំណើត ដែលមានគំរូដូចបង្ហាញក្នុងឧបសម្ព័ន្ធ៣គ(ប្រតិវេទន៍ដើមកំណើត) ដោយមិនគិតពីតម្លៃទំនិញពាក់ព័ន្ធ។

៣- អ្នកនាំចេញដែលស្នើសុំការផ្តល់សិទ្ធិនេះ ត្រូវបំពេញតាមការតម្រូវរបស់អាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញនូវរាល់ការធានាចាំបាច់ ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពទទួលបានដើមកំណើតនៃទំនិញ ក៏ដូចជាបំពេញតម្រូវការផ្សេងទៀតនៅក្នុងដំពូកនេះ។

៤- ប្រតិវេទន៍ដើមកំណើត(អត្ថបទដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ៣គ (ប្រតិវេទន៍ដើមកំណើត)) ត្រូវធ្វើឡើងដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតដោយការវាយអត្ថបទ ការបោះត្រា ឬការបោះពុម្ពសេចក្តីប្រកាសនៅលើក្តុយបត្រ ឬបញ្ជីវេចខ្ចប់ ក្នុងករណីដែលមិនមានក្តុយបត្រ។

៥- អាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ អាចផ្តល់ការទទួលស្គាល់ជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត អាស្រ័យតាមលក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងមាត្រា៣.២១។

**មាត្រា៣.២១ _ អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត**

១- ភាគីនីមួយៗ ត្រូវរៀបចំឱ្យមានការផ្តល់សិទ្ធិអ្នកនាំចេញដែលនាំចេញទំនិញក្រោមកិច្ចព្រមព្រៀងនេះ ជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។ អ្នកនាំចេញដែលស្នើសុំការផ្តល់សិទ្ធិនេះ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរឬក្នុងទម្រង់អេឡិចត្រូនិក និងត្រូវបំពេញតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញនូវការធានាចាំបាច់ ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពទទួលបានដើមកំណើតនៃទំនិញដែលមានក្នុងប្រតិវេទន៍ដើមកំណើត។ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញអាចផ្តល់ការទទួលស្គាល់ជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត អាស្រ័យតាមលក្ខខណ្ឌនានាដែលខ្លួនចាត់ទុកថាសមស្រប រាប់បញ្ចូលនូវចំណុច ដូចខាងក្រោម៖

(ក) អ្នកនាំចេញបានចុះបញ្ជីត្រឹមត្រូវ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃភាគីនាំចេញ

(ខ) អ្នកនាំចេញដឹងនិងយល់ពីវិធានដើមកំណើតដូចមានចែងក្នុងដំពូកនេះ

(គ) អ្នកនាំចេញមានបទពិសោធក្នុងកម្រិតសមរម្យលើការនាំចេញ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃភាគីនាំចេញ

(ឃ) អ្នកនាំចេញមានប្រវត្តិអនុលោមភាពល្អ ដែលបានវាស់វែងដោយការគ្រប់គ្រងហានិភ័យរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ

(ង) អ្នកនាំចេញ ក្នុងករណីជាពាណិជ្ជករ អាចទទួលបានសេចក្តីប្រកាសចេញដោយអ្នកផលិតបញ្ជាក់ពីស្ថានភាពទទួលបានដើមកំណើតនៃទំនិញ ដែលត្រូវបំពេញលើប្រតិវេទន៍ដើមកំណើតដែលចេញដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងការត្រៀមរួចជាស្រេច

របស់អ្នកផលិត ដើម្បីផ្តល់កិច្ចសហការក្នុងដំណើរការផ្ទៀងផ្ទាត់អនុលោមតាមមាត្រា ៣.៣០ និងបំពេញរាល់ការតម្រូវនៃជំពូកនេះ និង

(ច) អ្នកនាំចេញមានបញ្ជីគណនេយ្យនិងប្រព័ន្ធកត់ត្រាដែលរក្សាថែទាំបានល្អ ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃកាតីនាំចេញ។

២- អាជ្ញាធរមានសមត្ថកិច្ចនៃកាតីនាំចេញត្រូវ៖

(ក) ធ្វើឱ្យនីតិវិធីនិងតម្រូវការរបស់ខ្លួនស្តីពីអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត បានដឹងឮដល់សាធារណៈ និងងាយស្រួលស្វែងរក

(ខ) ផ្តល់ឱ្យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត នូវការផ្តល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬជាទម្រង់អេឡិចត្រូនិក

(គ) ផ្តល់ឱ្យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតនូវលេខកូដសម្គាល់សិទ្ធិ ដែលត្រូវតែជាក់បញ្ចូលក្នុងប្រតិវេទន៍ដើមកំណើត និង

(ឃ) បញ្ចូលព័ត៌មានស្តីពីសិទ្ធិអនុញ្ញាតដែលបានផ្តល់ ទៅក្នុងមូលដ្ឋានទិន្នន័យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតដូចមានយោងក្នុងកថាខណ្ឌ៦ ឱ្យបានទាន់ពេលវេលា។

៣- អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

(ក) អនុញ្ញាតឱ្យអាជ្ញាធរគយមានសមត្ថកិច្ចឬអាជ្ញាធរមានសមត្ថកិច្ចនៃកាតីនាំចេញអាចពិនិត្យឯកសារកំណត់ត្រានិងអាជីវកម្មដ្ឋាន សម្រាប់គោលបំណងតាមដានការប្រើប្រាស់សិទ្ធិអនុញ្ញាត អនុលោមតាមមាត្រា៣.៣១

(ខ) បំពេញប្រតិវេទន៍ដើមកំណើតសម្រាប់តែទំនិញដែលអ្នកនាំចេញបានទទួលសិទ្ធិអនុញ្ញាតពីអាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃកាតីនាំចេញឱ្យធ្វើដូចនេះបាន និងនៅពេលដែលអ្នកនាំចេញនោះមានឯកសារសមស្របទាំងអស់ដែលបញ្ជាក់ពីស្ថានភាពទទួលដើមកំណើតនៃទំនិញពាក់ព័ន្ធនៅពេលបំពេញប្រតិវេទន៍នោះ

(គ) ទទួលខុសត្រូវទាំងស្រុងលើប្រតិវេទន៍ដើមកំណើតទាំងអស់ដែលបានចេញ រួមទាំងកំហុសក្នុងការប្រើប្រាស់ទាំងឡាយផងដែរ និង

(ឃ) ជូនដំណឹងឱ្យបានភ្លាមៗដល់អាជ្ញាធរគយ ឬអាជ្ញាធរមានសមត្ថកិច្ចនៃកាតីនាំចេញនូវរាល់ការផ្លាស់ប្តូរពាក់ព័ន្ធនឹងព័ត៌មានដូចមានចែងក្នុងវាក្យខណ្ឌខ)។

៤- កាតីនីមួយៗត្រូវបញ្ចូលព័ត៌មាននៃអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត ឱ្យបានទាន់ពេលវេលាទៅក្នុងមូលដ្ឋានទិន្នន័យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតដូចខាងក្រោម៖

(ក) ឈ្មោះផ្លូវការនិងអាសយដ្ឋានរបស់អ្នកនាំចេញ

(ខ) លេខកូដសម្គាល់សិទ្ធិរបស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត

(គ) កាលបរិច្ឆេទចេញ និងកាលបរិច្ឆេទផុតសុពលភាពនៃការផ្តល់សិទ្ធិអនុញ្ញាតដល់អ្នកនាំចេញរបស់ខ្លួនប្រសិនបើមាន និង

(ឃ) បញ្ជីទំនិញដែលជាកម្មវត្ថុនៃការផ្តល់សិទ្ធិអនុញ្ញាត យ៉ាងហោចណាស់ត្រឹមកម្រិតជំពូកនៃប្រព័ន្ធសុខដុម។

រាល់ការផ្លាស់ប្តូរចំណុចណាមួយដូចមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ឃ) ឬការដកហូត ឬល្បះសិទ្ធិអនុញ្ញាត ត្រូវបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតឱ្យបានភ្លាមៗ។

៥- ទោះជាមានចែងក្នុងកថាខណ្ឌ ៤ មិនមានភាគីសមាជិកណាមួយត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មានដូចមានក្នុងកថាខណ្ឌនោះទៅក្នុងមូលដ្ឋានទិន្នន័យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតទៀតទេ ប្រសិនបើភាគីនោះមានគេហទំព័រដែលមានសុវត្ថិភាព មានផ្ទុកព័ត៌មានខាងលើដែលគូភាគីអាចចូលទៅប្រើប្រាស់បាន។

៦- អាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ ត្រូវធ្វើបច្ចុប្បន្នភាពនូវបញ្ជីអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងបោះផ្សាយចែករំលែកឱ្យបានទៀងទាត់។

៧- អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញត្រូវតាមដានការប្រើប្រាស់សិទ្ធិអនុញ្ញាត រាប់បញ្ចូលទាំងការផ្ទៀងផ្ទាត់ប្រតិវេទន៍ដើមកំណើតចេញដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងការដកហូតសិទ្ធិនៅពេលដែលលក្ខខណ្ឌមានចែងក្នុងកថាខណ្ឌ ១ មិនត្រូវបានបំពេញ។

៨- អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតត្រូវរៀបចំ ដើម្បីដាក់ជូនតាមសំណើរបស់អាជ្ញាធរគយនៃភាគីនាំចូលនៅពេលណាមួយ នូវរាល់ឯកសារសមស្របដែលបញ្ជាក់ពីស្ថានភាពទទួលបានដើមកំណើតរបស់ទំនិញ រាប់បញ្ចូលទាំងការអះអាងរបស់អ្នកផ្គត់ផ្គង់ឬអ្នកផលិត អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីនាំចូល ក៏ដូចជាការបំពេញតាមការតម្រូវនានានៃដំពូកនេះ។

**មាត្រា ៣.២២ : ការស្នើសុំនិងការពិនិត្យការស្នើសុំវិញ្ញាបនបត្រដើមកំណើតទំនិញ**

១- វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ តាមការស្នើសុំជាទម្រង់អេឡិចត្រូនិកឬទម្រង់ក្រដាស ដែលបានធ្វើឡើងដោយអ្នកនាំចេញ ឬក្រោមការទទួលខុសត្រូវរបស់អ្នកនាំចេញដោយអ្នកទទួលបានសិទ្ធិជាតំណាង អនុលោមតាមបទប្បញ្ញត្តិផ្ទៃក្នុងរបស់ភាគីនាំចេញ

២- អ្នកនាំចេញដែលស្នើសុំវិញ្ញាបនបត្រដើមកំណើតត្រូវត្រៀមលក្ខណៈគ្រប់ពេលវេលា តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញនូវរាល់ឯកសារសមស្របសម្រាប់បញ្ជាក់ពីស្ថានភាពទទួលបានដើមកំណើតនៃទំនិញពាក់ព័ន្ធក៏ដូចជាការបំពេញតាមការតម្រូវផ្សេងទៀតនៃដំពូកនេះ:

៣- អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យឱ្យបានត្រឹមត្រូវតាមសមត្ថកិច្ចនិងសមត្ថភាពរបស់ខ្លួន ដើម្បីធានាបានថា:

(ក) លិខិតស្នើសុំនិងវិញ្ញាបនបត្រដើមកំណើតគឺ បានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវដោយអ្នកដែលទទួលបានសិទ្ធអនុញ្ញាត

(ខ) ដើមកំណើតទំនិញគឺស្របទៅតាមបទប្បញ្ញត្តិនៃដំពូកនេះ:

(គ) លេខកូដទំនិញ ការបរិយាយ បរិមាណ និងទម្ងន់របស់ទំនិញ ម៉ាកឬស្លាក និងចំនួននៃការវេចខ្ចប់ ចំនួននិងប្រភេទនៃការវេចខ្ចប់ ដូចមានបញ្ជាក់ ស្របតាមទំនិញដែលនឹងត្រូវបាននាំចេញ និង

(ឃ) ទំនិញច្រើនមុខក្នុងការដឹកជញ្ជូនតែមួយដើង ដែលប្រកាសក្នុងវិញ្ញាបនបត្រដើមកំណើតតែមួយនឹងត្រូវបានអនុញ្ញាត ក្នុងលក្ខខណ្ឌដែលមុខទំនិញនីមួយៗមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយឡែករៀងគ្នា។

**មាត្រា៣.២៣ _ វិញ្ញាបនបត្រដើមកំណើតចេញជាលក្ខណៈប្រតិសកម្ម**

១- វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញមុនឬកំឡុងពេលដឹកជញ្ជូន។

២- ក្នុងករណីលើកលែង នៅពេលដែលវិញ្ញាបនបត្រដើមកំណើតមិនត្រូវបានចេញមុនឬកំឡុងពេលដឹកជញ្ជូន ដោយសារកំហុសឬការរំលងដោយអចេតនាឬមូលហេតុសមស្របណាមួយ វិញ្ញាបនបត្រដើមកំណើតអាចចេញជាលក្ខណៈប្រតិសកម្ម ប៉ុន្តែមានសុពលភាពមិនលើសពីមួយឆ្នាំ គិតចាប់ពីថ្ងៃដឹកជញ្ជូនដែលចាំបាច់ត្រូវបញ្ជាក់ "ISSUED RETROACTIVELY" ក្នុងទីតាំងសមស្របដូចមានលម្អិតក្នុងឧបសម្ព័ន្ធ៣ខ(វិញ្ញាបនបត្រដើមកំណើត)។

៣- អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះនិងនៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន បទប្បញ្ញត្តិក្នុងមាត្រានេះត្រូវអនុវត្តលើមុខទំនិញកំពុងត្រូវបានដឹកជញ្ជូនទៅកាន់ភាគីសមាជិកស្របតាមមាត្រា៣.១៤ ឬកំពុងស្ថិតក្នុងសន្និធិបណ្តោះអាសន្នក្រោមការគ្រប់គ្រងរបស់សមត្ថកិច្ចគយ។ នេះត្រូវដាក់ម្មវត្ថុនៃការដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល ក្នុងរយៈពេល៦ខែគិតចាប់ពីថ្ងៃបរិច្ឆេទខាងលើនូវវិញ្ញាបនបត្រដើមកំណើតដែលបានចេញប្រតិសកម្ម ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញ រួមជាមួយឯកសារដែលបង្ហាញថាទំនិញត្រូវបានដឹកជញ្ជូនត្រង់អនុលោមតាមបញ្ញត្តិនៃមាត្រា៣.១៤។

**មាត្រា៣.២៤ _ ការបាត់បង់នូវវិញ្ញាបនបត្រដើមកំណើត**

១- ក្នុងករណីវិញ្ញាបនបត្រដើមកំណើតត្រូវបានលួច បាត់ ឬបំផ្លាញ ក្រុមហ៊ុនផលិត អ្នកផលិត អ្នកនាំចេញឬតំណាងដែលទទួលបានសិទ្ធិអនុញ្ញាត អាចដាក់ពាក្យទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញវិញ្ញាបនបត្រនោះ ដើម្បីទទួលបានសេចក្តីចម្លងច្បាប់ដើមនៃវិញ្ញាបនបត្រដើមកំណើតដែលនឹងចេញដោយផ្អែកលើឯកសារនាំចេញដែលតម្កល់នៅអាជ្ញាធរមានសមត្ថកិច្ច។

២- សេចក្តីចម្លងច្បាប់ដើមនៃវិញ្ញាបនបត្រដើមកំណើត ត្រូវបានផ្តល់ការទទួលស្គាល់ដោយហត្ថលេខានិងត្រាផ្លូវការ និងមានបញ្ជាក់ពាក្យ "សេចក្តីចម្លងច្បាប់ដើម" ("CERTIFIED TRUE COPY") និងកាលបរិច្ឆេទចេញនៃវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម ក្នុងប្រឡង់សមស្របដូចមានលម្អិតក្នុងឧបសម្ព័ន្ធ៣ខ(វិញ្ញាបនបត្រដើមកំណើត)។ សេចក្តីចម្លងច្បាប់ដើមនៃវិញ្ញាបនបត្រដើមកំណើតត្រូវមានសុពលភាពដូចគ្នាទៅនឹងវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម។

៣- អ្នកនាំចេញត្រូវជូនដំណឹងភ្លាមៗនៃការបាត់បង់ទៅអាជ្ញាធរមានសមត្ថកិច្ច និងមិនត្រូវប្រើប្រាស់វិញ្ញាបនបត្រដើមកំណើតច្បាប់ដើម សម្រាប់ការនាំចេញក្រោមកិច្ចព្រមព្រៀងនេះទេ។

**មាត្រា៣.២៥ _ ការនាំចូលធំនិញដោះបំបែកឬមិនទាន់ផ្តុំមកតម្លើងតាមការដឹកជញ្ជូនច្រើនដើង**

តាមសំណើអ្នកនាំចូលនិងក្នុងលក្ខខណ្ឌកំណត់ដោយអាជ្ញាធរគយនៃការគីនាំចូល ផលិតផលដែលដោះបំបែកជាភាគបំណែកឬមិនទាន់ផ្តុំតម្លើងដូចក្នុងនិយមន័យនៃវិធានទូទៅ២(ក) របស់ប្រព័ន្ធសុខដុមដែលត្រូវបាននាំចូលដោយការដឹកជញ្ជូនច្រើនដើង សំអាងដើមកំណើតតែមួយសម្រាប់ផលិតផលបែបនេះត្រូវដាក់ជូនអាជ្ញាធរគយនៅពេលនាំចូលនៃការដឹកជញ្ជូនដើងទីមួយ។

**មាត្រា៣.២៦ _ ប្រព្រឹត្តកម្មចំពោះការប្រកាសខុសនៅក្នុងវិញ្ញាបនបត្រដើមកំណើត**

ការកោសលុបឬសរសេរត្រួតលើគ្នា មិនត្រូវបានអនុញ្ញាតឱ្យមាននៅលើវិញ្ញាបនបត្រដើមកំណើតឡើយ។ ការកែប្រែណាមួយត្រូវធ្វើឡើង ដោយការចេញវិញ្ញាបនបត្រដើមកំណើតថ្មីដើម្បីជំនួសវិញ្ញាបនបត្រមានកំហុស។ លេខយោងនៃវិញ្ញាបនបត្រដើមកំណើតដែលបានកែតម្រូវរួចគួរតែត្រូវបានបង្ហាញនៅក្នុងផ្នែកសមស្របនៅលើវិញ្ញាបនបត្រដើមកំណើតដែលបានចេញថ្មីនោះ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ៣ខ(វិញ្ញាបនបត្រដើមកំណើត)។ សុពលភាពនៃវិញ្ញាបនបត្រជំនួសនឹងដូចគ្នាទៅនឹងច្បាប់ដើមដំបូង។

**មាត្រា៣.២៧ _ ប្រព្រឹត្តកម្មនៃភាពលម្អៀងតិចតួច**

១- ការរកឃើញភាពលម្អៀងតិចតួចរវាងអំណៈអំណាង ដែលបានធ្វើឡើងនៅក្នុងសំអាងដើមកំណើត និងបានធ្វើឡើងក្នុងឯកសារដែលបានដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូលក្នុងគោលបំណងអនុវត្តបែបបទសម្រាប់នាំចូលទំនិញ ដោយឥទ្ធិពលបែបនេះមិនត្រូវធ្វើមោយភាពចំពោះសំអាងដើមកំណើតនោះទេ ប្រសិនបើវាពិតជាត្រូវគ្នានឹងទំនិញដែលបានដាក់ជូន។

២- កំហុសផ្លូវការដាក់ស្តែង ដូចជាកំហុសក្នុងការវាយអត្ថបទ លើសំអាងដើមកំណើត មិនគួរដោយហេតុធ្វើឱ្យឯកសារនេះត្រូវបដិសេធឡើយ ប្រសិនបើកំហុសទាំងនេះមិនមែនបង្កើតការសង្ស័យទាក់ទងនឹងភាពត្រឹមត្រូវនៃអំណៈអំណាងដែលបានធ្វើឡើងនៅក្នុងឯកសារនេះ។

## ផ្នែក ៤ៈ កិច្ចសហប្រតិបត្តិការនិងការផ្លាស់ដើមកំណើត

**មាត្រា៣.២៨ _ ការបដិសេធប្រព្រឹត្តកម្មអនុគ្រោះពន្ធ**

១- លើកលែងករណីផ្សេងទៀតដែលបានផ្តល់នៅក្នុងជំពូកនេះ អាជ្ញាធរគយនៃភាគីនាំចូលអាចបដិសេធការទាមទារប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ ឬយកត្រលប់មកវិញប្រាក់ពន្ធដែលមិនទាន់បានបង់ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ក្នុងករណីដែល៖

(ក) ទំនិញដែលមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ

(ខ) អ្នកនាំចូល អ្នកនាំចេញ ឬអ្នកផលិតទំនិញ ខកខានឬមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធណាមួយនៃជំពូកនេះ ដើម្បីទទួលបានប្រព្រឹត្តកម្មអត្រាពន្ធអនុគ្រោះ

(គ) អាជ្ញាធរគយនៃភាគីនាំចូល មិនបានទទួលព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់ថាទំនិញមានដើមកំណើត ឬ

(ឃ) អ្នកនាំចេញ អ្នកផលិត ឬអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរគយនៃភាគីនាំចេញ មិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធការផ្ទៀងផ្ទាត់ ដោយអនុលោមតាមមាត្រា៣.២៩ ឬមាត្រា៣.៣០។

២- ប្រសិនបើអាជ្ញាធរគយនៃភាគីនាំចូលបដិសេធចំពោះការទាមទារសម្រាប់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ ពួកគេត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅអ្នកនាំចូល ដោយរួមបញ្ចូលហេតុផលសម្រាប់សេចក្តីសម្រេចនោះ។

៣- នៅពេលមានការទំនាក់ទំនងអំពីហេតុផលសម្រាប់ការបដិសេធប្រព្រឹត្តកម្មអនុគ្រោះពន្ធរួចហើយ ក្នុងកំឡុងពេលដែលច្បាប់គយនៃភាគីនាំចូលអនុញ្ញាត អ្នកនាំចូលអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចនោះជាមួយនឹងអាជ្ញាធរដែលសមស្របស្ថិតនៅក្រោមច្បាប់គយនិងបទប្បញ្ញត្តិនៃភាគីនាំចូល។

**មាត្រា៣.២៩ _ ការត្រួតពិនិត្យជាប្រតិសកម្ម**

១- អាជ្ញាធរគយនៃភាគីនាំចូលអាចស្នើសុំការត្រួតពិនិត្យជាប្រតិសកម្មដោយចៃដន្យ ឬនៅពេលមានការសង្ស័យដោយសមហេតុផលណាមួយ អំពីយថាភូតភាពនៃឯកសារឬភាពត្រឹមត្រូវនៃព័ត៌មានដែលពាក់ព័ន្ធនឹងដើមកំណើតទំនិញពិតប្រាកដនៃទំនិញដែលមានការសង្ស័យ ឬផ្នែកខ្លះរបស់ទំនិញនោះ។

២- សម្រាប់គោលបំណងនៃកថាខណ្ឌ១ អាជ្ញាធរគយនៃភាគីនាំចូលអាចអនុវត្តដំណើរការត្រួតពិនិត្យដោយចេញលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីស្នើសុំព័ត៌មានបន្ថែមពីអាជ្ញាធរមានសមត្ថកិច្ចឬអាជ្ញាធរគយនៃភាគីនាំចេញ។

៣- សំណើសុំត្រូវតែអមជាមួយនឹងសំអាងដើមកំណើតច្បាប់ថតចម្លងដែលពាក់ព័ន្ធ ហើយត្រូវបញ្ជាក់ហេតុផលច្បាស់លាស់និងព័ត៌មានបន្ថែមណាមួយ ដែលបង្ហាញថាព័ត៌មានដែលបានបង្ហាញលើសំអាងដើមកំណើតនោះអាចមានភាពមិនច្បាស់លាស់ លុះត្រាតែការត្រួតពិនិត្យជាប្រតិសកម្មត្រូវបានស្នើដោយផ្អែកលើមូលដ្ឋានត្រួតពិនិត្យដោយចៃដន្យ។

៤- អាជ្ញាធរគយនៃភាគីនាំចូលអាចព្យួរបញ្ញត្តិនៃការផ្តល់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ ខណៈពេលរង់ចាំលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចូលអាចបញ្ចេញទំនិញទៅអ្នកនាំចូល ដោយអនុលោមតាមវិធានការរដ្ឋបាលដែលចាត់ទុកថាចាំបាច់ ប្រសិនបើទំនិញទាំងនោះមិនជាកម្មវត្ថុនៃការហាមឃាត់ឬការដាក់កម្រិតកំណត់នាំចូល និងមិនមានការសង្ស័យពីបទល្មើសណាមួយ។

៥- យោងលើកថាខណ្ឌ២ ភាគីពាក់ព័ន្ធដែលទទួលបានសំណើសុំការត្រួតពិនិត្យជាប្រតិសកម្មត្រូវឆ្លើយតបទៅនឹងសំណើសុំភ្លាមៗ និងឆ្លើយតបទៅភាគីនាំចូលក្នុងកំឡុងពេលមិនលើស៩០ថ្ងៃ បន្ទាប់ពីទទួលបានសំណើ។

៦. នៅពេលកិច្ចឆ្លើយតបពីភាគីពាក់ព័ន្ធមិនត្រូវបានទទួលក្នុងកំឡុងពេល៩០ថ្ងៃ បន្ទាប់ពីថ្ងៃដែលទទួលបានការស្នើសុំ យោងលើកថាខណ្ឌ៥នោះ អាជ្ញាធរគយនៃភាគីនាំចូលអាចបដិសេធប្រព្រឹត្តកម្មអនុគ្រោះពន្ធលើទំនិញដែលមានក្នុងសម្ភារដើមកំណើត ដែលជាកម្មវត្ថុក្នុងការត្រួតពិនិត្យជាប្រតិសកម្មនោះ។

**មាត្រា៣.៣០ _ ទស្សនកិច្ចផ្ទៀងផ្ទាត់**

១- អនុលោមតាមកថាខណ្ឌ២នៃមាត្រា៣.២៩ ប្រសិនបើអាជ្ញាធរគយនៃភាគីនាំចូលមិនពេញចិត្តជាមួយនឹងលទ្ធផលនៃការត្រួតពិនិត្យជាប្រតិសកម្មនោះ អាជ្ញាធរគយនៃភាគីនាំចូលនោះអាចរៀបចំឬស្នើសុំអាជ្ញាធរគយឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ ដើម្បីធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នៅអាជីវកម្មដ្ឋាននៃអ្នកផលិតឬអ្នកនាំចេញ ដែលរួមមានការត្រួតពិនិត្យគណនេយ្យ កំណត់ត្រារបស់អ្នកនាំចេញឬអ្នកផលិតឬការត្រួតពិនិត្យផ្សេងទៀតដែលយល់ថាសមស្រប ក្រោមលក្ខខណ្ឌលើកលែងជាពិសេសណាមួយសម្រាប់ហេតុផលអាចវិនិច្ឆ័យបាន។

២- មុនពេលធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ដោយអនុលោមតាមកថាខណ្ឌ១ អាជ្ញាធរគយនៃភាគីនាំចូលត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរគយនៃភាគីនាំចេញអំពីការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នេះ។

៣- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានលើកឡើងក្នុងកថាខណ្ឌ២ត្រូវតែមានអត្ថន័យគ្រប់ជ្រុងជ្រោយតាមតែអាចធ្វើទៅបាននិងត្រូវបញ្ចូលក្នុងចំណោមព័ត៌មានផ្សេងទៀតនូវ៖

(ក) អ្នកផលិត ឬអ្នកនាំចេញ ដែលជាម្ចាស់អាជីវកម្មដ្ឋានដែលនឹងត្រូវធ្វើទស្សនកិច្ច

(ខ) ហេតុផលនៃការមិនពេញចិត្តនឹងលទ្ធផលនៃការត្រួតពិនិត្យជាប្រតិសកម្មដែលបានរៀបចំដោយអាជ្ញាធរមានសមត្ថកិច្ចឬអាជ្ញាធរគយនៃភាគីនាំចេញ

(គ) ទិដ្ឋភាពគោលបំណងនៃសំណើធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ រួមបញ្ចូលទាំងឯកសារយោងរបស់ទំនិញដែលជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់។

៤- អាជ្ញាធរគយនៃភាគីនាំចូល ឬអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរគយនៃភាគីនាំចេញត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកផលិតឬអ្នកនាំចេញដែលជាម្ចាស់អាជីវកម្មដ្ឋាននឹងត្រូវធ្វើទស្សនកិច្ច។

៥- នៅពេលដែលមិនទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកផលិតឬអ្នកនាំចេញ ក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃនៃការទទួលបានលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ អាជ្ញាធរគយនៃភាគីនាំចូលអាចបដិសេធលើប្រព្រឹត្តកម្មអនុគ្រោះពន្ធ ចំពោះទំនិញដែលជាកម្មវត្ថុនៃការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នោះ។

៦- អាជ្ញាធរគយនៃភាគីនាំចូល ឬអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរគយនៃភាគីនាំចេញដែលធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ត្រូវផ្តល់ជូនការកំណត់ជាលាយលក្ខណ៍អក្សរថាតើទំនិញនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានឬមិនបានដើមកំណើតដល់អ្នកផលិតឬអ្នកនាំចេញដែលមានទំនិញជាកម្មវត្ថុនៃការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នោះ។

៧- នៅពេលចេញការកំណត់ជាលាយលក្ខណ៍អក្សរដូចដែលកំណត់ក្នុងកថាខណ្ឌ៦ ថាទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានដើមកំណើតហើយនោះ អាជ្ញាធរគយនៃភាគីនាំចូលត្រូវផ្តល់ឡើងវិញនូវអត្ថប្រយោជន៍អនុគ្រោះពន្ធភ្លាមៗ និងបង្វែរប្រាក់ពន្ធដែលបានបង់លើសពីពន្ធអនុគ្រោះឬសងត្រឡប់នូវប្រាក់និមុត្តធានា ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកនៃភាគី។

៨- នៅពេលចេញការកំណត់ជាលាយលក្ខណ៍អក្សរដូចដែលកំណត់ក្នុងកថាខណ្ឌ៦ ថាទំនិញមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានដើមកំណើតនោះទេ អ្នកផលិតឬអ្នកនាំចេញត្រូវបានអនុញ្ញាតរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានការកំណត់ជាលាយលក្ខណ៍អក្សរនោះដើម្បីផ្តល់យោបល់ ឬព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ទំនិញសម្រាប់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ។ ការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយត្រូវបញ្ជូនទៅអ្នកផលិតឬអ្នកនាំចេញក្នុងកំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានមតិយោបល់ឬព័ត៌មានបន្ថែម។

៩- ដំណើរការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ ព្រមទាំងការធ្វើទស្សនកិច្ចជាក់ស្តែងនិងការកំណត់ក្រោមកថាខណ្ឌ៦ត្រូវអនុវត្តនិងត្រូវជូនដំណឹងពីលទ្ធផលនៃការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នោះទៅអាជ្ញាធរមានសមត្ថកិច្ចឬអាជ្ញាធរគយនៃភាគីនាំចូលឬភាគីនាំចេញក្នុងកំឡុងពេលយ៉ាងយូរ ៦ខែ បន្ទាប់ពីថ្ងៃទីមួយនៃការទទួលសំណើជាលាយលក្ខណ៍អក្សរក្នុងការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់លើកដំបូង។ ក្នុងកំឡុងពេលនៃដំណើរការផ្ទៀងផ្ទាត់ កថាខណ្ឌ៨ នៃមាត្រា៣.២៩ ត្រូវបានអនុវត្ត។

**មាត្រា៣.៣១ _ តម្រូវការរក្សាទុកឯកសារ**

១- សម្រាប់គោលបំណងនៃដំណើរការផ្ទៀងផ្ទាត់យោងតាមមាត្រា៣.២៩ និងមាត្រា៣.៣០ ភាគីនីមួយៗតម្រូវដូចខាងក្រោម៖

(ក) ក្រុមហ៊ុនផលិត អ្នកផលិត ឬអ្នកនាំចេញត្រូវរក្សាទុកឯកសារកំណត់ត្រាគាំទ្រសំខាន់ៗទាំងអស់ដែលបញ្ជាក់ថាទំនិញដែលមានក្នុងសំអាងដើមកំណើតត្រូវបានចេញមានដើមកំណើតក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ គិតចាប់ពីថ្ងៃដែលចេញសំអាងដើមកំណើតឬក្នុងរយៈពេលវែងជាងនេះ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក និង

(ខ) អ្នកនាំចូលត្រូវរក្សាទុកឯកសារកំណត់ត្រាគាំទ្រសំខាន់ៗទាំងអស់ ដែលបញ្ជាក់ថាទំនិញដែលទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធមានដើមកំណើត ក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ គិតចាប់ពីថ្ងៃនាំចូលទំនិញឬក្នុងរយៈពេលវែងជាងនេះ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក និង

(គ) អាជ្ញាធរមានសមត្ថកិច្ច ត្រូវរក្សាទុកឯកសារកំណត់ត្រាគាំទ្រសំខាន់ៗទាំងអស់នៃការស្នើសុំសម្ពាងដើមកំណើត ក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ គិតចាប់ពីថ្ងៃដែលចេញសំអាងដើមកំណើតឬក្នុងរយៈពេលវែងជាងនេះ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក។

២- រាល់ឯកសារកំណត់ត្រាចែងក្នុងកថាខណ្ឌ១ អាចរក្សាទុកក្នុងឧបករណ៍ផ្ទុកណាមួយដែលអនុញ្ញាតឱ្យទាញយកទិន្នន័យវិញបានភ្លាមៗ រួមមានទម្រង់ឌីជីថល អេឡិចត្រូនិកអុបទិក ម៉ាញ៉េទិក ឬទម្រង់ជាលាយលក្ខណ៍អក្សរ។

**មាត្រា៣.៣២ _ ការសម្ងាត់**

រាល់ព័ត៌មានទាំងអស់ដែលទាក់ទងនឹងការអនុវត្តនៃជំពូកនេះ ដែលត្រូវបានប្រាស្រ័យទាក់ទងគ្នារវាងគូភាគី ត្រូវចាត់ទុកជាការសម្ងាត់។ អាជ្ញាធរនៃភាគីសមាជិកមិនត្រូវបង្ហាញព័ត៌មានទាំងនោះដោយគ្មានការអនុញ្ញាតច្បាស់លាស់ពីបុគ្គលឬអាជ្ញាធរដែលផ្តល់ព័ត៌មានទាំងនោះឡើយ។

**មាត្រា៣.៣៣ _ ចំណុចទំនាក់ទំនង**

ក្នុងកំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីសមាជិកនីមួយៗត្រូវចាត់តាំងចំនុចទំនាក់ទំនងមួយឬច្រើនរូបដែលស្ថិតក្នុងអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនសម្រាប់ការអនុវត្តជំពូកនេះ ហើយជូនដំណឹងអំពីព័ត៌មានទំនាក់ទំនងនៃចំណុចទំនាក់ទំនងរូបនោះ ឬចំណុចទំនាក់ទំនងច្រើនរូបនោះទៅភាគីសមាជិកម្ខាងទៀត។ ភាគីសមាជិកនីមួយៗត្រូវជូនដំណឹងភ្លាមៗដល់ភាគីសមាជិកម្ខាងទៀតនូវរាល់ការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានទំនាក់ទំនងទាំងនោះ។

**មាត្រា៣.៣៤ _ ការជួយទៅវិញទៅមក**

អាជ្ញាធរមានសមត្ថកិច្ចនៃភាគីសមាជិកទាំងពីរត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកនូវ៖

(ក) គំរូហត្ថលេខានិងត្រាផ្លូវការដែលប្រើនៅក្នុងការិយាល័យរបស់ខ្លួន សម្រាប់ការចេញវិញ្ញាបនបត្រដើមកំណើត។

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការផ្ទៀងផ្ទាត់សំអាងដើមកំណើត និង

(គ) គេហទំព័រដែលមានសុវត្ថិភាពសម្រាប់ការផ្ទៀងផ្ទាត់កូដ QR និងវិញ្ញាបនបត្រដើមកំណើតអេឡិចត្រូនិក។

## ផ្នែក ៦៖ ការពិគ្រោះយោបល់និងការកែតម្រូវ

**មាត្រា៣.៣៥ _ ការពិគ្រោះយោបល់និងការកែតម្រូវ**

គូភាគីត្រូវពិគ្រោះយោបល់និងសហការតាមការសមស្រប តាមរយៈគណៈកម្មាធិការចម្រុះ/អនុគណៈកម្មាធិការដើម្បី៖

(ក) ពិភាក្សានិងដោះស្រាយបញ្ហាទាក់ទងនឹងការអនុវត្តនៃជំពូកនេះ

(ខ) ត្រួតពិនិត្យការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ និង

(គ) ពិភាក្សាអំពីវិសោធនកម្មចាំបាច់ចំពោះជំពូកនេះដោយគិតគូរពីការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាដំណើរការផ្សេងទៀត និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។

## ឧបសម្ព័ន្ធ៣ក
## វិធានជាក់លាក់សម្រាប់ផលិតផល

**កំណត់សម្គាល់នៃឧបសម្ព័ន្ធ៖**

១- សម្រាប់ការបកស្រាយវិធានដើមកំណើតទំនិញក្នុងឧបសម្ព័ន្ធនេះ៖

(ក) **HS Code** សំដៅដល់នាមវលីនៃប្រព័ន្ធសុខដុម ឆ្នាំ២០២២

(ខ) **ផ្នែក** សំដៅដល់ផ្នែកដែលមានចែងក្នុងលេខកូដនៃប្រព័ន្ធសុខដុម

(គ) **ជំពូក** សំដៅដល់លេខពីរខ្ទង់ដំបូងនៃលេខចំណាត់ថ្នាក់ពន្ធគយ ដែលស្ថិតក្រោមលេខកូដនៃប្រព័ន្ធសុខដុម

(ឃ) **ចំណងជើង** សំដៅដល់លេខបួនខ្ទង់ដំបូងនៃលេខចំណាត់ថ្នាក់ពន្ធគយ ដែលស្ថិតក្រោមលេខកូដនៃប្រព័ន្ធសុខដុម និង

(ង) **ចំណងជើងរង** សំដៅដល់លេខប្រាំមួយខ្ទង់ដំបូងនៃលេខចំណាត់ថ្នាក់ពន្ធគយ ដែលស្ថិតក្រោមលេខកូដនៃប្រព័ន្ធសុខដុម។

២- ឧបសម្ព័ន្ធនេះត្រូវបានកំណត់ដូចខាងក្រោម៖

(ក) **ជួរឈរទី១** - HS Code (ផ្នែក ជំពូក ចំណងជើង ឬចំណងជើងរង)

(ខ) **ជួរឈរទី២** - ការពិពណ៌នាអំពីផលិតផល ដោយយោងទៅតាម HS Code

(គ) **ជួរឈរទី៣** - វិធានជាក់លាក់សម្រាប់ផលិតផល (លក្ខណៈវិនិច្ឆ័យដើមកំណើត)

(ឃ) **ជួរឈរទី៤** - ជម្រើសផ្សេងទៀតនៃវិធានជាក់លាក់សម្រាប់ផលិតផល (លក្ខណៈវិនិច្ឆ័យដើមកំណើត)

៣- នៅពេលដែលវិធានមួយត្រូវបានបញ្ជាក់ក្នុងជួរឈរទី៣ឬទី៤ អ្នកនាំចេញអាចអនុវត្តវិធានណាមួយដែលត្រូវបានកំណត់ក្នុងជួរឈរទី៣ឬទី៤។

៤- ក្នុងករណីមួយចំនួន នៅពេលដែលជួរឈរទី១ត្រូវបាននាំមុខដោយ 'ex' នោះបង្ហាញថាវិធាននៅក្នុងជួរឈរទី៣ឬទី៤ អនុវត្តទៅលើតែផ្នែកនៃចំណងជើងរង ចំណងជើង ឬជំពូកមួយនោះប៉ុណ្ណោះ ដូចដែលបានពិពណ៌នានៅក្នុងជួរឈរទី២។

៥- នៅពេលដែលវិធានជាក់លាក់សម្រាប់ផលិតផលមួយតម្រូវឱ្យវត្ថុធាតុដែលបានប្រើប្រាស់ ត្រូវឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ ឬប្រតិបត្តិការកែច្នៃ ឬដំណើរការផលិតជាក់លាក់មួយ វិធានទាំងនោះត្រូវអនុវត្តតែចំពោះវត្ថុធាតុមិនមានដើមកំណើតប៉ុណ្ណោះ។

៦- នៅពេលដែលវិធានដើមកំណើតជាក់លាក់មួយ ត្រូវបានកំណត់ដោយប្រើលក្ខណៈវិនិច្ឆ័យនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ វិធាននោះនឹងត្រូវបានចាត់ទុកថាត្រូវបានបំពេញ លុះត្រាតែវត្ថុធាតុមិនមានដើមកំណើតនីមួយៗ ដែលត្រូវបានប្រើប្រាស់ក្នុងផលិតកម្មទំនិញនោះបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ។

៧- សម្រាប់គោលបំណងនៃជួរឈរទី៣ និងទី៤ នៃឧបសម្ព័ន្ធនេះ៖

(ក) **WO ឬ wholly obtained** សំដៅដល់ផលិតផលដែលត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការទទួលបានទាំងស្រុង ស្របតាមមាត្រា៣.៣ នៃជំពូកនេះ

(ខ) CC សំដៅដល់រាល់វត្ថុធាតុមិនមានដើមកំណើតទាំងអស់ ដែលត្រូវបានប្រើនៅក្នុងផលិតកម្មទំនិញ ដែលបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត២ខ្ទង់

(គ) CTC សំដៅដល់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ

(ឃ) CTH សំដៅដល់រាល់វត្ថុធាតុមិនមានដើមកំណើតទាំងអស់ ដែលត្រូវបានប្រើនៅក្នុងផលិតកម្មទំនិញ ដែលបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត៤ខ្ទង់

(ង) CTSH សំដៅដល់រាល់វត្ថុធាតុមិនមានដើមកំណើតទាំងអស់ ដែលត្រូវបានប្រើនៅក្នុងផលិតកម្មទំនិញ បានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត៦ខ្ទង់

(ច) SO សំដៅដល់ប្រតិបត្តិការជាក់លាក់ឬតម្រូវការបច្ចេកទេសណាមួយ ដែលបានកំណត់លម្អិតនៅក្នុងនោះ

(ច) QVC សំដៅដល់សមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងកថាខណ្ឌ៨ នៃឧបសម្ព័ន្ធនេះ

(ឆ) N/A សំដៅដល់ ការមិនមានវិធានដែលអាចអនុវត្តបាន។

៨- សម្រាប់គោលបំណងនៃជួរឈរទី៣ឬទី៤ នៃឧបសម្ព័ន្ធនេះ QVCត្រូវគណនាដូចដែលបានបញ្ជាក់នៅក្នុងមាត្រា៣.៤៖

| HS Code (១) | បរិយាយផលិតផល (២) | វិធានជាក់លាក់សម្រាប់ផលិតផល (PSRs) | |
|---|---|---|---|
| | | (៣) | (៤) |
| 0101 - 0106 | សត្វរស់ | Wholly obtained | N/A |
| 0201 - 0210 | សាច់សត្វនិងល្បាយសាច់សត្វលាយគ្រឿងក្នុងដែលអាចបរិភោគបាន | All the materials of Chapters 1 and 2 used are wholly obtained | N/A |
| 0301 - 0309 | ត្រីនិងសត្វរន្តសត្វ(ក្តាម បង្គង) សិប្បិសត្វ (ខ្យង គ្រំ) និងនិបិដ្ឋាជ្ជិកសត្វ (សត្វគ្មានឆ្អឹងកងខ្នង) រស់នៅក្នុងទឹកផ្សេងទៀត | all the materials of Chapter 3 used are wholly obtained | N/A |
| 0401 - 0410 | ផលិតផលធ្វើពីទឹកដោះ៖ ស៊ុតសត្វស្លាប ទឹកឃ្មុំ ធម្មជាតិ គ្រឿងបរិភោគមានដើមកំណើតពីសត្វដែលមិនបានរៀបរាប់ឬចែងនៅកន្លែងផ្សេងទៀត | all the materials of Chapter 4 used are wholly obtained | N/A |
| Ex 0406 | ហ្ស៊ូម៉ា និងទឹកដោះ:កក | CTH | QVC |
| 0501 - 0511 | ផលិតផលដែលមានដើមកំណើតពីសត្វដែលគ្មានចែង ឬដាក់បញ្ចូលនៅកន្លែងផ្សេងទៀត | all the materials of Chapter 5 used are wholly obtained | N/A |

| HS Code (១) | បរិយាយផលិតផល (២) | វិធានជាក់លាក់សម្រាប់ផលិតផល (PSRs) | |
|---|---|---|---|
| | | (៣) | (៤) |
| 0601 - 0604 | ដើមឈើ និងរុក្ខជាតិរស់ផ្សេងទៀត មើម ឫស និងដើមឈើ និងរុក្ខជាតិប្រហាក់ប្រហែល ផ្កាកាត់ហើយ និងមែកឈើទាំងស្លឹកសម្រាប់លម្អ | all the materials of Chapter 6 used are wholly obtained | N/A |
| 0701 - 0714 | បន្លែដែលអាចបរិភោគបាន និងឫស និងមើមមួយចំនួន | all the materials of Chapter 7 used are wholly obtained | N/A |
| 0801 - 0810 | ផ្លែឈើ និងគ្រាប់ផ្លែឈើដែលអាចបរិភោគបាន សម្បកផ្លែឈើពពូកក្រូច ឬផ្លែម៉ឺឡុង | all the materials of Chapter 8 used are wholly obtained | N/A |
| 0811 - 0814 | ផ្លែឈើ និងគ្រាប់ផ្លែឈើ មិនទាន់ចម្អិន ឬចម្អិនដោយការចំហុយ ឬស្ងោរនឹងទឹកពុះ កក បើទោះមានឬមិនមានបន្ថែមស្ករ ឬសារជាតិផ្អែមដទៃទៀត | QVC | N/A |
| 0901 | កាហ្វេ | SO (roasting and blending) | QVC |
| 0902 | តែ | CC | QVC |
| Ex 0904 - 0910 | គ្រឿងទេសចម្រុះ | CC | QVC |
| 1001- 1008 | ធញ្ញជាតិ | all the materials of Chapter 10 used are wholly obtained | N/A |
| 1201-1207 1209 - 1214 | គ្រាប់ និងផ្លែឈើដែលមានជាតិប្រេង គ្រាប់ធញ្ញជាតិ គ្រាប់ពូជ និងផ្លែឈើផ្សេងៗ ដំណាំឧស្សាហកម្ម រុក្ខជាតិវិសជ ចំបើង និងស្មៅចំបើងសម្រាប់ចិញ្ចឹមសត្វ | all the materials of Chapter 12 used are wholly obtained | N/A |
| 1301 | ជ័រម្រ័ក្សណ៍ ជ័រធម្មជាតិ ជ័រឈើ ជ័រឈើទឹក និងអូឡេអូរេស៊ីន | Wholly Obtained | N/A |

| HS Code (๑) | បរិយាយផលិតផល (๒) | វិធានជាក់លាក់សម្រាប់ផលិតផល (PSRs) | |
|---|---|---|---|
| | | (๓) | (๔) |
| 1401 - 1404 | វត្ថុធាតុដើមជារុក្ខជាតិសម្រាប់វេញក្រង; បណ្ណាផលិតផលរុក្ខជាតិ ដែលពុំមានបញ្ជាក់ និងបញ្ចូលនៅទីតាំងផ្សេងទៀត | all the materials of Chapter 14 used are wholly obtained | N/A |
| 1510, 1512, 1514, 1515 | ប្រេងផ្សេងទៀតដែលបានពីអូលីវ គ្រាប់ឈូកគេន គ្រាប់កប្បាស គ្រាប់រុក្ខជាតិរេព កុលហ្សា ប្រេងម៉ាស្តាត ប្រេងរុក្ខជាតិផ្សេងទៀត បណ្ណាប្រភេទខ្លាញ់បានពីពពួកអតិសុខុមប្រាណ និងប្រេងនានា (រាប់បញ្ចូលទាំងប្រេង jojoba) | CTSH or SO (manufactured by refining crude oils) | QVC |
| 2401 | ថ្នាំជក់ធៅ សំណល់ថ្នាំជក់ | Wholly Obtained | N/A |
| 6101 - 6117 | សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរ ឬមួយ | CC | QVC |
| 6201 - 6217 | សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលមិនធ្វើឡើងពីការចាក់ដោយម្ជុលពីរឬមួយ | CC | QVC |
| 6301 - 6308 | វត្ថុវាយនកណ្ដាកែច្នៃផ្សេងៗទៀត ឈុត សម្លៀកបំពាក់ប្រើរួច និងវត្ថុវាយនកណ្ដាប្រើរួច ក្រណាត់កន្ទប | CC | QVC |
| 7106, 7108 and 7110 | លោហធាតុមានតម្លៃ :<br>- មិនទាន់កែច្នៃ | CTH | SO (Electrolytic, thermal or chemical separation of precious metals of heading 7106, 7108 or 7110) |
| 8702 - 8704 | យានយន្ត | QVC | N/A |

| HS Code (๑) | បរិយាយផលិតផល (๒) | វិធានជាក់លាក់សម្រាប់ផលិតផល (PSRs) | |
|---|---|---|---|
| | | (๓) | (๔) |
| 8711 | ទោចក្រយានយន្ត (រួមទាំងម៉ូតូមានឈ្នាន់ធាក់) និងទោចក្រយានមានម៉ាស៊ីន មានឬគ្មានរទេះចំហៀង; រទេះចំហៀង | QVC | N/A |

# ឧបសម្ព័ន្ធ៣ខ ទិញ្ញាបនបត្រដើមកំណើតទំនិញ

| | |
|---|---|
| ១- ឈ្មោះ អាសយដ្ឋាន ប្រទេសរបស់អ្នកនាំចេញ | *លេខវិញ្ញាបនបត្រ*<br>**<u>កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម</u>**<br>**វិញ្ញាបនបត្រដើមកំណើត**<br>ចេញនៅ _____<br>(ប្រទេស)<br>សូមពិនិត្យមើលកំណត់សម្គាល់នៅទំព័រខាងខ្នង |
| ២- ឈ្មោះ អាសយដ្ឋាន ប្រទេសរបស់អ្នកផលិត | |
| ៣- ឈ្មោះ អាសយដ្ឋាន ប្រទេសរបស់អ្នកទទួលទំនិញ | |
| ៤- មធ្យោបាយដឹកជញ្ជូននិងគម្រោយផ្លូវ សូមផ្តល់ប្រសិនបើដឹង<br>កាលបរិច្ឆេទចេញដំណើរ៖<br>ឈ្មោះរបស់នាវា/យន្តហោះ -ល-៖<br>កំពង់ផែផ្ទុកទំនិញ៖<br>កំពង់ផែផ្ទេរទំនិញ៖ | សម្រាប់ការប្រើប្រាស់ជាផ្លូវការ<br>☐ ត្រូវបានផ្តល់ប្រព្រឹត្តកម្មអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម<br>☐ មិនត្រូវបានផ្តល់ប្រព្រឹត្តកម្មអនុគ្រោះពន្ធ (សូមបញ្ជាក់នូវហេតុផល)<br>.....<br>ហត្ថលេខារបស់ហត្ថលេខីដែលទទួលបានសិទ្ធិនៃប្រទេសនាំចូល |
| | ៥-<br>☐ ក្លែយបត្រភាគីទីបី<br>(ឈ្មោះ និងអាសយដ្ឋាន) |
| | ៦- កំណត់សម្គាល់ |

| ៧- ចំនួនទំនិញ | ៨ក- ម៉ាកសញ្ញានិងចំនួនលេីកថ្នាប់ | ៨ខ- ចំនួននិងប្រភេទនៃកញ្ចប់, ការបរិយាយនៃផលិតផល, HS Code ក្នុងកម្រិត ៦ខ្ទង់ | ៩- លក្ខណៈនិថ្នៃដើមកំណើត | ១០- ទម្ងន់សរុប ឬបរិមាណនិងតម្លៃផ្សេងទៀត (FOB/ Ex-Work ប្រើតែពេលដែលលក្ខណៈនិថ្នៃ QVC ត្រូវបានប្រើប្រាស់) | ១១- លេខ និងកាលបរិច្ឆេទក្លែយបត្រ |
|---|---|---|---|---|---|
| | | | | | |

| | |
|---|---|
| ១២- សេចក្តីប្រកាសរបស់អ្នកនាំចេញ<br>ហត្ថលេខាខាងក្រោមនេះអះអាងថា ព័ត៌មានលម្អិត និងសេចក្តីប្រកាសខាងលើពិតជាត្រឹមត្រូវ ហើយផលិតផលទាំងអស់ត្រូវបានផលិតក្នុង<br>.....<br>(ប្រទេស)<br>ហើយដែលត្រូវបានអនុលោមតាមលក្ខខណ្ឌតម្រូវដើមកំណើតសម្រាប់ទំនិញទាំងនោះ ក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម សម្រាប់ផលិតផលទាំងឡាយណាដែលត្រូវបាននាំចេញទៅកាន់<br>.....<br>(ប្រទេសនាំចូល)<br>.....<br>ទីកន្លែង និងកាលបរិច្ឆេទ ហត្ថលេខានិងត្រារបស់ហត្ថលេខីដែលទទួលបានសិទ្ធិ | ១៣- ការបញ្ជាក់វិញ្ញាបនបត្រ<br>**ផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យដែលបានអនុវត្ត សូមធ្វើការបញ្ជាក់ថា ព័ត៌មាននៅទីនេះគឺត្រឹមត្រូវ ហើយថាទំនិញដែលបានពិពណ៌នាអនុលោមតាមលក្ខខណ្ឌតម្រូវដើមកំណើតដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម។**<br>ហត្ថលេខា និងត្រា<br>[QR Code or Website]<br>.....<br>ទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់អាជ្ញាធរមានសមត្ថកិច្ច |

## កំណត់សម្គាល់នៅទំព័រខាងខ្នង

**ប្រអប់១៖** បញ្ជាក់ឈ្មោះពេញស្របច្បាប់ អាសយដ្ឋាន(រួមទាំងប្រទេស) របស់អ្នកនាំចេញ។

**ប្រអប់២៖** ផ្តល់ឱ្យអ្នកផលិតទំនិញ(ឈ្មោះនិងប្រទេស)។ ប្រសិនបើអ្នកផលិតនិងអ្នកនាំចេញគឺដូចគ្នា នោះបំពេញប្រអប់ជាមួយនឹងព័ត៌មានលម្អិតដូចក្នុងប្រអប់១។ ប្រសិនបើអ្នកនាំចេញឬអ្នកផលិតចង់ឱ្យ រក្សាព័ត៌មាននេះជាការសម្ងាត់ នោះអាចទទួលយកបានដោយបញ្ជាក់ថា "អាចផ្តល់ជូនដល់អាជ្ញាធរ មានសមត្ថកិច្ចឬស្ថាប័នដែលមានការអនុញ្ញាត តាមការស្នើសុំ"។

**ប្រអប់៣៖** បញ្ជាក់ឈ្មោះពេញស្របច្បាប់ អាសយដ្ឋាន(រួមទាំងប្រទេស) របស់អ្នកទទួលទំនិញ។

**ប្រអប់៥៖ វិក្កយបត្រចេញដោយភាគីទីបី៖** ក្នុងករណីដែលវិក្កយបត្រត្រូវបានចេញដោយភាគីទីបី ប្រអប់ "វិក្កយបត្រចេញដោយភាគីទីបី" ត្រូវបានគូស (✓) ហើយព័ត៌មាន ដូចជា ឈ្មោះ អាសយដ្ឋានរបស់ ក្រុមហ៊ុនដែលចេញវិក្កយបត្រត្រូវបានបង្ហាញជាដើម។ ក្នុងករណីពិសេសដែលវិក្កយបត្រដែលចេញ ដោយភាគីទីបីមិនមាននៅពេលចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមកំណើត លេខវិក្កយបត្រ និងកាល បរិច្ឆេទនៃវិក្កយបត្រដែលចេញដោយអ្នកនាំចេញ ដែលវិញ្ញាបនបត្រដើមត្រូវបានចេញគួរតែត្រូវបាន បង្ហាញក្នុងប្រអប់១១ ហើយវាគួរតែត្រូវបានបង្ហាញនៅក្នុងប្រអប់៥ ថាទំនិញជាកម្មវត្ថុនៃការចេញ វិក្កយបត្រមួយទៀតដែលនឹងត្រូវចេញដោយភាគីទីបីសម្រាប់ការនាំចូលទៅក្នុងភាគីនាំចូល ដោយកំណត់ ឈ្មោះពេញស្របច្បាប់ និងអាសយដ្ឋានរបស់ក្រុមហ៊ុន ឬបុគ្គលដែលនឹងចេញវិក្កយបត្រមួយទៀត។ ក្នុងករណីបែបនេះ អាជ្ញាធរគយនៃភាគីនាំចូលអាចតម្រូវឱ្យអ្នកនាំចូលផ្តល់វិក្កយបត្រនិងឯកសារពាក់ ព័ន្ធផ្សេងទៀត ដែលបញ្ជាក់ពីប្រតិបត្តិការពីភាគីនាំចេញទៅភាគីនាំចូល ទាក់ទងនឹងទំនិញដែលបាន ប្រកាសសម្រាប់ការនាំចូល។

**ប្រអប់៦៖ កំណត់សម្គាល់៖** ប្រអប់នេះនឹងមានការសង្កេតដែលធ្វើឡើងដោយប្រទេសនាំចេញ ឧទាហរណ៍៖

"**ត្រូវបានចេញដោយប្រតិសកម្ម**"៖ ក្នុងករណីលើកលែងមួយចំនួន នៅពេលដែលវិញ្ញាបនបត្រដើម កំណើតមិនបានចេញមុនឬនៅពេលលើកដាក់មធ្យោបាយដឹកជញ្ជូន ឬវិញ្ញាបនបត្រដើមកំណើតត្រូវ បានចេញដោយប្រតិសកម្ម ដោយអនុលោមកថាខណ្ឌ១ នៃមាត្រា៣.២៥

"**ត្រូវបានបញ្ជាក់ជាច្បាប់ចម្លងពិត**"៖ ក្នុងករណីនៃការបាត់បង់ឬការបំផ្លិចបំផ្លាញនៃវិញ្ញាបនបត្រដើម កំណើត ដូចក្នុងមាត្រា៣.២៦

"**ការជំនួស**"៖ ក្នុងករណីនៃការចេញវិញ្ញាបនបត្រដើមកំណើតជំនួសដោយអនុលោមតាមមាត្រា៣.២៨ ត្រូវបង្ហាញលេខនៃវិញ្ញាបនបត្រដើមកំណើតមុន។

**ប្រអប់៧៖** បញ្ជាក់លេខរៀងមុខទំនិញ។

**ប្រអប់៨ក៖** ម៉ាកសញ្ញាដឹកជញ្ជូន និងចំនួនលើកញ្ចប់ ត្រូវបញ្ជាក់ផងដែរ។

**ប្រអប់៨ខ៖** ផ្តល់ការបរិយាយពេញលេញនៃទំនិញនីមួយៗ។ ការបរិយាយគួរតែលម្អិតគ្រប់គ្រាន់ដើម្បីឱ្យផលិតផលត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីគយដែលធ្វើការពិនិត្យ ហើយធ្វើឱ្យទាក់ទងទៅនឹងការបរិយាយក្នុងវិក្កយបត្រនិងការបរិយាយរបស់ប្រព័ន្ធសុខដុមនៃទំនិញ។ លេខកូដតាមប្រព័ន្ធសុខដុមគួរតែនៅកម្រិតប្រាំមួយខ្ទង់។

**លក្ខណៈវិនិច្ឆ័យដើមកំណើត៖** សម្រាប់ទំនិញដែលបំពេញលក្ខណៈវិនិច្ឆ័យដើមកំណើត អ្នកនាំចេញឬអ្នកផលិតត្រូវបង្ហាញក្នុងប្រអប់៩ នៃទម្រង់នេះ លក្ខណៈវិនិច្ឆ័យដើមកំណើតដែលបានបំពេញតាមរបៀបដូចក្នុងតារាងខាងក្រោម៖

| **លក្ខណៈវិនិច្ឆ័យដើមកំណើត** | |
|---|---|
| (ក) ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុងនៅក្នុងប្រទេសនាំចេញ បំពេញលក្ខខណ្ឌមាត្រា៣.៣ | "WO" |
| (ខ) ទំនិញបំពេញលក្ខខណ្ឌមាត្រា៣.៤ | |
| • ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ | វិធានជាក់ស្តែង CTC, ឧទាហរណ៍ "CC" ឬ "CTH" ឬ "CTSH" |
| • សមាសភាគតម្លៃតំបន់ | "QVC%", ឧទាហរណ៍ "40%" |
| • ប្រតិបត្តិការដោក់លាក់ | "SO" |
| (គ) ទំនិញដែលផលិតទាំងស្រុងពីវត្ថុធាតុមានដើមកំណើតដោយអនុលោមកថាខណ្ឌគ នៃមាត្រា៣.២ | "PE" |

**ប្រអប់១១៖** លេខវិក្កយបត្រ និងកាលបរិច្ឆេទនៃវិក្កយបត្រគួរតែត្រូវបានបង្ហាញនៅទីនេះ។

## ឧបសម្ព័ន្ធ៣គ
## ប្រតិវេទន៍ដើមកំណើតអនុលោមតាមមាត្រា៣.២០

អ្នកនាំចេញនូវផលិតផល[1]ដែលមានក្នុងឯកសារនេះ (លេខកូដសម្គាល់សិទ្ធិរបស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត[2]...) អះអាងថា លើកលែងករណីផ្សេងទៀតដែលមានការបង្ហាញច្បាស់លាស់ ផលិតផលទាំងនេះមានអនុគ្រោះដើមកំណើតនៃ... ស្របតាមវិធានដើមកំណើតនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម ហើយលក្ខណៈវិនិច្ឆ័យដើមកំណើតគឺ ... (សូមមើលកំណត់សម្គាល់សេចក្តីពន្យល់)។

[3]ទីកន្លែងនិងកាលបរិច្ឆេទ

ហត្ថលេខានិងត្រារបស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត បន្ថែមពីលើនេះ ឈ្មោះរបស់អ្នកចុះហត្ថលេខាលើប្រតិវេទន៍ត្រូវតែបង្ហាញជាអក្សរច្បាស់លាស់

កំណត់សម្គាល់សេចក្តីពន្យល់ (មិនសម្រាប់បោះពុម្ព) :
សម្រាប់គោលបំណងនៃលក្ខណៈវិនិច្ឆ័យដើមកំណើត :

| **លក្ខណៈវិនិច្ឆ័យដើមកំណើត** | |
|---|---|
| (ក) ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុងនៅក្នុងប្រទេសនាំចេញ បំពេញលក្ខខណ្ឌមាត្រា៣.៣ | "WO" |
| (ខ) ទំនិញបំពេញលក្ខខណ្ឌមាត្រា៣.៤<br>• ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ | ដែនដាក់ស្លែង CTC, ឧទាហរណ៍ "CC" ឬ "CTH" ឬ "CTSH" |
| • សមាសភាគតម្លៃតំបន់ | "QVC%", ឧទាហរណ៍ "40%" |
| • ប្រតិបត្តិការដោកំលាក់ | "SO" |
| (គ) ទំនិញដែលផលិតទាំងស្រុងពីវត្ថុធាតុមានដើមកំណើតដោយអនុលោមកថាខណ្ឌ(គ) នៃមាត្រា៣.២ | "PE" |

ប្រសិនបើមានមុខទំនិញច្រើនដែលមានលក្ខណៈនិច្ចយដើមកំណើតផ្សេងៗគ្នា នោះមុខទំនិញនីមួយៗ នឹងត្រូវបង្ហាញជាមួយនឹងលក្ខណៈនិច្ចយដើមកំណើតដែលត្រូវគ្នាទៅតាមមុខទំនិញនោះ។

---

[1] ព័ត៌មានអប្បបរមាដែលត្រូវបញ្ចូលក្នុងឯកសារពាណិជ្ជកម្ម មានដូចជាឈ្មោះនិងអាសយដ្ឋានរបស់អ្នកនាំចេញ ឈ្មោះនិងអាសយដ្ឋានរបស់អ្នកផលិត ប្រសិនបើមាន ឈ្មោះនិងអាសយដ្ឋានរបស់អ្នកនាំចូលឬអ្នកទទួលទំនិញ ការបរិយាយនៃទំនិញ(រួមបញ្ចូលទាំងលេខកូដយបត្រ បរិមាណនៃទំនិញ) និងHS Code ក្នុងកម្រិត៦ខ្ទង់ លក្ខណៈនិច្ចយដើមកំណើត តម្លៃ FOB នៅពេលដែលលក្ខណៈនិច្ចយ QVC ត្រូវបានប្រើប្រាស់ លេខយោងតែមួយគត់នៃឯកសារ

[2] សម្គាល់សិទ្ធិរបស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតត្រូវតែដាក់បញ្ចូលក្នុងចន្លោះនេះ។

[3] ការបង្ហាញទាំងនេះអាចត្រូវបានលុបចោល ប្រសិនបើព័ត៌មានទាំងនេះមាននៅលើឯកសារួចជាស្រេច។

# ជំពូកទី៤
# នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម

## មាត្រា៤.១ _ និយមន័យ

គោលបំណងនៃជំពូកនេះ៖ និយមន័យខាងក្រោមមានន័យថា៖

(ក) **ប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (AEO)** មានន័យថាជាកម្មវិធីដែលទទួលស្គាល់ប្រតិបត្តិករពាក់ព័ន្ធនឹងការចរាចរទំនិញជាលក្ខណៈអន្តរជាតិ ដែលបានអនុម័តដោយរដ្ឋបាលគយជាតិ អនុលោមតាមអង្គការគយពិភពលោក ឬស្តង់ដាសុវត្ថិភាពច្រវាក់ផលិតកម្មដែលមានតម្លៃស្មើ

(ខ) **ច្បាប់គយ** មានន័យថាច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការនាំចូល នាំចេញ ចរាចរ ឬសន្និធិទំនិញ ការគ្រប់គ្រង និងអនុវត្តច្បាប់ ដែលត្រូវបានប្រគល់ភារកិច្ចជាក់លាក់ដល់អាជ្ញាធរគយ ស្ថិតក្រោមដែនអំណាចច្បាប់គយ

(គ) **នីតិវិធីគយ** មានន័យថាវិធានការទាំងឡាយដែលបានអនុវត្តដោយរដ្ឋបាលគយនៃភាគីសមាជិកទៅលើទំនិញនិងមធ្យោបាយដឹកជញ្ជូន ដែលជាកម្មវត្ថុនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិគយ

(ឃ) **ការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមក (MRA)** មានន័យថាការរៀបចំរវាងភាគីដែលទទួលស្គាល់គ្នាទៅវិញទៅមក ដែលផ្តល់សិទ្ធិដល់ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាតហើយត្រូវបានផ្តល់យ៉ាងត្រឹមត្រូវដោយរដ្ឋបាលគយណាមួយ និង

(ង) **បុគ្គល** មានន័យថារូបវន្តបុគ្គលនិងនីតិបុគ្គល លើកលែងក្នុងបរិបទតម្រូវផ្សេងទៀត។

## មាត្រា៤.២ _ វិសាលភាព

ជំពូកនេះត្រូវអនុវត្ត ដោយអនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរបស់គូភាគី ចំពោះនីតិវិធីគយដែលតម្រូវសម្រាប់ការបញ្ចេញទំនិញពីគយដែលធ្វើពាណិជ្ជកម្មរវាងគូភាគី និងមធ្យោបាយដឹកជញ្ជូនដែលចូលឬចេញពីដែនគយនៃភាគីនីមួយៗ។

## មាត្រា៤.៣ _ បទប្បញ្ញត្តិទូទៅ

១- គូភាគីឯកភាពថាច្បាប់និងនីតិវិធីគយរបស់ខ្លួនត្រូវមានតម្លាភាព មិនមានភាពរើសអើង សង្គតិភាព និងជៀសវាងឧបសគ្គនីតិវិធីដែលមិនចាំបាច់នានាចំពោះការធ្វើពាណិជ្ជកម្ម។

២- បទប្បញ្ញត្តិនៃជំពូកនេះនឹងត្រូវអនុវត្ត ដោយអនុលោមតាមកាតព្វកិច្ចរបស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀងWTO ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ដោយពិចារណាពីកម្រិតផ្សេងៗគ្នានៃការត្រៀមរួចជាស្រេចក្នុងការអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្រោមជំពូកនេះ។

៣- នីតិវិធីគយរបស់គូភាគីត្រូវអនុលោមតាមស្តង់ដានិងអនុសាសន៍នៃការអនុវត្តរបស់អង្គការគយពិភពលោក(WCO) ប្រសិនបើអាចធ្វើទៅបាន។

៤- រដ្ឋបាលគយនៃភាគីនីមួយៗត្រូវពិនិត្យឡើងវិញជាប្រចាំនូវនីតិវិធីគយរបស់ខ្លួនក្នុងគោលបំណងធ្វើឱ្យមានសាមញ្ញកម្ម និងការអភិវឌ្ឍបន្ថែមទៀតដើម្បីសម្រួលដល់ពាណិជ្ជកម្មទ្វេភាគី។

**មាត្រា៤.៤ _ ការបោះពុម្ពផ្សាយនិងការទទួលបានព័ត៌មាន**

១- ភាគីនីមួយៗត្រូវជានាថាច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ នីតិវិធី និងវិធានរដ្ឋបាលរបស់ខ្លួន ដែលគ្រប់គ្រងលើកិច្ចការពាក់ព័ន្ធនឹងគយត្រូវបោះពុម្ពផ្សាយភ្លាមៗទាំងនៅលើអ៊ីនធឺណិត ឬបោះពុម្ពជាភាសាអង់គ្លេស តាមលទ្ធភាពដែលអាចធ្វើទៅបាន។

២- ភាគីនីមួយៗត្រូវកំណត់ បង្កើត និងរៀបចំទីកន្លែងផ្តល់ព័ត៌មានមួយឬច្រើន ដើម្បីឆ្លើយតបឬស្រាយចម្ងល់របស់បុគ្គលនានា ពាក់ព័ន្ធនឹងកិច្ចការគយ និងត្រូវខិតខំផ្សព្វផ្សាយជាសាធារណៈតាមរយៈមធ្យោបាយអេឡិចត្រូនិកនូវព័ត៌មានទាក់ទងនឹងនីតិវិធីសម្រាប់ការសាកសួរនេះ។

៣- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះឬនៅក្នុងផ្នែកណាមួយនៃកិច្ចព្រមព្រៀងនេះ តម្រូវឱ្យភាគីណាមួយបោះពុម្ពផ្សាយអំពីនីតិវិធីអនុវត្តច្បាប់និងគោលការណ៍ណែនាំប្រតិបត្តិការផ្ទៃក្នុងរួមទាំងការវិភាគហានិភ័យនិងវិធីសាស្ត្រកំណត់គោលដៅឡើយ។

៤- ភាគីនីមួយៗត្រូវអនុវត្តក្នុងកម្រិតដែលអាចអនុវត្តបាននិងមានសង្គតិភាពជាមួយនឹងប្រព័ន្ធច្បាប់និងគតិយុត្តិក្នុងប្រទេស ដោយជានាថាច្បាប់និងបទប្បញ្ញត្តិថ្មីឬច្បាប់និងបទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្ម នៃការអនុវត្តទូទៅពាក់ព័ន្ធនឹងការចរាចរ ការបញ្ចេញ និងការបំពេញបែបបទបញ្ចេញទំនិញពីគយ រួមទាំងទំនិញឆ្លងកាត់ត្រូវបានបោះពុម្ពផ្សាយឬព័ត៌មានទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបានឆាប់តាមដែលអាចធ្វើទៅបានមុនពេលចូលជាធរមាន ដើម្បីឱ្យភាគីពាក់ព័ន្ធមានឱកាសយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិថ្មី ឬច្បាប់និងបទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្មរួច។ ព័ត៌មាននិងការបោះពុម្ពផ្សាយទាំងនេះ ត្រូវមានជាភាសាអង់គ្លេសតាមលទ្ធភាពដែលអាចធ្វើទៅបាន។

៥- ការផ្លាស់ប្តូរអត្រាពន្ធឬអត្រាពន្ធគយ វិធានការដែលមានប្រសិទ្ធភាពធូរស្រាល ការវាស់វែងប្រសិទ្ធភាពដែលនឹងធ្វើឱ្យប៉ះពាល់ពីលទ្ធផលនៃការអនុលោមតាមកថាខណ្ឌ៤ វិធានការដែលបានអនុវត្តក្នុងកាលៈទេសៈបន្ទាន់ឬមានការសម្រួលបន្តិចបន្តួច ចំពោះប្រព័ន្ធច្បាប់និងគតិយុត្តក្នុងប្រទេស ត្រូវបានលើកលែងពីភាគព្វកិច្ចក្នុងកថាខណ្ឌ១និង៤។

**មាត្រា៤.៥ _ ការគ្រប់គ្រងហានិភ័យ**

ភាគីនីមួយៗត្រូវអនុម័តវិធីសាស្ត្រគ្រប់គ្រងហានិភ័យនៅក្នុងកិច្ចការគយ ដោយផ្តែកលើសូចនាករហានិភ័យនៃទំនិញពាក់ព័ន្ធ ដើម្បីសម្រួលពាណិជ្ជកម្មក្នុងការបញ្ចេញទំនិញដែលមានហានិភ័យទាប ខណៈផ្តោតការត្រួតពិនិត្យគយលើទំនិញដែលមានហានិភ័យខ្ពស់។

## មាត្រា៤.៦ _ ការធំនាក់ធំនឹងដោយពុំប្រើក្រដាសស្នាម

១- សម្រាប់គោលបំណងនៃកិច្ចសម្រួលពាណិជ្ជកម្ម ភាគីត្រូវព្យាយាមផ្តល់នូវបរិយាកាសអេឡិចត្រូនិក ដែលគាំទ្រដល់ប្រតិបត្តិការធុរកិច្ចរវាងរដ្ឋបាលគយនិងអង្គភាពពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរៀងៗខ្លួនរបស់គូភាគី។

២- ភាគីនីមួយៗត្រូវផ្លាស់ប្តូរយោបល់និងព័ត៌មានស្តីពីការសម្រេច និងលើកកម្ពស់ការទំនាក់ទំនងដោយពុំប្រើក្រដាសស្នាមរវាងរដ្ឋបាលគយរៀងៗខ្លួននិងអង្គភាពពាណិជ្ជកម្មរបស់ពួកគេ។

៣- ក្នុងការអនុវត្តគំនិតផ្តួចផ្តើមនៃការប្រើប្រាស់ទំនាក់ទំនងដោយពុំប្រើក្រដាសស្នាម រដ្ឋបាលគយរបស់គូភាគីត្រូវគិតគូរពីវិធីសាស្ត្រដែលបានព្រមព្រៀងនៅក្នុងអង្គការគយពិភពលោក។

## មាត្រា៤.៧ _ វិចារណបញ្ជាក់ជាមុន

១- ដោយអនុលោមតាមការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ភាគីនីមួយៗត្រូវចេញវិធានបញ្ជាក់ជាមុន ដល់អ្នកនាំចូលទំនិញក្នុងដែនដីរបស់ខ្លួន ឬអ្នកនាំចេញ ឬអ្នកផលិតទំនិញនៅក្នុងដែនដីនៃភាគីម្ខាងទៀតមុនពេលការនាំចូលទំនិញចូលទៅក្នុងដែនដីរបស់ខ្លួន។

២- សម្រាប់គោលបំណងនៃកថាខណ្ឌ១ ភាគីនីមួយៗត្រូវចេញវិធានថាតើទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញដែលមានដើមកំណើត ឬដើម្បីវាយតម្លៃចំណាត់ថ្នាក់ទំនិញ។ លើសពីនេះទៀត ភាគីនីមួយៗអាចចេញវិធានដែលគ្របដណ្តប់លើបញ្ហាពាណិជ្ជកម្មបន្ថែម ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម។ ភាគីនីមួយៗត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងដើមកំណើតឬការចាត់ថ្នាក់ទំនិញ ក្នុងរយៈពេលមួយសមស្រប គិតចាប់ពីថ្ងៃដែលទទួលបានពេញលេញនូវពាក្យស្នើសុំវិធានបញ្ជាក់ជាមុន។

៣- ភាគីនាំចូលត្រូវអនុវត្តវិធានបញ្ជាក់ជាមុនដែលបានចេញនៅក្នុងកថាខណ្ឌ១ ចាប់ពីថ្ងៃដែលវិធានបញ្ជាក់ជាមុនត្រូវបានចេញឬនៅពេលក្រោយដែលវិធានបានបញ្ជាក់ថានៅមានសុពលភាពក្នុងរយៈពេលដ៏សមស្របមួយនិងអនុលោមតាមនីតិវិធីជាតិស្តីពីវិធានបញ្ជាក់ជាមុន លើកលែងតែវិធាននោះត្រូវបានកែសម្រួលឬលុបចោល។

៤- វិធានបញ្ជាក់ជាមុនដែលចេញដោយភាគីសមាជិក ត្រូវមានលក្ខណៈគតិយុត្តិចំពោះបុគ្គលដែលវិធាននេះបានចេញឱ្យប៉ុណ្ណោះ។

៥- ភាគីសមាជិកអាចបដិសេធមិនចេញវិធានបញ្ជាក់ជាមុន ប្រសិនបើអង្គហេតុនិងកាលៈទេសៈដែលបង្កើតជាមូលដ្ឋាននៃការចេញវិធានបញ្ជាក់ជាមុនគឺជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ឬការត្រួតពិនិត្យផ្ទៃកដ្ឋបាលឬគតិយុត្តិ ឬការប្តឹងតវ៉ា។ ភាគីសមាជិកដែលបដិសេធមិនចេញវិធានបញ្ជាក់ជាមុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗ ដល់បុគ្គលដែលស្នើសុំវិធាន ដោយកំណត់នូវអង្គហេតុនិងកាលៈទេសៈពាក់ព័ន្ធនិងមូលដ្ឋាននៃការសម្រេចរបស់ខ្លួន។

៦- ភាគីនាំចូលអាចកែតម្រូវឬលុបចោលវិធានបញ្ជាក់ជាមុនបានដូចខាងក្រោម៖

(ក) ប្រសិនបើវិធាននោះផ្អែកលើកំហុសនៃអង្គហេតុ

(ខ) ប្រសិនបើមានការផ្លាស់ប្តូរនៅក្នុងអង្គហេតុឬកាល:ទេស:ដែលវិធានត្រូវបានផ្អែកលើ

(គ) ដើម្បីអនុលោមតាមការកែតម្រូវនៃជំពូកនេះ: ឬ

(ឃ) ដើម្បីអនុលោមតាមសេចក្តីសម្រេចរបស់តុលាការ ឬការផ្លាស់ប្តូរច្បាប់ក្នុងស្រុករបស់ខ្លួន។

៧- ភាគីនីមួយៗត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកស្នើសុំ ដែលពន្យល់ពីការសម្រេចរបស់ភាគីក្នុងការលុបចោលឬកែតម្រូវវិធានបញ្ជាក់ជាមុនដែលចេញជូនអ្នកស្នើសុំ។

៨- ដោយអនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរៀងៗខ្លួន ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យការកែតម្រូវឬការលុបចោលវិធានបញ្ជាក់ជាមុន ចូលជាធរមាននៅថ្ងៃដែលការកែតម្រូវឬការលុបចោលត្រូវបានចេញឬនៅថ្ងៃបន្ទាប់ទៀតដែលមានចែងបញ្ជាក់និងមិនត្រូវអនុវត្តចំពោះការនាំចូលទំនិញមុនកាលបរិច្ឆេទ លើកលែងតែបុគ្គលដែលចេញវិធានបញ្ជាក់ជាមុននោះ: មិនបានប្រព្រឹត្តទៅតាមលក្ខខណ្ឌរបស់ខ្លួន។

៩- ទោះជាមានចែងក្នុងកថាខណ្ឌ៨ក៏ដោយ ភាគីដែលចេញវិធានត្រូវពន្យារពេលកាលបរិច្ឆេទនៃការកែតម្រូវឬការលុបចោលវិធានបញ្ជាក់ជាមុនសម្រាប់រយៈពេលដ៏សមស្របមួយ និងអនុលោមតាមនីតិវិធីជាតិរបស់ភាគីនីមួយៗស្តីពីវិធានបញ្ជាក់ជាមុន ក្នុងករណីដែលបុគ្គលទទួលបានវិធានបញ្ជាក់ជាមុនបង្ហាញថាខ្លួនមានភាពសុចរិតនិងស្មោះត្រង់ចំពោះការខូចខាតរបស់ខ្លួនពាក់ព័ន្ធនឹងវិធាននោះ:។

## មាត្រា៤.៨ _ ការផាកពិន័យ

១- ភាគីនីមួយៗត្រូវរក្សាវិធានការក្នុងការផាកពិន័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬពិន័យរដ្ឋបាល ទោះបីតែមួយឬរួមបញ្ចូលគ្នា ចំពោះការបំពានច្បាប់ បទប្បញ្ញត្តិគយ ឬតម្រូវការនៃនីតិវិធីណាមួយរបស់ភាគីសមាជិក។

២- ភាគីនីមួយៗត្រូវធានាថា រាល់ការផាកពិន័យដែលចេញសម្រាប់ការបំពានលើច្បាប់ បទប្បញ្ញត្តិគយ ឬការតម្រូវនីតិវិធីត្រូវបានអនុវត្តតែលើបុគ្គលដែលបំពានក្រោមច្បាប់របស់ខ្លួនតែប៉ុណ្ណោះ:។

៣- ភាគីនីមួយៗត្រូវធានាថា ការផាកពិន័យដោយរដ្ឋបាលគយរបស់ខ្លួនគឺផ្អែកលើអង្គហេតុនិងកាល:ទេស: នៃករណីដែលសមស្របជាមួយកម្រិតនិងភាពធ្ងន់ធ្ងរនៃការបំពាន។

៤- ភាគីនីមួយៗត្រូវធានាថាខ្លួនរក្សាបាននូវវិធានការ ដើម្បីជៀសវាងការប៉:ទង្គិចផលប្រយោជន៍ ក្នុងការវាយតម្លៃនិងការប្រមូលប្រាក់ផាកពិន័យនិងពន្ធ។ ភាគីនីមួយៗនឹងធានាថាខ្លួនរក្សាវិធានការដើម្បីជៀសវាងនូវការបង្កើតការលើកទឹកចិត្ត ឬការវាយតម្លៃ ឬការប្រមូលប្រាក់ផាកពិន័យដែលមានអសង្គតិភាពជាមួយកថាខណ្ឌ៣។

៥- ភាគីនីមួយៗត្រូវធានាថា ប្រសិនបើការផាកពិន័យត្រូវបានដាក់ដោយរដ្ឋបាលគយរបស់ខ្លួន ចំពោះការបំពានលើច្បាប់ បទប្បញ្ញត្តិគយ ឬការតម្រូវនីតិវិធី នោះការពន្យល់ជាលាយលក្ខណ៍អក្សរត្រូវតែផ្តល់ឱ្យទៅបុគ្គលដែលត្រូវបានទទួលការផាកពិន័យនោះ: ដោយបញ្ជាក់អំពីលក្ខណៈ:នៃការបំពានលើច្បាប់ បទប្បញ្ញត្តិគយ ឬការតម្រូវនីតិវិធីសម្រាប់កំណត់ទំហំនៃការពិន័យ។

**មាត្រា៤.៩ _ ការបញ្ចេញទំនិញ**

១- ភាគីនីមួយៗ ត្រូវអនុម័តឬប្រកាន់ខ្ជាប់នូវនីតិវិធីគយសាមញ្ញសម្រាប់ការបញ្ចេញទំនិញប្រកបដោយប្រសិទ្ធភាពដើម្បីសម្រួលពាណិជ្ជកម្ម។

២- យោងតាមកថាខណ្ឌ១ ភាគីនីមួយៗ ត្រូវអនុម័តឬប្រកាន់ខ្ជាប់នីតិវិធីដែល៖

(ក) ផ្តល់ការបញ្ចេញទំនិញភ្លាមៗនៅពេលទទួលបានប្រតិវេទន៍គយ ការបំពេញតាមការតម្រូវ និងនីតិវិធីទាំងអស់

(ខ) អនុញ្ញាតឱ្យមានការដាក់ជូននិងដំណើរការឯកសារនិងទិន្នន័យ រួមទាំងអញ្ញត្តបណ្ណជាទម្រង់អេឡិចត្រូនិកនៅមុនពេលការមកដល់នៃទំនិញ ដើម្បីពន្លឿនការបញ្ចេញទំនិញពីការត្រួតពិនិត្យគយនៅពេលទំនិញមកដល់

(គ) អនុញ្ញាតឱ្យបញ្ចេញទំនិញនៅពេលមកដល់ ដោយមិនចាំបាច់តម្រូវឱ្យមានការផ្ទេរបណ្តោះអាសន្នទៅកាន់ភណ្ឌាគារគយ ឬទីកន្លែងផ្ទុកទំនិញផ្សេងទៀត និង

(ឃ) ដោយអនុលោមតាមច្បាប់របស់ខ្លួន ក្នុងករណីភាគីសមាជិកមិនបានបញ្ចេញទំនិញភ្លាមៗ ភាគីត្រូវជូនដំណឹងទៅអ្នកនាំចូល រួមទាំងមូលហេតុដែលទំនិញមិនត្រូវបានបញ្ចេញ និងបញ្ជាក់ថាភ្នាក់ងារព្រំដែនមួយណាដែលបានឃាត់ទុកការបញ្ចេញទំនិញនោះ បើមិនមែនជារដ្ឋបាលគយ។

៣- មិនមានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះតម្រូវឱ្យភាគីសមាជិកបញ្ចេញទំនិញពីគយ ប្រសិនបើការបញ្ចេញទំនិញនោះមិនបានបំពេញគ្រប់លក្ខខណ្ឌតម្រូវ ឬមិនទប់ស្កាត់ភាគីសមាជិកពីការដកនិមុត្តិធានាស្របតាមច្បាប់របស់ខ្លួន។

៤- ក្នុងកម្រិតដែលអនុវត្តបាននិងអនុលោមតាមច្បាប់គយរបស់ខ្លួននិងការតម្រូវផ្នែកច្បាប់នានាត្រូវបានបំពេញ ភាគីនីមួយៗអាចអនុញ្ញាតឱ្យទំនិញដែលមានបំណងនាំចូលអាចចរាចរក្នុងដែនដីក្រោមការត្រួតពិនិត្យរបស់គយចាប់តាំងពីការិយាល័យគយនៃច្រកចូលមួយទៅកាន់ការិយាល័យគយមួយទៀតនៅក្នុងដែនគយដែលទំនិញនឹងត្រូវបានបំពេញបែបបទនិងបញ្ចេញ។

**មាត្រា៤.១០ _ ប្រតិបត្តិការសេដ្ឋកិច្ចមានការអនុញ្ញាត**

ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មនិងលើកកម្ពស់ការអនុលោមតាមច្បាប់និងការគ្រប់គ្រងហានិភ័យរវាងទ្វេភាគី ភាគីនីមួយៗត្រូវខិតខំបញ្ចប់ប្រតិបត្តិការសេដ្ឋកិច្ចមានការអនុញ្ញាត(AEO)និងការរៀបចំការទទួលស្គាល់គ្នាទៅវិញទៅមក(MRA)រវាងរដ្ឋបាលគយរបស់ខ្លួន។

**មាត្រា៤.១១ _ កិច្ចសហប្រតិបត្តិការភ្នាក់ងារព្រំដែន**

ភាគីនីមួយៗត្រូវធានាថា អាជ្ញាធរនិងភ្នាក់ងាររបស់ខ្លួនដែលទទួលខុសត្រូវលើការគ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តនីតិវិធីព្រំដែន ពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និងការដើរជញ្ជូនឆ្លងកាត់ សហការគ្នាទៅវិញទៅមក និងសម្របសម្រួលសកម្មភាពការងារជាមួយគ្នា ដើម្បីសម្រួលពាណិជ្ជកម្មស្របតាមបញ្ញត្តិនៃជំពូកនេះ។

**មាត្រា៤.១២ _ ការដឹកជញ្ជូនរហ័ស**

១- ដោយអនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរៀងៗខ្លួន ភាគីនីមួយៗត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នូវនីតិវិធីគយរហ័ស សម្រាប់ទំនិញដែលនាំចូលតាមឃ្លាំងទំនិញផ្លូវអាកាស ដោយធានាបាននូវភាពអាចគ្រប់គ្រងបាននិងការជ្រើសរើសគយសមស្រប។ នីតិវិធីទាំងនេះត្រូវ៖

(ក) ផ្តល់ព័ត៌មានចាំបាច់ដើម្បីអាចបញ្ជូនទំនិញដឹកជញ្ជូនរហ័ស និងដំណើរការនីតិវិធីមុនពេលទំនិញមកដល់

(ខ) អនុញ្ញាតឱ្យមានការផ្តល់ព័ត៌មានតែមួយលើកដែលគ្របដណ្តប់គ្រប់ទំនិញ នៅក្នុងការដឹកជញ្ជូនរហ័ស ដូចជានិវេទនបណ្ណ តាមរយៈមធ្យោបាយអេឡិចត្រូនិច[1] ប្រសិនបើអាចធ្វើទៅបាន

(គ) អនុញ្ញាតឱ្យបញ្ជូនទំនិញជាកំលាក់មួយចំនួនដោយតម្រូវឱ្យផ្តល់ឯកសារអប្បបរមា តាមលទ្ធភាពដែលអាចធ្វើបាន

(ឃ) ក្នុងកាលៈទេសៈធម្មតា ផ្តល់នូវការបញ្ជូនទំនិញបញ្ជើរហ័សឱ្យបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីបានផ្តល់ឯកសារចាំបាច់នានាជូនអាជ្ញាធរគយ និងបន្ទាប់ពីទំនិញបានមកដល់

(ង) អនុវត្តចំពោះការដើរជញ្ជូនរាល់ទម្ងន់ឬតម្លៃ ដោយទទួលស្គាល់ថាភាគីសមាជិកអាចតម្រូវឱ្យមាននីតិវិធីចូលជាផ្លូវការណាមួយជាលក្ខខណ្ឌ សម្រាប់ការបញ្ជូនទំនិញ រាប់បញ្ចូលទាំងការប្រកាសប្រតិវេទន៍គយ ការផ្តល់ឯកសារគាំទ្រ និងការបង់ពន្ធគយ ដោយផ្អែកលើទម្ងន់ឬតម្លៃរបស់ទំនិញ និង

(ច) ក្នុងកាលៈទេសៈធម្មតា ទំនិញដែលនាំចូលតាមការដឹកជញ្ជូនរហ័សដែលមានតម្លៃស្មើឬទាបជាងការកំណត់ដោយច្បាប់ជាតិរបស់ភាគីនាំចូល[2]មិនត្រូវជាប់ការពិធីកិច្ចពន្ធឡើយ។

២- មិនមានបទប្បញ្ញត្តិណាមួយក្នុងកថាខណ្ឌ១ ប៉ះពាល់ដល់សិទ្ធិរបស់គូភាគីក្នុងការត្រួតពិនិត្យ ឃាត់ រឹបអូស ឯកហូត ឬបដិសេធការចូលទំនិញ ឬធ្វើសវនកម្មក្រោយពេលបញ្ជូនទំនិញពីគយ រួមទាំងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងរាំងគូភាគីពីការតម្រូវជាលក្ខខណ្ឌដើម្បីបញ្ជូនទំនិញ ដូចជាការផ្តល់ព័ត៌មានបន្ថែមនិងការបំពេញតម្រូវការនៃការអនុញ្ញាតដែលមិនស្ថិយប្រវត្តិឡើយ។

**មាត្រា៤.១៣ _ ការត្រួតពិនិត្យឧបសគ្គនិងបណ្តឹងតវ៉ា**

១- ភាគីនីមួយៗត្រូវធានាថាបុគ្គលណាមួយដែលខ្លួនចេញសេចក្តីសម្រេចលើបញ្ហាគយមានសិទ្ធិលើ៖

---

[1]ឯកសារបន្ថែមអាចត្រូវបានទាមទារមុននឹងអាចបញ្ជូនទំនិញពីគយ។

[2]ទោះបីជាមានចែងដូចក្នុងមាត្រានេះ ភាគីមួយអាចតណានាប្រាក់ពន្ធគយឬអាចទាមទារឯកសារនាំចូលផ្លូវការសម្រាប់ទំនិញមានជាប់កម្រិតកំណត់ឬទំនិញត្រូវគ្រប់គ្រង ដោយទំនិញទាំងនោះត្រូវមានអាជ្ញាបណ្ណនាំចូលឬការតម្រូវប្រហាក់ប្រហែល។

(ក) ការពិនិត្យឡើងវិញនៃផ្នែករដ្ឋបាល យ៉ាងហោចណាស់មួយកម្រិតលើសេចក្តីសម្រេចដោយរដ្ឋបាលគយរបស់ខ្លួនដែលឯកភាជ្ញ[3]ពីមន្ត្រីឬការិយាល័យ ដែលទទួលខុសត្រូវចំពោះសេចក្តីសម្រេចដែលកំពុងត្រួតពិនិត្យ និង

(ខ) ការពិនិត្យឡើងវិញតាមប្រព័ន្ធតុលាការ លើសេចក្តីសម្រេចដែលបានធ្វើឡើងនៅកម្រិតចុងក្រោយនៃការពិនិត្យឡើងវិញនៃផ្នែករដ្ឋបាល។

២- ភាគីនីមួយៗត្រូវជានាថានីតិវិធីរបស់ខ្លួនសម្រាប់ការការប្តឹងតវ៉ានិងត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្តដោយមិនជើសរើងនិងទាន់ពេលវេលា។

៣- ភាគីនីមួយៗត្រូវជានាថាអាជ្ញាធរដែលធ្វើការពិនិត្យឡើងវិញ ឬបណ្តឹងតវ៉ាដូចមានចែងក្នុងកថាខណ្ឌ១ ជូនដំណឹងដល់បុគ្គលជាលាយលក្ខណ៍អក្សរអំពីការកំណត់ ឬសេចក្តីសម្រេចរបស់ខ្លួនក្នុងការពិនិត្យឡើងវិញ ឬការប្តឹងតវ៉ា និងហេតុផលសម្រាប់ការកំណត់ ឬសេចក្តីសម្រេចដល់បុគ្គល។

## មាត្រា៤.១៤ _ កិច្ចសហប្រតិបត្តិការគយ

១- ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការគយបន្ថែមទៀតតាមរយៈការផ្លាស់ប្តូរព័ត៌មាន និងការចែករំលែកឧត្តមានុវត្តន៍រវាងរដ្ឋបាលគយ ដើម្បីធានានិងសម្រួលពាណិជ្ជកម្មស្របច្បាប់ រដ្ឋបាលគយនៃគូភាគីនឹងខិតខំបញ្ចប់និងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ឬកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកទាក់ទងនឹងគយ។

២- ក្នុងគោលបំណងអនុវត្តច្បាប់គយនិងផ្តល់ប្រសិទ្ធភាពចំពោះបទប្បញ្ញត្តិនៃការរៀបចំនេះ គូភាគីនៃកិច្ចព្រមព្រៀងត្រូវខិតខំ៖

(ក) សហការនិងជួយគ្នាទៅវិញទៅមកក្នុងការទប់ស្កាត់ និងស៊ើបអង្កេតបទល្មើសប្រឆាំងនឹងច្បាប់គយ

(ខ) ផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកតាមការស្នើសុំ ដើម្បីប្រើប្រាស់ក្នុងការអនុវត្តច្បាប់គយ និង

(គ) សហការក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ និងការអនុវត្តនីតិវិធីគយថ្មី ក្នុងការបណ្តុះបណ្តាលនិងការផ្លាស់ប្តូរមន្ត្រីទៅវិញទៅមក ការចែករំលែកការឧត្តមានុវត្តន៍ និងសហការលើផ្នែកផ្សេងៗទៀតដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។

៣- ជំនួយក្នុងជំពូកនេះត្រូវផ្តល់ជូនដោយអនុលោមតាមច្បាប់ផ្ទៃក្នុងរបស់ភាគីស្នើសុំ។

៤- គូភាគីត្រូវផ្លាស់ប្តូរចំណុចទំនាក់ទំនងផ្លូវការដើម្បីសម្រួលដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃជំពូកនេះ។

---

[3]កម្រិតនៃការត្រួតពិនិត្យរដ្ឋបាលសម្រាប់ភាគីអេមីរ៉ាតអារ៉ាប់រួមត្រូវរួមបញ្ចូលនូវអាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងដោយរដ្ឋបាលគយ។

**មាត្រា៤.១៥ _ ព័ត៌មានសម្ងាត់**

១- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងជំពូកនេះត្រូវបានបកស្រាយដើម្បីតម្រូវឱ្យភាគីសមាជិកផ្តល់ ឬអនុញ្ញាតឱ្យចូលប្រើព័ត៌មានសម្ងាត់ ការណែនាំដែលទាក់ទងនឹងព័ត៌មានទាំងនោះនឹងរារាំងដល់ការអនុវត្តច្បាប់ ឬផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬនឹងធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសសាធារណៈឬឯកជនណាមួយ។ រាល់ព័ត៌មានដែលទទួលបាននៅក្រោមជំពូកនេះត្រូវចាត់ទុកជាការសម្ងាត់ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីសមាជិកនោះ។

២- ដោយអនុលោមតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីនីមួយៗត្រូវរក្សាការសម្ងាត់នៃព័ត៌មានដែលទទួលបានដោយយោងតាមជំពូកនេះ ហើយត្រូវការពារព័ត៌មាននោះពីការណែនាំណាមួយដែលនាំឱ្យប៉ះពាល់ដល់ស្ថានភាពប្រកួតប្រជែងរបស់បុគ្គលដែលផ្តល់ព័ត៌មាន។

**មាត្រា៤.១៦ _ អនុគណៈកម្មាធិការស្តីពីនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម**

គូភាគីឯកភាពបង្កើតអនុគណៈកម្មាធិការស្តីពីនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម(អនុគណៈកម្មាធិការ CPTF) ក្រោមអនុគណៈកម្មាធិការពាណិជ្ជកម្មទំនិញ ដែលមានតំណាងរដ្ឋាភិបាលនៃអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនីមួយៗ។

# ជំពូកទី៥
# និយមន័យនិងក្បួនតាមអនាម័យ

## មាត្រា៥.១ _ និយមន័យ

១- និយមន័យដែលមាននៅក្នុងឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យក្នុងឧបសម្ព័ន្ធក.១ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក( ចាប់ពីពេលនេះតទៅហៅថា "កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ") ត្រូវបានអនុវត្ត។

២- បន្ថែមពីនេះ សម្រាប់គោលបំណងនៃជំពូកនេះ៖

**អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់ស្ថាប័នរដ្ឋាភិបាលនៃភាគីនីមួយៗដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍ ការគ្រប់គ្រងវិធានការអនាម័យនិងភូតគាមអនាម័យ និងបញ្ហាដែលទាក់ទងនៅក្នុងជំពូកនេះ និង

**វិធានការបន្ទាន់** សំដៅដល់វិធានការអនាម័យ ឬវិធានការភូតគាមអនាម័យដែលត្រូវបានដាក់ឱ្យអនុវត្តដោយភាគីនាំចូលចំពោះភាគីម្ខាងទៀត ដើម្បីដោះស្រាយបញ្ហាបន្ទាន់ក្នុងការការពារអាយុជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ ដែលកើតឡើង ឬគំរាមកំហែងនឹងកើតឡើងដល់ភាគីដែលបានដាក់ចេញនូវវិធានការនោះ។

## មាត្រា៥.២ _ គោលដៅ

គោលដៅនៃជំពូកនេះគឺដើម្បី៖

(ក) ការពារអាយុជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិនៅក្នុងដែនដីនៃគូភាគី ខណៈពេលសម្រួលការធ្វើពាណិជ្ជកម្មរវាងគូភាគី

(ខ) ធ្វើឱ្យប្រសើរនូវកិច្ចសហការលើការអនុវត្តកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ

(គ) ពង្រឹងការទំនាក់ទំនង ការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការរវាងគូភាគី និងជាពិសេសរវាងអាជ្ញាធរមានសមត្ថកិច្ចនៃគូភាគី

(ឃ) ជានាថាវិធានការអនាម័យ និងភូតគាមអនាម័យដែលត្រូវបានអនុវត្តដោយភាគីសមាជិកមិនបង្កើតជារបាំងមិនសមហេតុផលចំពោះពាណិជ្ជកម្ម

(ង) ធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនិងការយោគយល់គ្នា ក្នុងការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យរបស់ភាគីសមាជិកនីមួយៗ និង

(ច) លើកទឹកចិត្តដល់ការចូលរួមរបស់គូភាគីនៅក្នុងការអភិវឌ្ឍ ការអនុម័តនូវស្តង់ដា គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ។

**មាត្រា៥.៣ _ ឱសាលភាព**

ជំពូកនេះត្រូវបានអនុវត្តចំពោះគ្រប់វិធានការអនាម័យនិងភូតគាមអនាម័យរបស់ភាគីសមាជិក ដែលអាចប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលលើពាណិជ្ជកម្មរវាងគូភាគី។

**មាត្រា៥.៤ _ បទប្បញ្ញត្តិទូទៅ**

១- គូភាគីអះអាងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះគ្នាទៅវិញទៅមក នៅក្រោមកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ។

២- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរឹតត្បិតសិទ្ធិនិងកាតព្វកិច្ចដែលភាគីសមាជិកនីមួយៗមានក្រោមកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យនោះឡើយ។

៣- មិនមានភាគីសមាជិកណាមួយមានសិទ្ធិប្រើប្រាស់ការដោះស្រាយវិវាទក្រោមជំពូកទី១៤ (ការដោះស្រាយវិវាទ) ទាក់ទងទៅនឹងកាតព្វកិច្ចដែលបានពិពណ៌នានៅក្នុងជំពូកនេះនោះទេ។

**មាត្រា៥.៥ _ អាជ្ញាធរមានសមត្ថកិច្ចនិងចំណុចទំនាក់ទំនង**

១- ដើម្បីសម្រួលការទំនាក់ទំនងលើបញ្ហានានាដែលគ្របដណ្តប់ក្នុងជំពូកនេះ ភាគីសមាជិកនីមួយៗត្រូវជូនដំណឹងគ្នាអំពីអាជ្ញាធរមានសមត្ថកិច្ច និងចំណុចទំនាក់ទំនងរបស់ខ្លួននៅក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២- ភាគីសមាជិកនីមួយៗ ត្រូវជូនដំណឹងគ្នានូវការផ្លាស់ប្តូរណាមួយនៅក្នុងអាជ្ញាធរមានសមត្ថកិច្ចឬចំណុចទំនាក់ទំនងរបស់ខ្លួននៅក្នុងរយៈពេលមួយសមស្រប ដោយមិនលើសពី២០ថ្ងៃឡើយ។

**មាត្រា៥.៦ _ អនុគណៈកម្មាធិការវិធានការអនាម័យនិងភូតគាមអនាម័យ**

១- ក្នុងគោលបំណងឱ្យការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះដោយប្រសិទ្ធភាព គូភាគីបង្កើតអនុគណៈកម្មាធិការវិធានការអនាម័យនិងភូតគាមអនាម័យមួយ("អនុគណៈកម្មាធិការវិធានការ SPS") ដែលមានសមាសភាពពីតំណាងរដ្ឋាភិបាលនៃភាគីសមាជិកនីមួយៗដែលទទួលខុសត្រូវលើការងារអនាម័យនិងភូតគាមអនាម័យ។ អនុគណៈកម្មាធិការវិធានការ SPS ត្រូវធ្វើការតាមការណែនាំតម្រង់ទិសរបស់គណៈកម្មាធិការចម្រុះ ដែលបានបង្កើតឡើងក្រោមខ្លឹមសារនៃមាត្រា ១៦.១ (គណៈកម្មាធិការចម្រុះ)។

២- គោលបំណងនៃអនុគណៈកម្មាធិការវិធានការ SPS គឺដើម្បី៖

(ក) តាមដានការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ

(ខ) ពិចារណាលើការងារអនាម័យនិងភូតគាមអនាម័យដែលមានផលប្រយោជន៍រួម សម្រាប់កិច្ចសហប្រតិបត្តិការ និង

(គ) ធ្វើឱ្យប្រសើរឡើងនូវការទំនាក់ទំនង ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការលើការងារអនាម័យនិងភូតគាមអនាម័យ។

៣- អនុគណៈកម្មាធិការវិធានការ SPS មានគោលបំណងបម្រើជាវេទិកាមួយដើម្បី៖

(ក) ធ្វើឱ្យប្រសើរឡើងនូវការយោគយល់គ្នាទៅវិញទៅមក អំពីវិធានការអនាម័យនិងភូតគាម អនាម័យនិងដំណើរការនិយតកម្មនិងប្រតិបត្តិការរបស់ភាគីនីមួយៗ ដែលទាក់ទងនឹងវិធានការទាំងនោះ និង

(ខ) ផ្លាស់ប្តូរព័ត៌មានអំពីការអនុវត្តដំពូកនេះ។

៤- អនុគណៈកម្មាធិការស្តីពីវិធានការ SPS ត្រូវបង្កើតលក្ខខណ្ឌយោងរបស់ខ្លួននៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ហើយអាចកែប្រែលក្ខខណ្ឌទាំងនោះតាមការចាំបាច់ ហើយក្រោយមកត្រូវជួបប្រជុំតាមការចាំបាច់តាមការសម្រេចរបស់ខ្លួនឬតាមការណែនាំរបស់គណៈកម្មាធិការចម្រុះ។

៥- ប្រសិនបើភាគីសមាជិកពិនិត្យឃើញថា មានការរំខានដល់ពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ ភាគីនោះអាចស្នើសុំការពិគ្រោះយោបល់បច្ចេកទេសតាមរយៈអនុគណៈកម្មាធិការវិធានការ SPS ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម។ នៅពេលទទួលបានសំណើក្រោមកថាខណ្ឌនេះ ភាគីម្ខាងទៀតត្រូវឆ្លើយតបទៅនឹងសំណើនោះ ហើយត្រូវព្យាយាមផ្តល់ព័ត៌មានដែលបានស្នើសុំណាមួយនិងឆ្លើយតបទៅកាន់សំណួរដែលទាក់ទងទៅនឹងបញ្ហានោះ ហើយប្រសិនបើមានការស្នើសុំ ចាប់ផ្តើមពិគ្រោះយោបល់នៅក្នុងពេលវេលាមួយសមស្របបន្ទាប់ពីទទួលបានសំណើនោះ។ គូភាគីត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីសម្រេចបាននូវដំណោះស្រាយដែលពេញចិត្តទៅវិញទៅមក តាមរយៈការពិគ្រោះយោបល់នៅក្នុងពេលវេលាមួយដែលបានព្រមព្រៀងដោយគូភាគី។

**មាត្រា៥.៧ _ សមមូលភាព**

១- គូភាគីទទួលស្គាល់ថាគោលការណ៍នៃសមមូលភាពដែលត្រូវបានចែងក្រោមមាត្រា៤ នៃកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យមានផលប្រយោជន៍រួមសម្រាប់ភាគីទាំងពីរ។

២- គូភាគី ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការលើសមមូលភាព និងគោរពតាមនីតិវិធីសម្រាប់ការកំណត់សមមូលភាពនៃវិធានការអនាម័យនិងភូតគាមអនាម័យដោយអនុលោមតាមមាត្រា៤ នៃកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ ដោយពិចារណាដល់សេចក្តីសម្រេចពាក់ព័ន្ធផ្សេងៗរបស់គណៈកម្មាធិការអនាម័យនិងភូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO SPS Committee) និងស្តង់ដា គោលការណ៍ណែនាំនិងអនុសាសន៍អន្តរជាតិ ដោយអនុលោមតាមឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ។

៣- អនុលោមភាពរបស់ផលិតផលនាំចេញ ទៅនឹងវិធានការឬស្តង់ដាអនាម័យនិងភូតគាមអនាម័យរបស់ភាគីនាំចេញដែលត្រូវបានទទួលស្គាល់ថា សមមូលទៅនឹងវិធានការឬស្តង់ដាអនាម័យនិងភូតគាមអនាម័យរបស់ភាគីនាំចូលក៏ដោយ មិនត្រូវបានលើកលែងពីការបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់ពាក់ព័ន្ធផ្សេងទៀតរបស់ភាគីនាំចូលឡើយ។

**មាត្រា៥.៨ _ ការប្រែប្រួលទៅតាមលក្ខខណ្ឌតំបន់រួមបញ្ចូលទាំងតំបន់គ្មានសមាសភាពច្រែះឬដំចឹ និងតំបន់ដែលមានសមាសភាពច្រែះឬដំចឹកុងក្រឹតទាប**

១- គូភាគីទទួលស្គាល់ថាគោលការណ៍នៃការប្រែប្រួលទៅតាមលក្ខខណ្ឌតំបន់ រួមបញ្ចូលទាំងតំបន់គ្មានសមាសភាពច្រែះឬដំចឹ និងតំបន់ដែលមានសមាសភាពច្រែះឬដំចឹក្នុងកម្រិតទាប ដូចមានចែងក្រោមមាត្រា៦ នៃកិច្ចព្រមព្រៀងអនាម័យនិងកូតគាមអនាម័យ មានផលប្រយោជន៍រួមសម្រាប់ភាគីទាំងពីរ។

២- គូភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការលើការទទួលស្គាល់នូវលក្ខខណ្ឌតំបន់ និងគោរពតាមនីតិវិធីដោយអនុលោមតាមសេចក្តីសម្រេចដែលអនុម័តដោយគណៈកម្មការអនាម័យនិងកូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក និងស្តង់ដា គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិពាក់ព័ន្ធនានា ដោយអនុលោមតាមឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀងអនាម័យនិងកូតគាមអនាម័យ។

**មាត្រា៥.៩ _ ការវាយតម្លៃហានិភ័យ**

១- គូភាគីត្រូវធានាថា វិធានការអនាម័យនិងកូតគាមអនាម័យណាមួយត្រូវបានអនុវត្តចំពោះករណីចាំបាច់ដើម្បីការពារអាយុជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ និងត្រូវផ្អែកលើគោលការណ៍វិទ្យាសាស្ត្រ និងមិនត្រូវរក្សាការអនុវត្តដោយពុំមានកស្តតាងវិទ្យាសាស្ត្រគ្រប់គ្រាន់នោះឡើយ។

២- គូភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនលើការវាយតម្លៃហានិភ័យ ដោយអនុលោមតាមកិច្ចព្រមព្រៀងអនាម័យនិងកូតគាមអនាម័យ ដោយពិចារណាដល់សេចក្តីសម្រេចពាក់ព័ន្ធរបស់គណៈកម្មការអនាម័យនិងកូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោកនិងស្តង់ដា គោលការណ៍ណែនាំនិងអនុសាសន៍អន្តរជាតិ។

៣- ទោះបីមានចែងក្នុងកថាខណ្ឌទី១ក៏ដោយ ប្រសិនបើនៅតែពុំទាន់មានកស្តតាងវិទ្យាសាស្ត្រពាក់ព័ន្ធគ្រប់គ្រាន់ ភាគីសមាជិកអាចអនុម័តវិធានការអនាម័យនិងកូតគាមអនាម័យរបស់ខ្លួនជាបណ្តោះអាសន្នដោយផ្អែកលើព័ត៌មានពាក់ព័ន្ធដែលអាចប្រើប្រាស់បាន រួមទាំងព័ត៌មានពីអង្គការអន្តរជាតិពាក់ព័ន្ធ។ នៅក្នុងស្ថានភាពបែបនេះ ភាគីនាំចូលត្រូវស្វែងរកព័ត៌មានចាំបាច់បន្ថែមដោយគិតគូរពីកស្តតាងវិទ្យាសាស្ត្រ ដែលអាចប្រើប្រាស់បានសម្រាប់ការវាយតម្លៃហានិភ័យឱ្យបានកាន់តែច្បាស់ និងត្រួតពិនិត្យមើលឡើងវិញនូវវិធានការអនាម័យនិងកូតគាមអនាម័យ នៅក្នុងរយៈពេលមួយសមស្រប។ ក្នុងន័យនេះ ភាគីនាំចូលអាចស្នើសុំព័ត៌មានវិទ្យាសាស្ត្រនិងព័ត៌មានពាក់ព័ន្ធផ្សេងទៀតពីភាគីនាំចេញ។

៤- នៅពេលអនុវត្តការវាយតម្លៃហានិភ័យ គូភាគីត្រូវ៖

(ក) ធានាថាការវិភាគហានិភ័យត្រូវបានចងក្រងទុកជាឯកសារ ហើយនឹងផ្តល់ឱ្យភាគីនាំចេញនូវឱកាសក្នុងការផ្តល់យោបល់ទៅលើឯកសារវិភាគហានិភ័យ ក្នុងលក្ខណៈមួយដែលត្រូវបានកំណត់ដោយភាគីនាំចូល

(ខ) ពិចារណាជម្រើសនៃការគ្រប់គ្រងហានិភ័យ ដែលមិនរឹតត្បិតពាណិជ្ជកម្មលើសពីតម្រូវការដើម្បីសម្រេចបាននូវកម្រិតសមស្រប ក្នុងការការពារអនាម័យឬកូតគាមអនាម័យ និង

(គ) ជ្រើសរើសជម្រើសការគ្រប់គ្រងហានិភ័យមួយ ដែលមិនរឹតត្បិតពាណិជ្ជកម្មលើសពីតម្រូវការ ដើម្បីសម្រេចបាននូវកម្រិតសមស្របរបស់ខ្លួនក្នុងការការពារអនាម័យ ឬកូតគាមអនាម័យ ដោយពិចារណាលើលទ្ធភាពបច្ចេកទេសនិងសេដ្ឋកិច្ច។

៥- នៅពេលមានសំណើពីភាគីនាំចេញ ភាគីនាំចូលត្រូវជូនដំណឹងភាគីនាំចេញអំពីវឌ្ឍនភាពនៃសំណើវាយតម្លៃហានិភ័យជាក់លាក់មួយ និងការពន្យារពេលណាមួយដែលអាចកើតឡើងកំឡុងពេលដំណើរការ។

៦- ដោយមិនប៉ះពាល់ដល់វិធានការបន្ទាន់ ភាគីនាំចូលមិនត្រូវបញ្ឈប់ការនាំចូលទំនិញរបស់ភាគីនាំចេញដោយគ្រាន់តែឈរលើហេតុផលថា ភាគីនាំចូលកំពុងដំណើរការត្រួតពិនិត្យឡើងវិញនូវវិធានការអនាម័យឬកូតគាមអនាម័យ ប្រសិនបើភាគីនាំចូលបានអនុញ្ញាតឱ្យមានការនាំចូលទំនិញពីភាគីនាំចេញនៅកំឡុងពេលចាប់ផ្តើមដំណើរការត្រួតពិនិត្យឡើងវិញនោះ។

## មាត្រា៥.១០ _ ទិដ្ឋានការបន្ទាន់

ប្រសិនបើភាគីសមាជិកអនុម័តវិធានការបន្ទាន់មួយដែលមានភាពចាំបាច់សម្រាប់ការការពារអាយុជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ ភាគីសមាជិកនោះត្រូវជូនដំណឹងភ្លាមៗអំពីវិធានការនោះដោយប្រើប្រព័ន្ធជាក់ស្តើសេចក្តីជូនដំណឹងអនាម័យនិងកូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO SPS notification submission system) ជាមធ្យោបាយជូនដំណឹងបន្ទាន់។ ប្រសិនបើភាគីសមាជិកអនុម័តវិធានការបន្ទាន់មួយ ភាគីនោះត្រូវត្រួតពិនិត្យឡើងវិញនូវវិធានការនោះតាមកាលកំណត់ ហើយផ្តល់លទ្ធផលនៃការត្រួតពិនិត្យឡើងវិញទៅកាន់ភាគីម្ខាងទៀតនៅពេលមានការស្នើសុំ។

## មាត្រា៥.១១ _ តម្លាភាព

១- គូភាគីទទួលស្គាល់នូវតម្លៃនៃតម្លាភាព ក្នុងការអនុម័តនិងការដាក់ឱ្យអនុវត្តវិធានការអនាម័យនិងកូតគាមអនាម័យ និងសារៈសំខាន់នៃការចែករំលែកព័ត៌មានអំពីវិធានការនោះនៅលើមូលដ្ឋានដែលបាននិងកំពុងដំណើរការ។

២- ក្នុងការអនុវត្តមាត្រានេះ ភាគីសមាជិកនីមួយៗត្រូវពិចារណាដល់សេចក្តីសម្រេចពាក់ព័ន្ធរបស់គណៈកម្មាធិការអនាម័យនិងកូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក និងស្តង់ដាគោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ។

៣- ភាគីនីមួយៗត្រូវជូនដំណឹងអំពីវិធានការដែលបានស្នើ ឬការផ្លាស់ប្តូរវិធានការអនាម័យឬកូតគាមអនាម័យដែលអាចមានឥទ្ធិពលលើពាណិជ្ជកម្មនៃភាគីសមាជិកម្ខាងទៀត តាមប្រព័ន្ធជាក់ស្តើសេចក្តីជូនដំណឹងអនាម័យនិងកូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក និងចំណុចទំនាក់ទំនងដែលបានចាត់តាំងក្រោមមាត្រា៥.៥ ជាមធ្យោបាយបន្ថែមនៃការជូនដំណឹង។

៤- ផ្អែកតាមការស្នើសុំ ភាគីសមាជិកត្រូវផ្តល់ទៅកាន់ភាគីម្ខាងទៀតនូវច្បាប់ចម្លងនៃវិធានការអនាម័យនិងកូតគាមអនាម័យជាភាសាអង់គ្លេសប្រសិនបើមាន ដែលទាក់ទងនឹងការនាំចូលទំនិញទៅក្នុងដែនដីរបស់ខ្លួន។

**មាត្រា៥.១២ _ កិច្ចសហប្រតិបត្តិការនិងការកសាងសមត្ថភាព**

១- គូភាគីត្រូវស្វែងរកកាលានុវត្តភាពសម្រាប់បង្កើនកិច្ចសហប្រតិបត្តិការ កិច្ចសហការបន្ថែម រួមទាំងការកសាងសមត្ថភាព ជំនួយបច្ចេកទេស និងការផ្លាស់ប្តូរព័ត៌មានរវាងគ្នាលើការងារអនាម័យ និងកូតគាមអនាម័យដែលមានផលប្រយោជន៍រួម ដោយមានសង្គតិភាពជាមួយនឹងជំពូកនេះ។ គូភាគីត្រូវធ្វើសហប្រតិបត្តិការដើម្បីសម្រួលការអនុវត្តជំពូកនេះ។

២- គូភាគីត្រូវសហប្រតិបត្តិការ និងអាចរួមគ្នាកំណត់ការងារលើបញ្ហាអនាម័យនិងកូតគាមអនាម័យ ជាមួយនឹងគោលដៅលុបបំបាត់នូវឧបសគ្គដែលមិនចាំបាច់ចំពោះពាណិជ្ជកម្មរវាងគូភាគី។

# ជំពូកទី៦
# របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម

## មាត្រា៦.១ _ និយមន័យ

គោលបំណងនៃជំពូកនេះ៖

"TBT Agreement" មានន័យថាជាកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងរបស់WTO ហើយនិយមន័យនៃកិច្ចព្រមព្រៀងនោះត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម។

## មាត្រា៦.២ _ គោលបំណង

គោលបំណងនៃជំពូកនេះ គឺសម្រួលការធ្វើពាណិជ្ជកម្មទំនិញ រួមទាំងការលុបបំបាត់របាំងបច្ចេកទេសចំពោះពាណិជ្ជកម្មដែលមិនចាំបាច់ បង្កើនតម្លាភាព និងលើកកម្ពស់កិច្ចសហប្រតិបត្តិការនិយ័តកម្ម និងការអនុវត្តនិយ័តកម្មល្អឱ្យកាន់តែទូលំទូលាយ។ គោលបំណងបែបនេះ អាចរួមបញ្ចូល៖

(ក) ធានាថា ស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម មិនបង្កើតជាឧបសគ្គមិនចាំបាច់ចំពោះការធ្វើពាណិជ្ជកម្ម

(ខ) បង្កើនកិច្ចសហប្រតិបត្តិការ អនុលោមតាមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម

(គ) ជំរុញការយល់ដឹងទៅវិញទៅមកអំពីស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព និងលើកកម្ពស់តម្លាភាពរបស់ភាគីនីមួយៗ

(ឃ) សម្រួលការផ្លាស់ប្តូរព័ត៌មាននិងកិច្ចសហប្រតិបត្តិការក្នុងចំណោមគូភាគី ក្នុងវិស័យស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព និង

(ង) ដោះស្រាយបញ្ហានានាដែលអាចកើតមានឡើងស្ថិតក្រោមជំពូកនេះ។

## មាត្រា៦.៣ _ វិសាលភាព

១- ជំពូកនេះត្រូវអនុវត្តចំពោះការរៀបចំ ការអនុម័ត និងការអនុវត្តគ្រប់ស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពរបស់អង្គភាពរដ្ឋាភិបាលថ្នាក់កណ្តាល ដែលអាចមានផលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មទំនិញរវាងគូភាគី។

២- ទោះបីមានកថាខណ្ឌ១ ក៏ដោយ ជំពូកនេះមិនត្រូវអនុវត្តចំពោះ៖

(ក) យថាប្រភេទត្រូវទិញដែលបានរៀបចំដោយអង្គភាពរដ្ឋាភិបាល សម្រាប់ការតម្រូវផលិតកម្ម ឬការប្រើប្រាស់របស់ខ្លួន ដែលត្រូវបានគ្របដណ្តប់ដោយលទ្ធកម្មរបស់រដ្ឋាភិបាល ឬ

(ខ) វិធានការអនាម័យឬកូតគាមអនាម័យដែលគ្របដណ្តប់ដោយជំពូកទី៥ (វិធានការអនាម័យ និងកូតគាមអនាម័យ)។

**មាត្រា៦.៤ _ ការអះអាងលើកិច្ចព្រមព្រៀងស្តីពីឧបសគ្គបច្ចេកទេសចំពោះពាណិជ្ជកម្ម**
គូភាគីអះអាងអំពីសិទ្ធិនិងកាតព្វកិច្ចដែលមានស្រាប់របស់ពួកគេ ដោយគោរពគ្នាទៅវិញទៅមកក្រោមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម។

**មាត្រា៦.៥ _ ស្តង់ដា**

១- ភាគីនីមួយៗត្រូវប្រើប្រាស់ស្តង់ដាការណែនាំ និងអនុសាសន៍អន្តរជាតិពាក់ព័ន្ធ ក្នុងកម្រិតដូចមានចែងក្នុងមាត្រា២.៤ និង៥.៤ នៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាពរបស់ខ្លួន។

២- ដើម្បីកំណត់ថាស្តង់ដាការណែនាំ ឬអនុសាសន៍អន្តរជាតិ ដូចមានន័យបានចែងនៅក្នុងមាត្រា២ និង៥ និងឧបសម្ព័ន្ធ៣ នៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មបានយកមកអនុវត្ត ភាគីនីមួយៗត្រូវធ្វើការកំណត់គោលការណ៍របស់ខ្លួនផ្អែកតាម "សេចក្តីសម្រេចរបស់គណៈកម្មការស្តីពីគោលការណ៍សម្រាប់ការអភិវឌ្ឍស្តង់ដាការណែនាំ និងអនុសាសន៍អន្តរជាតិដែលទាក់ទងនឹងមាត្រា២ មាត្រា៥ និងឧបសម្ព័ន្ធ៣ នៃកិច្ចព្រមព្រៀង" ដែលបានអនុម័តនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដោយគណៈកម្មាធិការផ្អែករបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មរបស់WTO (ឧបសម្ព័ន្ធ២ ដល់ផ្នែកទី១ នៃG/TBT/1/Rev14) និងកំណែបន្ទាប់ខាងមុខរបស់សេចក្តីសម្រេច។[1]

៣- គូភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការរវាងអង្គភាពស្តង់ដាជាតិរៀងៗខ្លួន លើផ្នែកដែលមានផលប្រយោជន៍ទៅវិញទៅមក នៅក្នុងបរិបទនៃការចូលរួមរបស់ខ្លួនក្នុងអង្គភាពស្តង់ដានីយកម្មអន្តរជាតិ ដើម្បីធានាថាស្តង់ដាអន្តរជាតិដែលត្រូវបានអភិវឌ្ឍដោយអង្គភាពទាំងនោះគឺសម្រួលដល់ការធ្វើពាណិជ្ជកម្មនិងមិនបង្កើតជាឧបសគ្គដែលមិនចាំបាច់ចំពោះពាណិជ្ជកម្មអន្តរជាតិ។

**មាត្រា៦.៦ _ បទប្បញ្ញត្តិបច្ចេកទេស**

១- គូភាគីត្រូវប្រើប្រាស់ស្តង់ដារអន្តរជាតិទាំងស្រុងឬផ្នែកពាក់ព័ន្ធ ជាមូលដ្ឋានសម្រាប់រៀបចំបទប្បញ្ញត្តិបច្ចេកទេសរបស់ខ្លួន លុះត្រាតែស្តង់ដារអន្តរជាតិឬផ្នែកពាក់ព័ន្ធទាំងនោះមិនមានប្រសិទ្ធភាពឬមិនសមស្រប សម្រាប់ធ្វើឱ្យសម្រេចបាននូវគោលបំណងស្របច្បាប់ដែលបានកំណត់។ តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ភាគីនីមួយៗត្រូវផ្តល់ហេតុផលរបស់ខ្លួន ចំពោះការមិនប្រើប្រាស់ស្តង់ដាអន្តរជាតិឬផ្នែកពាក់ព័ន្ធ ធ្វើជាមូលដ្ឋានក្នុងការរៀបចំបទប្បញ្ញត្តិបច្ចេកទេសរបស់ខ្លួន។

២- ភាគីនីមួយៗត្រូវផ្តល់ការពិចារណាជាវិជ្ជមានលើសំណើរបស់ភាគីសមាជិកម្ខាងទៀត ក្នុងការចរចាលើកិច្ចរៀបចំដើម្បីសម្រេចឱ្យបាននូវសមមូលនៃបទប្បញ្ញត្តិបច្ចេកទេស។

៣- តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ភាគីនីមួយៗត្រូវពន្យល់ពីមូលហេតុដែលខ្លួនមិនទទួលយកសំណើរបស់ភាគីសមាជិកម្ខាងទៀតចំពោះការចរចាលើកិច្ចរៀបចំនោះ។

---

[1] "ស្តង់ដាអន្តរជាតិទាំងនោះ" ត្រូវរួមបញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ត្រឹមឯកសារដែលបានអភិវឌ្ឍដោយអង្គការអន្តរជាតិសម្រាប់ស្តង់ដានីយកម្ម (ISO) គណៈកម្មការអេឡិចត្រូតិចនិកអន្តរជាតិ (IEC) សហព័ន្ធទូរគមនាគមន៍អន្តរជាតិ (ITU) និងគណៈកម្មការកូដិច (CAC)។

៤- គូភាគីត្រូវពង្រឹងការប្រាស្រ័យទាក់ទងនិងការសម្របសម្រួលគ្នាទៅវិញទៅមក នៅពេលសមស្រប ក្នុងបរិបទនៃការពិភាក្សា អំពីសមមូលនៃបទប្បញ្ញត្តិបច្ចេកទេសនិងបញ្ហាពាក់ព័ន្ធនៅក្នុងវេទិកាអន្តរជាតិ ដូចជាគណៈកម្មាធិការផ្នែករបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មរបស់ WTO។

**មាត្រា៦.៧ _ នីតិវិធីវាយតម្លៃអនុលោមភាព**

១- គូភាគីទទួលស្គាល់ថា ដោយអាស្រ័យលើវិស័យជាក់លាក់ពាក់ព័ន្ធ យន្តការនានាមានសម្រាប់ជួយសម្រួល ក្នុងការទទួលយកនៅក្នុងដែនដីរបស់ភាគីសមាជិកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃអនុលោមភាពដែលបានធ្វើឡើងនៅក្នុងដែនគ្រប់គ្រងរបស់ភាគីសមាជិកម្ខាងទៀត។ យន្តការបែបនេះអាចរួមបញ្ចូល៖

(ក) ការទទួលស្គាល់ទៅលើកិច្ចរៀបចំនិងកិច្ចព្រមព្រៀងទទួលស្គាល់ពហុភាគីអន្តរជាតិ ដែលកំពុងមានជាធរមាន ក្នុងចំណោមអង្គភាពវាយតម្លៃអនុលោមភាព

(ខ) ការលើកកម្ពស់ការទទួលស្គាល់ទៅវិញទៅមក នូវលទ្ធផលវាយតម្លៃអនុលោមភាពដោយភាគីសមាជិកម្ខាងទៀត តាមរយៈការទទួលស្គាល់លើការចាត់តាំងអង្គភាពវាយតម្លៃអនុលោមភាពរបស់ភាគីសមាជិកម្ខាងទៀតនោះ

(គ) ការលើកទឹកចិត្តឱ្យមានការរៀបចំកិច្ចរៀបចំស្មើគ្រិត្តរវាងអង្គភាពវាយតម្លៃអនុលោមភាពនៅក្នុងដែនដីរបស់ភាគីនីមួយៗ

(ឃ) ការទទួលយកប្រតិវេទន៍នៃអនុលោមភាពរបស់អ្នកផលិតឬអ្នកផ្គត់ផ្គង់ នៅពេលសមស្រប

(ង) ការធ្វើសុខដុមនីយកម្មលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ការចាត់តាំងអង្គភាពវាយតម្លៃអនុលោមភាព រួមទាំងនីតិវិធីនៃការវាយតម្លៃទទួលស្គាល់ ឬ

(ច) យន្តការផ្សេងៗទៀត ដូចបានឯកភាពគ្នាទៅវិញទៅមកដោយគូភាគី។

២- នៅពេលដែលសមស្រប ភាគីនីមួយៗត្រូវជានាថាលទ្ធផលនៃនីតិវិធីវាយតម្លៃអនុលោមភាព ដែលបានធ្វើឡើងនៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀតត្រូវបានទទួលយក ទោះបីជានីតិវិធីទាំងនោះមានលក្ខណៈខុសគ្នាពីនីតិវិធីរបស់ខ្លួនក៏ដោយ ឱ្យតែនីតិវិធីនោះផ្តល់ការធានាគ្រប់គ្រាន់អំពីការបំពេញតាមបទប្បញ្ញត្តិបច្ចេកទេសដែលអាចអនុវត្តបាន ឬស្តង់ដាដែលសមមូលទៅនឹងនីតិវិធីរបស់ខ្លួនផ្ទាល់។ នៅពេលដែលភាគីណាមួយមិនទទួលយកលទ្ធផលនៃនីតិវិធីវាយតម្លៃអនុលោមភាពដែលបានធ្វើឡើងនៅក្នុងដែនគ្រប់គ្រងរបស់ភាគីសមាជិកម្ខាងទៀត ភាគីនោះត្រូវពន្យល់ពីមូលហេតុនៃការសម្រេចចិត្តរបស់ខ្លួន តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត។

៣- ដើម្បីបង្កើនភាពជឿជាក់លើភាពអាចទុកចិត្តបានដែលមិនផ្លាស់ប្តូរ ចំពោះលទ្ធផលវាយតម្លៃអនុលោមភាព គូភាគីអាចពិគ្រោះលើបញ្ហានោះ ដូចជា សមត្ថភាពផ្នែកបច្ចេកទេសរបស់អង្គភាពវាយតម្លៃអនុលោមភាពពាក់ព័ន្ធជាដើម។

៤- ភាគីនីមួយៗត្រូវផ្តល់ការពិចារណាជាវិជ្ជមានលើសំណើរបស់ភាគីសមាជិកម្ខាងទៀត ដើម្បីចរចាលើកិច្ចព្រមព្រៀងឬកិច្ចរៀបចំនានា សម្រាប់ការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោមរបស់ពួកគេរៀងៗខ្លួន។ គូភាគីត្រូវពិចារណាអំពីលទ្ធភាពនៃការចរចាលើ

កិច្ចព្រមព្រៀងឬកិច្ចរៀបចំនានា សម្រាប់ការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃអនុលោមភាពរបស់ពួកគេរៀងៗខ្លួននៅក្នុងវិស័យដែលបានឯកភាពគ្នាទៅវិញទៅមក។

៥- គូភាគីត្រូវខិតខំពង្រឹងការផ្លាស់ប្តូរព័ត៌មានរបស់ខ្លួនអំពីយន្តការនៃការទទួលយក ដោយឈរលើទស្សនៈសម្រួលដល់ការទទួលយកនូវលទ្ធផលវាយតម្លៃអនុលោមភាព។

## មាត្រា៦.៨ _ កិច្ចសហប្រតិបត្តិការ

១- គូភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនក្នុងវិស័យស្តង់ដាបទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាព ដោយឈរលើទស្សនៈ៖

(ក) បង្កើនភាពយោគយល់ទៅវិញទៅមកនូវប្រព័ន្ធរៀងៗខ្លួន

(ខ) ពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារនិយ័តកម្មរបស់គូភាគី លើបញ្ហាផលប្រយោជន៍ទាំងសងខាង រួមទាំងការការពារសុខភាព សុវត្ថិភាព និងបរិស្ថាន

(គ) សម្រួលពាណិជ្ជកម្ម តាមរយៈការប្រតិបត្តិនូវការអនុវត្តនិយ័តល្អ និង

(ឃ) តាមការសមស្រប ពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីជានាថាបទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាពគឺផ្អែកតាមស្តង់ដាអន្តរជាតិឬផ្នែកពាក់ព័ន្ធ និងមិនបង្កើតជាឧបសគ្គមិនចាំបាច់ចំពោះការធ្វើពាណិជ្ជកម្មរវាងគូភាគី។

២- ដើម្បីសម្រេចបាននូវគោលដៅដែលមានចែងក្នុងកថាខណ្ឌ១ គូភាគីត្រូវធ្វើការរួមគ្នាលើបញ្ហានិយ័តកម្ម ដូចបានឯកភាពគ្នាទាំងសងខាងនិងតាមលទ្ធភាពដែលអាចអនុវត្តបាន ហើយអាចរួមបញ្ចូល៖

(ក) ការលើកកម្ពស់នៃការអនុវត្តនិយ័តកម្មល្អផ្អែកតាមគោលការណ៍នៃការគ្រប់គ្រងហានិភ័យ

(ខ) ការផ្លាស់ប្តូរព័ត៌មាន ដោយឈរលើទស្សនៈក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងប្រសិទ្ធភាពនៃបទប្បញ្ញត្តិបច្ចេកទេសរបស់ខ្លួន

(គ) ការអភិវឌ្ឍនូវការផ្តួចផ្តើមរួមគ្នា សម្រាប់គ្រប់គ្រងហានិភ័យចំពោះសុខភាព សុវត្ថិភាព ឬបរិស្ថាន និងការទប់ស្កាត់នូវការអនុវត្តក្លែងបន្លំនានា និង

(ឃ) ការផ្លាស់ប្តូរព័ត៌មានអំពីការពិនិត្យតាមដានទីផ្សារ នៅពេលសមស្រប។

៣- គូភាគីត្រូវលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការរវាងអង្គភាពរៀងៗខ្លួន ដែលទទួលខុសត្រូវលើស្តង់ដានីយកម្ម ការវាយតម្លៃភាពអនុលោម ការវាយតម្លៃទទួលស្គាល់ និងមាត្រាសាស្ត្រ ដោយឈរលើទស្សនៈសម្រួលពាណិជ្ជកម្ម និងចៀសវាងបង្កើតជាឧបសគ្គមិនចាំបាច់ចំពោះការធ្វើពាណិជ្ជកម្មរវាងគូភាគី។

## មាត្រា៦.៩ _ តម្លាភាព

១- តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ភាគីនីមួយៗត្រូវផ្តល់ព័ត៌មាន រួមទាំងគោលដៅនិងហេតុផលជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិបច្ចេកទេសឬនីតិវិធីវាយតម្លៃអនុលោមភាព ដែលភាគីនីមួយៗបានអនុម័តទទួលយកឬស្នើសុំឱ្យអនុម័តទទួលយក ហើយអាចប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មរវាងគូភាគី ក្នុងរយៈពេលសមស្របដូចបានឯកភាពគ្នារវាងគូភាគី។

២- នៅពេលដែលបទប្បញ្ញត្តិបច្ចេកទេសដែលបានស្នើឡើង ត្រូវបានដាក់ជូនសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈឬបានជូនដំណឹងទៅWTO ភាគីសមាជិកត្រូវផ្តល់ការពិចារណាសមស្របចំពោះមតិយោបល់ដែលទទួលបានពីភាគីសមាជិកម្ខាងទៀត តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ហើយត្រូវផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរចំពោះមតិយោបល់ដែលបានផ្តល់ដោយភាគីសមាជិកម្ខាងទៀត។

៣- គូភាគីត្រូវធានាថា រាល់បទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាពដែលបានអនុម័តអាចរកបានជាសាធារណៈ។

៤- នៅពេលដែលភាគីសមាជិកធ្វើការឃាត់ទំនិញដែលបាននាំចូល នៅចំណុចច្រកនាំចូលដោយសារទំនិញមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសឬនីតិវិធីវាយតម្លៃអនុលោមភាព ភាគីនោះត្រូវជូនដំណឹងដល់អ្នកនាំចូលឬតំណាងរបស់ពួកគេ ព្រមទាំងចំណុចទំនាក់ទំនងរបស់ភាគីសមាជិកម្ខាងទៀតដូចបានកំណត់នៅក្រោមមាត្រា៦.១០ ឱ្យបានឆាប់ហើសតាមដែលអាចធ្វើទៅបានអំពីមូលហេតុនៃការឃាត់ទំនិញ។

## មាត្រា៦.១០ _ ចំណុចទំនាក់ទំនង

១. សម្រាប់គោលបំណងនៃជំពូកនេះ ចំណុចទំនាក់ទំនងគឺ៖

(ក) សម្រាប់ព្រះរាជាណាចក្រកម្ពុជា វិទ្យាស្ថានស្តង់ដាកម្ពុជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឬអ្នកស្នងតំណែងរបស់ខ្លួន និង

(ខ) សម្រាប់អេមីរ៉ាតអារ៉ាប់រួម ផ្នែកស្តង់ដានិងបទប្បញ្ញត្តិ ក្រសួងឧស្សាហកម្មនិងបច្ចេកវិទ្យាទំនើប ឬអ្នកស្នងតំណែងរបស់ខ្លួន។

២. ភាគីនីមួយៗត្រូវជូនដំណឹងភ្លាមៗដល់ភាគីសមាជិកម្ខាងទៀត អំពីការផ្លាស់ប្តូរចំណុចទំនាក់ទំនងរបស់ខ្លួនណាមួយ។

## មាត្រា៦.១១ _ ការផ្លាស់ប្តូរព័ត៌មាននិងការពិភាក្សាផ្នែកបច្ចេកទេស

១- តាមការស្នើសុំរបស់ភាគីសមាជិកម្ខាងទៀត ព័ត៌មានឬការពន្យល់ណាមួយដែលភាគីសមាជិកផ្តល់ឱ្យអនុលោមតាមជំពូកនេះ នឹងត្រូវផ្តល់ជូនតាមរយៈការបោះពុម្ពឬតាមប្រព័ន្ធអេឡិចត្រូនិកក្នុងរយៈពេលសមស្រប។ ភាគីនីមួយៗត្រូវខិតខំឆ្លើយតបទៅនឹងសំណើបែបនេះក្នុងរយៈពេល ៦០ថ្ងៃ។

២- រាល់ការប្រាស្រ័យទាក់ទងគ្នារវាងគូភាគីលើបញ្ហាណាមួយ ដែលគ្របដណ្តប់ដោយជំពូកនេះ ត្រូវធ្វើឡើងតាមរយៈចំណុចទំនាក់ទំនងដែលបានចាត់តាំងក្រោមមាត្រា៦.១០។

៣- តាមការស្នើសុំរបស់ភាគីសមាជិកចំពោះការពិភាក្សាផ្នែកបច្ចេកទេសលើបញ្ហាណាមួយដែលកើតមានឡើងក្រោមជំពូកនេះ គូភាគីត្រូវខិតខំក្នុងកម្រិតដែលអាចអនុវត្តបាន ដើម្បីចូលរួមក្នុងការពិភាក្សាផ្នែកបច្ចេកទេស ដោយជូនដំណឹងដល់ចំណុចទំនាក់ទំនងដែលបានចាត់តាំងក្រោមមាត្រា៦.១០ ។

# ជំពូកទី៧
# ឧបាស្រ័យពាណិជ្ជកម្ម

## ផ្នែក ក
## ១- វិធានការការពារទ្វេភាគី

**មាត្រា៧.១ _ និយមន័យ**
គោលបំណងនៃផ្នែកនេះ៖

**វិធានការការពារទ្វេភាគី** មានន័យថាជាវិធានការការពារដែលបានកំណត់នៅក្នុងមាត្រា៧.២

**ឧស្សាហកម្មក្នុងស្រុក** មានន័យថា ដោយទាក់ទងនឹងទំនិញនាំចូល ក្រុមអ្នកផលិតទំនិញដូចគ្នាឬទំនិញប្រកួតប្រជែងដោយផ្ទាល់ដែលចរាចរនៅក្នុងដែនដីរបស់ភាគីសមាជិក ឬជាក្រុមអ្នកផលិតដែលមានទិន្នផលរួមនៃទំនិញដូចគ្នាឬទំនិញប្រកួតប្រជែងដោយផ្ទាល់ បង្កើតជាទំហំដ៏ធំនៃផលិតកម្មក្នុងស្រុកសរុបនៃទំនិញទាំងនោះ

**ការខូចខាតធ្ងន់ធ្ងរ** មានន័យថាជាការខូចខាតធំធេងជាទូទៅដល់ស្ថានភាពរបស់ឧស្សាហកម្មក្នុងស្រុក

**ការគំរាមកំហែងនៃការខូចខាតធ្ងន់ធ្ងរ** មានន័យថាការខូចខាតធ្ងន់ធ្ងរដែលនឹងកើតមានឡើងជាក់លាក់ដោយផ្អែកលើមូលដ្ឋាននៃការពិតនិងមិនមែនគ្រាន់តែផ្អែកលើការនិយាយចោទប្រកាន់ ការប៉ាន់ស្មាន ឬលទ្ធភាពកើតឡើងតិចតួច និង

**រយៈពេលអន្តរកាល** ទាក់ទងនឹងផលិតជាក់លាក់មួយ មានន័យថាជាអំឡុងពេលគិតចាប់ពីកិច្ចព្រមព្រៀងនេះបានចូលជាធរមានរហូតដល់៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលពន្ធគយនៃទំនិញជាក់លាក់មួយនោះត្រូវបានលុបចោលឬកាត់បន្ថយ ដោយអនុលោមតាមឧបសម្ព័ន្ធ២ (តារាងសន្យាពន្ធគយ) ដែលអំឡុងពេលនេះមិនត្រូវលើសពី១៥(ដប់ប្រាំ)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀង ទោះក្នុងកាលៈទេសៈណាក៏ដោយ។

**មាត្រា៧.២ _ ការអនុវត្តវិធានការការពារ**

១- ប្រសិនបើដោយសារតែការកាត់បន្ថយឬលុបបំបាត់ពន្ធគយនៅក្រោមកិច្ចព្រមព្រៀងនេះ ទំនិញដែលមានប្រភពដើមមកពីភាគីសមាជិកម្ខាងទៀត ត្រូវបាននាំចូលទៅក្នុងដែនដីនៃភាគីសមាជិកក្នុងបរិមាណកើនឡើង ដែលស្ថិតក្នុងលក្ខខណ្ឌដាច់ខាត ឬពាក់ព័ន្ធនឹងផលិតកម្មក្នុងស្រុក ដែលនៅក្រោមលក្ខខណ្ឌទាំងនេះបានបង្ក ឬគំរាមកំហែងបង្កការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតទំនិញដូចគ្នាឬទំនិញប្រកួតប្រជែងដោយផ្ទាល់ ភាគីសមាជិកនោះអាចចាត់វិធានការក្នុងកម្រិតដែលចាំបាច់ ដើម្បីទប់ស្កាត់ឬដោះស្រាយការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនិងសម្រួលធ្វើការកែតម្រូវប៉ះប៉ូវឧស្សាហកម្មក្នុងស្រុករបស់ខ្លួន ដូចជា៖

(ក) ល្បួរការកាត់បន្ថយអត្រាពន្ធគយបន្ថែមលើទំនិញដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ ឬ

(ខ) បង្កើនអត្រាពន្ធគយលើទំនិញ ដល់កម្រិតមួយដែលមិនលើសពីកម្រិតទាបបំផុតនៃ៖

(i) អត្រាពន្ធគយដែលអនុវត្តសម្រាប់ប្រជាជាតិទទួលបានភាពអនុគ្រោះបំផុត លើទំនិញកំពុងប្រើប្រាស់ ក្នុងពេលដាក់ចេញវិធានការការពារនេះ ឬ

(ii) អត្រាមូលដ្ឋាននៃពន្ធគយដែលបានបញ្ជាក់នៅក្នុងតារាងពន្ធគយ ដែលមាននៅក្នុងឧបសម្ព័ន្ធ២ (តារាងសន្យាពន្ធគយ) ដោយអនុលោមតាមមាត្រា២.៤(ការកាត់បន្ថយឬការលុបបំបាត់ពន្ធគយ)។

២- គូភាគីយល់ថា គ្មានការកំណត់បរិមាណនាំចូលសម្រាប់អត្រាពន្ធគយណាមួយឬការរឹតត្បិតបរិមាណនាំចូល ជាទម្រង់ដែលត្រូវបានអនុញ្ញាតនៃវិធានការការពារទេ។

**មាត្រា៧.៣ _ ការជូនដំណឹងនិងការពិគ្រោះយោបល់**

១- ភាគីសមាជិកត្រូវបញ្ជូនភ្លាមៗ នូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតនៅពេល៖

(ក) ចាប់ផ្តើមការស៊ើបអង្កេតដូចមានចែងនៅក្នុងមាត្រា៧.៤ ទាក់ទងនឹងការខូចខាតធ្ងន់ធ្ងរ ឬការគំរាមកំហែងពីការខូចខាតធ្ងន់ធ្ងរ និងហេតុផលនៃករណីនោះ:

(ខ) រកឃើញការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងពីការខូចខាតធ្ងន់ធ្ងរ ដែលបណ្តាលមកពីកំណើនការនាំចូល

(គ) អនុវត្តឬពន្យារពេលការដាក់ចេញវិធានការការពារទ្វេភាគី និង

(ឃ) ធ្វើសេចក្តីសម្រេចចិត្តកែប្រែវិធានការការពារទ្វេភាគី ដោយរាប់បញ្ចូលទាំងការធ្វើសេរីភាវូបនីយកម្មបន្ថែមជាលំដាប់។

២- សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលមានចែងនៅក្នុងវាក្យខណ្ឌ១(ក) ត្រូវរួមបញ្ចូល៖

(ក) ការពិពណ៌នាច្បាស់លាស់អំពីទំនិញមានដើមកំណើត ដែលជាកម្មវត្ថុនៃការស៊ើបអង្កេត រួមទាំងចំណងជើង(Heading) និងចំណងជើងរង(Subheading) ក្រោមប្រព័ន្ធសុខដុម និងនាមវលើជាតិរបស់ភាគីសមាជិក

(ខ) សេចក្តីសង្ខេបមូលហេតុចំពោះការចាប់ផ្តើមស៊ើបអង្កេត និង

(គ) កាលបរិច្ឆេទនៃការចាប់ផ្តើមស៊ើបអង្កេតនិងរយៈពេលស៊ើបអង្កេត។

៣- ភាគីសមាជិកត្រូវផ្តល់ជូនភាគីម្ខាងទៀត នូវច្បាប់ថតចម្លងមួយច្បាប់នៃរបាយការណ៍ចេញផ្សាយជាសាធារណៈ ដោយអាជ្ញាធរមានសមត្ថកិច្ចដែលត្រូវបានកំណត់នៅក្នុងមាត្រា៧.៤ កថាខណ្ឌ១។ របាយការណ៍ដែលបានផ្តល់ជូនភាគីម្ខាងទៀត ត្រូវធ្វើជាភាសាអង់គ្លេស។

៤- សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដូចមានចែងនៅក្នុងវាក្យខណ្ឌ១(ខ) ដល់(ឃ) ត្រូវរួមបញ្ចូល៖

(ក) ការពិពណ៌នាជាក់លាក់អំពីទំនិញមានដើមកំណើត ដែលជាកម្មវត្ថុនៃវិធានការការពារទ្វេភាគី រួមទាំងចំណងជើងនិងចំណងជើងរងក្រោមប្រព័ន្ធសុខដុមនិងនាមវលើជាតិរបស់ភាគីសមាជិក

(ខ) កស្តុតាងអំពីការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងពីការខូចខាតធ្ងន់ធ្ងរ ដែលបណ្តាលមកពីកំណើនការនាំចូលនៃទំនិញដែលមានដើមកំណើតពីភាគីសមាជិក ដែលជាលទ្ធផលនៃការកាត់បន្ថយឬលុបបំបាត់ពន្ធគយ ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ

(គ) ការពិពណ៌នាជាក់លាក់នៃវិធានការការពារទ្វេភាគីដែលបានស្នើសុំ

(ឃ) កាលបរិច្ឆេទដែលបានស្នើសុំសម្រាប់ការដាក់ចេញវិធានការការពារទ្វេភាគី រយៈពេលពឹងទុក និងបើសិនជាអាច កាលវិភាគសម្រាប់ការធ្វើសេចក្តីវិបនីយកម្មបន្ថែមជាលំដាប់នៃវិធានការការពារទ្វេភាគី ដូចមានចែងនៅក្នុងមាត្រា៧.៥ កថាខណ្ឌ៣ និង

(ង) កស្តុតាងដែលឧស្សាហកម្មក្នុងស្រុកពាក់ព័ន្ធកំពុងកែតម្រូវប៉ះប៉ូវ ក្នុងករណីមានការពន្យារបន្ថែមនៃវិធានការការពារទ្វេភាគី។

៥- ភាគីសមាជិកដែលបានស្នើអនុវត្តឬពន្យារបន្ថែមវិធានការការពារទ្វេភាគី ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ឱ្យមានកិច្ចពិគ្រោះយោបល់ជាមុនជាមួយនឹងភាគីម្ខាងទៀត ក្នុងគោលបំណងដើម្បីពិនិត្យឡើងវិញនូវព័ត៌មានដែលមានចែងក្នុងកថាខណ្ឌ២និង៤ ដែលទទួលបានពីការស៊ើបអង្កេតដូចមាននៅក្នុងមាត្រា៧.៤ ផ្លាស់ប្តូរទស្សនៈអំពីវិធានការការពារទ្វេភាគី និងឈានដល់ការយោគយល់គ្នាអំពីមធ្យោបាយនានា ដើម្បីសម្រេចវត្ថុបំណងដែលបានចែងនៅក្នុងមាត្រា៧.៧។

## មាត្រា៧.៤ _ នីតិវិធីស៊ើបអង្កេត

១- ភាគីសមាជិកត្រូវអនុវត្តវិធានការការពារ លុះត្រាបន្ទាប់ពីការស៊ើបអង្កេតដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមមាត្រា៣និងមាត្រា៤.២នៃកិច្ចព្រមព្រៀងស្តីពីការការពារ។ ក្នុងន័យនេះ មាត្រា៣និងមាត្រា៤.២ ត្រូវបានបញ្ចូលនិងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

២- ភាគីនីមួយៗត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបញ្ចប់ការស៊ើបអង្កេត ដោយយោងតាមកថាខណ្ឌ១ ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមស៊ើបអង្កេត។

## មាត្រា៧.៥ _ ទិសាលភាពនិងរយៈពេលនៃវិធានការការពារទ្វេភាគី

១- គ្មានភាគីណាមួយត្រូវអនុវត្តវិធានការការពារទេ៖

(ក) លើកលែងតែដល់កម្រិតដែលចាំបាច់ ដើម្បីការពារឬដោះស្រាយការខូចខាតធ្ងន់ធ្ងរនិងជួយសម្រួលដល់ការកែតម្រូវប៉ះប៉ូវឧស្សាហកម្ម

(ខ) ក្នុងរយៈពេលលើសពី២(ពីរ)ឆ្នាំ លើកលែងតែរយៈពេលនេះអាចត្រូវបានពន្យារបន្ថែមរហូតដល់១ឆ្នាំ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចូលកំណត់ ដោយអនុលោមតាមនីតិវិធីដែលបញ្ជាក់នៅក្នុងមាត្រានេះថា វិធានការនេះនៅតែបន្តមានភាពចាំបាច់ដើម្បីការពារឬដោះស្រាយការខូចខាតធ្ងន់ធ្ងរ និងជួយសម្រួលការកែតម្រូវប៉ះប៉ូវឧស្សាហកម្ម និងមានកស្តុតាងថាឧស្សាហកម្មនោះកំពុងកែតម្រូវប៉ះប៉ូវ ល្អីកណាយៈពេលសរុបនៃការអនុវត្តវិធានការការពារ ដែលរួមបញ្ចូលទាំងរយៈពេលអនុវត្តដំបូងនិងការពន្យារបន្ថែមនៃរយៈពេលនេះមិនត្រូវលើសពី៣ឆ្នាំ ឬ

(គ) ហួសរយៈពេលផុតកំណត់នៃរយៈពេលអន្តរកាល។

២- គ្មានវិធានការការពារទ្វេភាគីណាមួយ ត្រូវបានអនុវត្តលើការនាំចូលទំនិញមានដើមកំណើតមួយ ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកាត់បន្ថយឬលុបបំបាត់ពន្ធគយសម្រាប់ទំនិញមានដើមកំណើតនោះ ដូចមានចែងក្រោមកិច្ចព្រមព្រៀងនេះ។

៣- គ្មានវិធានការការពារណាមួយត្រូវបានអនុវត្តម្តងទៀត លើការនាំចូលទំនិញមានដើមកំណើតណាមួយដែលកន្លងមកបានធ្លាប់ទទួលរងនូវវិធានការនេះ ក្នុងរយៈពេលមួយស្មើនឹងរយៈពេលនៃវិធានការការពារពីមុន ក្នុងករណីរយៈពេលដែលមិនបានអនុវត្តវិធានការនេះមានរយៈពេលយ៉ាងតិចពីរឆ្នាំ។

៤- ដើម្បីជួយសម្រួលដល់ការកែតម្រូវប៉ះប៉ូវឧស្សាហកម្ម ក្នុងស្ថានភាពដែលរយៈពេលវែងទុកនៃវិធានការការពារលើសពីមួយឆ្នាំ ភាគីដែលអនុវត្តវិធានការការពារត្រូវធ្វើសេរីភាវូបនីយកម្មបន្ថែមជាលំដាប់ក្នុងចន្លោះពេលណាមួយទៀងទាត់ អំឡុងពេលអនុវត្តនោះ។

៥- នៅពេលភាគីសមាជិកបញ្ចប់វិធានការការពារ អត្រាពន្ធគយសម្រាប់ទំនិញមានដើមកំណើតដែលស្ថិតនៅក្រោមវិធានការការពារនោះ ត្រូវតែជាអត្រាដែលកំពុងអនុវត្តដោយអនុលោមតាមឧបសម្ព័ន្ធ២(តារាងសន្យាពន្ធគយ) ដែលនឹងមានប្រសិទ្ធភាពសម្រាប់តែវិធានការការពារនោះប៉ុណ្ណោះ។

**មាត្រា៧.៦ _ វិធានការការពារបណ្តោះអាសន្ន**

១- ក្នុងកាលៈទេសៈសំខាន់ដែលការពន្យារពេលអាចបង្កការខូចខាត ដែលមានផលលំបាកដល់ការស្តារឡើងវិញ ភាគីសមាជិកអាចដាក់វិធានការការពារបណ្តោះអាសន្នដែលត្រូវយកទម្រង់វិធានការដែលបានកំណត់ក្នុងមាត្រា៧.២ អនុលោមតាមសេចក្តីកំណត់បឋមរបស់អាជ្ញាធរមានសមត្ថកិច្ចថា ពិតជាមានកស្តុតាងច្បាស់លាស់ដែលការនាំចូលទំនិញមានដើមកំណើតពីភាគីសមាជិកម្ខាងទៀតនោះមានការកើនឡើង ដោយសារការកាត់បន្ថយឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងនេះ និងការនាំចូលកើនឡើងបែបនេះបានបង្កឬគំរាមកំហែងបង្ករការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃភាគីនាំចូល។

២- នៅមុនពេលអាជ្ញាធរមានសមត្ថកិច្ចនៃភាគីសមាជិកអាចធ្វើសេចក្តីកំណត់បឋម ភាគីនោះត្រូវផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ ដោយពន្យល់ភាគីដែលមានចំណាប់អារម្មណ៍រាប់បញ្ចូលទាំងអ្នកនាំចូលនិងអ្នកនាំចេញ អំពីវិធីអាចទទួលបាននូវច្បាប់ថតចម្លងដែលមិនសម្ងាត់នៃការដាក់ពាក្យស្នើសុំដាក់វិធានការការពារបណ្តោះអាសន្ន និងតាមអាចអនុវត្តទៅបានត្រូវផ្តល់ជូនភាគីដែលចាប់អារម្មណ៍នូវឱកាសគ្រប់គ្រាន់ បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីផ្តល់នូវកស្តុតាងនិងទស្សនៈពាក់ព័ន្ធនឹងពាក្យស្នើសុំការដាក់វិធានការការពារបណ្តោះអាសន្ន។

៣- ភាគីដែលដាក់វិធានការត្រូវជូនដំណឹងដល់ភាគីសមាជិកម្ខាងទៀតមុនពេលដាក់វិធានការការពារបណ្តោះអាសន្ន និងត្រូវចាប់ផ្តើមប្រឹក្សាយោបល់ភ្លាមៗបន្ទាប់ពីវិធានការការពារបណ្តោះអាសន្នត្រូវបានអនុវត្ត។

៤- រយៈពេលនៃវិធានការការពារបណ្តោះអាសន្នណាមួយមិនត្រូវលើសពី២០០ថ្ងៃ អំឡុងពេលដែលភាគីអនុវត្តវិធានការការពារបណ្តោះអាសន្ន ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងមាត្រា៧.៤។

៥- ភាគីត្រូវផ្តល់ត្រឡប់មកវិញភ្លាមនូវកំណើនពន្ធគយណាមួយដែលត្រូវបានប្រមូល ប្រសិនបើការស៊ើបអង្កេតដែលមានរៀបរាប់ក្នុងមាត្រា៧.៤ កថាខណ្ឌ១ មិនបណ្តាលឱ្យរកឃើញថាតម្រូវការនៃមាត្រា៧.២ ត្រូវបានបំពេញ។

៦- ភាគីសមាជិកមិនអាចអនុវត្តវិធានការការពារបណ្តោះអាសន្ន រហូតដល់រយៈពេលយ៉ាងតិច៤៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនចាប់ផ្តើមស៊ើបអង្កេត។

**មាត្រា៧.៧ _ សំណង**

១- ភាគីសមាជិកដែលបានស្នើដាក់ឬពន្យារវិធានការការពារទ្វេភាគី ដោយពិគ្រោះយោបល់ជាមួយភាគីសមាជិកម្ខាងទៀត ត្រូវផ្តល់ឱ្យភាគីសមាជិកម្ខាងទៀតនោះតាមការឯកភាពគ្នាទាំងសងខាងនូវមធ្យោបាយគ្រប់គ្រាន់នៃសំណងពាណិជ្ជកម្មក្នុងទម្រង់សម្បទាន ដែលមានផលពាណិជ្ជកម្មសមមូល ឬស្មើនឹងតម្លៃនៃពន្ធគយបន្ថែម ដែលអាចជាលទ្ធផលបណ្តាលមកពីវិធានការនោះ។ ភាគីដែលអនុវត្តវិធានការការពារទ្វេភាគីត្រូវផ្តល់ឱកាស ដើម្បីប្រឹក្សាយោបល់ក្នុងរយៈពេល ៣០ ថ្ងៃ នៃកាលបរិច្ឆេទដែលវិធានការការពារទ្វេភាគីត្រូវបានអនុវត្ត។

២- ប្រសិនបើការប្រឹក្សាយោបល់ចែងក្នុងកថាខណ្ឌ១ មិននាំឱ្យមានការព្រមព្រៀងលើសំណងពាណិជ្ជកម្មក្នុងរយៈពេល៣០ថ្ងៃ នៃការចាប់ផ្តើមនៃការប្រឹក្សាយោបល់នោះទេ ភាគីម្ខាងទៀតអាចព្យួរការអនុវត្តសម្បទានសមមូលចំពោះពាណិជ្ជកម្មទំនិញរបស់ភាគីដែលបានដាក់វិធានការការពារទ្វេភាគី។

៣- ភាគីសមាជិកដែលមានបំណងព្យួរការអនុវត្តសម្បទាន ត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីសមាជិកម្ខាងទៀតដែលអនុវត្តវិធានការការពារទ្វេភាគីឱ្យបានយ៉ាងតិច៣០ថ្ងៃមុននឹងភាគីនោះព្យួរការអនុវត្តសម្បទាន អនុលោមតាមកថាខណ្ឌ២។

៤- សិទ្ធិព្យួរការអនុវត្តសម្បទានដែលអនុលោមតាមកថាខណ្ឌ២ មិនត្រូវអនុវត្តសម្រាប់រយៈពេល ២ ឆ្នាំដំបូង ដែលក្នុងអំឡុងពេលនោះវិធានការការពារទ្វេភាគីកំពុងអនុវត្ត ដោយហេតុថាវិធានការការពារទ្វេភាគីនោះត្រូវបានអនុវត្ត ដោយមូលហេតុមានការកើនឡើងដាច់ខាតនៃការនាំចូល ហើយវិធានការការពារទ្វេភាគីនេះអនុលោមទៅតាមបទប្បញ្ញត្តិនៃផ្នែកនេះ។

៥- កាតព្វកិច្ចក្នុងការផ្តល់សំណងក្រោមកថាខណ្ឌ១និងសិទ្ធិព្យួរការអនុវត្តសម្បទានដែលអនុលោមតាមកថាខណ្ឌ២ ត្រូវបញ្ឈប់នៅពេលបញ្ចប់វិធានការការពារទ្វេភាគី។

៦- សំណងណាមួយត្រូវផ្អែកលើរយៈពេលសរុបនៃការអនុវត្តវិធានការការពារទ្វេភាគី ដែលប្រសិនអាចអនុវត្តបាន ត្រូវរាប់បញ្ចូលរយៈពេលអនុវត្តវិធានការការពារបណ្តោះអាសន្នណាមួយ។

## ២- វិធានការការពារសកល

**មាត្រា៧.៨ _ វិធានការការពារសកល**

១- ភាគីនីមួយៗរក្សាសិទ្ធិនិងកាតព្វកិច្ចក្រោមមាត្រា XIX នៃGATT ១៩៩៤ និងកិច្ចព្រមព្រៀងការការពាររបស់WTO។ កិច្ចព្រមព្រៀងនេះមិនផ្តល់សិទ្ធិនិងកាតព្វកិច្ចបន្ថែមដល់គូភាគី ពាក់ព័ន្ធនឹងវិធានការការពារសកលក្រោមមាត្រាXIX នៃGATT ១៩៩៤ និងកិច្ចព្រមព្រៀងការពារឡើយ។

២- ភាគីសមាជិកដែលដាក់វិធានការការពារសកល ត្រូវដកចេញការនាំចូលទំនិញមានដើមកំណើតនៃភាគីសមាជិកម្ខាងទៀត ប្រសិនបើចំណែកនៃការនាំចូលផលិតផលពាក់ព័ន្ធ នៅក្នុងដែនដីភាគីនាំចូលនោះមិនលើសបីភាគរយ នៃការនាំចូលសរុបនៃទំនិញនោះ ដោយមានន័យថាសមាជិកប្រទេសកំពុងអភិវឌ្ឍដែលមានចំណែកនាំចូលតិចជាងបីភាគរយ មានចំណែកសរុបរួមគ្នាមិនលើសប្រាំបួនភាគរយនៃការនាំចូលសរុបនៃទំនិញនោះ។

៣- ចំពោះទំនិញដូចគ្នា គ្មានភាគីណាមួយត្រូវអនុវត្តក្នុងពេលតែមួយ នូវ៖

(ក) វិធានការការពារទ្វេភាគីឬបណ្តោះអាសន្ន និង

(ខ) វិធានការក្រោមមាត្រា XIX នៃGATT ១៩៩៤ និងកិច្ចព្រមព្រៀងការពារ។

៤- ជាលទ្ធផលនៃវិធានការការពារសកល នៅពេលដែលពន្ធការពារត្រូវបានអនុវត្ត គម្លាតនៃការអនុគ្រោះពន្ធត្រូវតែរក្សាការពារ ដោយអនុលោមតាមតារាងសម្បទាននៃគូភាគីក្រោមជំពូកទី២ (ពាណិជ្ជកម្មទំនិញ)។

## ផ្នែក ខ ប្រឆាំងការលក់បង្ខូចថ្លៃនិងពន្ធប៉ះប៉ូវ

### មាត្រា៧.៩ _ បទប្បញ្ញត្តិទូទៅ

១- គូភាគីបញ្ជាក់ឡើងវិញអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ក្រោមបទប្បញ្ញត្តិនៃមាត្រាVI នៃGATT ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រាVI នៃGATT ១៩៩៤(កិច្ចព្រមព្រៀងប្រឆាំងនឹងការលក់បង្ខូចថ្លៃ) និងកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការប៉ះប៉ូវ(កិច្ចព្រមព្រៀង SCM)។

២- គូភាគីទទួលស្គាល់សិទ្ធិក្នុងការអនុវត្តវិធានការនានា ស្របនឹងមាត្រាVI នៃGATT ១៩៩៤ កិច្ចព្រមព្រៀងប្រឆាំងនឹងការលក់បង្ខូចថ្លៃ កិច្ចព្រមព្រៀងSCM និងសារៈសំខាន់នៃការជំរុញតម្លាភាពក្នុងដំណើរការងារនៃការប្រឆាំងការលក់បង្ខូចថ្លៃនិងពន្ធប៉ះប៉ូវ និងផ្តល់ឱកាសដល់ភាគីដែលមានចំណាប់អារម្មណ៍ ដើម្បីចូលរួមពេញលេញក្នុងនីតិវិធីទាំងនោះ។

៣- លើកលែងតែចែងផ្សេងពីនេះក្នុងមាត្រានេះ កិច្ចព្រមព្រៀងនេះមិនផ្តល់សិទ្ធិឬកាតព្វកិច្ចបន្ថែមដល់គូភាគី ពាក់ព័ន្ធនឹងវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃនិងវិធានការប៉ះប៉ូវ រាប់បញ្ចូលទាំងការចាប់ផ្តើមនិងការរៀបចំនៃការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងប្រឆាំងនឹងការឧបត្ថម្ភធន ក៏ដូចជាការអនុវត្តវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និង/ឬ វិធានការប៉ះប៉ូវ។

៤- ក្នុងនីតិវិធីណាមួយដែលអាជ្ញាធរស៊ើបអង្កេតនៃភាគីសមាជិក កំណត់ធ្វើការស៊ើបអង្កេតនៅទីតាំងផ្ទាល់ អាជ្ញាធរស៊ើបអង្កេតត្រូវគោរពតាមឧបសម្ព័ន្ធ I នៃកិច្ចព្រមព្រៀងការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងឧបសម្ព័ន្ធ VI នៃកិច្ចព្រមព្រៀង SCM។

### មាត្រា៧.១០ _ សេចក្តីជូនដំណឹងនិងការប្រឹក្សាយោបល់

១- នៅពេលអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីសមាជិក ទទួលបានពាក្យស្នើសុំប្រឆាំងការបង្ខូចថ្លៃដែលមានលក្ខណៈគ្រប់គ្រាន់ពាក់ព័ន្ធនឹងការនាំចូលពីភាគីសមាជិកម្ខាងទៀត ភាគីនោះត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីសមាជិកម្ខាងទៀត ឱ្យបានយូរមុនការទទួលបានពាក្យស្នើសុំនោះ តាមដែលអាចធ្វើទៅបាន។

២- នៅពេលអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីសមាជិក ទទួលបានពាក្យស្នើសុំពន្ធប៉ះប៉ូវដែលមានលក្ខណៈគ្រប់គ្រាន់ពាក់ព័ន្ធនឹងការនាំចូលពីភាគីសមាជិកម្ខាងទៀត និងមុនពេលចាប់ផ្តើមស៊ើបអង្កេត ភាគីនោះត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនភាគីសមាជិកម្ខាងទៀតអំពីការទទួលបានពាក្យស្នើសុំនោះ និងផ្តល់ឱ្យភាគីសមាជិកម្ខាងទៀតនូវកិច្ចប្រជុំមួយ ដើម្បីពិគ្រោះយោបល់ជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធពាក្យស្នើសុំនោះ តាមភាពសមស្របនិងអនុលោមតាមប្រការនីតិវិធី ដែលមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិរបស់ភាគីនោះ។

**មាត្រា៧.១១ _ ការលាតត្រដាងការណ៍ពិតសំខាន់**

អាជ្ញាធរស៊ើបអង្កេតរបស់ភាគីសមាជិកត្រូវធានាថា មុនពេលការកំណត់ចុងក្រោយត្រូវបានធ្វើឡើង ការលាតត្រដាងការណ៍ពិតសំខាន់ៗទាំងអស់ដែលកំពុងស្ថិតក្រោមការពិចារណា ដែលជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តថាតើត្រូវអនុវត្តវិធានការស្តារឬអត់។ ប្រការនេះគឺគ្មានធ្វើឱ្យប៉ះពាល់ដល់មាត្រា៦.៥ នៃកិច្ចព្រមព្រៀងប្រឆាំងការលក់បង្ខូចថ្លៃ និងមាត្រា១២.៤ នៃកិច្ចព្រមព្រៀងSCMឡើយ។ ការលាតត្រដាងការណ៍ពិតនានាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងអនុញ្ញាតឱ្យភាគីមានចំណាប់អារម្មណ៍មានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការបញ្ចេញមតិរបស់ពួកគេ។

**មាត្រា៧.១២ _ ការមិនអនុវត្តដំណោះស្រាយវិវាទ**

គ្មានភាគីសមាជិកណាមួយត្រូវទាមទារប្រើប្រាស់ជំពូកទី១៨(ដំណោះស្រាយវិវាទ) នៃកិច្ចព្រមព្រៀងនេះសម្រាប់បញ្ហាកើតឡើងក្រោមមាត្រានេះ។

## ផ្នែក គ កិច្ចសហប្រតិបត្តិការ

**មាត្រា៧.១៣ _ កិច្ចសហប្រតិបត្តិការ**

គូភាគីត្រូវខិតខំជំរុញកិច្ចសហប្រតិបត្តិការលើឧបាស្រ័យពាណិជ្ជកម្មរវាងអាជ្ញាធរពាក់ព័ន្ធនៃភាគីនីមួយៗដែលមានការទទួលខុសត្រូវលើបញ្ហាឧបាស្រ័យពាណិជ្ជកម្ម។

## ជំពូកទី៨
## ពាណិជ្ជកម្មសេវាកម្ម

**មាត្រា៨.១ _ និយមន័យ**
គោលបំណងនៃជំពូកនេះ៖

**នីតិបុគ្គលមួយ** គឺ៖

(ក) "ត្រូវបានកាន់កាប់" ដោយបុគ្គលរបស់ភាគីសមាជិកណាមួយ ប្រសិនបើច្រើនជាង៥០ ភាគរយនៃដើមទុនគឺត្រូវបានកាន់កាប់ផលប្រយោជន៍ដោយបុគ្គលរបស់ភាគីសមាជិកនោះ;

(ខ) "ត្រូវបានគ្រប់គ្រង" ដោយបុគ្គលរបស់ភាគីសមាជិកណាមួយ ប្រសិនបើបុគ្គលទាំងនោះមានសិទ្ធិអំណាចក្នុងការជ្រើសរើសតែងតាំងសមាសភាពភាគច្រើននៃនាយកគ្រប់គ្រង ឬបើមិនដូច្នេះ មានសិទ្ធិតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តសកម្មភាពរបស់ខ្លួន ឬ

(គ) "ត្រូវបានចងសម្ព័ន្ធ" ជាមួយបុគ្គលណាមួយផ្សេងទៀត នៅពេលដែលនីតិបុគ្គលនោះគ្រប់គ្រងឬត្រូវបានគ្រប់គ្រងដោយបុគ្គលណាមួយផ្សេងទៀត ឬនៅពេលដែលទាំងនីតិបុគ្គលនិងបុគ្គលផ្សេងទៀតនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលតែមួយ។

**សេវាកម្មដែលបានផ្តត់ផ្តង់ ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល** សំដៅដល់សេវាកម្មទាំងឡាយណាដែលត្រូវបានផ្តត់ផ្តង់មិនមែនសម្រាប់គោលបំណងពាណិជ្ជកម្ម និងគោលបំណងប្រកួតប្រជែងជាមួយអ្នកផ្តត់ផ្តង់សេវាកម្មមួយឬច្រើន។

**សេវាកម្មជួសជុលនិងថែទាំអាកាសយាន** សំដៅដល់សកម្មភាពធ្វើទៅលើអាកាសយានឬផ្នែកណាមួយនៃអាកាសយាន ខណៈដែលអាកាសយាននេះត្រូវបានដាក់ឱ្យនៅក្រៅការបម្រើសេវាកម្ម និងមិនពាប់បញ្ចូលសេវាកម្មដែលគេហៅថាការថែទាំលក្ខណៈបណ្តាញ។

**វត្តមានពាណិជ្ជកម្ម** សំដៅដល់ប្រភេទធុរកិច្ចឬការបង្កើតវិជ្ជាជីវៈណាមួយ តាមរយៈ៖

(ក) ការបង្កើត ការទិញ ឬការរក្សាទុកនីតិបុគ្គលមួយ ឬ

(ខ) ការបង្កើតឬការរក្សាទុកសាខាឬការិយាល័យតំណាង នៅក្នុងដែនដីរបស់ភាគីសមាជិកណាមួយ ក្នុងគោលបំណងផ្តត់ផ្តង់សេវាកម្ម

**សេវាកម្មកក់សំបុត្រតាមប្រព័ន្ធកំព្យូទ័រ** សំដៅដល់សេវាកម្មផ្តល់ឱ្យដោយប្រព័ន្ធកំព្យូទ័រដែលផ្តុំកន្លែព័ត៌មានកាលវិភាគរបស់ក្រុមហ៊ុនអាកាសចរណ៍ ភាពទំនេរ តម្លៃសំបុត្រនិងលក្ខខណ្ឌតម្លៃសំបុត្រ តាមរយៈការកក់ទុកដែលអាចធ្វើឡើងបាន ឬតាមរយៈសំបុត្រដែលអាចចេញឱ្យបាន។

**នីតិបុគ្គល** សំដៅដល់អង្គភាពស្របច្បាប់ណាមួយដែលត្រូវបានបង្កើតឡើងឬត្រូវបានរៀបចំឡើងក្រោមច្បាប់ជាធរមាន ទោះបីជាដើម្បីស្វែងរកប្រាក់ចំណេញឬដើម្បីគោលបំណងដ៏ទៃទៀតក្តី និងទោះបីជា

ក្រោមកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិរដ្ឋាភិបាល ដែលរួមមានក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនបរធនបាលកិច្ច/មូលនិធិ ក្រុមហ៊ុនសហកម្មសិទ្ធ សហព័ន្ធជីវកម្ម ក្រុមហ៊ុនឯកកម្មសិទ្ធិ ឬសមាគម។

**នីតិបុគ្គលរបស់ភាគីសមាជិកម្ខាងទៀត** សំដៅដល់នីតិបុគ្គលមួយដែល៖

(ក) ត្រូវបានបង្កើតឬរៀបចំឡើងក្រោមច្បាប់របស់ភាគីសមាជិកម្ខាងទៀតនោះ ហើយបានចូលរួមនៅក្នុងប្រតិបត្តិការធុរកិច្ចជាសារវន្ត នៅក្នុងដែនដីរបស់៖

(i) ភាគីសមាជិកនោះ ឬ

(ii) រាល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយត្រូវបានកាន់កាប់ដោយ ឬគ្រប់គ្រងដោយរូបវន្តបុគ្គលនៃភាគីម្ខាងទៀតនោះ ឬដោយនីតិបុគ្គលដែលបានបំពេញរាល់លក្ខខណ្ឌនៃវាក្យខណ្ឌ (ក)(i) ឬ

(ខ) ក្នុងករណីការផ្តត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ដែលត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយ៖

(i) រូបវន្តបុគ្គលរបស់ភាគីសមាជិកនោះ ឬ

(ii) នីតិបុគ្គលនៃភាគីសមាជិកម្ខាងទៀតនោះ ដូចបានកំណត់ក្នុងវាក្យខណ្ឌ (i)

**វិធានការរបស់ភាគីសមាជិក** សំដៅដល់វិធានការទាំងឡាយណាដែលត្រូវបានអនុវត្តដោយ៖

(ក) រដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់ក្រោមជាតិ និងអាជ្ញាធរ និង

(ខ) អង្គភាពមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តសិទ្ធិអំណាចដែលត្រូវបានផ្ទេរដោយរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់ក្រោមជាតិ ឬអាជ្ញាធរមានសមត្ថកិច្ច។

ដើម្បីបំពេញកាតព្វកិច្ចនិងការសន្យារបស់ខ្លួនក្នុងកិច្ចព្រមព្រៀងនេះ ភាគីសមាជិកនីមួយៗត្រូវអនុវត្តវិធានការសមស្របតាមដែលខ្លួនមាន ដើម្បីធានាលើការអនុវត្តវិធានការទាំងនោះដោយរដ្ឋាភិបាលថ្នាក់តំបន់ ឬថ្នាក់ក្រោមជាតិ និងអាជ្ញាធរ និងអង្គភាពមិនមែនរដ្ឋាភិបាលនៅក្នុងដែនដីរបស់ខ្លួន។

**វិធានការរបស់ភាគីសមាជិកដែលប៉ះពាល់ដល់ពាណិជ្ជកម្មសេវាកម្ម** រួមមានវិធានការទាក់ទងនឹង៖

(ក) ការទិញ ការទូទាត់ ឬការប្រើសេវាកម្មណាមួយ

(ខ) សិទ្ធិប្រើប្រាស់និងការប្រើប្រាស់សេវាកម្ម ដែលតម្រូវឱ្យផ្តត់ផ្គង់ជូនជាសាធារណៈជាទូទៅដោយភាគីសមាជិក ពាក់ព័ន្ធនឹងការផ្តត់ផ្គង់សេវាកម្ម និង

(គ) វត្តមានរបស់បុគ្គលរួមទាំងវត្តមានពាណិជ្ជកម្មនៃភាគីសមាជិកសម្រាប់ការផ្តត់ផ្គង់សេវាកម្មនៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀត

**អ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខ** សំដៅដល់បុគ្គលទាំងឡាយណា ទោះជាសាធារណៈឬឯកជនដែលត្រូវបានផ្តល់សិទ្ធិឬបង្កើតឡើងជាផ្លូវការ ឬដោយការអនុវត្តជាក់ស្តែងដោយភាគីសមាជិកឱ្យធ្វើជាអ្នកផ្តត់ផ្គង់សេវាកម្មនោះផ្តាច់មុខ នៅក្នុងទីផ្សារពាក់ព័ន្ធក្នុងដែនដីរបស់ភាគីសមាជិកនោះ

**រូបវន្តបុគ្គលរបស់ភាគីសមាជិកម្ខាងទៀត** សំដៅដល់ជនជាតិឬនិវាសនជនអចិន្ត្រៃយ៍[1]នៃអេមីរ៉ាតអារ៉ាប់រួមឬកម្ពុជា

**បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលមួយ

**វិស័យសេវាកម្ម** សំដៅដល់៖

(ក) ដោយយោងតាមតារាងសន្យាតាមវិស័យ អនុវិស័យសេវាកម្មមួយឬច្រើនឬទាំងអស់ ដូចមានចែងក្នុងតារាងសន្យាតាមវិស័យរបស់ភាគីសមាជិក ឬ

(ខ) បើមិនដូច្នេះ វិស័យសេវាកម្មទាំងអស់ រួមទាំងអនុវិស័យទាំងអស់របស់សេវាកម្ម។

**ការលក់និងការធ្វើទីផ្សារសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស** សំដៅដល់កាលានុវត្តភាពសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ពាក់ព័ន្ធក្នុងការលក់ និងការធ្វើទីផ្សារសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសរបស់ខ្លួនដោយសេរី ដោយរាប់បញ្ចូលគ្រប់ទិដ្ឋភាពនៃការធ្វើទីផ្សារ ដូចជាការស្រាវជ្រាវទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការចែកចាយ។ សកម្មភាពទាំងនេះមិនរាប់បញ្ចូលការកំណត់តម្លៃសេវាដឹកជញ្ជូនតាមផ្លូវអាកាសនិងលក្ខខណ្ឌដែលត្រូវអនុវត្តឡើយ

**អ្នកប្រើប្រាស់សេវាកម្ម** សំដៅដល់បុគ្គលដែលទទួលឬប្រើប្រាស់សេវាកម្មណាមួយ។

**សេវាកម្មរបស់ភាគីសមាជិកម្ខាងទៀត** សំដៅដល់សេវាកម្មដែលត្រូវបានផ្គត់ផ្គង់៖

(ក) ចេញពីឬនៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀតនោះ ឬក្នុងករណីដឹកជញ្ជូនតាមផ្លូវទឹក ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីសមាជិកម្ខាងទៀតនោះ ឬដោយបុគ្គលរបស់ភាគីសមាជិកម្ខាងទៀតនោះដែលផ្គត់ផ្គង់សេវាកម្មតាមរយៈប្រតិបត្តិការនាវានិង/ឬការប្រើប្រាស់នាវានោះទាំងមូលឬដោយផ្នែក ឬ

(ខ) ក្នុងករណីការផ្គត់ផ្គង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គលដោយអ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីសមាជិកម្ខាងទៀតនោះ។

**អ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីសមាជិក** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលនៃភាគីសមាជិកដែលផ្គត់ផ្គង់សេវាកម្ម[2]។

**សេវាកម្ម** រួមបញ្ចូលសេវាកម្មទាំងឡាយនៅក្នុងវិស័យណាមួយ លើកលែងតែសេវាកម្មដែលបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ឱ្យដោយរដ្ឋាភិបាល។

---

[1]សម្រាប់អេមីរ៉ាតអារ៉ាប់រួម ៣ក្យ "និវាសនជនអចិន្ត្រៃយ៍" ត្រូវសំដៅដល់ រូបវន្តបុគ្គលដែលកាន់កាប់លិខិតបញ្ជាក់សិទ្ធិរស់នៅមានសុពលភាពក្រោមច្បាប់និងបទប្បញ្ញត្តិរបស់អេមីរ៉ាតអារ៉ាប់រួម។

[2]ក្នុងករណីដែលសេវាកម្មមិនត្រូវបានផ្គត់ផ្គង់ផ្ទាល់ដោយនីតិបុគ្គលមួយ ប៉ុន្តែផ្គត់ផ្គង់តាមរយៈទម្រង់ផ្សេងៗនៃវត្តមានពាណិជ្ជកម្ម ដូចជាសាខាឬការិយាល័យតំណាង ផ្តួយមកវិញតាមរយៈវត្តមានពាណិជ្ជកម្មនោះ អ្នកផ្គត់ផ្គង់សេវាកម្ម (ឧទាហរណ៍ នីតិបុគ្គល) ត្រូវទទួលបានប្រព្រឹត្តកម្ម ដែលផ្តល់សម្រាប់អ្នកផ្គត់ផ្គង់សេវានោះ នៅក្រោមកិច្ចព្រមព្រៀងនេះ។ ប្រព្រឹត្តកម្មនេះត្រូវបន្តផ្តល់ឱ្យវត្តមានពាណិជ្ជកម្មដែលសេវាកម្មត្រូវបានផ្គត់ផ្គង់និងមិនចាំបាច់បន្តផ្តល់ដល់ផ្នែកណាមួយផ្សេងទៀតរបស់អ្នកផ្គត់ផ្គង់ដែលមានទីវេសនដ្ឋានក្រៅដែនដីដែលសេវាកម្មនោះត្រូវបានផ្គត់ផ្គង់។

**ការផ្គត់ផ្គង់សេវាកម្ម** រួមបញ្ចូលទាំងផលិតកម្ម ការចែកចាយ ការធ្វើទីផ្សារ ការលក់ និងការផ្តល់សេវាកម្ម

**ពាណិជ្ជកម្មសេវាកម្ម** ត្រូវបានផ្តល់និយមន័យថា ជាការផ្គត់ផ្គង់សេវាកម្ម៖

(ក) ចេញពីដែនដីរបស់ភាគីសមាជិកទៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀត

(ខ) នៅក្នុងដែនដីរបស់ភាគីសមាជិកទៅកាន់អ្នកប្រើប្រាស់សេវារបស់ភាគីសមាជិកម្ខាងទៀត

(គ) ដោយអ្នកផ្គត់ផ្គង់សេវារបស់ភាគីសមាជិក តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀត និង

(ឃ) ដោយអ្នកផ្គត់ផ្គង់សេវារបស់ភាគីសមាជិក តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ភាគីសមាជិកនៅក្នុងដែនដីរបស់ភាគីសមាជិកម្ខាងទៀត។

**សិទ្ធិចរាចរណ៍** សំដៅដល់សិទ្ធិសម្រាប់សេវាកម្មដែលបានរៀបចំពេលវេលាទុកមុនឬមិនបានរៀបចំពេលវេលាទុកមុន សម្រាប់ធ្វើប្រតិបត្តិការឬដឹកអ្នកដំណើរ ទំនិញ និងបញ្ជើដែលមានផលកម្រៃ ឬប្រាក់ជួល ពីទៅ នៅក្នុង ឬខាងលើដែនដីនៃភាគីសមាជិក រួមបញ្ចូលទាំងចំណុចដែលត្រូវបម្រើសេវាកម្ម ផ្លូវដែលត្រូវធ្វើប្រតិបត្តិការ ប្រភេទនៃចរាចរណ៍ដែលត្រូវធ្វើ សមត្ថភាពផ្ទុកដែលត្រូវផ្តល់ជូន កម្រៃសេវាកម្មដែលត្រូវយក និងលក្ខខណ្ឌនានា និងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសក្រុមហ៊ុនអាកាសចរណ៍ រួមមានលក្ខណៈវិនិច្ឆ័យជាចំនួន កម្មសិទ្ធិ និងការគ្រប់គ្រង។

## មាត្រា៨.២ _ វិសាលភាព

១- ជំពូកនេះអនុវត្តចំពោះវិធានការដែលត្រូវអនុម័តឬរក្សាទុកដោយភាគី ដែលប៉ះពាល់ពាណិជ្ជកម្មសេវាកម្ម។

២- ជំពូកនេះមិនត្រូវអនុវត្តចំពោះ៖

(ក) ច្បាប់ បទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវ គ្រប់គ្រងលទ្ធកម្មដោយភ្នាក់ងារដ្ឋាភិបាលសម្រាប់សេវាកម្មបម្រើឱ្យគោលបំណងរបស់រដ្ឋាភិបាល ហើយមិនមែនសម្រាប់លក់បន្តក្នុងគោលដៅពាណិជ្ជកម្មឬមិនមែនសម្រាប់ផ្គត់ផ្គង់សេវាកម្មសម្រាប់គោលដៅពាណិជ្ជកម្ម

(ខ) សេវាកម្មដែលបានផ្គត់ផ្គង់ ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល

(គ) ឧបត្ថម្ភធនឬជំនួយផ្តល់ឱ្យដោយភាគីសមាជិក ដែលរួមបញ្ចូលទាំងកម្ចីរដ្ឋាភិបាល ការធានា ធានារ៉ាប់រងជាដើម

(ឃ) វិធានការនានាដែលប៉ះពាល់ដល់រូបវន្តបុគ្គលរបស់ភាគីសមាជិក ដែលព្យាយាមចូលទៅកាន់ទីផ្សារការងាររបស់ភាគីសមាជិកម្ខាងទៀត ឬវិធានការទាក់ទងនឹងសញ្ជាតិ ការស្នាក់នៅ ឬការធ្វើការងារជាលក្ខណៈអចិន្ត្រៃយ៍។ មិនមានបទប្បញ្ញត្តិណាមួយក្នុងជំពូកនេះឬឧបសម្ព័ន្ធនៃជំពូកនេះ ហាមឃាត់ភាគីសមាជិកអនុវត្តវិធានការក្នុងការគ្រប់គ្រងការចូលមកនិងការស្នាក់នៅបណ្តោះអាសន្នរបស់រូបវន្តបុគ្គលនៅក្នុងដែនដីរបស់ខ្លួន រួមទាំងវិធានការចាំបាច់ដើម្បីការពារបូរណភាពដែនដី និងក្នុងការធានាដល់ការធ្វើដំណើររបស់រូបវន្តបុគ្គលប្រកបដោយសណ្តាប់ធ្នាប់ឆ្លងកាត់ដែនដីរបស់ខ្លួន លុះត្រាតែវិធានការទាំងនោះ

មិនត្រូវបានអនុវត្ត ក្នុងគោលបំណងធ្វើឱ្យធ្វើមោយភាពឬប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីសមាជិកណាមួយ ក្រោមលក្ខខណ្ឌដូចមានចែងក្នុងតារាងសន្យាតាមវិស័យ[3]

(ង) វិធានការប៉ះពាល់ដល់សិទ្ធិហោះហើរឬវិធានការប៉ះពាល់សេវាកម្មផ្សេងទៀតដែលទាក់ទងទៅនឹងសិទ្ធិនៃការធ្វើចរាចរណ៍ផ្លូវអាកាស ក្រៅពីវិធានការនានាដែលប៉ះពាល់ដល់៖[4]

(i) សេវាកម្មជួសជុលនិងថែទាំយន្តហោះ

(ii) សេវាកម្មលក់និងធ្វើទីផ្សាររបស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

(iii) សេវាកម្មកក់សំបុត្រតាមប្រព័ន្ធកុំព្យូទ័រ

(iv) សេវាកម្មប្រតិបត្តិការលើដី

(v) សេវាកម្មប្រតិបត្តិការអាកាសយានដ្ឋាន

៣- សិទ្ធិនិងកាតព្វកិច្ចនានារបស់គូភាគីចំពោះសេវាកម្មហិរញ្ញវត្ថុ ត្រូវគ្រប់គ្រងដោយឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុនៃកិច្ចព្រមព្រៀងGATS ដែលត្រូវបានបញ្ចូលក្នុងនិងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា៨.៣ _ តារាងសន្យាតាមវិស័យ**

១- ភាគីសមាជិកនីមួយៗត្រូវចែងក្នុងតារាងកម្មវិធី ហៅថាតារាងសន្យាតាមវិស័យជាក់លាក់នូវការសន្យាជាក់លាក់ដែលភាគីនោះផ្តល់ឱ្យ ដោយអនុលោមតាមមាត្រា៨.៥ មាត្រា៨.៦ និងមាត្រា ៨.៧។

២- ចំពោះវិស័យទាំងឡាយណាដែលការសន្យាទាំងនោះត្រូវបានផ្តល់ឱ្យ តារាងសន្យាតាមវិស័យនីមួយៗត្រូវបញ្ជាក់អំពី៖

(ក) លក្ខខណ្ឌកំណត់ ការកម្រិត និងលក្ខខណ្ឌនានាស្តីពីការបើកទីផ្សារ

(ខ) លក្ខខណ្ឌនិងគុណវុឌ្ឍិលើប្រព្រឹត្តកម្មជាតិ

(គ) ការអនុវត្តនានាពាក់ព័ន្ធនឹងការសន្យាបន្ថែម

(ឃ) ក្របខណ្ឌពេលវេលាសមស្របសម្រាប់ការអនុវត្តនៃការសន្យាទាំងនោះ និង

(ង) កាលបរិច្ឆេទចូលជាធរមាននៃការសន្យា។

៣- វិធានការនានាដែលមិនមានសង្គតិភាពជាមួយមាត្រា៨.៥ និងមាត្រា៨.៦ ត្រូវសរសេរចូលក្នុងតារាងជួរឈរដែលពាក់ព័ន្ធនឹងមាត្រា៨.៥។ ក្នុងករណីនេះ ការបញ្ចូលនេះនឹងត្រូវបានចាត់ទុកថាផ្តល់លក្ខខណ្ឌឬគុណវុឌ្ឍិចំពោះមាត្រា៨.៦ ផងដែរ។

៤- តារាងសន្យាតាមវិស័យជាក់លាក់របស់គូភាគីត្រូវបានចែងក្នុងឧបសម្ព័ន្ធ៨ក (តារាងសន្យាតាមវិស័យ)។

---

[3]ការណ៍នៃការតម្រូវឱ្យមានទីជ្ឈាការសម្រាប់រូបវន្តបុគ្គលនៃប្រទេសជាក់លាក់ណាមួយ ហើយមិនមែនសម្រាប់រូបវន្តបុគ្គលនៃប្រទេសផ្សេងៗមិនត្រូវចាត់ទុកថាធ្វើឱ្យមោយៈឬធ្វើឱ្យខូចផលប្រយោជន៍តាមការសន្យាជាក់លាក់ណាមួយនោះទេ។

[4]ទោះបីជាមានចែងក្នុងវាក្យខណ្ឌ (iv) និង (v) ក៏ដោយ ដំពូកនេះត្រូវអនុវត្តចំពោះវិធានការនានាដែលប៉ះពាល់ដល់សេវាកម្មប្រតិបត្តិការលើដីនិងសេវាកម្មប្រតិបត្តិការអាកាសយានដ្ឋានចំពោះតែភាគីដែលជ្រើសរើសផ្តល់ការសន្យាពាក់ព័ន្ធនឹងសេវាកម្មទាំងនេះ ដោយអនុលោមតាមមាត្រា ៨.៣ (តារាងសន្យាតាមវិស័យជាក់លាក់) តែប៉ុណ្ណោះ។

**មាត្រា៨.៤ _ ប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុត**

ក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប្រសិនបើភាគីសមាជិកចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មជាមួយដៃគូមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ដោយមានសំណើពីភាគីសមាជិកម្ខាងទៀត ភាគីសមាជិកនោះត្រូវប្រឹងប្រែងចរចាបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះនូវប្រព្រឹត្តកម្ម ដែលមានភាពអនុគ្រោះមិនតិចជាងប្រព្រឹត្តកម្ម ដែលផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងជាមួយដៃគូមិនមែនជាភាគីសមាជិកនោះ។ គូភាគីត្រូវពិចារណាលើកាលៈទេសៈដែលភាគីសមាជិកណាមួយចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មជាមួយដៃគូមិនមែនជាភាគីសមាជិក។

**មាត្រា៨.៥ _ ការបើកទីផ្សារ**

១- ចំពោះការបើកទីផ្សារតាមម៉ូដនៃការផ្តត់ផ្គង់សេវាកម្ម ដែលបានកំណត់ក្នុងនិយមន័យនៃ "ពាណិជ្ជកម្មសេវាកម្ម" ដូចមានចែងក្នុងមាត្រា៨.១ ភាគីសមាជិកនីមួយៗ ត្រូវផ្តល់ឱ្យសេវាកម្ម និងអ្នកផ្តត់ផ្គង់សេវាកម្មនានាពីភាគីសមាជិកម្ខាងទៀត នូវប្រព្រឹត្តកម្មដែលមានភាពអនុគ្រោះមិនតិចជាងប្រព្រឹត្តកម្មដែលបានផ្តល់ឱ្យនៅក្រោមលក្ខខណ្ឌកំណត់ ការកម្រិត និងលក្ខខណ្ឌនានាដែលបានព្រមព្រៀងគ្នានិងបានបញ្ជាក់ច្បាស់នៅក្នុងតារាងសន្យាតាមវិស័យរបស់ខ្លួន[5]។

២- ចំពោះវិស័យទាំងឡាយណាដែលការសន្យាបើកទីផ្សារត្រូវបានផ្តល់ឱ្យ ដែលការនានាដែលភាគីសមាជិកមិនត្រូវរក្សាទុកឬមិនត្រូវអនុម័ត បើទោះបីឈរលើមូលដ្ឋានរដ្ឋបាលថ្នាក់តំបន់ឬរដ្ឋបាលដែនដីទាំងស្រុងក្តី លើកលែងតែត្រូវបានបញ្ជាក់ច្បាស់នៅក្នុងតារាងសន្យាតាមវិស័យរបស់ខ្លួនត្រូវបានកំណត់ដូចខាងក្រោម៖

(ក) ការកម្រិតលើចំនួនអ្នកផ្តត់ផ្គង់សេវាកម្មក្នុងទម្រង់ជាចំនួនកូតា ការផ្តាច់មុខ អ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខ ឬតម្រូវឱ្យលក្ខខណ្ឌតម្រូវសេដ្ឋកិច្ច

(ខ) ការកម្រិតលើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសកម្មក្នុងទម្រង់ជាចំនួនកូតា ឬតម្រូវឱ្យលក្ខខណ្ឌតម្រូវសេដ្ឋកិច្ច

(គ) ការកម្រិតលើចំនួនសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្មគិតជាឯកតាក្នុងទម្រង់ជាចំនួនកូតា ឬតម្រូវឱ្យលក្ខខណ្ឌតម្រូវសេដ្ឋកិច្ច[6]

(ឃ) ការកំណត់លើចំនួនសរុបរូបវន្តបុគ្គល ដែលអាចនឹងត្រូវបានជួលមកធ្វើការក្នុងវិស័យសេវាកម្មជាក់លាក់ណាមួយ ឬដែលអ្នកផ្តត់ផ្គង់សេវាកម្មអាចជួលមកធ្វើការបាននិងដែលចាំបាច់និងពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តត់ផ្គង់សេវាកម្មជាក់លាក់ណាមួយ ក្នុងទម្រង់ជាចំនួនកូតា ឬតម្រូវឱ្យលក្ខខណ្ឌតម្រូវសេដ្ឋកិច្ច

---

[5] ប្រសិនបើភាគីណាមួយផ្តល់ការសន្យាបើកទីផ្សារទាក់ទងទៅនឹងការផ្តត់ផ្គង់សេវាកម្ម តាមរយៈម៉ូដផ្តត់ផ្គង់សេវាកម្ម ដូចមានចែងក្នុងវាក្យខណ្ឌ (ក) នៃនិយមន័យនៃ "ពាណិជ្ជកម្មសេវាកម្ម" ដូចមានចែងក្នុងមាត្រា៨.១ និងប្រសិនបើចលនាឆ្លងកាត់ព្រំដែននៃមូលធនគឺជាផ្នែកសំខាន់មួយនៃសេវាកម្មរបស់ខ្លួន ភាគីសមាជិកនោះត្រូវប្តេជ្ញាថានឹងអនុញ្ញាតចំពោះចលនាមូលធននោះ។ ប្រសិនបើភាគីសមាជិកផ្តល់ការសន្យាបើកទីផ្សារទាក់ទងទៅនឹងការផ្តត់ផ្គង់សេវាតាមរយៈម៉ូដផ្តត់ផ្គង់សេវាកម្មក្នុងវាក្យខណ្ឌ(គ) នៃនិយមន័យនៃ "ពាណិជ្ជកម្មសេវាកម្ម" ដូចមានចែងក្នុងមាត្រា ៨.១ នោះភាគីសមាជិកនោះត្រូវប្តេជ្ញាថានឹងអនុញ្ញាតចំពោះការផ្ទេរមូលធនដែលពាក់ព័ន្ធនោះចូលដែនដីរបស់ខ្លួន។

[6] វាក្យខណ្ឌ២(គ) មិនគ្របដណ្តប់លើជំនាននានានៃភាគីណាមួយដែលកំណត់ជាតុចូលសម្រាប់ការផ្តត់ផ្គង់សេវាកម្មទាំងនោះឡើយ។

(ង) វិធានការទាំងឡាយណាដែលរឹតត្បិតឬតម្រូវឱ្យមានប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះខុនដែលតាមរយៈវិធានការទាំងនោះ ទើបអ្នកផ្តត់ផ្គង់សេវាកម្មអាចផ្តល់សេវាកម្មណាមួយបាន និង

(ច) ការកម្រិតលើការចូលរួមមូលធនរបស់បរទេសក្នុងទម្រង់ជាភាគរយអតិបរមា ដែលកម្រិតលើភាគហ៊ុនបរទេសឬលើតម្លៃសរុបនៃការវិនិយោគបរទេសដោយបុគ្គល ឬដោយការចូលរួមហ៊ុន។

**មាត្រា៨.៦ _ ប្រព្រឹត្តកម្មជាតិ**

១. ដោយអនុលោមតាមសៃ័យសេវាកម្មដែលបានចែងក្នុងតារាងសន្យាជាក់លាក់របស់ខ្លួន និងផ្អែកលើលក្ខខណ្ឌនិងគុណវុឌ្ឍិណាមួយដែលបានចែងក្នុងនោះ ភាគីសមាជិកនីមួយៗត្រូវផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្គង់សេវាកម្មរបស់ភាគីសមាជិកម្ខាងទៀត ពាក់ព័ន្ធនឹងរាល់វិធានការដែលជះឥទ្ធិពលដល់ការផ្តត់ផ្គង់សេវាកម្ម នូវប្រព្រឹត្តកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងប្រព្រឹត្តកម្មដែលខ្លួនផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្គង់សេវាកម្មរបស់ខ្លួន។[7]

២. ភាគីសមាជិកអាចបំពេញបានតាមលក្ខខណ្ឌតម្រូវក្នុងកថាខណ្ឌ១ តាមរយៈការផ្តល់សេវាកម្មនិងអ្នកផ្តត់ផ្គង់សេវាកម្មនៃភាគីម្ខាងទៀតនូវប្រព្រឹត្តកម្មជាផ្លូវការដូចគ្នា ឬប្រព្រឹត្តកម្មជាផ្លូវការខុសគ្នាពីប្រព្រឹត្តកម្មដែលខ្លួនផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្គង់សេវាកម្មដូចគ្នារបស់ខ្លួន។

៣. ប្រព្រឹត្តកម្មជាផ្លូវការដូចគ្នាឬជាផ្លូវការខុសគ្នាដោយភាគីសមាជិក ត្រូវចាត់ទុកថាមានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខណ្ឌប្រកួតប្រជែង ដោយផ្តល់ភាពអនុគ្រោះដល់សេវាកម្មឬអ្នកផ្តត់ផ្គង់សេវាកម្មរបស់ភាគីសមាជិកនោះ ធៀបនឹងសេវាកម្មឬអ្នកផ្តត់ផ្គង់សេវាកម្មដូចគ្នានៃភាគីសមាជិកម្ខាងទៀត។

**មាត្រា៨.៧ _ ការសន្យាបន្ថែម**

គូភាគីអាចចរចាការសន្យាដោយអនុលោមតាមវិធានការដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលមិនផ្អែកលើតារាងសន្យាដែលស្ថិតក្រោមមាត្រា៨.៥ និងមាត្រា៨.៦ រួមទាំងអ្វីដែលពាក់ព័ន្ធនឹងគុណវុឌ្ឍិ ស្តង់ដានិងអាជ្ញាបណ្ណផ្សេងៗ។ ការសន្យានេះត្រូវបានចែងនៅក្នុងតារាងសន្យាជាក់លាក់របស់ភាគីនោះ។

**មាត្រា៨.៨ _ ការកែប្រែតារាងសន្យា**

គូភាគីត្រូវធ្វើការពិគ្រោះយោបល់ដើម្បីពិចារណាលើការកែប្រែ ឬការដកចេញណាមួយនៃការសន្យាជាក់លាក់នៅក្នុងការតារាងសន្យាជាក់លាក់របស់ភាគីសមាជិកដែលបានស្នើសុំ ដោយផ្អែកលើការស្នើជាលាយលក្ខណ៍អក្សរដោយភាគីសមាជិក។ ការពិគ្រោះយោបល់ត្រូវធ្វើឡើងក្នុងរយៈពេលបីខែ បន្ទាប់ពីភាគីសមាជិកស្នើសុំបានធ្វើសំណើរបស់ខ្លួន។ នៅក្នុងការពិគ្រោះយោបល់នេះ គូភាគីត្រូវមានបំណងធានាថា កម្រិតទូទៅនៃការសន្យាដែលមានផលប្រយោជន៍ទៅវិញទៅមកនៃភាពអនុគ្រោះ តិចជាងការធ្វើ

[7] ការសន្យាជាក់លាក់ដែលមានក្រោមមាត្រានេះ ពុំត្រូវបានបកស្រាយដើម្បីតម្រូវឱ្យភាគីណាមួយផ្តល់នូវសំណងទុទាត់ចំពោះគុណវិបត្តិប្រកួតប្រជែងណាមួយ ដែលជាលទ្ធផលចេញពីចរិតលក្ខណៈបរទេសនៃសេវាកម្មឬអ្នកផ្តត់ផ្គង់សេវាកម្មពាក់ព័ន្ធឡើយ។

ពាណិជ្ជកម្មដែលបានផ្តល់នៅក្នុងតារាងសន្យាជាក់លាក់ មុនពេលការពិគ្រោះយោបល់បានធ្វើឡើង។ ការកែប្រែតារាងសន្យា គឺអាស្រ័យទៅនិតិវិធីណាមួយដែលបានអនុម័តដោយគណៈកម្មាធិការចម្រុះដែលត្រូវបានបង្កើតក្នុងជំពូកទី១៦(រដ្ឋបាលនៃកិច្ចព្រមព្រៀង)។

**មាត្រា៨.៩ _ បទប្បញ្ញត្តិក្នុងស្រុក**

១- ក្នុងវិស័យដែលការសន្យាជាក់លាក់ត្រូវបានផ្តល់ ភាគីសមាជិកនីមួយៗត្រូវធានាថា រាល់វិធានការនៃការអនុវត្តទូទៅដែលជៈឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលម្អៀង។

២- (ក) ភាគីសមាជិកនីមួយៗត្រូវរក្សា ឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវអង្គជំនុំជម្រះ អង្គភាពនិច្ឆ័យនៃមជ្ឈត្តកម្មឬរដ្ឋបាល ឬនីតិវិធី តបតាមសំណើរបស់អ្នកផ្គត់ផ្គង់សេវាកម្មដែលរងការប៉ះពាល់ដើម្បីផ្តល់ឱ្យមានការពិនិត្យឡើងវិញភ្លាមៗ ហើយក្នុងករណីសមហេតុផល ផ្តល់ដំណោះស្រាយសមរម្យចំពោះសេចក្តីសម្រេចរដ្ឋបាលនានាដែលជៈឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។ ករណីដែលនីតិវិធីទាំងនោះពុំមានឯករាជ្យភាពពីភ្នាក់ងារដែលទទួលបន្ទុកពិនិត្យលើសេចក្តីសម្រេចរដ្ឋបាលពាក់ព័ន្ធទាំងនោះ ភាគីសមាជិកនោះត្រូវធានាថា នីតិវិធីទាំងនោះធ្វើឡើងសម្រាប់ការពិនិត្យឡើងវិញប្រកបដោយសត្យានុម័តនិងមិនលម្អៀងយ៉ាងពិតប្រាកដ។

(ខ) ប្រការទាំងឡាយនៃវាក្យខណ្ឌ(ក) ពុំត្រូវបានបកស្រាយដើម្បីតម្រូវឱ្យភាគីសមាជិកបង្កើតនូវអង្គជំនុំជម្រះឬនីតិវិធីទាំងឡាយណា ដែលអសង្គតិភាពនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញឬចរិតលក្ខណៈនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ។

៣- ករណីដែលមានតម្រូវការសេចក្តីអនុញ្ញាតសម្រាប់ការផ្តត់ផ្តង់សេវាកម្ម ដែលការសន្យាជាក់លាក់ត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីសមាជិកនីមួយៗត្រូវ៖

(ក) ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីការសម្រេចពាក់ព័ន្ធនឹងពាក្យស្នើសុំនោះ ក្នុងរយៈពេលសមស្របបន្ទាប់ពីការដាក់ពាក្យស្នើសុំ ដែលចាត់ទុកថាមានភាពពេញលេញក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក

(ខ) បង្ហាញនូវពាល់ព័ត៌មានបន្ថែមទាំងឡាយដែលតម្រូវឱ្យមាន តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំ ដើម្បីបំពេញពាក្យស្នើសុំឱ្យបានពេញលេញនិងផ្តល់នូវឱកាសដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនោះក្នុងអំឡុងពេលសមស្របមួយ ក្នុងករណីពាក្យស្នើសុំពុំមានភាពពេញលេញ

(គ) ផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនៃពាក្យស្នើសុំ ដោយពុំមានការពន្យារពេលមិនសមហេតុផល តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំ

(ឃ) ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំ តាមលទ្ធភាពដែលអាចធ្វើទៅបាន អំពីមូលហេតុនៃការសម្រេចបែបនោះជាលាយលក្ខណ៍អក្សរនិងដោយមិនពន្យារពេល ប្រសិនបើពាក្យស្នើ

សុំត្រូវបានបញ្ឈប់ឬបដិសេធ។ អ្នកដាក់ពាក្យស្នើសុំនឹងមានលទ្ធភាពក្នុងការដាក់ឡើងវិញនូវពាក្យស្នើសុំថ្មី តាមឆន្ទានុសិទ្ធិរបស់ខ្លួន។

៤- ក្នុងទិដ្ឋភាពមួយដើម្បីជានាថារាល់វិធានការទាំងឡាយណាដែលពាក់ព័ន្ធនឹងតម្រូវការនិងនីតិវិធីចំពោះគុណវុឌ្ឍិ លក្ខខណ្ឌតម្រូវនៃស្តង់ដារបច្ចេកទេសនិងការផ្តល់អាជ្ញាបណ្ណ មិនបង្កើតឱ្យមានរបាំងមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម ក្នុងករណីវិស័យដែលការសន្យាជាក់លាក់ត្រូវបានផ្តល់ គូភាគីត្រូវមានបំណងក្នុងការធានាថាលក្ខខណ្ឌតម្រូវទាំងនោះគឺ៖

កាតគីនីមួយៗត្រូវខិតខំធានាថា អ្នកផ្តត់ផ្គង់មេក្នុងដែនដីរបស់ខ្លួនផ្តល់ការចូលទៅកាន់ធាតុផ្សំនៃបណ្តាញក្នុងលក្ខណៈដាច់ដោយឡែកពីគ្នា ដោយមានលក្ខខណ្ឌសមហេតុផល មិនរើសអើង និងមានតម្លាភាពសម្រាប់ការផ្តត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈ។ កាតគីសមាជិកអាចកំណត់ធាតុផ្សំនៃបណ្តាញដែលតម្រូវឱ្យមានក្នុងដែនដីរបស់ខ្លួននិងអ្នកផ្តត់ផ្គង់ដែលអាចទទួលបានធាតុផ្សំទាំងនោះ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។

**មាត្រា១៥ _ ប្រព័ន្ធទូរសព្ទចល័តអន្តរជាតិរ៉ូមីង**

១- តូកាតគីត្រូវខិតខំសហការក្នុងការជំរុញអត្រាតម្លៃដែលមានតម្លាភាពនិងសមហេតុផល សម្រាប់សេវាទូរសព្ទចល័តអន្តរជាតិរ៉ូមីង ដែលអាចជំរុញកំណើនពាណិជ្ជកម្មរវាងតូកាតគីនិងបង្កើនសុខុមាលភាពអតិថិជន។

២- កាតគីសមាជិកអាចអនុវត្តតាមជំហាននីមួយៗ ដើម្បីបង្កើនតម្លាភាពនិងការប្រកួតប្រជែងដែលទាក់ទងនឹងសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង ដូចជា៖

(ក) ជានាថា ព័ត៌មានពាក់ព័ន្ធអត្រាតម្លៃលក់រាយ មានភាពងាយស្រួលក្នុងការទទួលបានសម្រាប់អតិថិជន និង

(ខ) កាត់បន្ថយភាពរាំងស្ទះប្រព័ន្ធរ៉ូមីង ពោលគឺនៅពេលដែលអតិថិជនអាចភ្ជាប់សេវាទូរគមនាគមន៍ដោយប្រើប្រាស់ឧបករណ៍តាមជម្រើសរបស់ខ្លួន នៅពេលធ្វើដំណើរទៅដែនដីរបស់ភាគីសមាជិកពីដែនដីនៃភាគីម្ខាងទៀត។

៣- គូភាគីទទួលស្គាល់ថា ភាគីសមាជិក ក្នុងកម្រិតដែលខ្លួនមានសិទ្ធិ អាចសម្រេចចិត្តលើកកម្ពស់ការប្រកួតប្រជែងទាក់ទងនឹងអត្រាតម្លៃទូរសព្ទចល័តអន្តរជាតិរ៉ូមីង តាមរយៈការរៀបចំពាណិជ្ជកម្ម ឬអនុម័ត ឬរក្សាវិធានការពាក់ព័ន្ធនឹងអត្រាលក់ដុំឬលក់រាយសេវារ៉ូមីងអន្តរជាតិ ក្នុងទស្សនៈមួយដើម្បីជានាថា អត្រាតម្លៃមានភាពសមហេតុផល។ ប្រសិនបើភាគីសមាជិកយល់ឃើញថាសមរម្យ ភាគីនោះអាចសហការនិងអនុវត្តយន្តការនេះជាមួយភាគីម្ខាងទៀត ដើម្បីសម្រួលនូវការអនុវត្តវិធានការទាំងនោះ រាប់បញ្ចូលទាំងការរៀបចំកិច្ចព្រមព្រៀងជាមួយភាគីម្ខាងទៀតនោះ។

៤- ប្រសិនបើភាគីសមាជិក (ពីពេលនេះហៅថា "ភាគីទីមួយ" នៅក្នុងកថាខណ្ឌនេះ) ជ្រើសរើសលើការដាក់បញ្ញត្តិអត្រាតម្លៃឬលក្ខខណ្ឌសម្រាប់ការលក់ដុំឬរាយលើសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង ភាគីនោះត្រូវជានាថាអ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈនៃភាគីម្ខាងទៀត (ពីពេលនេះហៅថា "ភាគីទីពីរ" នៅក្នុងកថាខណ្ឌនេះ) អាចទទួលបានអត្រាតម្លៃឬលក្ខខណ្ឌលក់ដុំឬរាយលើសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង សម្រាប់អតិថិជនរបស់ខ្លួនដែលប្រើសេវារ៉ូមីងនៅក្នុងដែនដីភាគីទីមួយ ប្រសិនបើភាគីទីពីរមានការរៀបចំកិច្ចព្រមព្រៀងជាមួយភាគីទីមួយ ដើម្បីធ្វើបញ្ញត្តិជាលក្ខណៈបដិការនូវអត្រាតម្លៃឬលក្ខខណ្ឌលក់ដុំឬរាយ លើសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង សម្រាប់អ្នកផ្គត់ផ្គង់របស់ភាគីទាំងពីរ។[5] ភាគីទីមួយអាចតម្រូវឱ្យអ្នកផ្គត់ផ្គង់របស់ភាគីទីពីរប្រើប្រាស់កិច្ចចរចាពាណិជ្ជកម្មយ៉ាងពេញលេញ ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងលក្ខខណ្ឌសម្រាប់ទទួលបានអត្រាតម្លៃនិងលក្ខខណ្ឌទាំងនេះ។

៥- ភាគីសមាជិកដែលធានាឱ្យមានបញ្ញត្តិអត្រាតម្លៃ ឬលក្ខខណ្ឌលក់ដុំឬរាយលើសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង ដោយអនុលោមតាមកថាខណ្ឌ៤ ត្រូវបានចាត់ទុកថាស្របតាមមាត្រា១១ និងមាត្រា១២ ចំពោះសេវាទូរសព្ទចល័តអន្តរជាតិរ៉ូមីង។

---

[5] ដើម្បីឱ្យច្បាស់ជាងនេះ៖

(ក) មិនមានភាគីណាមួយ ដោយឈរលើមូលដ្ឋាននៃភាគច្រើនជំពាក់ដោយភាគីទីមួយ ក្រោមបទប្បញ្ញត្តិនៃប្រទេសដែលទទួលបានការអនុគ្រោះបំផុត ឬក្រោមបទប្បញ្ញត្តិស្តីពីការមិនរើសអើងជាក់លាក់នៃទូរគមនាគមន៍នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិណាមួយ អាចស្វែងរកឬទទួលបានសម្រាប់អ្នកផ្គត់ផ្គង់របស់ខ្លួន នូវការដាក់បញ្ញត្តិអត្រាតម្លៃឬលក្ខខណ្ឌលក់ដុំឬរាយលើសេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីង ដែលត្រូវបានកំណត់ក្រោមមាត្រានេះ។

(ខ) ការដាក់បញ្ញត្តិអត្រាតម្លៃឬលក្ខខណ្ឌដែលគ្រប់គ្រងដោយភាគីទីមួយនឹងមានសម្រាប់អ្នកផ្គត់ផ្គង់នៃភាគីទីពីរ លុះត្រាតែការដាក់បញ្ញត្តិអត្រាតម្លៃឬលក្ខខណ្ឌដែលបានកំណត់គឺសមហេតុផល អាចប្រៀបធៀបទៅនឹងការធ្វើនិយតកម្មអត្រាតម្លៃឬលក្ខខណ្ឌដែលគ្រប់គ្រងក្រោមកិច្ចការរៀបចំ។ អង្គភាពនិយតកម្មទូរគមនាគមន៍របស់ភាគីទីមួយ ក្នុងករណីមានការខ្វែងគំនិតគ្នា ត្រូវកំណត់ថាតើអត្រាតម្លៃឬលក្ខខណ្ឌនោះអាចប្រៀបធៀបបានដោយសមហេតុផលឬទេ។ សម្រាប់គោលបំណងនៃលេខយោងនេះ "អត្រាតម្លៃឬលក្ខខណ្ឌដែលអាចប្រៀបធៀបបានដោយសមហេតុផល" សំដៅដល់អត្រាតម្លៃឬលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាដោយអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធ ឬក្នុងករណីមានការខ្វែងគំនិតគ្នា ត្រូវបានកំណត់ដោយអង្គភាពនិយតកម្មទូរគមនាគមន៍នៃភាគីទីមួយ។

៦. មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះ ត្រូវតម្រូវឱ្យភាគីធ្វើបញ្ញត្តិអត្រាតម្លៃឬលក្ខខណ្ឌ សម្រាប់សេវាកម្មទូរសព្ទចល័តអន្តរជាតិរ៉ូមីងទេ។

# ជំពូកទី៩
# ពាណិជ្ជកម្មឌីជីថល

## មាត្រា៩.១ _ និយមន័យ
គោលបំណងនៃជំពូកនេះ៖

**ការកំណត់យថាភូតភាព**(authentication) សំដៅដល់ដំណើរការឬសកម្មភាពនៃការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ភាគីទៅនឹងការប្រាស្រ័យទាក់ទងតាមអេឡិចត្រូនិកឬប្រតិបត្តិការ និងធានានូវភាពត្រឹមត្រូវនៃការប្រាស្រ័យទាក់ទងតាមអេឡិចត្រូនិក។

**កាតព្វកិច្ចពន្ធគយ**(customs duty) សំដៅដល់កាតព្វកិច្ចពន្ធគយ ដូចមានចែងក្នុងជំពូកទី២ (ពាណិជ្ជកម្មទំនិញ)។

**ហត្ថលេខាឌីជីថលឬអេឡិចត្រូនិក**(digital or electronic signature) សំដៅដល់ទិន្នន័យជាទម្រង់ឌីជីថលឬអេឡិចត្រូនិក ដែលមាននៅក្នុង មានការភ្ជាប់ឬមានការចងជាតក្តីផ្នែក ឬជាសម្ងាត់ជាមួយឯកសារឌីជីថលឬអេឡិចត្រូនិក ហើយដែលអាចត្រូវបានប្រើដើម្បីកំណត់ឬផ្ទៀងផ្ទាត់ភាគីហត្ថលេខីទាក់ទងនឹងឯកសារឌីជីថលឬអេឡិចត្រូនិក និងអាចបង្ហាញពីការយល់ព្រមពីភាគីហត្ថលេខីនៃព័ត៌មានដែលមាននៅក្នុងឯកសារឌីជីថលឬអេឡិចត្រូនិក។

**ការផ្ទេរតាមរយៈឌីជីថលឬអេឡិចត្រូនិក ឬផ្ទេរដោយឌីជីថលឬអេឡិចត្រូនិក** (digital or electronic transmission or transmitted digitally or electronically) សំដៅដល់ការបញ្ជូនដែលធ្វើឡើងដោយប្រើមធ្យោបាយអេឡិចត្រូម៉ាញ៉េទិក រួមទាំងដោយមធ្យោបាយហ្វូតុង(photonic) ផងដែរ។

**ទិន្នន័យបើកចំហ**(open data) សំដៅដល់ព័ត៌មានដែលមិនមែនជាកម្មវត្ថុនៃការរក្សាសិទ្ធិបែបពាណិជ្ជកម្ម រួមទាំងទិន្នន័យដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយសេរីដល់សាធារណៈ ដោយរដ្ឋាភិបាលថ្នាក់កណ្តាលនៃរដ្ឋាភិបាល។

**ទិន្នន័យបុគ្គល**(personal data) សំដៅដល់រាល់ព័ត៌មាន ដោយរួមទាំងទិន្នន័យដែលកំណត់អត្តសញ្ញាណរូបវន្តបុគ្គលឬព័ត៌មាន ដែលទោះបីជាមិនអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលជាក់លាក់ក៏ដោយ ប៉ុន្តែអាចត្រូវបានរួមបញ្ចូលគ្នាយ៉ាងងាយស្រួលជាមួយនឹងព័ត៌មានផ្សេងទៀត ដើម្បីកំណត់អត្តសញ្ញាណរូបវន្តបុគ្គលជាក់លាក់ណាមួយបាន[1]។

**ឯកសាររដ្ឋបាលពាណិជ្ជកម្ម**(trade administration documents) សំដៅដល់ឯកសារបែបបទដែលត្រូវបានចេញឬគ្រប់គ្រងដោយភាគីមួយ ដែលត្រូវបំពេញដោយអ្នកនាំចេញ នាំចូល ឬសម្រាប់អ្នកនាំចេញ នាំចូលដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូលទំនិញទៀត

[1] និយមន័យនេះគឺអនុលោមតាមច្បាប់និងបទបញ្ញត្តិរបស់ភាគីពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល។

**សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ**(unsolicited commercial electronic message) សំដៅដល់សារអេឡិចត្រូនិកដែលត្រូវបានធ្វើសម្រាប់គោលបំណងពាណិជ្ជកម្មឬទីផ្សារទៅកាន់អាសយដ្ឋានអេឡិចត្រូនិក ដោយគ្មានការយល់ព្រមពីអ្នកទទួលឬទោះបីជាមានការបដិសេធយ៉ាងច្បាស់លាស់ពីអ្នកទទួល តាមរយៈការចូលប្រើអ៊ីនធឺណិតឬអ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍[2]

## មាត្រា៩.២ _ គោលបំណង

១- គូភាគីទទួលស្គាល់កំណើនសេដ្ឋកិច្ចនិងកាលានុវត្តភាពដែលផ្តល់ឱ្យតាមរយៈពាណិជ្ជកម្មឌីជីថល សារៈសំខាន់នៃការចៀសវាងឧបសគ្គ ចំពោះការប្រើប្រាស់និងការអភិវឌ្ឍនៃពាណិជ្ជកម្មឌីជីថល និងសារៈសំខាន់នៃក្របខ័ណ្ឌគតិយុត្ត ដែលលើកកម្ពស់ទំនុកចិត្តអ្នកប្រើប្រាស់ក្នុងពាណិជ្ជកម្មឌីជីថល ហើយគូភាគីបញ្ជាក់ពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោមWTO។

២- គូភាគីព្យាយាមជំរុញបរិយាកាសអំណោយផល ដល់ភាពរីកចម្រើនបន្ថែមទៀតនៃពាណិជ្ជកម្មឌីជីថល រួមទាំងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចពិភពលោក តាមរយៈការពង្រឹងទំនាក់ទំនងទ្វេភាគី។

## មាត្រា៩.៣ _ បទប្បញ្ញត្តិទូទៅ

១- ជំពូកនេះត្រូវអនុវត្តចំពោះរាល់វិធានការដែលត្រូវបានអនុវត្តឬរក្សា ដោយភាគីសមាជិកដែលប៉ះពាល់ពាណិជ្ជកម្មដោយមធ្យោបាយអេឡិចត្រូនិក។

២- ជំពូកនេះមិនត្រូវអនុវត្តចំពោះ៖

(ក) លទ្ធកម្មសាធារណៈ ឬ

(ខ) ព័ត៌មានដែលកាន់កាប់ឬប្រើប្រាស់ដោយ ឬក្នុងនាមភាគីសមាជិក ឬវិធានការពាក់ព័ន្ធនឹងព័ត៌មាននោះ រាប់បញ្ចូលទាំងវិធានការដែលទាក់ទងនឹងការប្រមូលព័ត៌មាននោះផងដែរ។

៣- ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ គូភាគីបានបញ្ជាក់ថា វិធានការដែលប៉ះពាល់ដល់សេវាកម្មឬទំនិញដែលត្រូវបានផ្តល់ឬផ្គត់ផ្គង់តាមមធ្យោបាយអេឡិចត្រូនិក ត្រូវអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងជំពូកទី២(ពាណិជ្ជកម្មទំនិញ)ជំពូកទី៨ (ពាណិជ្ជកម្មសេវាកម្ម) និងជំពូកទី១០ (វិនិយោគ) រាប់បញ្ចូលរាល់ទាំងឧបសម្ព័ន្ធ ការលើកលែង ឬការជាក់កម្រិតដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះដែលអនុវត្តបានចំពោះបទប្បញ្ញត្តិទាំងនោះ។

៤- ពុំមានភាគីណាមួយមានសិទ្ធិប្តឹងឱ្យមានការដោះស្រាយវិវាទនៅក្រោមជំពូកទី១៨(ការដោះស្រាយវិវាទ) ចំពោះបញ្ហាណាមួយដែលកើតឡើងក្រោមជំពូកនេះឡើយ។

---

[2] និយមន័យនេះគឺអនុលោមតាមច្បាប់និងបទបញ្ញត្តិរបស់គូភាគី។ ភាគីសមាជិកអាចអនុវត្តនិយមន័យលើសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំដែលបានបញ្ជូនតាមរយៈមធ្យោបាយមួយឬច្រើន រួមមានសេវាសារខ្លី(SMS) ឬអ៊ីមែល។ ទោះបីមានការចែងដូចក្នុងលេខយោងនេះ គូភាគីត្រូវខិតខំប្រឹងប្រែងអនុវត្តឬរក្សាវិធានការឱ្យមានសង្គតិភាពនឹងមាត្រា៩.១០ ដែលកំណត់ដើម្បីស្រួលបញ្ជូនសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ។

## មាត្រា៩.៤ _ ពន្ធគយ

១- ភាគីនីមួយៗ ត្រូវប្រកាន់ខ្ជាប់ការអនុវត្តនាពេលបច្ចុប្បន្នចំពោះការមិនដាក់ពន្ធគយលើការបញ្ជូនតាមប្រព័ន្ធនីជីថលឬអេឡិចត្រូនិក រវាងបុគ្គលនៃភាគីមួយនិងបុគ្គលនៃភាគីមួយទៀត។

២- ការអនុវត្តយោងលើកថាខណ្ឌ១គឺអនុលោមតាមសេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីនៃអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ទាក់ទងទៅនឹងកម្មវិធីការងារស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក WT/MIN(22)/32។

៣- ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ កថាខណ្ឌ១មិនត្រូវពាក់ព័ន្ធភាគីសមាជិកពីការដាក់អាករ កម្រៃ ឬបន្ទុកនានាលើមាតិកាដែលបានបញ្ជូនតាមប្រព័ន្ធនីជីថលឬអេឡិចត្រូនិក ក្នុងលក្ខខណ្ឌដែលការដាក់អាករ កម្រៃ ឬបន្ទុកនោះត្រូវបានធ្វើឡើងស្របតាមកិច្ចព្រមព្រៀងនេះ។

៤- ភាគីនីមួយៗអាចកែសម្រួលការអនុវត្តរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌ១និង៣ ស្របតាមលទ្ធផលបន្តបន្ទាប់ណាមួយ នៅក្នុងសេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីនៃអង្គការពាណិជ្ជកម្មពិភពលោកស្តីពីពន្ធគយលើការបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកក្នុងក្របខ័ណ្ឌនៃកម្មវិធីការងារស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## មាត្រា៩.៥ _ ក្របខ័ណ្ឌប្រតិបត្តិការអេឡិចត្រូនិកក្នុងស្រុក

១- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងរៀបចំឬរក្សាក្របខ័ណ្ឌគតិយុត្ត ដែលគ្រប់គ្រងលើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក ដោយពិចារណាលើច្បាប់គំរូ UNCITRAL ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១៩៩៦) ឬអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងកិច្ចសន្យាអន្តរជាតិ ដែលបានបង្កើតឡើងនៅទីក្រុងញូវយ៉ក កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥។

២- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែង៖

(ក) ចៀសវាងនូវបទប្បញ្ញត្តិមិនចាំបាច់ ដែលជាបន្ទុកលើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក និង

(ខ) សម្រួលដល់ការផ្តល់ជាតុចូលពីតួអង្គពាក់ព័ន្ធ ក្នុងការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តសម្រាប់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួន រួមបញ្ចូលទាំងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការរៀបចំឯកសារពាណិជ្ជកម្ម។

## មាត្រា៩.៦ _ ការកំណត់យថាភូតភាព

១- លើកលែងតែក្នុងកាល:ទេស:ដែលច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនមានចែងផ្សេងពីនេះ ភាគីសមាជិកមិនត្រូវបដិសេធសុពលភាពគតិយុត្តនៃហត្ថលេខា ដោយគ្រាន់តែឈរលើមូលដ្ឋានថាហត្ថលេខានោះស្ថិតក្នុងទម្រង់នីជីថលឬអេឡិចត្រូនិកឡើយ។[3]

២- ដោយមានការពិចារណាលើបទដ្ឋានអន្តរជាតិលើការកំណត់យថាភូតភាពអេឡិចត្រូនិក ភាគីនីមួយៗត្រូវ៖

[3] កម្ពុជាមិនត្រូវមានកាតព្វកិច្ចអនុវត្តកថាខណ្ឌនេះក្នុងរយៈពេលប៥(ប្រាំ)ឆ្នាំ ក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

(ក) អនុញ្ញាតឱ្យអ្នកចូលរួមក្នុងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក អាចកំណត់បច្ចេកវិទ្យា និងគំរូអនុវត្តសម្រាប់ការកំណត់យថាភូតភាពអេឡិចត្រូនិក ដែលសមស្របសម្រាប់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិករបស់អ្នកចូលរួមក្នុងប្រតិបត្តិការនោះ

(ខ) មិនដាក់កម្រិតការទទួលស្គាល់បច្ចេកវិទ្យា និងគំរូអនុវត្តសម្រាប់ការកំណត់យថាភូតភាពសម្រាប់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក និង

(គ) អនុញ្ញាតឱ្យអ្នកចូលរួមក្នុងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក មានឱកាសបង្ហាញថាប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួន អនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់យថាភូតភាពអេឡិចត្រូនិក។

៣- បើទោះបីជាមានចែងក្នុងកថាខណ្ឌ២ខាងលើក៏ដោយ ចំពោះប្រភេទប្រតិបត្តិការជាក់លាក់មួយ ភាគីសមាជិកអាចតម្រូវចំពោះវិធីសាស្ត្រក្នុងការកំណត់យថាភូតភាព ដែលត្រូវឆ្លើយតបទៅនឹងស្តង់ដាអនុវត្តជាក់លាក់ឬត្រូវមានការបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់និងបទប្បញ្ញត្តិនៃភាគីនោះ។

៤- គូភាគីត្រូវលើកទឹកចិត្តដល់ការប្រើប្រាស់មធ្យោបាយអន្តរប្រតិបត្តិការ សម្រាប់ការកំណត់យថាភូតភាព។

## មាត្រា៩.៧ _ ការធ្វើពាណិជ្ជកម្មដោយមិនប្រើក្រដាស

ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែង៖

(ក) ធ្វើឱ្យឯកសារដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មអាចរកបានជាសាធារណៈទាំងក្នុងទម្រង់ទិដ្ឋភាព ឬទម្រង់អេឡិចត្រូនិក និង

(ខ) ទទួលយកឯកសារដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលបានដាក់ជូនជាទម្រង់អេឡិចត្រូនិក ឱ្យសមមូលតាមផ្លូវច្បាប់ជាមួយនឹងទម្រង់ឯកសារដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មជាទម្រង់ក្រដាសដែរ។

## មាត្រា៩.៨ _ កិច្ចការពារអ្នកប្រើប្រាស់តាមអនឡាញ

១- គូភាគីទទួលស្គាល់សារៈសំខាន់នៃការអនុម័តនិងការរក្សាវិធានការ ដែលមានតម្លាភាពនិងប្រសិទ្ធភាព ដើម្បីការពារអ្នកប្រើប្រាស់ពីការអនុវត្តពាណិជ្ជកម្មដែលក្លែងបន្លំ ឆបោក និងបំភ័ន្ត នៅពេលខ្លួនចូលរួមក្នុងពាណិជ្ជកម្មទិដ្ឋភាព។

២- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងរៀបចំឬរក្សាច្បាប់ការពារអ្នកប្រើប្រាស់ ដើម្បីហាមឃាត់សកម្មភាពពាណិជ្ជកម្មដែលក្លែងបន្លំ ឆបោក និងបំភ័ន្ត ដែលបង្កឬអាចបង្កឱ្យមានការខូចខាតដល់អ្នកប្រើប្រាស់ដែលបានចូលរួមក្នុងពាណិជ្ជកម្មទិដ្ឋភាព។[4]

---

[4] ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ ភាគីសមាជិកអាចអនុវត្តស្របតាមកាតព្វកិច្ចក្នុងកថាខណ្ឌនេះ តាមរយៈការរៀបចំឬរក្សានូវវិធានការដូចជាច្បាប់ឬបទប្បញ្ញត្តិការពារអ្នកប្រើប្រាស់ដែលអាចអនុវត្តជាទូទៅបាន ឬច្បាប់ឬបទប្បញ្ញត្តិតាមវិស័យឬជាក់លាក់មួយ ដែលពាក់ព័ន្ធនឹងការការពារអ្នកប្រើប្រាស់។

**មាត្រា៩.៩ _ កិច្ចការពារទិន្នន័យបុគ្គល**

១- គូភាគីទទួលស្គាល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនិងសង្គម នៃកិច្ចការពារទិន្នន័យបុគ្គលរបស់បុគ្គលដែលបង្កើតឬចូលរួមក្នុងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក និងការរួមចំណែកនៃកិច្ចការពារទិន្នន័យបុគ្គលក្នុងការបង្កើនទំនុកចិត្តអ្នកប្រើប្រាស់ក្នុងពាណិជ្ជកម្មឌីជីថល។

២- ក្នុងន័យនេះ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងរៀបចំឬរក្សាក្របខ័ណ្ឌគតិយុត្ត ដែលផ្តល់កិច្ចការពារទិន្នន័យបុគ្គលរបស់អ្នកប្រើប្រាស់ពាណិជ្ជកម្មឌីជីថល។[5] ក្នុងការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តទាំងឡាយសម្រាប់កិច្ចការពារទិន្នន័យបុគ្គល ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងពិចារណាទៅលើគោលការណ៍និងសេចក្តីណែនាំនានារបស់អង្គការអន្តរជាតិពាក់ព័ន្ធ។

**មាត្រា៩.១០ _ គោលការណ៍ចូលប្រើប្រាស់ និងការប្រើប្រាស់អ៊ីនធឺណិតសម្រាប់ពាណិជ្ជកម្មឌីជីថល**

ដើម្បីគាំទ្រដល់ការអភិវឌ្ឍនិងការកែចម្រើននៃពាណិជ្ជកម្មឌីជីថល ភាគីនីមួយៗទទួលស្គាល់ថាអ្នកប្រើប្រាស់នៅក្នុងដែនដីរបស់ខ្លួនគួរតែអាច៖

(ក) ចូលនិងប្រើប្រាស់សេវាកម្មនិងកម្មវិធីដែលជាជម្រើសរបស់អ្នកប្រើប្រាស់ លើកលែងតែមានការហាមឃាត់ដោយច្បាប់និងបទប្បញ្ញត្តិរបស់ភាគីសមាជិក។

(ខ) ដំណើរការសេវាកម្មនិងកម្មវិធីដែលជាជម្រើសរបស់អ្នកប្រើប្រាស់ ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីសមាជិក រួមទាំងតម្រូវការនៃសកម្មភាពអនុវត្តច្បាប់និងបទប្បញ្ញត្តិ និង

(គ) ភ្ជាប់ឧបករណ៍ដែលជាជម្រើសរបស់អ្នកប្រើប្រាស់ទៅអ៊ីនធឺណិត ឱ្យតែឧបករណ៍ទាំងនោះមិនបង្កឱ្យមានការខូចខាតដល់បណ្តាញ និងមិនត្រូវបានហាមឃាត់ដោយច្បាប់និងបទប្បញ្ញត្តិរបស់ភាគីសមាជិក។

**មាត្រា៩.១១ _ សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ**

១- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងរៀបចំឬរក្សាវិធានការ ទាក់ទងនឹងសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំដែលផ្ញើទៅកាន់អាសយដ្ឋានសារអេឡិចត្រូនិក ដោយ៖

(ក) តម្រូវឱ្យអ្នកផ្ញើសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំផ្តល់លទ្ធភាពឱ្យអ្នកទទួលឈប់ពីការបន្តការទទួលសារទាំងនោះ

(ខ) តម្រូវឱ្យមានការយល់ព្រមពីអ្នកទទួល ក្នុងការទទួលសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចដែលបានកំណត់នៅក្នុងច្បាប់និងបទប្បញ្ញត្តិនៃភាគីនីមួយៗ ឬ

(គ) ធ្វើឱ្យការផ្ញើសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ មានចំនួនអប្បបរមា។

---

[5] ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ៖ ភាគីសមាជិកអាចអនុវត្តស្របតាមកាតព្វកិច្ចក្នុងកថាខណ្ឌនេះ តាមរយៈការរៀបចំឬរក្សានូវវិធានការដូចជាច្បាប់ស្តីពីឯកជនភាពទូលំទូលាយ ច្បាប់ស្តីពីព័ត៌មានផ្ទាល់ខ្លួនឬកិច្ចការពារទិន្នន័យបុគ្គល ច្បាប់ពិសេសតាមវិស័យដែលគ្របដណ្តប់លើឯកជនភាព ឬច្បាប់ដែលផ្តល់ដល់សហគ្រាស សម្រាប់ការអនុវត្តដោយស្ម័គ្រចិត្តពាក់ព័ន្ធនឹងឯកជនភាព។

២- ភាគីនីមួយៗត្រូវខិតខំអនុញ្ញាតឱ្យមានលទ្ធភាព ក្នុងការប្តឹងតវ៉ាទៅអ្នកផ្តើសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំដែលមិនអនុលោមតាមវិធានការ ដែលបានរៀបចំឬក្សាដូចមានចែងក្នុងកថាខណ្ឌ១។

៣- គូភាគីត្រូវខិតខំប្រឹងប្រែងសហការឱ្យបានសមស្របទាំងសងខាង ទាក់ទងនឹងបទប្បញ្ញត្តិស្តីពីសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ។

**មាត្រា៩.១២ _ រំហូរព័ត៌មានឆ្លងកាត់ព្រំដែន**

១- ដោយទទួលស្គាល់សារៈសំខាន់នៃរំហូរព័ត៌មានដោយសេរីក្នុងការសម្រួលពាណិជ្ជកម្ម និងដោយទទួលស្គាល់សារៈសំខាន់នៃកិច្ចការពារទិន្នន័យបុគ្គល គូភាគីត្រូវខិតខំប្រឹងប្រែងចៀសវាងពីការដាក់ឬក្សានូវរបាំងដែលមិនចាំបាច់ ចំពោះរំហូរព័ត៌មានអេឡិចត្រូនិកឆ្លងកាត់ព្រំដែន។

២- គូភាគីទទួលស្គាល់ថា ភាគីនីមួយៗអាចមានតម្រូវការច្បាប់និងបទប្បញ្ញត្តិរៀងខ្លួន ទាក់ទងនឹងការបញ្ជូនព័ត៌មានតាមមធ្យោបាយអេឡិចត្រូនិក។ ភាគីសមាជិកមិនត្រូវបានរារាំងពីការអនុវត្តឬការរក្សារាល់វិធានការនានា ដែលខ្លួនគិតថាចាំបាច់ដើម្បីសម្រេចគោលបំណងគោលនយោបាយសាធារណៈស្របច្បាប់[6] ឬសម្រាប់ការការពារផលប្រយោជន៍សន្តិសុខដាចាំបាច់។ វិធានការទាំងនេះមិនត្រូវមានការជំទាស់ពីភាគីម្ខាងទៀតឡើយ។

**មាត្រា៩.១៣ _ ទិន្នន័យបើកចំហ**

១- គូភាគីទទួលស្គាល់ថា ការសម្រួលដល់សាធារណជនក្នុងការចូលនិងប្រើប្រាស់ទិន្នន័យបើកចំហរួមចំណែកដល់ការជំរុញផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម ការប្រកួតប្រជែង ការកែលម្អផលិតភាពនិងនវានុវត្តន៍។ នៅពេលដែលភាគីសមាជិកជ្រើសរើសផ្តល់ទិន្នន័យបើកចំហដែលអាចរកបាន ភាគីសមាជិកនោះត្រូវខិតខំទៅតាមអ្វីដែលអាចអនុវត្តបាននិងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ជានាថា៖

(ក) ព័ត៌មានទាំងនោះមានលក្ខណៈអនាមិកដោយសមស្រប មានទិន្នន័យមេតាដាក់លាក់ និងតាមលក្ខណៈបច្ចេកទេសដែលអាចធ្វើបាន ស្ថិតក្នុងទម្រង់ដែលអាចអានបានដោយម៉ាស៊ីន និងមានទម្រង់បើកចំហដែលអនុញ្ញាតឱ្យសាធារណជនស្វែងរក ទាញយក ប្រើប្រាស់ ប្រើប្រាស់ឡើងវិញ និងចែកចាយឡើងវិញបានដោយសេរីនូវព័ត៌មានទាំងនោះ និង

(ខ) ព័ត៌មានទាំងនោះត្រូវបានបង្កើតឡើងក្នុងទម្រង់លម្អ ដែលអាចទុកចិត្តបាន ងាយស្រួលប្រើនិងអាចប្រើបានដោយសេរីនៃសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ(APIs) ហើយព័ត៌មានទាំងនោះត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ។

២- គូភាគីត្រូវខិតខំសហការ ដើម្បីស្វែងរកនូវវិធីដែលភាគីនីមួយៗអាចពង្រីកការចូលនិងប្រើប្រាស់ទិន្នន័យបើកចំហ ក្នុងគោលបំណងដើម្បីជំរុញនិងបង្កើតឱកាសអាជីវកម្មនិងការស្រាវជ្រាវ ស្របតាមច្បាប់និងបទប្បញ្ញត្តិរៀងៗខ្លួន។

---

[6] សម្រាប់គោលបំណងកថាខណ្ឌនេះ គូភាគីបញ្ជាក់ថា ភាពចាំបាច់ពីក្រោយការអនុវត្តនៃគោលនយោបាយសាធារណៈស្របច្បាប់នេះ ត្រូវធ្វើការសម្រេចដោយភាគីសមាជិកអនុវត្ត។

## មាត្រា៩.១៤ _ ដ្ឋាភិបាលឌីជីថល

១- គូភាគីទទួលស្គាល់ថា បច្ចេកវិទ្យាអាចធ្វើឱ្យប្រតិបត្តិការរបស់រដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព និងកាន់តែរហ័ស អាចធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងភាពជឿជាក់លើសេវាកម្មរបស់រដ្ឋាភិបាល និងអាចធ្វើឱ្យរដ្ឋាភិបាលបម្រើឱ្យកាន់តែប្រសើរឡើង នូវតម្រូវការរបស់ប្រជាពលរដ្ឋនិងបុគ្គលពាក់ព័ន្ធផ្សេងទៀត។

២- ក្នុងន័យនេះ គូភាគីត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រ ដើម្បីធ្វើបរិវត្តកម្មឌីជីថលនូវប្រតិបត្តិការនិងសេវាកម្មរបស់រដ្ឋាភិបាលរៀងៗខ្លួន ដែលអាចមានដូចជា៖

(ក) ការអនុវត្តដំណើរការរដ្ឋាភិបាលប្រកបដោយភាពបើកចំហនិងបរិយាប័ន្ន ដោយផ្តោតលើភាពងាយប្រាស្រ័យ តម្លាភាពនិងគណនេយ្យភាព ក្នុងរបៀបមួយដែលយកឈ្នះលើគម្លាតឌីជីថល

(ខ) ការលើកកម្ពស់ការសម្របសម្រួលនិងកិច្চសហការឆ្លងវិស័យនិងអន្តរដ្ឋាភិបាល លើបញ្ហាទាក់ទងនឹងរបៀបវារៈឌីជីថល

(គ) ការរៀបចំដំណើរការ សេវាកម្ម និងគោលនយោបាយរបស់រដ្ឋាភិបាល ដោយត្រូវគិតរាប់បញ្ចូលបរិយាប័ន្នឌីជីថល

(ឃ) ការលើកកម្ពស់ថ្នាលឌីជីថលនិងការជំរុញការអនុវត្តឌីជីថលរួម សម្រាប់ជួយដល់ការផ្តល់សេវារដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព

(ង) ការប្រើប្រាស់បច្ចេកវិទ្យាឈានមុខចុងក្រោយ ដើម្បីកសាងសមត្ថភាពក្នុងការប៉ាន់ស្មានទុកជាមុននូវគ្រោះមហន្តរាយនិងវិបត្តិនានា និងសម្របសម្រួលដល់ការឆ្លើយតបយ៉ាងសកម្ម

(ច) ការបង្កើតតម្លៃជាសាធារណៈពីទិន្នន័យរបស់រដ្ឋាភិបាល បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាឈានមុខចុងក្រោយ ដោយដាក់បញ្ចូលទៅក្នុងការរៀបចំផែនការ ការផ្តល់ និងការត្រួតពិនិត្យនៃគោលនយោបាយសាធារណៈ និងការអនុវត្តវិធាននិងគោលការណ៍សីលធម៌សម្រាប់ការប្រើប្រាស់ទិន្នន័យនិងបច្ចេកវិទ្យាប្រកបដោយភាពទុកចិត្ត ទំនួលខុសត្រូវ និងសុវត្ថិភាព

(ឆ) ការធ្វើឱ្យទិន្នន័យបើកចំហនិងដំណើរការក្នុងការបង្កើតគោលនយោបាយ (រួមទាំងអាល់ហ្គោរីត(algorithms)) អាចផ្តល់ឱ្យសាធារណជនក្នុងការចូលរួម អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីរៀងៗខ្លួន និង

(ជ) ការលើកកម្ពស់គំនិតផ្តួចផ្តើមដើម្បីបង្កើនកម្រិតសមត្ថភាព និងជំនាញឌីជីថលរបស់ប្រជាពលរដ្ឋនិងមន្ត្រីរដ្ឋាភិបាល។

៣. ដោយទទួលស្គាល់ថា គូភាគីអាចទទួលបានអត្ថប្រយោជន៍ តាមរយៈការចែករំលែកបទពិសោធរបស់ខ្លួនជាមួយគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលឌីជីថល គូភាគីត្រូវខិតខំប្រឹងប្រែងសហការលើសកម្មភាពទាក់ទងនឹងបរិវត្តកម្មឌីជីថលនៃរដ្ឋាភិបាលនិងសេវាកម្មរដ្ឋាភិបាល ដែលអាចរួមមាន៖

(ក) ការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធលើយុទ្ធសាស្ត្រនិងគោលនយោបាយរដ្ឋាភិបាលឌីជីថល

(ខ) ការចែករំលែកឧត្តមានុវត្តន៍លើរដ្ឋាភិបាលទីជីថល និងការផ្តល់តាមបែបទីជីថលនូវសេវារដ្ឋាភិបាល និង

(គ) ការផ្តល់ប្រឹក្សាឬការបណ្តុះបណ្តាល រួមទាំងតាមរយៈការផ្លាស់ប្តូរមន្ត្រីនិងអ្នកជំនាញបច្ចេកទេស ដើម្បីជួយភាគីម្ខាងទៀតក្នុងការកសាងសមត្ថភាពរដ្ឋាភិបាលទីជីថល។

## មាត្រា៩.១៥ _ ចិក្ខុយបត្រឌីជីថលនិងអេឡិចត្រូនិក

១- គូភាគីទទួលស្គាល់សារៈសំខាន់នៃក្តៃយបត្រទីជីថលនិងអេឡិចត្រូនិក ដើម្បីបង្កើនប្រសិទ្ធភាព ភាពត្រឹមត្រូវ និងភាពជឿទុកចិត្តនៃប្រតិបត្តិការ។

២- គូភាគីទទួលស្គាល់អត្ថប្រយោជន៍នៃប្រព័ន្ធក្តៃយបត្រទីជីថលនិងអេឡិចត្រូនិក ដែលអាចធ្វើអន្តរប្រតិបត្តិការបាន។ នៅពេលបង្កើតវិធានការទាក់ទងនឹងក្តៃយបត្រទីជីថលនិងអេឡិចត្រូនិក ភាគីសមាជិកត្រូវខិតខំប្រឹងប្រែងគិតគូរពើស្តង់ដាអន្តរជាតិ តាមដែលអាចធ្វើទៅបាន និងអនុលោមតាមការត្រៀមខ្លួនរបស់ខ្លួនទាក់ទងនឹងសមត្ថភាព បទប្បញ្ញត្តិ និងហេដ្ឋារចនាសម្ព័ន្ធ។

៣- គូភាគីយល់ព្រមសម្របសម្រួលនិងសហការលើគំនិតផ្តួចផ្តើមដែលលើកកម្ពស់ លើកទឹកចិត្ត គាំទ្រ ឬសម្រួលការអនុវត្តក្តៃយបត្រទីជីថលនិងអេឡិចត្រូនិក។

## មាត្រា៩.១៦ _ ការឆ្លងកាត់ឌីជីថលនិងអេឡិចត្រូនិក

១- ដោយទទួលស្គាល់ការរីកចម្រើនយ៉ាងឆាប់រហ័សនៃការទូទាត់តាមប្រព័ន្ធទីជីថលនិងអេឡិចត្រូនិក ជាពិសេសតាមរយៈស្ថាប័នធនាគារនិងហិរញ្ញវត្ថុ ស្ថាប័នមិនមែនធនាគារនិងមិនមែនហិរញ្ញវត្ថុ គូភាគីត្រូវខិតខំប្រឹងប្រែង គាំទ្រដល់ការអភិវឌ្ឍនៃការទូទាត់ទីជីថលនិងអេឡិចត្រូនិកឆ្លងកាត់ព្រំដែនដែលមានប្រសិទ្ធភាព សុវត្ថិភាព និងសន្តិសុខ ដោយ៖

(ក) ជំរុញការអនុវត្តនិងការប្រើប្រាស់ស្តង់ដាដែលទទួលយកជាអន្តរជាតិ សម្រាប់ការទូទាត់ទីជីថលនិងអេឡិចត្រូនិក

(ខ) លើកកម្ពស់អន្តរប្រតិបត្តិការនិងការផ្សារភ្ជាប់គ្នានៃហេដ្ឋារចនាសម្ព័ន្ធការទូទាត់ទីជីថលនិងអេឡិចត្រូនិក និង

(គ) លើកទឹកចិត្តឱ្យមាននវានុវត្តន៍និងការប្រកួតប្រជែងក្នុងសេវាកម្មទូទាត់តាមទីជីថលនិងអេឡិចត្រូនិក។

២- ក្នុងន័យនេះ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែង ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនដើម្បី៖

(ក) ធ្វើឱ្យច្បាប់និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅ ទាក់ទងនឹងការទូទាត់តាមទីជីថលនិងអេឡិចត្រូនិក មានជាសាធារណៈ រួមទាំងច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការអនុញ្ញាតនិយតកម្ម តម្រូវការអាជ្ញាបណ្ណ នីតិវិធី និងស្តង់ដាបច្ចេកទេស

(ខ) ធ្វើការសម្រេចចិត្តលើការអនុញ្ញាតនិយតកម្មឬអាជ្ញាបណ្ណ ទាក់ទងនឹងការទូទាត់ទីជីថលនិងអេឡិចត្រូនិក ឱ្យបានទាន់ពេលវេលា

(គ) មិនរើសអើងតាមអំពើចិត្តនិងដោយអយុត្តិធម៌ រវាងស្ថាប័នធនាគារ និងហិរញ្ញវត្ថុនិងស្ថាប័នមិនមែនធនាគារនិងមិនមែនហិរញ្ញវត្ថុ ទាក់ទងនឹងការទទួលបានសេវានិងហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់ឥដ្ឋិជីថលនិងអេឡិចត្រូនិក

(ឃ) អនុវត្តឬប្រើប្រាស់ស្តង់ដាអន្តរជាតិសម្រាប់ការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិករវាងស្ថាប័នហិរញ្ញវត្ថុនិងអ្នកផ្តត់ផ្គង់សេវាកម្ម ដើម្បីអនុញ្ញាតឱ្យមានអន្តរប្រតិបត្តិការកាន់តែរឹងមាំរវាងប្រព័ន្ធទូទាត់ឥដ្ឋិជីថលនិងអេឡិចត្រូនិក

(ង) ជួយសម្រួលដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងលើកទឹកចិត្តដល់ស្ថាប័នធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នមិនមែនធនាគារនិងមិនមែនហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យផលិតផលនិងសេវាកម្មរបស់ពួកគេអាចប្រើប្រាស់ដល់ភាគីទីបីប្រកបដោយសុវត្ថិភាពនិងសន្តិសុខតាមដែលអាចធ្វើទៅបាន ដើម្បីជួយសម្រួលដល់អន្តរប្រតិបត្តិការ នវានុវត្តន៍និងការប្រកួតប្រជែងកាន់តែខ្លាំង នៅក្នុងការទូទាត់អេឡិចត្រូនិក និង

(ច) ជួយសម្រួលដល់នវានុវត្តន៍និងការប្រកួតប្រជែង និងការជាក់ឱ្យប្រើប្រាស់ផលិតផលនិងសេវាកម្មទូទាត់ហិរញ្ញវត្ថុនិងអេឡិចត្រូនិកថ្មីៗឱ្យបានទាន់ពេលវេលា។

**មាត្រា៩.១៧ _ អត្តសញ្ញាណឥដ្ឋិជីថល**

ដោយទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការរវាងគូភាគីលើអត្តសញ្ញាណឥដ្ឋិជីថលសម្រាប់រូបវន្តបុគ្គលនិងសហគ្រាសនឹងជំរុញការតភ្ជាប់និងការកែចម្រើនបន្ថែមទៀតនៃពាណិជ្ជកម្មឥដ្ឋិជីថល ហើយដោយទទួលស្គាល់ថាភាគីនីមួយៗអាចប្រើវិធីសាស្ត្រតាមផ្លូវច្បាប់និងបច្ចេកទេសផ្សេងៗគ្នាចំពោះអត្តសញ្ញាណឥដ្ឋិជីថល គូភាគីត្រូវខិតខំបន្តយន្តការដើម្បីលើកកម្ពស់ភាពត្រូវគ្នាលើរបបអត្តសញ្ញាណឥដ្ឋិជីថលរៀងៗខ្លួន។ កិច្ចសហប្រតិបត្តិការនេះអាចរួមបញ្ចូល៖

(ក) ការបង្កើតក្របខ័ណ្ឌសមស្របនិងស្តង់ដារួម ដើម្បីជំរុញអន្តរប្រតិបត្តិការបច្ចេកទេសរវាងការអនុវត្តអត្តសញ្ញាណឥដ្ឋិជីថលរបស់ភាគីនីមួយៗ

(ខ) ការអភិវឌ្ឍកិច្ចការពារអត្តសញ្ញាណឥដ្ឋិជីថលដែលប្រហាក់ប្រហែលគ្នា ក្រោមក្របខ័ណ្ឌច្បាប់រៀងៗខ្លួនរបស់ភាគីនីមួយៗ ឬការទទួលស្គាល់ឥទ្ធិពលផ្លូវច្បាប់របស់ខ្លួន ទោះត្រូវបានអនុម័តដោយស្វ័យភាពឬដោយកិច្ចព្រមព្រៀង

(គ) ការគាំទ្រដល់ការអភិវឌ្ឍក្របខ័ណ្ឌអន្តរជាតិស្តីពីរបបអត្តសញ្ញាណឥដ្ឋិជីថល និង

(ឃ) ការផ្លាស់ប្តូរចំណេះដឹងនិងជំនាញលើឧត្តមានុវត្តន៍ទាក់ទងនឹងគោលនយោបាយ និងបទប្បញ្ញត្តិអត្តសញ្ញាណឥដ្ឋិជីថល ការអនុវត្តបច្ចេកទេសនិងស្តង់ដាសន្តិសុខ និងការជំរុញការប្រើប្រាស់អត្តសញ្ញាណឥដ្ឋិជីថល។

**មាត្រា៩.១៨ _ កិច្ចសហប្រតិបត្តិការ**

១- ដោយទទួលស្គាល់ពីសារៈសំខាន់នៃពាណិជ្ជកម្មឥដ្ឋិជីថលចំពោះសេដ្ឋកិច្ចសម័យទំនើប គូភាគីត្រូវខិតខំរក្សាកិច្ចសន្ទនាលើបញ្ហានិយតកម្មទាក់ទងនឹងពាណិជ្ជកម្មឥដ្ឋិជីថល ក្នុងគោលបំណងចែក

រំលែកព័ត៌មាននិងបទពិសោធតាមការសមស្រប រួមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងការអនុវត្តនិងឧត្តមានុវត្តន៍ទាក់ទងនឹងពាណិជ្ជកម្មឌីជីថល រួមទាំងទាក់ទងនឹង៖

(ក) កិច្ចការពារអ្នកប្រើប្រាស់តាមអ៊ីនធឺណិត

(ខ) កិច្ចការពារទិន្នន័យបុគ្គល

(គ) ការប្រឆាំងការសម្អាតប្រាក់និងការអនុលោមតាមទណ្ឌកម្មសម្រាប់ពាណិជ្ជកម្មឌីជីថល

(ឃ) សារពាណិជ្ជកម្មអេឡិចត្រូនិកដែលមិនមានការស្នើសុំ

(ង) ការកំណត់យថាភូតភាព

(ច) បញ្ហាពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្មឌីជីថល

(ឆ) បញ្ហាប្រឈមសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងពាណិជ្ជកម្មឌីជីថល

(ជ) រដ្ឋាភិបាលឌីជីថល និង

(ឈ) ផ្នែកផ្សេងទៀតតាមការព្រមព្រៀងគ្នាដោយគូភាគី។

២. គូភាគីមានចក្ខុវិស័យរួមគ្នាដើម្បីជំរុញពាណិជ្ជកម្មឌីជីថលប្រកបដោយសន្តិសុខ និងទទួលស្គាល់ថាការគំរាមកំហែងដល់សន្តិសុខសាយប័រ ធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តលើពាណិជ្ជកម្មឌីជីថល។ អាស្រ័យហេតុនេះ គូភាគីទទួលស្គាល់សារៈសំខាន់នៃ៖

(ក) ការកសាងសមត្ថភាពរបស់ភ្នាក់ងាររដ្ឋាភិបាលរបស់ខ្លួន ដែលទទួលខុសត្រូវចំពោះការឆ្លើយតបឧប្បត្តិហេតុសន្តិសុខសាយប័រ រួមទាំងតាមរយៈការផ្លាស់ប្តូរឧត្តមានុវត្តន៍

(ខ) ការប្រើប្រាស់យន្តការសហការ ដើម្បីសហការលើបញ្ហាដែលប៉ះពាល់ដល់សន្តិសុខសាយប័រនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់គូភាគី ក្នុងគោលបំណងកសាងលម្អសាយប័រដែលមានសុវត្ថិភាពនិងសន្តិសុខ និង

(គ) ការជំរុញការអភិវឌ្ឍកម្លាំងការងារសាធារណៈនិងឯកជនដ៏រឹងមាំ នៅក្នុងផ្នែកសន្តិសុខសាយប័រ រួមទាំងគំនិតផ្តួចផ្តើមដែលអាចធ្វើទៅបានពាក់ព័ន្ធនឹងការទទួលស្គាល់គុណវុឌ្ឍិទៅវិញទៅមក។

# ជំពូកទី១០
# វិនិយោគ

## មាត្រា១០.១ _ កិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម

១- គូភាគីបញ្ជាក់ឡើងវិញនូវការប្តេជ្ញាក្រោមកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កម្ពុជា នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ (ហៅថា"កិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម") និងការធ្វើវិសោធនកម្មឬដំឡើងកម្រិតកិច្ចព្រមព្រៀងនេះនាពេលអនាគត។ លើសពីនេះ គូភាគីបន្តការប្តេជ្ញារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងវិនិយោគកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ដើម្បីជំរុញកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាក្នុងការទាក់ទាញនិងផ្តល់កិច្ចសម្រួលវិនិយោគទ្វេទិស។

២- គូភាគីបានឯកភាពគ្នាចរចាដំឡើងកម្រិត នូវកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ដែលនៅជាធរមានឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយគ្របដណ្តប់លើសោលភាពនៃការជំរុញ ការផ្តល់កិច្ចសម្រួល និងកិច្ចសហប្រតិបត្តិការវិនិយោគក្នុងកិច្ចខិតខំប្រឹងប្រែងនាពេលអនាគត។

៣- រាល់ការធ្វើវិសោធនកម្មឬដំឡើងកម្រិតបន្តបន្ទាប់នៃកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម នឹងត្រូវដាក់បញ្ចូលជាផ្នែកនៃជំពូកវិនិយោគនេះ។

## មាត្រា១០.២ _ ការជំរុញវិនិយោគ

១- គូភាគីអះអាងពីបំណងក្នុងការលើកស្ទួយបរិយាកាសវិនិយោគប្រកបដោយភាពទាក់ទាញ និងពង្រីកពាណិជ្ជកម្មទំនិញនិងសេវាកម្ម។ ដោយមានសង្គតិភាពជាមួយមាត្រា២ (ការជំរុញនិងការលើកទឹកចិត្តការវិនិយោគ) នៃកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ភាគីទាំងពីរត្រូវចាត់វិធានការសមស្រប ដើម្បីលើកទឹកចិត្តនិងផ្តល់កិច្ចសម្រួលដល់ហូរវិនិយោគ ទំនិញ និងសេវាកម្ម និងធានាបាននូវលក្ខខណ្ឌអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងរយៈពេលវែង ព្រមទាំងការធ្វើពិពិធកម្មពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

២- បន្ថែមលើមាត្រា២ (ការជំរុញនិងការលើកទឹកចិត្តការវិនិយោគ) នៃកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម និងស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន គូភាគីត្រូវសហការជំរុញនិយោគតាមរយៈ៖

(ក) ការកំណត់កាលានុវត្តភាពវិនិយោគ

(ខ) ការពង្រឹងយុទ្ធនាការជំរុញវិនិយោគ

(គ) ការចែករំលែកព័ត៌មានស្តីពីវិធានការជំរុញវិនិយោគនៅក្រៅប្រទេសតាមលទ្ធភាពជាក់ស្តែង

(ឃ) ការផ្លាស់ប្តូរព័ត៌មានស្តីពីច្បាប់វិនិយោគ បទប្បញ្ញត្តិ និងគោលនយោបាយតាមលទ្ធភាពជាក់ស្តែង

(ង) ការជំរុញបរិយាកាសដែលទាក់ទាញដើម្បីបង្កើនរំហូរនៃការវិនិយោគក្នុងន័យជំរុញការតភ្ជាប់រវាងស្ថាប័នជំរុញវិនិយោគ ក្នុងស្មារតីលើកកម្ពស់វិនិយោគទ្វេភាគី។

៣- ដោយទទួលស្គាល់ថា ការផ្តល់កិច្ចសម្រួលវិនិយោគទៅក្រៅប្រទេសដល់សហគ្រាសវិនិយោគជាសសរស្តម្ភគន្លឹះនៃកិច្ចសហប្រតិបត្តិការទ្វេភាគី គូភាគីត្រូវពង្រឹងកិច្ចសហការរបស់ខ្លួនក្នុងវិស័យនេះ។ ដើម្បីជានាបានប្រសិទ្ធភាព គូភាគីត្រូវខិតខំកំណត់និងចែករំលែកព័ត៌មានអំពីសកម្មភាពនិងវិស័យវិនិយោគដែលមានសក្តានុពលទៅក្រៅប្រទេស និងជំរុញលើកទឹកចិត្តដល់សហគ្រាសទាំងនោះឱ្យវិនិយោគនៅក្នុងដែនដីនៃភាគីម្ខាងទៀត។

## មាត្រា១០.៣ _ កិច្ចសម្រួលវិនិយោគ

១- ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីនីមួយៗត្រូវខិតខំសម្រួលវិនិយោគមកពីភាគីម្ខាងទៀតតាមរយៈ៖

(ក) ការធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនិងប្រសិទ្ធផលនៃបរិយាកាសវិនិយោគក្នុងស្រុក ក្នុងគោលបំណងផ្តល់កិច្ចសម្រួលដល់វិនិយោគប្រកបដោយគុណភាពរវាងភាគីទាំងពីរ

(ខ) ការបង្កើតបរិយាកាសដែលមានភាពចាំបាច់សម្រាប់ការវិនិយោគគ្រប់ទម្រង់ រួមទាំងការបង្កើតលក្ខខណ្ឌអំណោយផលក្នុងការផ្ទេរហិរញ្ញវត្ថុសម្រាប់គម្រោងវិនិយោគ

(គ) ការធ្វើសាមញ្ញកម្មនីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំនិងការអនុម័តគម្រោងវិនិយោគ

(ឃ) ការជំរុញផ្សព្វផ្សាយព័ត៌មានស្តីពីវិនិយោគ រួមទាំងប៉ុន្តែមិនកម្រិតត្រឹមបទបញ្ជា បទប្បញ្ញត្តិ គោលនយោបាយវិនិយោគ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគី និងនីតិវិធីវិនិយោគ និង

(ង) ពង្រឹងយន្តការច្រកចេញចូលតែមួយដើម្បីផ្តល់ជំនួយនិងសេវាកម្មប្រឹក្សាយោបល់ជូនដល់វិស័យធុរកិច្ច រួមទាំងកិច្ចសម្រួលដល់ការចេញអាជ្ញាបណ្ណនិងលិខិតអនុញ្ញាត។

២- ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក ភាគីនីមួយៗត្រូវធ្វើឱ្យវិនិយោគិននៃភាគីម្ខាងទៀតអាចរកបាននូវវិធានការនានាដែលចែងពីទម្រង់បែបបទស្នើសុំវិនិយោគ។ ភាគីនីមួយៗត្រូវការពារពីការបញ្ចេញព័ត៌មានសម្ងាត់អំពីធុរកិច្ចដែលនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការប្រកួតប្រជែងរបស់វិនិយោគិនឬការវិនិយោគ។ មិនមានបទប្បញ្ញត្តិណាមួយក្នុងកថាខណ្ឌនេះត្រូវបានយកមកប្រើប្រាស់សម្រាប់បកស្រាយ ដើម្បីរារាំងភាគីសមាជិកពីការទទួលបានឬបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តប្រកបដោយសមធម៌ និងដោយសុចរិតនិងស្មោះត្រង់នៃច្បាប់ក្នុងស្រុករបស់ខ្លួន។

៣- ភាគីនីមួយៗត្រូវខិតខំផ្តល់ព័ត៌មានទៅភាគីម្ខាងទៀត ស្តីពីវិធានការពាក់ព័ន្ធនឹងកិច្ចសម្រួលវិនិយោគ ដែលភាគីនីមួយៗអនុម័តនៅពេលអនាគត ឬធ្វើកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងតំបន់ និងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងកិច្ចសម្រួលវិនិយោគ។

## មាត្រា១០.៤ _ ការធ្វើធុរកិច្ចប្រកបដោយតាពទទួលខុសត្រូវ

១- ភាគីនីមួយៗត្រូវលើកទឹកចិត្តវិនិយោគិននិងសហគ្រាសវិនិយោគ ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងដែនដីឬស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនឱ្យដាក់បញ្ចូលការអនុវត្តធុរកិច្ចនិងគោលនយោបាយ

ផ្ទៃក្នុងរបស់ខ្លួនដោយស្មើគ្រចិត្តនូវគោលការណ៍ ស្តង់ដា វិធានការណែនាំដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិនៃការធ្វើធុរកិច្ចប្រកបដោយភាពទទួលខុសត្រូវ ដែលត្រូវបានទទួលការយល់ព្រមឬគាំទ្រដោយសមាជិកនោះ។

២- អនុលោមតាមប្រព័ន្ធច្បាប់របស់ខ្លួន ភាគីនីមួយៗត្រូវលើកទឹកចិត្តដល់វិនិយោគិនឬសហគ្រាសវិនិយោគកំពុងធ្វើប្រតិបត្តិការក្នុងដែនដីរបស់ខ្លួន ឱ្យអនុវត្តនិងរក្សាការចូលរួមនិងការសន្ទនាដែលមានអត្ថន័យ អនុលោមតាមគោលការណ៍ ស្តង់ដា និងវិធានការណែនាំជាលក្ខណៈអន្តរជាតិនៃការធ្វើធុរកិច្ចប្រកបដោយភាពទទួលខុសត្រូវ ដែលត្រូវបានទទួលការយល់ព្រមឬគាំទ្រដោយភាគីនោះ។

៣- ភាគីនីមួយៗទទួលស្គាល់ពីសារៈសំខាន់នៃវិនិយោគិននិងសហគ្រាសវិនិយោគដែល អនុវត្តករណីយកិច្ច ដើម្បីនឹងកំណត់និងដៅផលអវិជ្ជមានលើបញ្ហាបរិស្ថាននិងលក្ខខណ្ឌការងារនៅក្នុងប្រតិបត្តិការ ខ្សែច្រវាក់ផ្គត់ផ្គង់ និងទំនាក់ទំនងធុរកិច្ចផ្សេងទៀត។

៤- ភាគីទាំងពីរយល់ព្រមផ្លាស់ប្តូរព័ត៌មាននិងឧត្តមានុវត្តន៍ តាមលទ្ធភាពដែលអាចធ្វើបានស្តីពីមធ្យោបាយជួយសម្រួលដល់ការអនុវត្តដោយសហគ្រាសវិនិយោគនិងវិនិយោគិន ចំពោះការអនុវត្តធុរកិច្ចប្រកបដោយភាពទទួលខុសត្រូវ និងរាយការណ៍ជូនគណៈកម្មាធិការវិនិយោគ។

## មាត្រា១០.៥ _ ការមិនលើកលែងចំពោះវិធានការពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព និងបរិស្ថាន

១- ដោយទទួលស្គាល់សារៈសំខាន់នៃការជំរុញវិនិយោគសម្រាប់កំណើនបៃតង គូភាគីត្រូវចៀសវាងការជំរុញលើកទឹកចិត្តវិនិយោគដល់វិនិយោគិននៃភាគីសមាជិកម្ខាងទៀត តាមរយៈការបន្ធូរបន្ថយវិធានការបរិស្ថាន។ ដើម្បីជានាបាននូវប្រសិទ្ធភាព ភាគីនីមួយៗមិនត្រូវលើកលែងឬដកចេញវិធានការបរិស្ថានដើម្បីជាការជំរុញលើកទឹកចិត្តដល់ការបង្កើត ការទិញ ឬការពង្រីកការវិនិយោគនៅក្នុងដែនដីរបស់ខ្លួន។

២- គូភាគីទទួលស្គាល់ថា មិនគប្បីក្នុងការលើកទឹកចិត្តការវិនិយោគដោយការបន្ធូរបន្ថយវិធានការក្នុងស្រុកដែលពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព បរិស្ថាន ឬកម្មវត្ថុនៃបទប្បញ្ញត្តិដទៃទៀត។ ស្របជាមួយគ្នានេះ គ្មានភាគីសមាជិកណាមួយត្រូវបន្ធូរបន្ថយ លើកលែងឬដកចេញ ឬផ្តល់ការបន្ធូរបន្ថយ លើកលែង ឬដកចេញនូវវិធានការទាំងនេះដើម្បីជំរុញលើកទឹកចិត្តដល់ការបង្កើត ការទិញយក ឬការពង្រីក ឬគ្រប់គ្រងវិនិយោគរបស់វិនិយោគិននៅក្នុងដែនដីរបស់ខ្លួនឡើយ។ ប្រសិនបើភាគីសមាជិកចាត់ទុកថា ភាគីសមាជិកម្ខាងទៀតបានផ្តល់ការជំរុញលើកទឹកចិត្តបែបនេះ ភាគីសមាជិកនោះអាចស្នើសុំការពិគ្រោះយោបល់ជាមួយភាគីសមាជិកម្ខាងទៀត ហើយគូភាគីត្រូវពិគ្រោះយោបល់ក្នុងគោលបំណងចៀសវាងការជំរុញលើកទឹកចិត្តបែបនេះ។

៣- គូភាគីបញ្ជាក់ឡើងវិញនូវសិទ្ធិរបស់ខ្លួន ក្នុងការធ្វើបញ្ញត្តិនៅក្នុងដែនដីរបស់ខ្លួនដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយដែលទទួលស្គាល់ដោយច្បាប់ ដូចជាការពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាននិងការដោះស្រាយបម្រែបម្រួលអាកាសធាតុ ការការពារសង្គមឬអ្នកប្រើប្រាស់ ឬលើកកម្ពស់និងការពារសុខភាព សុវត្ថិភាព សមភាពយេនឌ័រ និងភាពចម្រុះនៃវប្បធម៌។

**មាត្រា១០.៦ _ គណៈកម្មាធិការវិនិយោគ**

គូភាគីត្រូវបង្កើតគណៈកម្មាធិការវិនិយោគកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ដែលមានសមាសភាពតំណាងនៃភាគីទាំងពីរ។ ភាគីអេមីរ៉ាតអារ៉ាប់រួមនឹងដឹកនាំដោយអនុរដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុឬតំណាងដែលទទួលបានការតែងតាំងស្របច្បាប់ ហើយភាគីកម្ពុជានឹងដឹកនាំដោយអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬតំណាងដែលទទួលបានការតែងតាំងស្របច្បាប់។ គណៈកម្មាធិការនេះអាចបង្កើតក្រុមការងារបានទៅតាមភាពចាំបាច់របស់គូភាគី។

**មាត្រា១០.៧ _ គោលដៅនៃគណៈកម្មាធិការវិនិយោគ**

១- គោលដៅនៃគណៈកម្មាធិការវិនិយោគមានដូចខាងក្រោម៖

(ក) ជំរុញនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងគូភាគី

(ខ) តាមដានទំនាក់ទំនងពាណិជ្ជកម្មនិងការវិនិយោគ ដើម្បីកំណត់កាលានុវត្តភាពសម្រាប់ពង្រីកការវិនិយោគ និងកំណត់បញ្ហាពាក់ព័ន្ធនឹងការវិនិយោគដែលអាចលើកយកមកចរចានៅក្នុងវេទិកាសមស្របណាមួយ

(គ) រៀបចំការប្រឹក្សាយោបល់ស្តីពីចំណាប់អារម្មណ៍វិនិយោគជាក់លាក់ទៅកាន់គូភាគី

(ឃ) បំពេញការងារឈានទៅសម្រេចបាននូវការពង្រីកវិហារវិនិយោគ

(ង) កំណត់ និងបំពេញការងារឈានទៅសម្រេចបាននូវការលុបបំបាត់ឧបសគ្គរាំងដល់វិហារវិនិយោគ និង

(ច) ប្រមូលផ្តុំទស្សនៈរបស់វិស័យឯកជនលើបញ្ហាពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ។

២- ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ គណៈកម្មាធិការមិនត្រូវអនុវត្តតួនាទីនៃ "ការដោះស្រាយវិវាទវិនិយោគរវាងវិនិយោគិននៃភាគីជាប់កិច្ចសន្យាមួយនិងភាគីជាប់កិច្ចសន្យាម្ខាងទៀត" ដូចដែលបង្កើតដោយកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម។

**មាត្រា១០.៨ _ តួនាទីរបស់គណៈកម្មាធិការ**

១- គណៈកម្មាធិការនេះត្រូវជួបប្រជុំតាមពេលវេលានិងទីកន្លែងតាមការឯកភាពដោយគូភាគី ប៉ុន្តែគូភាគីត្រូវខិតខំធ្វើយ៉ាងណាជួបប្រជុំគ្នាយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ ភាគីសមាជិកអាចស្នើនូវបញ្ហាជាក់លាក់នៃពាណិជ្ជកម្មឬវិនិយោគទៅគណៈកម្មាធិការ ដោយបញ្ជូនសំណើជាលាយលក្ខណ៍អក្សរដែលរួមបញ្ចូលនូវបញ្ហាពាក់ព័ន្ធសម្រាប់កិច្ចពិភាក្សាទៅភាគីសមាជិកម្ខាងទៀត។ គណៈកម្មាធិការត្រូវលើកយកបញ្ហាមកពិភាក្សាភ្លាមៗបន្ទាប់ពីទទួលបានសំណើនេះ លើកលែងតែភាគីស្នើសុំឯកភាពពន្យារពេលការពិភាក្សាលើបញ្ហានោះ។

២- គូភាគីត្រូវខិតខំផ្តល់ឱកាសជូនគណៈកម្មាធិការ ដើម្បីពិភាក្សាបញ្ហាមុនអនុវត្តសកម្មភាពនានាដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ពាណិជ្ជកម្មឬវិនិយោគនៃភាគីសមាជិកម្ខាងទៀត។

៣- មុខងាររបស់គណៈកម្មាធិការត្រូវ៖

(ក) ដើរតួជាចំណុចបង្គោលនៃបញ្ហាវិនិយោគដែលបានលើកឡើងពីដំណាក់នេះ

(ខ) ពិភាក្សានិងពិនិត្យការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ

(គ) ពិភាក្សារាល់បញ្ហាពាក់ព័ន្ធនឹងវិនិយោគផ្សេងទៀតដែលទាក់ទងនឹងជំពូកនេះ និង

(ឃ) ពិភាក្សាលើវិធានការដែលបានអនុម័តឬរក្សាទុក ក្នុងគោលបំណងជំរុញលក្ខខណ្ឌអំណោយផលសម្រាប់វិនិយោគិននៃគូភាគី។

៤- តាមភាពចាំបាច់ គណៈកម្មាធិការត្រូវរៀបចំអនុសាសន៍សមស្របជាយមានមតិពុងសង់ស៊ីសពីគូភាគីសម្រាប់ការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព ឬការសម្រេចបានកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ។

៥- គណៈកម្មាធិការត្រូវមានសមាសភាពពីតំណាងនៃគូភាគី។ គណៈកម្មាធិការត្រូវកំណត់វិធាននៃនីតិវិធីដើម្បីអនុវត្តនូវមុខងាររបស់ខ្លួន។

៦- ដោយមានការយល់ព្រមពីគូភាគី គណៈកម្មាធិការអាចរៀបចំកិច្ចប្រជុំរួមជាមួយសិស័យឯកជន។

៧- ភាគីសមាជិកត្រូវចាត់តាំងឬរក្សាទុកចំណុចបង្គោល ឬយន្តការសមស្របមួយឬច្រើន។

៨- គូភាគីអាចប្រគល់មុខងារបន្ថែមជូនចំណុចបង្គោលឬយន្តការសមស្រប ដែលបានបង្កើតឡើងក្រោមមាត្រានេះ ដើម្បីស្វះស្វែងដោះស្រាយបញ្ហារបស់វិនិយោគិនឬបុគ្គលមានបំណងវិនិយោគពាក់ព័ន្ធនឹងវិធានការនានាដែលគ្របដណ្តប់ដោយជំពូកនេះ ឬផ្តល់ជាអនុសាសន៍នូវវិធានការដើម្បីកែលម្អបរិយាកាសវិនិយោគ។

## មាត្រា១០.៥ _ ការមិនអនុវត្តចំពោះការដោះស្រាយវិវាទ

១- គ្មានភាគីសមាជិកណាមួយមានសិទ្ធិប្រើប្រាស់ការដោះស្រាយវិវាទ ចំពោះបញ្ហាដែលកើតឡើងពីឬពាក់ព័ន្ធនឹងជំពូកនេះ។

២- ជំពូកនេះមិនត្រូវយកធ្វើជាមធ្យោបាយ ក្នុងការបកស្រាយបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិនៃភាគីសមាជិក និងមិនត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការទាមទារឬតាមវិធីណាមួយដោយអ្នកទាមទារ ក្រោមនីតិវិធីសម្រាប់ការដោះស្រាយវិវាទវិនិយោគរវាងវិនិយោគិននិងរដ្ឋដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិនៃភាគីសមាជិក។

# ជំពូកទី១១
# កម្មសិទ្ធិបញ្ញា

## ផ្នែក ក បទប្បញ្ញត្តិទូទៅ

### មាត្រា១១.១ _ និយមន័យ

គោលបំណងនៃជំពូកនេះ៖

**កម្មសិទ្ធិបញ្ញា** រួមមាន៖

(ក) សិទ្ធិអ្នកនិពន្ធ រួមទាំងសិទ្ធិអ្នកនិពន្ធនៅក្នុងកម្មវិធីកុំព្យូទ័រ និងក្នុងប្រព័ន្ធទិន្នន័យ និងសិទ្ធិប្រហាក់ប្រហែល

(ខ) ប្រកាសនីយបត្រតក្កកម្ម និងម៉ូដែលមានអត្ថប្រយោជន៍

(គ) ម៉ាក

(ឃ) គំនូរឧស្សាហកម្ម

(ង) គំនូសបង្ហាញនៃសៀគ្វីបង្រួម

(ច) ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និង

(ឆ) ពូជដំណាំ។

**ពលរដ្ឋ** ទាក់ទងនឹងសិទ្ធិពាក់ព័ន្ធ សំដៅដល់បុគ្គលនៃភាគីសមាជិកដែលបំពេញតាមលក្ខណវិនិច្ឆ័យសម្រាប់ទទួលបានការការពារដែលមានចែងក្នុងកិច្ចព្រមព្រៀងដែលមានក្នុងមាត្រា១១.៥ ឬកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(TRIPS) និង

WIPO សំដៅដល់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

### មាត្រា១១.២ _ គោលបំណង

កិច្ចការពារនិងពង្រឹងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា គួររួមចំណែកដល់ការជំរុញពាណិជ្ជកម្ម ការវិនិយោគ នវានុវត្តន៍បច្ចេកវិទ្យា និងការផ្ទេរនិងផ្សព្វផ្សាយបច្ចេកវិទ្យា ដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់អ្នកផលិតនិងអ្នកប្រើប្រាស់ចំណេះដឹងបច្ចេកវិទ្យា ដែលផ្តល់លក្ខណៈអំណោយផលដល់សុខុមាលភាពសង្គមសេដ្ឋកិច្ច និងធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិនិងកាតព្វកិច្ច។

### មាត្រា១១.៣ _ គោលការណ៍

ពុំមានបទប្បញ្ញត្តិណាមួយក្នុងជំពូកនេះ រារាំងភាគីណាមួយពីការអនុម័តវិធានការសមស្របដើម្បីទប់ស្កាត់ការបំពានសិទ្ធិកម្មសិទ្ធិបញ្ញាដោយម្ចាស់សិទ្ធិ ឬការអនុវត្តដែលរារាំងពាណិជ្ជកម្មដោយមិនសមហេតុផល ឬប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការផ្ទេរបច្ចេកវិទ្យាអន្តរជាតិ ឱ្យតែវិធានការទាំងនោះស្របតាមកិច្ចព្រមព្រៀងនេះ។

**មាត្រា១១.៤ _ លក្ខណៈនិងវិសាលភាពនៃកាតព្វកិច្ច**

ភាគីនីមួយៗត្រូវអនុវត្តបទប្បញ្ញត្តិនានានៃជំពូកនេះ។ ភាគីសមាជិកអាច ប៉ុន្តែមិនមានកាតព្វកិច្ច ផ្តល់កិច្ចការពារឬការអនុវត្តសិទ្ធិទូលំទូលាយចំពោះសិទ្ធិកម្មសិទ្ធិបញ្ញាក្រោមច្បាប់របស់ខ្លួន ជាងការតម្រូវដោយជំពូកនេះ ឱ្យតែកិច្ចការពារឬការអនុវត្តសិទ្ធិនោះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃជំពូកនេះ។ ភាគីនីមួយៗមានសេរីភាពក្នុងការកំណត់វិធីសាស្ត្រសមស្រប ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះក្នុងប្រព័ន្ធច្បាប់និងការអនុវត្តរបស់ខ្លួន។

**មាត្រា១១.៥ _ កិច្ចព្រមព្រៀងអន្តរជាតិ**

១- គូភាគីបញ្ជាក់ឡើងវិញនូវកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងកិច្ចព្រមព្រៀងពហុភាគីដូចខាងក្រោម៖

(ក) សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ ដែលត្រូវបានកែសម្រួលដោយច្បាប់ទីក្រុងវ៉ាស៊ីនតោន ឆ្នាំ២០០១

(ខ) អនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ ១៨៨៣ ដែលត្រូវបានកែសម្រួលដោយច្បាប់ទីក្រុងស្តុកខុល ឆ្នាំ១៩៦៧

(គ) អនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៨៨៦ ដែលត្រូវបានកែសម្រួលដោយច្បាប់ទីក្រុងប៉ារីស ឆ្នាំ១៩៧១ (អនុសញ្ញាទីក្រុងប៊ែន)

(ឃ) ពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៩ នៅទីក្រុងម៉ាឌ្រីដ។

២- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងផ្តល់សច្ចាប័ន ឬចូលជាភាគីកិច្ចព្រមព្រៀងនីមួយៗខាងក្រោម ប្រសិនបើភាគីណាមួយមិនទាន់ក្លាយជាភាគីនៃកិច្ចព្រមព្រៀងនោះ៖

(ក) សន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស ស្តីពីការសម្រួលដល់ការទទួលបាននូវស្នាដៃ ដែលបានបោះពុម្ពសម្រាប់ជនពិការភ្នែក បាត់បង់សមត្ថភាពចក្ខុវិញ្ញាណ ឬជនមានពិការភាពស្នាដៃបោះពុម្ពដទៃទៀត ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ នៅទីក្រុងម៉ារ៉ាកេស (សន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស)

(ខ) អនុសញ្ញាអន្តរជាតិ ស្តីពីការការពារពូជថ្មីនៃដំណាំ ដែលត្រូវបានកែសម្រួលនៅទីក្រុងហ្សឺណែវ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩១(UPOV)

(គ) សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពីការសម្តែងនិងហ្វូណូក្រាម ធ្វើនៅទីក្រុងហ្សឺណែវ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៦ (WPPT)

(ឃ) អនុសញ្ញាអន្តរជាតិ ស្តីពីការការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ធ្វើនៅទីក្រុងរ៉ូម ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៦១

(ង) សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពីសិទ្ធិអ្នកនិពន្ធ ធ្វើនៅទីក្រុងហ្សឺណែវ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៦(WCT) និង

(ច) សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែស ស្តីពីការទទួលស្គាល់ជាអន្តរជាតិនៃការតម្កល់មីក្រូសរីរាង្គ សម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧។

**មាត្រា១១.៦ _ កម្មសិទ្ធិបញ្ញានិងសុខភាពសាធារណៈ:**

១- ក្នុងការបង្កើតឬធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីសមាជិកអាចអនុម័តវិធានការចាំបាច់ដើម្បីការពារសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងដើម្បីលើកកម្ពស់ផលប្រយោជន៍សាធារណៈក្នុងវិស័យដែលមានសារៈសំខាន់ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងបច្ចេកវិទ្យារបស់ខ្លួន ឱ្យតែវិធានការទាំងនោះស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ។

២- គូភាគីទទួលស្គាល់គោលការណ៍ដែលបានបង្កើតឡើងនៅក្នុងសេចក្តីប្រកាសទីក្រុងដូហា ស្តីពីកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានិងសុខភាពសាធារណៈ ដែលបានអនុម័តនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០១ (សេចក្តីប្រកាសទីក្រុងដូហា) សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងហុងកុង ដែលបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៥ និងវិសោធនកម្មណាមួយនៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីអនុវត្តសេចក្តីប្រកាសស្តីពីកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានិងសុខភាពសាធារណៈ ដែលចូលជាធរមានចំពោះគូភាគី ដោយសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយបញ្ជាក់ថា បទប្បញ្ញត្តិនៃជំពូកនេះមិនប៉ះពាល់ដល់សេចក្តីប្រកាសទីក្រុងដូហាឡើយ។

**មាត្រា១១.៧ _ ប្រព្រឹត្តកម្មជាតិ**

១- ចំពោះគ្រប់ប្រភេទនៃកម្មសិទ្ធិបញ្ញាដែលគ្របដណ្តប់ក្នុងជំពូកនេះ ភាគីនីមួយៗត្រូវផ្តល់ដល់ពលរដ្ឋនៃភាគីផ្សេងទៀត នូវប្រព្រឹត្តកម្មមិនតិចជាងប្រព្រឹត្តកម្មដែលខ្លួនផ្តល់ឱ្យពលរដ្ឋរបស់ខ្លួនទាក់ទងនឹងការការពារសិទ្ធិកម្មសិទ្ធិបញ្ញាដែលជាកម្មវត្ថុនៃការលើកលែង ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានិងនៅក្នុងកិច្ចព្រមព្រៀងពហុភាគីនានាដែលគ្រប់គ្រងដោយWIPO ដែលភាគីនោះជាភាគី។

២- ដោយស្របទៅនឹងការប្រើប្រាស់បន្ទាប់បន្សំនៃហ្វូណូក្រាម ដោយមធ្យោបាយតាមប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងអាណាឡូកនិងតាមលេកធាតុអាកាសដោយសេរី ភាគីសមាជិកអាចកំណត់កម្រិតសិទ្ធិរបស់អ្នកសម្តែងនិងផលិតកររបស់ភាគីផ្សេងទៀត ត្រឹមសិទ្ធិផ្តល់ឱ្យពលរដ្ឋរបស់ខ្លួននៅក្នុងដែនសមត្ថកិច្ចរបស់ភាគីផ្សេងទៀតនោះ។

៣- ភាគីសមាជិកអាចមិនអនុវត្តកថាខណ្ឌ១ ទាក់ទងនឹងនីតិវិធីតុលាការនិងរដ្ឋបាលរបស់ខ្លួន រួមទាំងការតម្រូវឱ្យពលរដ្ឋរបស់ភាគីផ្សេងទៀតកំណត់អាសយដ្ឋាន សម្រាប់សេវាកម្មនៃដំណើរការនៅក្នុងដែនដីរបស់ខ្លួនឬចាត់តាំងភ្នាក់ងារនៅក្នុងដែនដីរបស់ខ្លួន ឱ្យតែការមិនអនុវត្តនោះ គឺ៖
(ក) ចាំបាច់ដើម្បីជានាការអនុលោមតាមច្បាប់ឬបទប្បញ្ញត្តិដែលមិនស្របតាមជំពូកនេះ និង
(ខ) មិនត្រូវបានអនុវត្តដោយសារអោចបង្កើតជាការដាក់កំហិតបែបក្លែងបន្លំលើពាណិជ្ជកម្ម។

៤- កថាខណ្ឌ១មិនអនុវត្តចំពោះនីតិវិធីដែលមានចែងក្នុងកិច្ចព្រមព្រៀងពហុភាគី ដែលអនុម័តក្រោមការគ្រប់គ្រងរបស់WIPO ទាក់ទងនឹងការទទួលបានឬការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា។

**មាត្រា១១.៨ _ កម្ចាត**

១- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែង ស្របតាមប្រព័ន្ធច្បាប់និងការអនុវត្តរបស់ខ្លួន ដើម្បីធ្វើឱ្យមានព័ត៌មានជាសាធារណៈទាក់ទងនឹងការដាក់ពាក្យស្នើសុំនិងការចុះបញ្ជីម៉ាកពាណិជ្ជកម្ម ម៉ាកសម្គាល់កូមិសាស្ត្រចំនិញ គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម និងពូជដំណាំ ដែលអាចស្វែងរកបានដោយមជ្ឈដ្ឋានទូទៅ។

២- គូភាគីទទួលស្គាល់ពីសារៈសំខាន់នៃសម្ភារៈព័ត៌មាន ដូចជាប្រព័ន្ធទិន្នន័យដែលអាចចូលទៅបានជាសាធារណៈនៃកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជី ដែលជួយក្នុងការកំណត់អត្តសញ្ញាណកម្មវត្ថុដែលបានក្លាយទៅជាទ្រព្យសម្បត្តិរបស់សាធារណៈ។

៣- ភាគីនីមួយៗត្រូវខិតខំធ្វើឱ្យមានព័ត៌មានទាំងនោះអាចប្រើប្រាស់បានជាភាសាអង់គ្លេស។

**មាត្រា១១.៩ _ ការអនុវត្តជំពូកនេះចំពោះកម្មវត្ថុដែលមានស្រាប់ និងសកម្មភាពពីមុនៗ**

១- លើកលែងមានចែងក្នុងជំពូកនេះ ជំពូកនេះចងកាតព្វកិច្ចចំពោះកម្មវត្ថុទាំងអស់ដែលមាននៅកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះចំពោះភាគីសមាជិក ហើយដែលត្រូវបានការពារនៅកាលបរិច្ឆេទនោះនៅក្នុងដែនដីនៃភាគីសមាជិកដែលទាមទារឱ្យមានការការពារ ឬដែលបំពេញឬដែលបន្ទាប់មកបំពេញតាមលក្ខណៈនិីថ្ងៃ សម្រាប់ការការពារក្រោមជំពូកនេះដោយមិនធ្វើឱ្យប៉ះពាល់ដោយមិនសមហេតុផលនូវប្រយោជន៍សមធម៌របស់ភាគីទីបី។

២- លើកលែងមានចែងក្នុងជំពូកនេះ ភាគីសមាជិកមិនតម្រូវឱ្យស្ថាការការពារឡើងវិញចំពោះកម្មវត្ថុដែលនៅកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដែលបានក្លាយជាទ្រព្យសម្បត្តិរបស់សាធារណៈនៅក្នុងដែនដីរបស់ខ្លួន។

៣- ជំពូកនេះពុំចងកាតព្វកិច្ចចំពោះសកម្មភាពនានា ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះនោះទេ។

**មាត្រា១១.១០ _ ការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញា**

ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិណាមួយ ដែលចែងពីការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញានៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលភាគីសមាជិកជាភាគី មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះរារាំងភាគីសមាជិកពីការកំណត់ថាតើលក្ខខណ្ឌណាឬស្ថិតក្រោមលក្ខខណ្ឌណា ដែលការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញាត្រូវអនុវត្តក្រោមប្រព័ន្ធច្បាប់របស់ខ្លួន។

## ផ្នែក ខ កិច្ចសហប្រតិបត្តិការ

### មាត្រា១១.១១ _ គំនិតផ្តួចផ្តើមនិងសកម្មភាពសហប្រតិបត្តិការ

គូភាគីត្រូវខិតខំសហការលើកម្មវត្ថុដែលមានចែងក្នុងជំពូកនេះ ដូចជាតាមរយៈការសម្របសម្រួល ការបណ្តុះបណ្តាល និងការផ្លាស់ប្តូរព័ត៌មានសមស្របរវាងអង្គភាពកម្មសិទ្ធិបញ្ញារៀងៗខ្លួនឬស្ថាប័នផ្សេងទៀត តាមការកំណត់របស់ភាគីនីមួយៗ។ សកម្មភាពសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមដែលធ្វើឡើងក្រោមជំពូកនេះ ត្រូវផ្អែកតាមធនធានដែលមាន និងតាមការស្នើសុំនិងតាមលក្ខខណ្ឌនិងការកំណត់ដែលបានព្រមព្រៀងគ្នារវាងគូភាគី។ កិច្ចសហប្រតិបត្តិការអោចគ្របដណ្តប់លើវិស័យដូចជា៖

(ក) ការអភិវឌ្ឍគោលនយោបាយកម្មសិទ្ធិបញ្ញាក្នុងស្រុកនិងអន្តរជាតិ

(ខ) ប្រព័ន្ធគ្រប់គ្រងនិងចុះបញ្ជីកម្មសិទ្ធិបញ្ញា

(គ) ការអប់រំនិងការយល់ដឹងទាក់ទងនឹងកម្មសិទ្ធិបញ្ញា

(ឃ) បញ្ហាកម្មសិទ្ធិបញ្ញាទាក់ទងនឹង៖

(i) សហគ្រាសធុនតូចនិងមធ្យម

(ii) សកម្មភាពវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

(iii) ការបង្កើត ការផ្ទេរ និងការផ្សព្វផ្សាយបច្ចេកវិទ្យា និង

(iv) ការលើកកម្ពស់ស្ត្រីនិងយុវជន

(ង) គោលនយោបាយពាក់ព័ន្ធនឹងការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ការស្រាវជ្រាវ នវានុវត្តន៍ និងកំណើនសេដ្ឋកិច្ច

(ច) ការអនុវត្តកិច្ចព្រមព្រៀងពហុភាគីស្តីពីកម្មសិទ្ធិបញ្ញាដូចជាកិច្ចព្រមព្រៀងដែលបានអនុម័តឬគ្រប់គ្រងដោយ WIPO

(ឆ) ការកសាងសមត្ថភាព

(ជ) ការពង្រឹងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា

(ឈ) ជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍកម្មសិទ្ធិបញ្ញា

(ញ) ធនធានពន្ធុ ចំណេះដឹងប្រពៃណី និងវិញ្ញត្តិវប្បធម៌

(ដ) ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

(ឋ) អង្គភាពគ្រប់គ្រងសិទ្ធិរួម

(ឌ) ឧស្សាហកម្មថ្នែប្រតិដ្ឋ និង

(ឍ) សកម្មភាពនិងគំនិតផ្តួចផ្តើមផ្សេងទៀតដែលអាចត្រូវបានកំណត់ទាំងសងខាងរវាងគូភាគី។

### មាត្រា១១.១២ _ កិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

១- គូភាគីទទួលស្គាល់ពីសារៈសំខាន់នៃការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធចុះបញ្ជីប្រកាសនីយបត្រតក្កកម្មរៀងៗខ្លួន ក៏ដូចជាការសម្រួលនិងធ្វើឱ្យសាមញ្ញនូវនីតិវិធីនិងដំណើរការនៃអង្គភាពប្រកាសនីយបត្រតក្កកម្មរៀងៗខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកប្រើប្រាស់ប្រព័ន្ធប្រកាសនីយបត្រតក្កកម្មនិងសាធារណជនទាំងអស់។

២- បន្ថែមលើកថាខណ្ឌ១ គូភាគីត្រូវខិតខំប្រឹងប្រែងសហការរវាងអង្គភាពប្រកាសនីយបត្រតក្កកម្ម របស់ខ្លួន ដើម្បីសម្រួលដល់ការចែករំលែកនិងប្រើប្រាស់ការងារស្រាវជ្រាវនិងពិនិត្យ។ កិច្ចការនេះ អាចរួមបញ្ចូល៖

(ក) ការធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវ និងការពិនិត្យអាចស្វែងរកបានដោយអង្គភាពប្រកាសនីយបត្រតក្កកម្មរបស់ភាគីផ្សេងទៀត និង

(ខ) ការផ្លាស់ប្តូរព័ត៌មានស្តីពីប្រព័ន្ធជានាគុណភាពនិងស្តង់ដាគុណភាពទាក់ទងនឹងការពិនិត្យប្រកាសនីយបត្រតក្កកម្ម។

៣- ដើម្បីកាត់បន្ថយនីតិវិធីស្មុគស្មាញនិងកម្រៃចំណាយនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម គូភាគីត្រូវខិតខំប្រឹងប្រែងសហការដើម្បីកាត់បន្ថយភាពខុសគ្នានៃនីតិវិធី និងដំណើរការរបស់អង្គភាពប្រកាសនីយបត្រតក្កកម្មរៀងៗខ្លួន។

## ផ្នែក គ ម៉ាក

### មាត្រា១១.១៣ _ ប្រភេទនៃសញ្ញាដែលអាចចុះបញ្ជីជាម៉ាក

ភាគីនីមួយៗត្រូវជានាថា សញ្ញាឬបង្គុំនៃសញ្ញាណាមួយដែលអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញនិងសេវាកម្មរបស់សហគ្រាសមួយពីទំនិញនិងសេវាកម្មរបស់សហគ្រាសផ្សេងទៀត ទើបអាចបង្កើតជាម៉ាក។ សញ្ញាទាំងនោះ ជាពិសេសពាក្យ រួមទាំងឈ្មោះបុគ្គល អក្សរ លេខ សមាសធាតុជារូបភាព រូបទម្រង់បីខ្នាត និងបង្គុំនៃពណ៌ ក៏ដូចជាបង្គុំនៃសញ្ញាទាំងនោះ ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការចុះបញ្ជីជាម៉ាក។ នៅពេលដែលសញ្ញាមិនមានភាពញែកជាច់ផ្ទាល់ចំពោះទំនិញឬសេវាកម្មដែលពាក់ព័ន្ធ គូភាគីអាចធ្វើការចុះបញ្ជីផ្អែកលើភាពញែកជាច់ដែលទទួលបានតាមរយៈការប្រើប្រាស់។ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងក្នុងការការពារម៉ាកជាសំឡេងនិងក្លិន។

### មាត្រា១១.១៤ _ ការប្រើប្រាស់សញ្ញាដែលដូចឬប្រហាក់ប្រហែលគ្នា

ភាគីនីមួយៗត្រូវផ្តល់ឱ្យម្ចាស់ម៉ាកដែលបានចុះបញ្ជី មានសិទ្ធិផ្តាច់មុខក្នុងការហាមភាគីទីបីដែលមិនមានការយល់ព្រមពីម្ចាស់ម៉ាក ពីការប្រើប្រាស់នៅក្នុងដំណើរការពាណិជ្ជកម្មនូវសញ្ញាដែលដូចឬប្រហាក់ប្រហែលសម្រាប់ទំនិញឬសេវាកម្មដែលដូចឬប្រហាក់ប្រហែល ទៅនឹងទំនិញឬសេវាកម្មរបស់ម្ចាស់ម៉ាកដែលត្រូវបានចុះបញ្ជី ដែលការប្រើប្រាស់បែបនេះបណ្តាលឱ្យមានការភ័ន្តច្រឡំ។ ក្នុងករណីនៃការប្រើប្រាស់សញ្ញាដែលដូចសម្រាប់ទំនិញឬសេវាកម្មដូចគ្នា ត្រូវចាត់ទុកថាមានការភ័ន្តច្រឡំ។

### មាត្រា១១.១៥ _ ការលើកលែង

ភាគីសមាជិកអាចផ្តល់នូវការលើកលែងដែលមានកម្រិត ចំពោះសិទ្ធិដែលទទួលបានពីការចុះបញ្ជីម៉ាក ដូចជាការប្រើប្រាស់ដោយត្រឹមត្រូវនៃពាក្យពណ៌នា ឱ្យតែការលើកលែងទាំងនោះគិតគូរពីផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់ម៉ាកនិងភាគីទីបី។

## មាត្រា១១.១៦ _ ម៉ាកល្បី

១- ពុំមានភាគីណាមួយត្រូវបានតម្រូវជាលក្ខខណ្ឌ សម្រាប់កំណត់ថាម៉ាកមួយគឺជាម៉ាកល្បី ថាម៉ាកនោះត្រូវធ្លាប់បានចុះបញ្ជីនៅភាគីនោះឬនៅក្នុងដែនយុត្តាធិការផ្សេងទៀត រួមទាំងមាននៅក្នុងបញ្ជីម៉ាកល្បីឬបានការទទួលស្គាល់ជាមុនថាជាម៉ាកល្បី។

២- មាត្រា៦ស្ងួននៃអនុសញ្ញាទីក្រុងប៉ារីស ត្រូវយកមកអនុវត្តផងដែរចំពោះទំនិញឬសេវាកម្មដែលមិនដូចឬប្រហាក់ប្រហែល ទៅនឹងទំនិញឬសេវាកម្មដែលកំណត់ដោយម៉ាកល្បីដែលបានចុះបញ្ជី[1] ឱ្យតែការប្រើប្រាស់ម៉ាកនោះពាក់ព័ន្ធនឹងទំនិញឬសេវាកម្មទាំងនោះអាចបង្ករបង្ហាញពីទំនាក់ទំនងរវាងទំនិញឬសេវាកម្មទាំងនោះនិងម្ចាស់ម៉ាក ហើយឱ្យតែផលប្រយោជន៍របស់ម្ចាស់ម៉ាកអាចរងការខូចខាតដោយសារការប្រើប្រាស់បែបនេះ។

៣- ភាគីនីមួយៗទទួលស្គាល់ពីសារៈសំខាន់នៃអនុសាសន៍រួមគ្នា ទាក់ទងនឹងបទប្បញ្ញត្តិស្តីពីការការពារម៉ាកល្បី ដែលត្រូវបានអនុម័តដោយសន្និបាតនៃសហភាពប៉ារីសសម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្មនិងមហាសន្និបាតរបស់WIPO នៅក្នុងកិច្ចប្រជុំជាសេរីលើកទី៣៤ នៃសន្និបាតរបស់រដ្ឋជាសមាជិក WIPO ថ្ងៃទី២០ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៩។

៤- ភាគីនីមួយៗត្រូវចែងពីវិធានការសមស្របក្នុងការបដិសេធពាក្យស្នើសុំ ឬលុបចោលការចុះបញ្ជីនិងហាមឃាត់ការប្រើប្រាស់ម៉ាកដែលដូចឬប្រហាក់ប្រហែលទៅនឹងម៉ាកល្បីមួយ[2] សម្រាប់ទំនិញឬសេវាកម្មដូចឬប្រហាក់ប្រហែល ប្រសិនបើការប្រើប្រាស់ម៉ាកនោះអាចនាំឱ្យមានការភ័ន្តច្រឡំទៅនឹងម៉ាកល្បីពីមុន។ ភាគីសមាជិកក៏អាចផ្តល់វិធានការបែបនេះ រួមទាំងក្នុងករណីដែលម៉ាកបន្តមន្ទាប់ដែលទំនងជាមានលក្ខណៈបោកបញ្ឆោត។

## មាត្រា១១.១៧ _ មូលដ្ឋានគតិយុត្តិនៃការពិនិត្យ ការប្តឹងជំទាស់ និងការលុបចេញពីបញ្ជី

ភាគីនីមួយៗត្រូវផ្តល់នូវប្រព័ន្ធសម្រាប់ការពិនិត្យនិងចុះបញ្ជីម៉ាក ដែលរួមទាំង៖

(ក) ការប្រាស្រ័យទាក់ទងជាមួយអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ អំពីមូលហេតុនៃការបដិសេធការចុះបញ្ជីម៉ាក ដែលអាចធ្វើតាមមធ្យោបាយអេឡិចត្រូនិក

(ខ) ការផ្តល់ឱ្យអ្នកដាក់ពាក្យស្នើសុំនូវឱកាស ដើម្បីឆ្លើយតបទៅនឹងទំនាក់ទំនងពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីតវ៉ានឹងការបដិសេធបឋមនិងធ្វើការប្តឹងតវ៉ាចំពោះការបដិសេធចុងក្រោយណាមួយក្នុងការចុះបញ្ជីម៉ាក

(គ) ការផ្តល់ឱកាសឱ្យមានការប្តឹងជំទាស់នឹងការចុះបញ្ជីម៉ាកឬបណ្តឹងលុបម៉ាក និង

(ឃ) ការតម្រូវឱ្យសេចក្តីសម្រេចរដ្ឋបាលនៅក្នុងនីតិវិធីបណ្តឹងជំទាស់ និងការលុបម៉ាកចេញពីបញ្ជីត្រូវមានហេតុផលនិងធ្វើជាលាយលក្ខណ៍អក្សរ ដែលអាចត្រូវបានផ្តល់ជូនតាមមធ្យោបាយអេឡិចត្រូនិក។

---

[1] ក្នុងការកំណត់ថា តើម៉ាកមួយជាម៉ាកល្បីនៅក្នុងភាគីសមាជិក ភាគីនោះមិនចាំបាច់តម្រូវថាកេរ្តិ៍ឈ្មោះម៉ាកមានសែលភាពគ្របដណ្តប់ហួសពីផ្នែកសាធារណៈដែលជាទូទៅពាក់ព័ន្ធនឹងទំនិញឬសេវាកម្មនោះ។

[2] គួរតែយល់ថា ម៉ាកល្បីគឺជាម៉ាកដែលល្បីរួចហើយមុនពេលដាក់ពាក្យស្នើសុំ ឬចុះបញ្ជី ឬប្រើប្រាស់ម៉ាកលើកដំបូង ដែលត្រូវកំណត់ដោយភាគីសមាជិក។

**មាត្រា១១.១៨ _ ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក**

កាតព្វកិច្ចមួយៗត្រូវខិតខំប្រឹងប្រែងផ្តល់នូវ៖

(ក) ប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនិងរក្សាការចុះបញ្ជីម៉ាក និង

(ខ) ប្រព័ន្ធព័ត៌មានអេឡិចត្រូនិកដែលមានជាសាធារណៈ រួមទាំងទិន្នន័យអនឡាញនៃពាក្យស្នើសុំចុះបញ្ជីម៉ាកនិងម៉ាកដែលបានចុះបញ្ជី។

**មាត្រា១១.១៩ _ ចំណាត់ថ្នាក់ទំនិញនិងសេវាកម្ម**

កាតព្វកិច្ចមួយៗត្រូវអនុម័តឬក្សាប្រព័ន្ធចំណាត់ថ្នាក់ម៉ាក ដែលស្របតាមកិច្ចព្រមព្រៀងទីក្រុងនីសស្តីពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាកម្ម សម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ដែលធ្វើឡើងនៅទីក្រុងនីស នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៧ ដែលបានកែសម្រួលនិងធ្វើវិសោធនកម្ម (ចំណាត់ថ្នាក់ទីក្រុងនីស)។ កាតព្វកិច្ចមួយៗត្រូវផ្តល់៖

(ក) ការចុះបញ្ជីនិងការបោះពុម្ពផ្សាយនៃពាក្យស្នើសុំចុះបញ្ជី ត្រូវបង្ហាញពីទំនិញនិងសេវាកម្មតាមឈ្មោះ ដោយចាត់ជាក្រុមតាមចំណាត់ថ្នាក់ដែលបង្កើតឡើងដោយចំណាត់ថ្នាក់ទីក្រុងនីស[3] និង

(ខ) ទំនិញឬសេវាកម្មអាចមិនត្រូវបានចាត់ទុកថាមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយផ្អែកលើមូលដ្ឋានថា នៅក្នុងការចុះបញ្ជីឬការបោះពុម្ពផ្សាយណាមួយ ទំនិញឬសេវាកម្មទាំងនោះ ត្រូវបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់តែមួយនៃចំណាត់ថ្នាក់ទីក្រុងនីស។ ផ្ទុយមកវិញ កាតព្វកិច្ចមួយៗត្រូវផ្តល់ថាទំនិញឬសេវាកម្មអាចមិនត្រូវបានចាត់ទុកថាខុសគ្នាដោយផ្អែកលើមូលដ្ឋានថា នៅក្នុងការចុះបញ្ជីឬការបោះពុម្ពផ្សាយណាមួយត្រូវបានចាត់ថ្នាក់ក្នុងចំណាត់ថ្នាក់ផ្សេងគ្នានៃចំណាត់ថ្នាក់ទីក្រុងនីស។

**មាត្រា១១.២០ _ រយៈពេលការពារម៉ាក**

កាតព្វកិច្ចមួយៗត្រូវផ្តល់ថា ការចុះបញ្ជីម៉ាកដំបូងនិងការចុះបញ្ជីម៉ាកសាជាថ្មី មានរយៈពេលមិនតិចជាង ១០ឆ្នាំ។

## ផ្នែក ឃ ឈ្មោះប្រទេស

**មាត្រា១១.២១ _ ឈ្មោះប្រទេស**

កាតព្វកិច្ចមួយៗត្រូវផ្តល់នូវមធ្យោបាយផ្លូវច្បាប់ សម្រាប់បុគ្គលដែលពាក់ព័ន្ធក្នុងការទប់ស្កាត់ការប្រើប្រាស់លក្ខណៈពាណិជ្ជកម្មនៃឈ្មោះប្រទេសរបស់កាតព្វកិច្ចសមាជិកទាក់ទងនឹងទំនិញឬសេវាកម្ម ដែលធ្វើឱ្យអ្នកប្រើប្រាស់ភ័ន្តច្រឡំអំពីប្រភពដើមនៃទំនិញនិងសេវាកម្មនោះ។

---

[3] កាតព្វកិច្ចសមាជិកដែលពឹងផ្អែកលើការបកប្រែចំណាត់ថ្នាក់ទីក្រុងនីស ត្រូវអនុវត្តតាមកំណែប្រែដែលបានធ្វើបច្ចុប្បន្នភាពនៃចំណាត់ថ្នាក់ទីក្រុងនីសត្រឹមកម្រិតដែលការបកប្រែជាផ្លូវការត្រូវបានធ្វើឡើងនិងបោះផ្សាយ។

## ផ្នែក ឆ ម៉ាកសម្គាល់កូមិសាស្ត្រទំនិញ

### មាត្រា១១.២២ _ កិច្ចការពារឬការទទួលស្គាល់ម៉ាកសម្គាល់កូមិសាស្ត្រទំនិញ

១- ម៉ាកសម្គាល់កូមិសាស្ត្រទំនិញ សំដៅដល់ការសម្គាល់ដែលកំណត់អត្តសញ្ញាណទំនិញថាមានដើមកំណើតនៅក្នុងដែនដីនៃភាគីសមាជិកឬតំបន់ឬមូលដ្ឋាននៅក្នុងដែនដីនោះ ដែលបានផ្តល់ជាគុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញ ដែលកើតចេញពីតំបន់កូមិសាស្ត្រនោះ។

២- គូភាគីទទួលស្គាល់ថា ម៉ាកសម្គាល់កូមិសាស្ត្រទំនិញអាចត្រូវបានការពារតាមរយៈប្រព័ន្ធម៉ាកឬប្រព័ន្ធដោយឡែក។

### មាត្រា១១.២៣ _ នីតិវិធីរដ្ឋបាលសម្រាប់ការការពារម៉ាកសម្គាល់កូមិសាស្ត្រទំនិញ

ប្រសិនបើភាគីសមាជិកផ្តល់នូវនីតិវិធីរដ្ឋបាលសម្រាប់ការការពារ ឬការទទួលស្គាល់ម៉ាកសម្គាល់កូមិសាស្ត្រទំនិញ ទោះជាតាមប្រព័ន្ធម៉ាកឬប្រព័ន្ធដោយឡែកពាក់ព័ន្ធនឹងការស្នើសុំការការពារឬបណ្តឹង ភាគីនោះត្រូវធានាថា ច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនដែលគ្រប់គ្រងការដាក់ពាក្យស្នើសុំឬបណ្តឹងទាំងនោះ គឺត្រូវមានជាសាធារណៈនិងកំណត់នីតិវិធីច្បាស់លាស់សម្រាប់សកម្មភាពទាំងនេះ។

### មាត្រា១១.២៤ _ កាលបរិច្ឆេទការពារម៉ាកសម្គាល់កូមិសាស្ត្រទំនិញ

ប្រសិនបើភាគីសមាជិកផ្តល់ការការពារឬទទួលស្គាល់ម៉ាកសម្គាល់កូមិសាស្ត្រទំនិញ ដែលការការពារឬការទទួលស្គាល់ត្រូវចាប់ផ្តើមពីពេលចុះកាលបរិច្ឆេទ[4]របស់ភាគីនោះឬកាលបរិច្ឆេទចុះបញ្ជីរបស់ភាគីនោះតាមករណីនីមួយៗ។

## ផ្នែក ច ប្រកាសនីយបត្រតក្កកម្មនិងតំនួរខេសព្វាហកម្ម

### មាត្រា១១.២៥ _ រយៈពេលអន្តរកាល

១. ភាគីនីមួយៗមិនត្រូវទទួលស្គាល់ព័ត៌មានដែលលាតត្រដាងជាសាធារណៈនៃតក្កកម្មទាក់ទងនឹងសំណុំលិខិតស្នើសុំដើម្បីចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម[5] ប្រសិនបើការលាតត្រដាងសាធារណៈនោះ៖

(ក) ត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកស្នងរបស់បុព្វជន ឬបុគ្គលដែលទទួលបានព័ត៌មានពីអ្នកដាក់ពាក្យស្នើសុំឬអ្នកស្នងរបស់បុព្វជន នៅក្នុងឬក្រៅដែនដីនៃភាគីសមាជិក និង

---

[4] សម្រាប់ភាពប្រាកដប្រជា កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដែលចែងក្នុងមាត្រានេះ រួមទាំងកាលបរិច្ឆេទអាទិភាពនៃការដាក់ពាក្យស្នើសុំក្រោមអនុសញ្ញាទីក្រុងប៉ារីស ប្រសិនបើមាន។

[5] សម្រាប់ភាពប្រាកដប្រជា ប្រកាសនីយបត្រតក្កកម្មអាចរួមបញ្ចូលទាំងម៉ូដែលសម្រាប់ការប្រើប្រាស់ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាតិ។

(ខ) បានកើតឡើងក្នុងរយៈពេលយ៉ាងតិច ១២ ខែ មុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំស្របតាមច្បាប់និងបទប្បញ្ញត្តិជាតិនៃភាគីនីមួយៗ។

២. ភាគីនីមួយៗមិនត្រូវទទួលស្គាល់ព័ត៌មានដែលលាតត្រដាងជាសាធារណៈ ទាក់ទងនឹងការដាក់ពាក្យស្នើសុំដើម្បីចុះបញ្ជីគំនូរឧស្សាហកម្ម ប្រសិនបើការលាតត្រដាងជាសាធារណៈនោះ៖

(ក) ត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកស្នងរបស់បុព្វជន ឬបុគ្គលដែលទទួលបានព័ត៌មានពីអ្នកដាក់ពាក្យស្នើសុំឬអ្នកស្នងរបស់បុព្វជន នៅក្នុងឬក្រៅដែនដីនៃភាគីសមាជិក និង

(ខ) បានកើតឡើងក្នុងរយៈពេលយ៉ាងតិច១២ខែមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំស្របតាមច្បាប់និងបទប្បញ្ញត្តិជាតិនៃភាគីនីមួយៗ។

**មាត្រា១១.២៦ _ និដ្ឋភាពនីតិវិធីនៃការត្រួតពិនិត្យ ការប្តឹងជំទាស់ និងអោយភាពប្រកាសនីយបត្រគក្តកម្ម និងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីមួយចំនួន**

ភាគីនីមួយៗត្រូវផ្តល់ប្រព័ន្ធពិនិត្យនិងចុះបញ្ជីប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្ម ដែលរួមបញ្ចូល៖

(ក) ការប្រាស្រ័យទាក់ទងជាមួយអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ អំពីមូលហេតុនៃការបដិសេធការចុះបញ្ជីប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្ម ដែលអាចធ្វើតាមមធ្យោបាយអេឡិចត្រូនិក

(ខ) ការផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំ ដើម្បីឆ្លើយតបទៅនឹងទំនាក់ទំនងរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីតវ៉ានឹងការបដិសេធបឋមណាមួយ និងធ្វើការប្តឹងតវ៉ាតាមប្រព័ន្ធតុលាការ ចំពោះការបដិសេធចុងក្រោយណាមួយនៃការចុះបញ្ជីប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្ម

(គ) ការផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ ក្នុងការស្នើសុំលុបឬធ្វើមោឃភាពប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្មដែលបានចុះបញ្ជី ហើយបន្ថែមលើនេះ អាចផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ ដើម្បីជំទាស់នឹងការចុះបញ្ជីប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្ម និង

(ឃ) ការធ្វើសេចក្តីសម្រេចនៅក្នុងនីតិវិធីនៃបណ្តឹងជំទាស់ បណ្តឹងលុប ឬបណ្តឹងមោឃភាពត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជាក់ពីមូលហេតុដែលអាចបញ្ជូនដោយមធ្យោបាយអេឡិចត្រូនិក។

**មាត្រា១១.២៧ _ វិសោធនកម្ម ការកែតម្រូវ និងការសង្កេត**

ភាគីនីមួយៗត្រូវផ្តល់ឱ្យអ្នកដាក់ពាក្យស្នើសុំប្រកាសនីយបត្រគក្តកម្មឬគំនូរឧស្សាហកម្ម យ៉ាងហោចណាស់នូវឱកាសចំនួនមួយ ដើម្បីធ្វើវិសោធនកម្ម ការកែតម្រូវ ឬការសង្កេតទាក់ទងនឹងពាក្យស្នើសុំរបស់ខ្លួននៅក្នុងព្រំដែននៃការបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំបឋម ស្របតាមច្បាប់និងបទប្បញ្ញត្តិជាតិរបស់ភាគីនីមួយៗ។

**មាត្រា១១.២៨ _ ការការពារគំនូរឧស្សាហកម្ម**

១- គូភាគីត្រូវជានាថា លក្ខខណ្ឌតម្រូវសម្រាប់ការធានា ឬការអនុវត្តការការពារគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជី ដោយមិនធ្វើឱ្យប៉ះពាល់ដល់ឱកាសក្នុងការទទួលបានឬអនុវត្តការការពារ ដោយមិនសមហេតុផល។

២- រយៈពេលនៃការការពារគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីត្រូវមានរយៈពេលសរុបយ៉ាងហោចណាស់១៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។

**មាត្រា១១.២៩ _ ការលើកលែង**

ភាគីសមាជិកអាចផ្តល់នូវការលើកលែងដែលមានកម្រិត ចំពោះសិទ្ធិផ្តាច់មុខដែលផ្តល់ដោយប្រកាសនីយបត្រតក្តកម្មឬគំនូរឧស្សាហកម្ម ឱ្យតែការផ្តល់ការលើកលែងនេះមិនមានទំនាស់មិនសមហេតុផលដល់ការធ្វើអាជីវកម្មជាធម្មតានៃប្រកាសនីយបត្រតក្តកម្មឬគំនូរឧស្សាហកម្ម និងមិនធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់សិទ្ធិ ដោយគិតពីប្រយោជន៍ស្របច្បាប់របស់ភាគីទីបី។

## ផ្នែក ឆ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

**មាត្រា១១.៣០ _ និយមន័យ**

សម្រាប់គោលបំណងនៃមាត្រា១១.៣១ និងមាត្រា១១.៣៣ ដល់មាត្រា១១.៤០ និយមន័យខាងក្រោមអនុវត្តចំពោះអ្នកសម្តែងនិងផលិតកហ្វូណូក្រាម៖

(ក) **ទូរផ្សាយ** មានន័យថាការផ្សាយដោយមធ្យោបាយឥតខ្សែ សម្រាប់ការទទួលបានដោយសាធារណៈនូវសំឡេងឬរូបភាព និងសំឡេងឬនិមិត្តសញ្ញានៃសំឡេងឬរូបភាព ការផ្សាយបែបនេះតាមផ្កាយរណបត្រូវបានចាត់ទុកជាទូរផ្សាយផងដែរ ការផ្សាយតាមកុងនីយកម្មសញ្ញាគឺជា "ទូរផ្សាយ" ប្រសិនបើមធ្យោបាយកុងនីយកម្មត្រូវបានផ្តល់ឱ្យជាសាធារណៈដោយអង្គភាពទូរផ្សាយឬដោយមានការយល់ព្រមពីអង្គភាពទូរផ្សាយ

(ខ) **ការផ្សព្វផ្សាយជាសាធារណៈនៃការសម្តែងឬហ្វូណូក្រាម** មានន័យថាការផ្សាយជាសាធារណៈដោយមធ្យោបាយណាមួយ ក្រៅពីការផ្សាយតាមទូរផ្សាយនៃសំឡេងនៃការសម្តែង ឬសំឡេង ឬនិមិត្តសញ្ញានៃសំឡេងដែលបានថតបញ្ចូលទៅក្នុងហ្វូណូក្រាម

(គ) **ការថតបញ្ចូល** មានន័យថាការថតបញ្ចូលសំឡេងឬនិមិត្តសញ្ញានៃសំឡេង ដែលអាចឱ្យទទួលបាន ផលិតឡើងវិញ ឬផ្សព្វផ្សាយ តាមរយៈឧបករណ៍មួយ

(ឃ) **ការសម្តែង** មានន័យថាការសម្តែងដែលបានថតបញ្ចូលឬមិនបានថតបញ្ចូលក្នុងហ្វូណូក្រាមលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ

(ង) **អ្នកសម្តែង** មានន័យថាតួសម្តែង អ្នកចម្រៀង តន្ត្រីករ អ្នករាំ និងបុគ្គលផ្សេងទៀតដែលសម្តែង ច្រៀង បង្ហាញ ថ្លែង ដើរតួ បកប្រែ ឬសម្តែងស្នាដៃអក្សរសាស្ត្រ ឬសិល្បៈផ្សេងទៀត ឬវិញ្ញត្តិវប្បធម៌

(ច) **ហ្វូណូក្រាម** មានន័យថា ការថតបញ្ចូលសំឡេងនៃការសម្តែង ឬសំឡេងផ្សេងទៀត ឬនិមិត្តសញ្ញានៃសំឡេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត

(ឆ) **ផលិតកហ្វូណូក្រាម** មានន័យថា បុគ្គលដែលផ្តួចផ្តើមគំនិតនិងមានការទទួលខុសត្រូវសម្រាប់ការថតបញ្ចូលលើកដំបូងនៃសំឡេងនៃការសម្តែង ឬសំឡេងផ្សេងទៀត ឬនិមិត្តសញ្ញានៃសំឡេង

(ជ) **ការបោះផ្សាយការសម្តែងឬហ្វូណូក្រាម** មានន័យថា ការផ្តល់ការថតចម្លងការសម្តែង ឬហ្វូណូក្រាមដល់សាធារណជន ដោយមានការយល់ព្រមពីម្ចាស់សិទ្ធិ ឱ្យតែការថតចម្លងនេះត្រូវបានផ្តល់ជូនសាធារណជនក្នុងបរិមាណមួយសមហេតុផល

(ឈ) ទាក់ទងនឹងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល សិទ្ធិក្នុងការអនុញ្ញាតឬហាមឃាត់សំដៅលើសិទ្ធិផ្តាច់មុខ។

### មាត្រា១១.៣១ _ សិទ្ធិផលិតឡើងវិញ

ភាគីនីមួយៗត្រូវផ្តល់[6]ដល់អ្នកនិពន្ធ អ្នកសម្តែង និងផលិតកហ្វូណូក្រាម[7] នូវសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឬហាមឃាត់រាល់ការផលិតឡើងវិញនូវស្នាដៃ ការសម្តែង ឬហ្វូណូក្រាមគ្រប់ទម្រង់ទាំងអស់ រួមទាំងក្នុងទម្រង់អេឡិចត្រូនិកផងដែរ។

### មាត្រា១១.៣២ _ សិទ្ធិក្នុងការផ្សព្វផ្សាយជាសាធារណៈ

ដោយមិនប៉ះពាល់ដល់មាត្រា១១(១)(ii) មាត្រា១១ស្នូន (១)(i) និង (ii) មាត្រា១១ស្នូន៣ (១)(ii) មាត្រា១៨(១)(ii) និងមាត្រា១៨ស្នូន(១) នៃអនុសញ្ញាទីក្រុងប៊ែន ភាគីនីមួយៗត្រូវផ្តល់ដល់អ្នកនិពន្ធនូវសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ឬហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃរបស់ខ្លួនតាមមធ្យោបាយដោយប្រើខ្សែឬឥតខ្សែ រួមទាំងការដាក់ជូនសាធារណជននូវស្នាដៃរបស់ពួកគេតាមរបៀបដែលសមាជិកសាធារណៈអាចទទួលបានស្នាដៃទាំងនេះពីទីកន្លែងឬនៅពេលណាមួយក៏បាន[8]។

### មាត្រា១១.៣៣ _ សិទ្ធិចែកចាយ

ភាគីនីមួយៗត្រូវផ្តល់ដល់អ្នកនិពន្ធ អ្នកសម្តែង និងផលិតកហ្វូណូក្រាមនូវសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឬហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ដើមនិងច្បាប់ចម្លង[9]ស្នាដៃសម្តែង ឬហ្វូណូក្រាមរបស់ខ្លួន តាមរយៈការលក់ឬការផ្ទេរកម្មសិទ្ធិផ្សេងទៀត។

---

[6] សម្រាប់គោលប្រកាសដ៏ប្រជា គូភាគីយល់ថា វាជាបញ្ហាច្បាប់របស់ភាគីនីមួយៗក្នុងការកំណត់ថាស្នាដៃ ការសម្តែង ឬហ្វូណូក្រាមជាទូទៅ ឬប្រភេទជាក់លាក់ណាមួយនៃស្នាដៃ ការសម្តែង និងហ្វូណូក្រាមមិនត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធឬសិទ្ធិប្រហាក់ប្រហែល លុះត្រាតែស្នាដៃនៃការសម្តែងឬហ្វូណូក្រាមនោះត្រូវបានថតបញ្ចូលក្នុងទម្រង់សម្ភារៈណាមួយ។

[7] ការសំដៅទៅ "អ្នកនិពន្ធ អ្នកសម្តែង និងផលិតកហ្វូណូក្រាម" ក៏សំដៅផងដែរដល់អ្នកស្នងផលប្រយោជន៍របស់ពួកគេ។

[8] គូភាគីយល់ថា ការផ្តល់គ្រឿងបរិក្ខារបន្ថែមសម្រាប់បើកនិងបង្កើតការផ្សព្វផ្សាយ មិនអាចចាត់ទុកថាជាការផ្សព្វផ្សាយក្នុងអត្ថន័យនៃដំពូកនេះ ឬអនុសញ្ញាទីក្រុងប៊ែននោះទេ។ គូភាគីយល់បន្ថែមទៀតថា គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះរារាំងភាគីណាមួយពីការអនុវត្តមាត្រា១០ស្នូន(២) នៃអនុសញ្ញាទីក្រុងប៊ែននោះទេ។

[9] ពាក្យថា "ច្បាប់ចម្លង" និង "ច្បាប់ដើមនិងច្បាប់ចម្លង" ដែលជាកម្មវត្ថុនៃសិទ្ធិចែកចាយនៅក្នុងមាត្រានេះ សំដៅផ្តាច់មុខដល់ច្បាប់ចម្លងដែលបានថតបញ្ចូលដែលអាចដាក់ឱ្យចរាចរជាវត្ថុរូបវន្ត។

**មាត្រា១១.៣៤ _ សិទ្ធិប្រមាក់ប្រមែល**

១- ភាគីនីមួយៗត្រូវផ្តល់សិទ្ធិដែលមានចែងក្នុងជំពូកនេះ ដែលទាក់ទងអ្នកសម្តែង ផលិតកហ្វូណូក្រាម៖ ទៅអ្នកសម្តែងនិងផលិតកហ្វូណូក្រាមដែលជាពលរដ្ឋ[10]នៃភាគីផ្សេងទៀត និងទៅការសម្តែងឬហ្វូណូក្រាម ដែលបានផ្សព្វផ្សាយលើកដំបូងឬត្រូវបានថតបញ្ចូលលើកដំបូង[11]នៅក្នុងដែនដីនៃភាគីផ្សេងទៀត[12]។ ការសម្តែងឬហ្វូណូក្រាមត្រូវបានចាត់ទុកថា បានបោះពុម្ពផ្សាយលើកដំបូងនៅក្នុងដែនដីនៃភាគីសមាជិក ប្រសិនបើវាត្រូវបានបោះពុម្ពផ្សាយនៅក្នុងដែនដីនៃភាគីនោះក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយដើម។

២- ភាគីនីមួយៗត្រូវផ្តល់ឱ្យអ្នកសម្តែងនូវសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឬហាមឃាត់៖

(ក) ការផ្សាយតាមទូរផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈនៃការសម្តែងដែលមិនបានថតបញ្ចូល លើកលែងតែការសម្តែងនោះជាការសម្តែងដែលបានផ្សព្វផ្សាយតាមទូរផ្សាយរួចហើយ និង

(ខ) ការថតបញ្ចូលនៃការសម្តែងដែលមិនទាន់បានថតបញ្ចូល។

៣- ភាគីនីមួយៗត្រូវផ្តល់ឱ្យអ្នកសម្តែងនិងផលិតកហ្វូណូក្រាមនូវសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ឬហាមឃាត់ការផ្សាយតាមទូរផ្សាយនូវការសម្តែងឬហ្វូណូក្រាមរបស់ខ្លួន ដោយមធ្យោបាយប្រើខ្សែឬឥតខ្សែ[13,14] និងការផ្សព្វផ្សាយជាសាធារណៈនូវការសម្តែងឬហ្វូណូក្រាមទាំងនោះ តាមរបៀបដែលសមាជិកសាធារណៈអាចទទួលបានស្នាដៃទាំងនេះពីទីកន្លែង ឬនៅពេលណាមួយ។

៤- ទោះបីជាមានចែងក្នុងកថាខណ្ឌ៣និងមាត្រា១១.៣៦ ការអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌ ៣ ចំពោះប្រព័ន្ធផ្សព្វផ្សាយអាណាឡូកនិងតាមរលកជាតុអាកាសដោយគ្មានអន្តរកម្ម និងការលើកលែងឬការកម្រិតសិទ្ធិចំពោះសកម្មភាពទាំងនោះ គឺអាស្រ័យលើច្បាប់នៃប្រទេសភាគីនីមួយៗ[15]។

---

[10] សម្រាប់គោលបំណងនៃការកំណត់លក្ខណៈនៃថ្នូរសម្រាប់ការទទួលបានសិទ្ធិក្រោមមាត្រានេះ ចំពោះអ្នកសម្តែង ភាគីសមាជិកផ្តល់ប្រព្រឹត្តកម្មដល់ "ពលរដ្ឋ" ដូចពលរដ្ឋដែលបានបំពេញតាមលក្ខណៈនៃថ្នូរសម្រាប់ទទួលបានសិទ្ធិ តាមមាត្រា ៣ នៃសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែង និងហ្វូណូក្រាម។

[11] សម្រាប់គោលបំណងនៃមាត្រានេះ ការថតបញ្ចូលមានន័យថាការថតបញ្ចូលបញ្ចប់ចុងក្រោយនៃខ្សែអាត់មេ ឬឧបករណ៍ដែលមានតម្លៃស្មើ។

[12] ដើម្បីឱ្យកាន់តែច្បាស់ នៅក្នុងកថាខណ្ឌនេះ៖ទាក់ទងនឹងការសម្តែងឬហ្វូណូក្រាមដែលបានបោះពុម្ពផ្សាយលើកដំបូងឬត្រូវបានថតបញ្ចូលលើកដំបូងនៅក្នុងដែនដីនៃភាគីសមាជិក ភាគីសមាជិកអាចអនុវត្តលក្ខណៈនៃថ្នូរនៃការបោះពុម្ពផ្សាយ ឬជម្រើសផ្សេងពីនេះ លក្ខណៈនៃថ្នូរនៃការថតបញ្ចូល ឬទាំងពីរ។ ដើម្បីឱ្យកាន់តែច្បាស់ ស្របតាមមាត្រា១១.៣ នៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវផ្តល់ជូនការសម្តែងនិងហ្វូណូក្រាមដែលបានបោះពុម្ពផ្សាយលើកដំបូងឬត្រូវបានថតបញ្ចូលលើកដំបូងនៅក្នុងដែនដីនៃភាគីផ្សេងទៀត នូវប្រព្រឹត្តកម្មមិនតិចជាងដែលខ្លួនបានផ្តល់ឱ្យការសម្តែងឬហ្វូណូក្រាមដែលបានបោះពុម្ពផ្សាយលើដំបូងឬថតបញ្ចូលលើកដំបូងនៅក្នុងដែនដីរបស់ខ្លួន។

[13] ទាក់ទងនឹងការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ ភាគីសមាជិកអាចបំពេញភាតព្វកិច្ចដោយអនុវត្តមាត្រា ១៥(១)និងមាត្រា ១៥(៤) នៃសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែង និងហ្វូណូក្រាម និងអាចអនុវត្តមាត្រា ១៥(២) សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាម ប៉ុន្តែធ្វើឡើងស្របតាមភាតព្វកិច្ចរបស់ភាគីនោះក្រោមមាត្រា ១១.៣ នៃកិច្ចព្រមព្រៀងនេះ។

[14] ដើម្បីឱ្យកាន់តែច្បាស់ ភាតព្វកិច្ចក្នុងកថាខណ្ឌនេះមិនរាប់បញ្ចូលការផ្សាយទូរផ្សាយឬការផ្សព្វផ្សាយជាសាធារណៈ តាមខ្សែឬឥតខ្សែ នៃសំឡេងឬនិមិត្តសញ្ញានៃសំឡេងដែលបានថតបញ្ចូលក្នុងហ្វូណូក្រាម ដែលត្រូវបានបញ្ចូលក្នុងស្នាដៃភាពយន្តឬស្នាដៃសោតទស្សន៍ផ្សេងទៀត។

[15] សម្រាប់គោលបំណងវាក្យខណ្ឌនេះ គួរតែយល់ថាភាគីសមាជិកអាចផ្តល់ការផ្សាយឡើងវិញនៃការផ្សាយតាមរលកជាតុអាកាសដោយសៅដោយគ្មានអន្តរកម្ម ប៉ុន្តែការផ្សាយឡើងវិញទាំងនេះត្រូវបានអនុញ្ញាតតាមច្បាប់ដោយអាជ្ញាធរផ្សព្វផ្សាយនៃផ្ទៃកិបាលរបស់ភាគីនោះ។ អង្គភាពណាមួយដែលពាក់ព័ន្ធនឹងការផ្សាយឡើងវិញទាំងនេះ ត្រូវអនុលោមតាមវិធាន បទបញ្ជា ឬបទប្បញ្ញត្តិពាក់ព័ន្ធនៃអាជ្ញាធរនោះ ហើយការផ្សាយឡើងវិញទាំងនេះមិនរាប់បញ្ចូលការបញ្ជូននិងការទទួលបានតាមអ៊ីនធឺណិតនោះទេ។ ដើម្បីឱ្យកាន់តែច្បាស់ លេខយោងនេះមិនកម្រិតលទ្ធភាពរបស់ភាគីសមាជិកក្នុងការអនុវត្តវាក្យខណ្ឌនេះឡើយ។

**មាត្រា១១.៣៥ _ រយៈពេលការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល**

ភាគីនីមួយៗត្រូវផ្តល់រយៈពេលការពារស្នាដៃ ការសម្តែង ឬហ្វូណូក្រាម ដែលត្រូវបានគណនា[16]៖

(ក) ផ្អែកលើមូលដ្ឋានជីវិតរបស់រូបវន្តបុគ្គល រយៈពេលមិនត្រូវតិចជាងមួយជីវិតរបស់អ្នកនិពន្ធបូកថែម៥០ឆ្នាំ បន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ[17] និង

(ខ) ផ្អែកលើមូលដ្ឋានក្រៅពីជីវិតរបស់រូបវន្តបុគ្គល រយៈពេលគឺ៖

(i) មិនត្រូវតិចជាង៥០ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃការបោះពុម្ពផ្សាយ[18] ស្នាដៃ ការសម្តែងឬហ្វូណូក្រាម ដែលមានការអនុញ្ញាតលើកដំបូង ឬ

(ii) ស្នាដៃអនាមិកនិងស្នាដៃរហស្សនាមត្រូវបានការពាររយៈពេល៥០ឆ្នាំ គិតចាប់ពីដើមឆ្នាំប្រក្រតីទិន បន្ទាប់ពីឆ្នាំដែលស្នាដៃទាំងនោះត្រូវបានបោះពុម្ពផ្សាយលើកដំបូង[19]

(iii) ការសម្តែងឬហ្វូណូក្រាម ត្រូវមានរយៈពេលការពារមិនតិចជាង៥០ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំបង្កើតស្នាដៃ ការសម្តែង ឬហ្វូណូក្រាមនោះ។

**មាត្រា១១.៣៦ _ ដែនកំណត់ និងការលើកលែង**

១- ចំពោះផ្នែកនេះ ភាគីនីមួយៗត្រូវកំណត់ពីដែនកំណត់ឬការលើកលែងចំពោះសិទ្ធិផ្តាច់មុខក្នុងករណីពិសេសមួយចំនួនដែលមិនធ្វើឱ្យមានទំនាស់ដល់ការធ្វើអាជីវកម្មជាធម្មតានៃស្នាដៃ ការសម្តែង ឬហ្វូណូក្រាម និងមិនធ្វើឱ្យខូចប្រយោជន៍ស្របច្បាប់របស់ម្ចាស់សិទ្ធិ។

២- មាត្រានេះមិនកាត់បន្ថយឬពង្រីកវិសាលភាពនៃការអនុវត្តដែនកំណត់និងការលើកលែង ដែលអនុញ្ញាតដោយកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា អនុសញ្ញាទីក្រុងប៊ែន សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីសិទ្ធិអ្នកនិពន្ធ ឬសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាមឡើយ។

**មាត្រា១១.៣៧ _ តុល្យភាពនៅក្នុងប្រព័ន្ធសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល**

ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងសម្រេចឱ្យបាននូវតុល្យភាពសមស្រប នៅក្នុងប្រព័ន្ធសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលជាអាទិ៍ តាមមធ្យោបាយនៃដែនកំណត់ឬការលើកលែងដែលស្របតាមមាត្រា១១.៣៦ រួមទាំងសម្រាប់បរិស្ថានឌីជីថល ដោយយកចិត្តទុកដាក់ចំពោះគោលបំណងស្របច្បាប់ ដូចជា ចំពោះការិះគន់ ការផ្តល់មតិយោបល់ ការរាយការណ៍ព័ត៌មាន ការបង្រៀន ការផ្តល់អាហារូបករណ៍ ការស្រាវជ្រាវ និង

---

[16] ដើម្បីឱ្យកាន់តែច្បាស់ ក្នុងការអនុវត្តមាត្រានេះ ពុំមានអ្វីក៏ងភាគីសមដិកពីការលើកម្ពស់ភាពជាក់លាក់ចំពោះការប្រើប្រាស់និងការធ្វើអាជីវកម្មស្របច្បាប់នៃស្នាដៃ ការសម្តែង ឬហ្វូណូក្រាមក្នុងអំឡុងពេលនៃការការពារ អនុលោមតាមមាត្រា១១.៣៦និងភាគព្វកិច្ចអន្តរជាតិរបស់ភាគីនោះ។

[17] តុភាគីយល់ថា ប្រសិនបើភាគីសមដិកផ្តល់ឱ្យពលរដ្ឋរបស់ខ្លួនន្ថែរយៈពេលការការពារសិទ្ធិអ្នកនិពន្ធលើសពីមួយជីវិតរបស់អ្នកនិពន្ធបូកថែម៧០ឆ្នាំ នោះ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះឬមាត្រា១១.៧ ត្រូវកាំងភាគីនោះពីការអនុវត្តមាត្រា(៨) នៃអនុសញ្ញាទីក្រុងប៊ែន ចំពោះរយៈពេលការពារដែលលើសពីរយៈពេល ដែលមានចែងក្នុងវាក្យខណ្ឌនេះអំពីការការពារស្នាដៃរបស់ភាគីផ្សេងទៀត។

[18] ដើម្បីឱ្យកាន់តែច្បាស់ សម្រាប់គោលបំណងនៃវាក្យខណ្ឌ(ខ) ប្រសិនបើច្បាប់របស់ភាគីសមដិកចែងពីការគណនារយៈពេលគិតចាប់ពីការថតបញ្ចូលជាជាងការបោះពុម្ពផ្សាយដែលបានអនុញ្ញាតលើកដំបូង ភាគីនោះអាចបន្តគណនារយៈពេលគិតចាប់ពីការថតបញ្ចូល។

[19] ក្នុងករណីអ្នកនិពន្ធស្នាដៃនោះត្រូវបានគេស្គាល់ឬបញ្ជាក់ឬបានបង្ហាញពីអត្តសញ្ញាណរបស់គាត់ ការការពារនឹងមានរយៈពេលមួយជីវិតរបស់អ្នកនិពន្ធ និង៥០ឆ្នាំ បន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ។

គោលបំណងប្រហាក់ប្រហែលផ្សេងទៀត និងជួយសម្រួលដល់ការទទួលបានស្នាដៃដែលបានបោះពុម្ពផ្សាយ សម្រាប់ជនពិការភ្នែក ចាត់បង់សមត្ថភាពចក្ខុវិញ្ញាណ ឬជនមានពិការភាពស្នាដៃបោះពុម្ពដទៃទៀត[20,21]។

**មាត្រា១១.៣៨ _ កិច្ចសន្យាផ្ទេរសិទ្ធិ**

ចំពោះសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ភាគីនីមួយៗត្រូវចែងថា បុគ្គលណាមួយដែលទទួលបានឬកាន់កាប់សិទ្ធិបេតិកភណ្ឌ[22]នៃស្នាដៃ ការសម្តែង ឬហ្វូណូក្រាម៖

(ក) អាចផ្ទេរសិទ្ធិនោះដោយសេរីនិងដោយឡែកពីគ្នាតាមកិច្ចសន្យា និង

(ខ) តាមរយៈកិច្ចសន្យា រួមទាំងកិច្ចសន្យាការងារដែលចែងពីការបង្កើតស្នាដៃ ការសម្តែង ឬហ្វូណូក្រាម អាចអនុវត្តសិទ្ធិនោះក្នុងនាមបុគ្គលនោះផ្ទាល់ និងទទួលបានអត្ថប្រយោជន៍ពេញលេញដែលកើតចេញពីសិទ្ធិនោះ[23]។

**មាត្រា១១.៣៩ _ ភាពឯកិច្ចទាក់ទងនឹងការការពារវិធានការបច្ចេកវិទ្យា និងសិទ្ធិគ្រប់គ្រងព័ត៌មាន**

១- ភាគីនីមួយៗត្រូវផ្តល់ការការពារតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ និងវិធានការដោះស្រាយតាមផ្លូវច្បាប់ដែលមានប្រសិទ្ធភាពប្រឆាំងនឹងការគេចវេសនៃវិធានការបច្ចេកវិទ្យា ដែលមានប្រសិទ្ធភាពដែលត្រូវបានប្រើប្រាស់ដោយអ្នកនិពន្ធ អ្នកសម្តែង ឬផលិតករហ្វូណូក្រាមពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងមាត្រា១១.៣១ ដល់មាត្រា១១.៣៤ នៃកិច្ចព្រមព្រៀងនេះ ដែលតែត្បិតលើសកម្មភាពទាក់ទងនឹងស្នាដៃ ការសម្តែង ឬហ្វូណូក្រាម ដែលមិនមានការអនុញ្ញាតពីអ្នកនិពន្ធ អ្នកសម្តែង ឬផលិតករហ្វូណូក្រាមដែលពាក់ព័ន្ធឬអនុញ្ញាតដោយច្បាប់។

២- ភាគីនីមួយៗត្រូវផ្តល់វិធានការដោះស្រាយតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធភាពប្រឆាំងនឹងបុគ្គលណាមួយ ដែលបានដឹងដោយគ្មានការអនុញ្ញាត លុបចោល ឬផ្លាស់ប្តូរសិទ្ធិគ្រប់គ្រងព័ត៌មានអេឡិចត្រូនិកណាមួយនិង/ឬចែកចាយ នាំចូលសម្រាប់ចែកចាយ ផ្សព្វផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈ ដោយគ្មានការអនុញ្ញាត ស្នាដៃ ឬច្បាប់ចម្លងនៃស្នាដៃ ដោយដឹងថាសិទ្ធិគ្រប់គ្រងព័ត៌មានអេឡិចត្រូនិក[24]ត្រូវបានលុបចោល ឬផ្លាស់ប្តូរដោយគ្មានការអនុញ្ញាត។

---

[20] ដូចដែលបានទទួលស្គាល់ដោយសន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស។

[21] ដើម្បីឱ្យកាន់តែច្បាស់ ការប្រើប្រាស់មួយដែលមានលក្ខណៈពាណិជ្ជកម្ម អាចក្នុងកាលៈទេសៈសមស្រប ត្រូវបានចាត់ទុកថាមានគោលបំណងស្របច្បាប់តាមមាត្រា១១.៣៦។

[22] ដើម្បីឱ្យកាន់តែច្បាស់ បទប្បញ្ញត្តិនេះមិនប៉ះពាល់ដល់ការអនុវត្តសិទ្ធិសីលធម៌។

[23] គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ប៉ះពាល់ដល់លទ្ធភាពរបស់ភាគីសមាជិកក្នុងការបង្កើត (i)កិច្ចសន្យាជាក់លាក់ដែលចែងពីការបង្កើតស្នាដៃ ការសម្តែង ឬហ្វូណូក្រាម ក្នុងករណីអត្ថមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើឱ្យមានការផ្ទេរសិទ្ធិបេតិកភណ្ឌដោយប្រតិបត្តិការនៃច្បាប់ និង(ii)ការកម្រិតសមស្របចំពោះការការពារផលប្រយោជន៍ម្ចាស់សិទ្ធិដើម ដោយពិចារណាពីផលប្រយោជន៍ស្របច្បាប់នៃអ្នកទទួលសិទ្ធិ។

[24] សម្រាប់ភាពច្បាស់លាស់ "សិទ្ធិគ្រប់គ្រងព័ត៌មាន" ត្រូវបកស្រាយតាមបទប្បញ្ញត្តិដែលមានចែងក្រោមមាត្រា១២ នៃសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីសិទ្ធិអ្នកនិពន្ធ។

**មាត្រា១១.៤០ _ អង្គភាពគ្រប់គ្រងសិទ្ធិរួម**

គូភាគីទទួលស្គាល់តួនាទីរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមសម្រាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលក្នុងការប្រមូលនិងបែងចែកលាភការផ្អែកតាមការអនុវត្តជាក់ស្តែង ដែលស្មើភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដែលអាចរួមបញ្ចូលនូវយន្តការរក្សាកំណត់ត្រានិងរបាយការណ៍សមស្រប។

## ផ្នែក ៩ ការអនុវត្តសិទ្ធិ

**មាត្រា១១.៤១ _ ភាពកិច្ចទូទៅក្នុងការអនុវត្តសិទ្ធិ**

ភាគីនីមួយៗត្រូវធានាថា នីតិវិធីអនុវត្តសិទ្ធិដែលមានចែងក្នុងផ្នែកនេះមាននៅក្រោមច្បាប់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យមានការអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងសកម្មភាពណាមួយ នៃការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាដែលមានចែងក្នុងជំពូកនេះ រួមទាំងវិធានការដោះស្រាយឆាប់ហ័សដើម្បីការពារមិនឱ្យមានការរំលោភបំពាន និងដំណោះស្រាយធ្វើឱ្យមានការរារាំងចាលចំពោះការរំលោភបំពាននាពេលអនាគត។ នីតិវិធីទាំងនេះត្រូវអនុវត្តក្នុងលក្ខណៈមួយ ដើម្បីចៀសវាងការបង្កើតជាឧបសគ្គចំពោះពាណិជ្ជកម្មស្របច្បាប់និងផ្តល់ការការពារប្រឆាំងនឹងការបំពានសិទ្ធិរបស់ខ្លួន។

**មាត្រា១១.៤២ _ វិធានការតាមអាត់ច្រកព្រំដែន**

១- អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួននិងបទប្បញ្ញត្តិនៃផ្នែកទី III ជំពូកទី៤ នៃកិច្ចព្រមព្រៀងTRIPS ភាគីនីមួយៗត្រូវអនុម័តឬក្សានីតិវិធីដើម្បីឱ្យម្ចាស់សិទ្ធិដែលមានមូលដ្ឋានស្របច្បាប់ ដែលសង្ស័យថាអាចមានការនាំចូលទំនិញក្លែងបន្លំម៉ាកឬរំលោភសិទ្ធិអ្នកនិពន្ធ អាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងភាគីដែលនីតិវិធីវិធានការតាមមាត់ច្រកព្រំដែនត្រូវអនុវត្ត សម្រាប់ការព្យួរបែបបទដោយអាជ្ញាធរគយរបស់ភាគីនោះ នូវការអនុញ្ញាតឱ្យចរាចរទំនិញទាំងនោះដោយសេរី។

២- ភាគីសមាជិកអាចអនុញ្ញាតឱ្យមានពាក្យស្នើសុំបែបនេះ ធ្វើឡើងចំពោះទំនិញដែលពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាផ្សេងទៀត ឱ្យតែលក្ខខណ្ឌតម្រូវនៃផ្នែកទី III ជំពូកទី៤នៃកិច្ចព្រមព្រៀងTRIPS ត្រូវបានបំពេញ។ ភាគីសមាជិកក៏អាចចែងពីនីតិវិធីឆ្លើយតបទាក់ទងនឹងការព្យួរបែបបទដោយអាជ្ញាធរគយនៃការអនុញ្ញាតឱ្យចរាចរទំនិញដែលរំលោភបំពាន ដែលមានទិសដៅសម្រាប់ការនាំចេញពីដែនដីរបស់ខ្លួនស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

# ជំពូកទី១២
# សហគ្រាសធុនតូច និងមធ្យម

## មាត្រា១២.១ _ គោលការណ៍ទូទៅ

១- ដោយទទួលស្គាល់អំពីតួនាទីជាមូលដ្ឋានរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងការរក្សាថាមវន្ត និងជំរុញភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចរៀងខ្លួន គូភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការដើតស្និទ្ធិ រវាងសហគ្រាសធុនតូចនិងមធ្យមរបស់ខ្លួន និងសហការក្នុងការជំរុញការបង្កើតការងារនិងកំណើន នៃសហគ្រាសធុនតូចនិងមធ្យម។

២- គូភាគីទទួលស្គាល់តួនាទីសំខាន់នៃវិស័យឯកជននៅក្នុងកិច្ចសហប្រតិបត្តិការនៃសហគ្រាសធុន តូចនិងមធ្យម ដែលត្រូវអនុវត្តនៅក្នុងជំពូកនេះ។

## មាត្រា១២.២ _ កិច្ចសហប្រតិបត្តិការដើម្បីបង្កើនឱកាសពាណិជ្ជកម្មនិងវិនិយោគ សម្រាប់សហគ្រាសធុនតូចនិងមធ្យម

ក្នុងគោលដៅដើម្បីសម្រេចបានកិច្ចសហប្រតិបត្តិការរឹងមាំរវាងគូភាគី ក្នុងការជំរុញឱកាសពាណិជ្ជកម្ម សម្រាប់សហគ្រាសធុនតូចនិងមធ្យម ភាគីនីមួយៗត្រូវខិតខំបង្កើនឱកាសពាណិជ្ជកម្មនិងវិនិយោគ និង ជាពិសេសត្រូវ៖

(ក) ជំរុញកិច្ចសហប្រតិបត្តិការរវាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រសហគ្រាសធុនតូចនិងមធ្យម របស់ គូភាគី ក្នុងនោះរួមមានមជ្ឈមណ្ឌលសហគ្រាសធុនតូចនិងមធ្យម កន្លែងបណ្តុះនិង ពន្លឿនអាជីវកម្ម មជ្ឈមណ្ឌលគាំទ្រដល់ការនាំចេញ និងមជ្ឈមណ្ឌលផ្សេងៗទៀតដែល សមស្រប ដើម្បីបង្កើតបណ្តាញអន្តរជាតិសម្រាប់ចែករំលែកឧត្តមានុវត្តន៍ ផ្លាស់ប្តូរការ ស្រាវជ្រាវទីផ្សារ និងជំរុញការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងពាណិជ្ជកម្ម អន្តរជាតិ ទីដីថលូបនីយកម្មរបស់សហគ្រាសធុនតូចនិងមធ្យម និងការផ្ទេរបច្ចេកវិទ្យា ព្រមទាំងការកែចម្រើនអាជីវកម្មនៅក្នុងទីផ្សារក្នុងស្រុក។

(ខ) ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីដទៃទៀតទៅលើសកម្មភាពនានា ដើម្បីជំរុញ សហគ្រាសធុនតូចនិងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រីនិងយុវជន ព្រមទាំងអាជីវកម្ម បង្កើតថ្មី និងជំរុញភាពជាដៃគូរវាងសហគ្រាសធុនតូចនិងមធ្យមទាំងនេះនិងការចូលរួម របស់ពួកគេនៅក្នុងពាណិជ្ជកម្មអន្តរជាតិ

(គ) បង្កើនកិច្ចសហប្រតិបត្តិការរបស់សហគ្រាសធុនតូចនិងមធ្យម ជាមួយដៃគូដទៃទៀតដើម្បី ផ្លាស់ប្តូរព័ត៌មាននិងឧត្តមានុវត្តន៍ក្នុងវិស័យនានា រួមមានការជំរុញតួនាទីរបស់សហគ្រាស ធុនតូចនិងមធ្យម ក្នុងភាពជាដៃគូរដ្ឋាភិបាលនិងវិស័យឯកជន ការធ្វើឱ្យប្រសើរឡើងនូវ ការទទួលបានមូលធននិងឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម ឱកាសនៃការ ចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងលទ្ធកម្មសាធារណៈ និងការជួយដល់សហ គ្រាសធុនតូចនិងមធ្យមក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ និង

(ឃ) លើកទឹកចិត្តឱ្យមានការចូលរួមនៅក្នុងថ្នាលទូរសេទ្ធចល័តឬគេហទំព័រ ដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់សម្រាប់សហគ្រិននិងអ្នកពិគ្រោះយោបល់ដើម្បីចែករំលែកព័ត៌មាននិងឧត្តមានុវត្តន៍ក្នុងការជួយតភ្ជាប់សហគ្រាសធុនតូចនិងមធ្យម ទៅកាន់អ្នកផ្គត់ផ្គង់និងអ្នកទិញអន្តរជាតិ និងដៃគូអាជីវកម្មសក្តានុពលដទៃទៀត។

**មាត្រា១២.៣ _ ការចែករំលែកព័ត៌មាន**

១- ភាគីនីមួយៗត្រូវប្រឹងប្រែងបង្កើត ឬរក្សានូវគេហទំព័រសម្រាប់ប្រើប្រាស់ជាសាធារណៈនិងសេវាដែលផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ រួមមាន៖

(ក) អត្ថបទនៃកិច្ចព្រមព្រៀងនេះ

(ខ) សេចក្តីសង្ខេបនៃកិច្ចព្រមព្រៀងនេះ និង

(គ) ព័ត៌មានរៀបចំឡើងសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលរួមមាន៖

(i) ការពិព័ណ៌នាអំពីបទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលភាគីយល់ឃើញថាពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម និង

(ii) ព័ត៌មានបន្ថែមដែលអាចមានសារៈប្រយោជន៍ សម្រាប់សហគ្រាសធុនតូចនិងមធ្យមដែលចាប់អារម្មណ៍ ក្នុងការទទួលបានអត្ថប្រយោជន៍ពីឱកាសដែលផ្តល់ឱ្យដោយកិច្ចព្រមព្រៀងនេះ។

២- ភាគីនីមួយៗត្រូវបញ្ចូលក្នុងតំណគេហទំព័រឬព័ត៌មាន តាមរយៈការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិកដោយស្វ័យប្រវត្តិទៅកាន់៖

(ក) គេហទំព័រប្រហាក់ប្រហែលរបស់ភាគីដទៃទៀត និង

(ខ) គេហទំព័ររបស់ភ្នាក់ងាររដ្ឋាភិបាលនិងអង្គភាពសមស្របផ្សេងទៀតរបស់ខ្លួន ដែលផ្តល់ព័ត៌មានដែលភាគីនោះយល់ឃើញថា មានអត្ថប្រយោជន៍សម្រាប់បុគ្គលដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើពាណិជ្ជកម្ម វិនិយោគ ឬការធ្វើអាជីវកម្មនៅក្នុងដែនដីរបស់ភាគីនោះ។

៣- ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីនីមួយៗ ព័ត៌មានដែលរៀបរាប់ក្នុងកថាខណ្ឌ ២(ខ) ត្រូវរួមបញ្ចូលនូវ៖

(ក) បទប្បញ្ញត្តិគយ នីតិវិធីគយ និងមន្ត្រីទំនាក់ទំនងសម្រាប់ការផ្តល់ព័ត៌មាន

(ខ) បទប្បញ្ញត្តិឬនីតិវិធីពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ការសម្ងាត់ពាណិជ្ជកម្ម និងការការពារសិទ្ធិតក្កកម្ម

(គ) បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដា គុណភាព ឬនីតិវិធីវាយតម្លៃអនុលោមភាព

(ឃ) វិធានអនាម័យឬភូតគាមអនាម័យដែលពាក់ព័ន្ធនឹងការនាំចេញឬការនាំចូល

(ង) បទប្បញ្ញត្តិពាក់ព័ន្ធនឹងវិនិយោគបរទេស

(ច) ការចុះបញ្ជីអាជីវកម្ម

(ឆ) កម្មវិធីជំរុញពាណិជ្ជកម្ម

(ជ) កម្មវិធីប្រកួតប្រជែង

(ឈ) កម្មវិធីវិនិយោគនិងកម្មវិធីហិរញ្ញប្បទានលើសហគ្រាសធុនតូចនិងមធ្យម

(ញ) ពន្ធដារឬគណនេយ្យ

(ជ) ឱកាសក្នុងលទ្ធកម្មសាធារណៈ និង

(ឍ) ព័ត៌មានផ្សេងៗទៀត ដែលភាគីយល់ឃើញថាមានសារប្រយោជន៍សម្រាប់សហគ្រាសធុនតូចនិងមធ្យម។

៤- ភាគីនីមួយៗត្រូវប្រឹងប្រែងត្រួតពិនិត្យជាទៀងទាត់នូវព័ត៌មាននិងតំណនៅលើគេហទំព័រ ដូចមានចែងក្នុងកថាខណ្ឌ១និង២ ដើម្បីធានាថាព័ត៌មាននិងតំណនានាបានធ្វើបច្ចុប្បន្នកម្មនិងត្រឹមត្រូវជាក់លាក់។

៥- ភាគីនីមួយៗត្រូវរៀបចំឱ្យមានព័ត៌មាននៅក្នុងមាត្រានេះជាភាសាអង់គ្លេស តាមដែលអាចធ្វើទៅបាន។ ប្រសិនបើព័ត៌មាននេះជាភាសាដើមនៃកិច្ចព្រមព្រៀងនេះ ភាគីត្រូវប្រឹងប្រែងរៀបចំឱ្យមានព័ត៌មាននេះឱ្យបានសមស្រប។

## មាត្រា១២.៤ _ អនុគណៈកម្មាធិការសម្រាប់កិច្ចការពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម

១- គូភាគីបង្កើតអនុគណៈកម្មាធិការសម្រាប់កិច្ចការពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម (អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម) ដែលមានសមាសភាពពីតំណាងរដ្ឋាភិបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៃភាគីនីមួយៗ។

២- អនុគណៈកម្មការសហគ្រាសធុនតូចនិងមធ្យមត្រូវ៖

(ក) ស្វែងរកវិធីជួយដល់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងដែនដីនៃគូភាគី ដើម្បីទាញយកអត្ថប្រយោជន៍ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងនេះ និងពង្រីកភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យម

(ខ) កំណត់និងផ្តល់អនុសាសន៍លើមធ្យោបាយសម្រាប់កិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងគូភាគី ដើម្បីអភិវឌ្ឍនិងជំរុញភាពជាដៃគូរវាងសហគ្រាសធុនតូចនិងមធ្យមនៃគូភាគី

(គ) ផ្លាស់ប្តូរនិងពិភាក្សាលើបទពិសោធនិងនវានុវត្តន៍របស់ភាគីនីមួយៗ ក្នុងការគាំទ្រនិងជួយដល់អ្នកនាំចេញដែលជាសហគ្រាសធុនតូចនិងមធ្យម តាមរយៈកម្មវិធីបណ្តុះបណ្តាល ការអប់រំផ្នែកពាណិជ្ជកម្ម ហិរញ្ញប្បទានពាណិជ្ជកម្ម ស្ថានបេសកកម្មពាណិជ្ជកម្ម កិច្ចសម្រួលពាណិជ្ជកម្ម ពាណិជ្ជកម្មឌីជីថល ការស្វែងរកដៃគូពាណិជ្ជកម្មនៅក្នុងដែនដីនៃគូភាគីនិងការបង្កើតការទទួលស្គាល់អាជីវកម្មល្អ

(ឃ) ជំរុញឱ្យមានសិក្ខាសាលា សិក្ខាសាលាតាមប្រព័ន្ធអនឡាញ វគ្គបណ្តុះបណ្តាល ឬសកម្មភាពផ្សេងៗទៀត សម្រាប់ផ្តល់ព័ត៌មានដល់សហគ្រាសធុនតូចនិងមធ្យមអំពីអត្ថប្រយោជន៍ដែលមានចំពោះខ្លួនក្រោមកិច្ចព្រមព្រៀងនេះ

(ង) ស្វែងរកឱកាសសម្រាប់ការអភិវឌ្ឍសមត្ថភាព ដើម្បីសម្រួលដល់ការងាររបស់ភាគីនីមួយៗក្នុងការអភិវឌ្ឍនិងជំរុញការប្រឹក្សា ជំនួយ និងកម្មវិធីបណ្តុះបណ្តាលលើការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យម

(ច) ផ្តល់អនុសាសន៍លើព័ត៌មានបន្ថែមដែលភាគីសមាជិកអាចបញ្ចូលនៅលើគេហទំព័រ ដែលបានចែងក្នុងមាត្រា១២.៣

(ឆ) ត្រួតពិនិត្យឡើងវិញនិងសម្របសម្រួលកម្មវិធីការងាររបស់ខ្លួន ជាមួយនឹងការងាររបស់អនុគណៈកម្មាធិការផ្សេងៗ ក្រុមការងារដទៃទៀត និងសាខាអង្គភាពដែលបង្កើតក្រោមកិច្ចព្រមព្រៀងនេះ ក៏ដូចជាអង្គភាពអន្តរជាតិពាក់ព័ន្ធដទៃទៀត ដើម្បីចៀសវាងនូវភាពជាន់គ្នានៃកម្មវិធីការងារ និងដើម្បីកំណត់ឱកាសសមស្របសម្រាប់កិច្ចសហប្រតិបត្តិការលើការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រាសធុនតូចនិងមធ្យម ដើម្បីផ្សារភ្ជាប់ក្នុងឱកាសពាណិជ្ជកម្មនិងវិនិយោគដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងនេះ

(ជ) សហការនិងលើកទឹកចិត្តឱ្យអនុគណៈកម្មាធិការ ក្រុមការងារ និងសាខាអង្គភាពដែលត្រូវបានបង្កើតក្រោមកិច្ចព្រមព្រៀងនេះ គិតគូរពិចារណារួមបញ្ចូលការប្តេជ្ញាចិត្តនិងសកម្មភាពពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យមទៅក្នុងការងាររបស់ខ្លួន

(ឈ) ត្រួតពិនិត្យការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ និងបញ្ញត្តិពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យមនៅក្នុងកិច្ចព្រមព្រៀងនេះ និងរាយការណ៍អំពីលទ្ធផលនិងផ្តល់អនុសាសន៍ជូនគណៈកម្មាធិការចម្រុះ ដែលអាចត្រូវបានរួមបញ្ចូលនៅក្នុងការងារនិងកម្មវិធីជំនួយដល់សហគ្រាសធុនតូចនិងមធ្យមនាពេលអនាគត តាមការសមស្រប

(ញ) សម្រួលការអភិវឌ្ឍកម្មវិធីជួយដល់សហគ្រាសធុនតូចនិងមធ្យមឱ្យចូលរួម និងធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធិភាព ទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់និងពិភពលោករបស់គូភាគី

(ដ) ជំរុញការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងពាណិជ្ជកម្មឌីជីថល ដើម្បីទាញយកប្រយោជន៍ជាឱកាសដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងនេះ និងការចូលទៅកាន់ទីផ្សារថ្មីៗភ្លាមៗ

(ឋ) សម្រួលការផ្លាស់ប្តូរព័ត៌មានអំពីចំណេះដឹងសហគ្រិនភាព និងកម្មវិធីលើកកម្ពស់ការយល់ដឹងសម្រាប់យុវជននិងស្ត្រី ដើម្បីជំរុញបរិយាកាសសហគ្រិនភាពនៅក្នុងដែនដីនៃគូភាគី

(ឌ) បញ្ជូនរបាយការណ៍ប្រចាំឆ្នាំនៃសកម្មភាពរបស់ភាគី ដែលបណាមានការសម្រេចផ្ទុយពីនេះដោយគូភាគី និងផ្តល់អនុសាសន៍សមស្របជូនគណៈកម្មាធិការចម្រុះ និង

(ឍ) ពិចារណាអំពីបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម តាមការសម្រេចរបស់អនុគណៈកម្មការ រួមមានបញ្ហាដែលលើកឡើងដោយសហគ្រាសធុនតូច និងមធ្យមពាក់ព័ន្ធនឹងសមត្ថភាពរបស់ខ្លួនក្នុងការទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ។

៣- អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ត្រូវចាប់ផ្តើមក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងត្រូវប្រជុំជារៀងរាល់ឆ្នាំចាប់ពីពេលនោះតទៅ លើកលែងតែគូភាគីសម្រេចផ្សេងពីនេះ។

៤- អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ត្រូវស្វែងរកកិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញនិងអង្គការផ្តល់ជំនួយអន្តរជាតិ សមស្របក្នុងការអនុវត្តកម្មវិធីនិងសកម្មភាពរបស់អនុគណៈកម្មាធិការ។

**មាត្រា១២.៤ _ ការមិនអនុវត្តការដោះស្រាយវិវាទ**

ភាគីសមាជិកមិនត្រូវមានសិទ្ធិអនុវត្តការដោះស្រាយវិវាទក្រោមជំពូកទី១៤(ការដោះស្រាយវិវាទ) ចំពោះបញ្ហាណាមួយដែលមានក្រោមជំពូកនេះ។

# ជំពូកទី១៣
# កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស

## មាត្រា១៣.១ _ គោលបំណង

១- គូភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងនេះ សម្រាប់ផលប្រយោជន៍ទៅវិញទៅមក ដើម្បីធ្វើសេរីភាវូបនីយកម្មនិងសម្រួលពាណិជ្ជកម្មនិងវិនិយោគរវាងគូភាគី និងជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍពាណិជ្ជកម្មរបស់គូភាគី។

២- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសក្រោមជំពូកនេះ ត្រូវរៀបចំឡើងដោយផ្អែកតាមការយល់ស្របគ្នារវាងគូភាគី ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ក្នុងគោលបំណងដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា គាំទ្រដល់ដំណើរទៅកាន់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនិងកិច្ចសម្រួលពាណិជ្ជកម្ម និងធ្វើឱ្យកាន់តែប្រសើរឡើងនូវការចូលទៅទីផ្សារនិងការបើកចំហទីផ្សារ ដើម្បីរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនិងបរិយាប័ន្ននៃគូភាគី។

៣- ដោយទទួលស្គាល់ពីសារៈសំខាន់នៃការជំរុញគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសសម្រាប់ផលប្រយោជន៍ទៅវិញទៅមក គូភាគីព្រមព្រៀងគ្នាក្នុងការជំរុញនិងធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូសេដ្ឋកិច្ចនិងបច្ចេកទេស លើវិស័យដែលគូភាគីទទួលបានផលប្រយោជន៍ទៅវិញទៅមក ដោយពិចារណាអំពីកម្រិតខុសគ្នានៃការអភិវឌ្ឍនិងសមត្ថភាពរបស់គូភាគី។

## មាត្រា១៣.២ _ វិសាលភាពនិងវិស័យនៃកិច្ចសហប្រតិបត្តិការ

១- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសក្រោមជំពូកនេះ ត្រូវគាំទ្រដល់បរិយាប័ន្ន ប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការអនុវត្តនិងការប្រើប្រាស់កិច្ចព្រមព្រៀងនេះ តាមរយៈសកម្មភាពដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងវិនិយោគ។ គូភាគីត្រូវផ្តោតជាបឋមលើសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស លើវិស័យដូចខាងក្រោម៖

(ក) ការអភិវឌ្ឍពាណិជ្ជកម្មនិងវិនិយោគ រួមទាំងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ
(ខ) សេវាកម្ម ទេសចរណ៍ និងធនាគារ
(គ) កសិកម្ម នេសាទ និងកសិឧស្សាហកម្ម
(ឃ) ពាណិជ្ជកម្មឌីជីថល
(ង) វិធានអនាម័យនិងភូតគាមអនាម័យ
(ច) បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដា និងនីតិវិធីត្រួតពិនិត្យអនុលោមភាព
(ឆ) ឌីជីថលូបនីយកម្ម នវានុវត្តន៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មានវិទ្យាគមនាគមន៍
(ជ) ការអប់រំនិងការអភិវឌ្ឍធនធានមនុស្ស
(ឈ) កម្មសិទ្ធិបញ្ញា
(ញ) នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម
(ដ) ថាមពល

(ថ) វិស័យផ្សេងៗទៀត តាមការព្រមព្រៀងរបស់គូភាគី។

២- គូភាគីអាចព្រមព្រៀងគ្នាក្នុងកម្មវិធីការងារប្រចាំឆ្នាំ អំពីសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដើម្បីកែសម្រួលបញ្ជីកិច្ចសហប្រតិបត្តិការខាងលើ រួមទាំងបន្ថែមវិស័យផ្សេងៗទៀត សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស។

**មាត្រា១៣.៣ _ កម្មវិធីការងារប្រចាំឆ្នាំនៃសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស**

១- គណៈកម្មការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ត្រូវអនុម័តកម្មវិធីការងារប្រចាំឆ្នាំនៃសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស (តទៅនេះហៅជារួមថា "កម្មវិធីការងារប្រចាំឆ្នាំ") ដោយផ្អែកលើសំណើរបស់គូភាគី។

២- សកម្មភាពនីមួយៗនៅក្នុងកម្មវិធីការងារប្រចាំឆ្នាំដែលរៀបចំឡើងក្រោមជំពូកនេះត្រូវ (ក) ស្របតាមគោលបំណងដែលបានព្រមព្រៀងគ្នានៅក្នុងមាត្រា១៣.១ (ខ) ពាក់ព័ន្ធនឹងពាណិជ្ជកម្មឬវិនិយោគ និងគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ (គ) មានការចូលរួមពីភាគីទាំងពីរ (ឃ) ផ្តោតលើអាទិភាពទៅវិញទៅមករបស់គូភាគី និង(ង) ចៀសវាងនូវសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសដែលមានស្រាប់។

**មាត្រា១៣.៤ _ គោលនយោបាយប្រកួតប្រជែង**

១- គូភាគីទទួលស្គាល់អំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការដោទូទៅនៅក្នុងវិស័យគោលនយោបាយប្រកួតប្រជែង។ គូភាគីត្រូវសហការដើម្បីផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយប្រកួតប្រជែង ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកនិងធនធាន របស់ខ្លួន។ គូភាគីអាចអនុវត្តកិច្ចសហប្រតិបត្តិការបែបនេះតាមរយៈអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន។

២- គូភាគីត្រូវពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងការអនុវត្តប្រឆាំងនឹងការប្រកួតប្រជែង និងផលប៉ះពាល់អវិជ្ជមានដល់ពាណិជ្ជកម្ម។ ការពិភាក្សាត្រូវអនុវត្តដោយមិនប៉ះពាល់ចំពោះស្វ័យភាពរបស់ភាគីនីមួយៗ ក្នុងការអភិវឌ្ឍ រក្សាទុក និងអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រកួតប្រជែងក្នុងស្រុក។

**មាត្រា១៣.៥ _ ធនធាន**

១- ធនធានសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសក្រោមកិច្ចព្រមព្រៀងនេះ ត្រូវផ្តល់តាមការព្រមព្រៀងដោយគូភាគី និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់គូភាគី។

២- ឈរលើមូលដ្ឋានផលប្រយោជន៍ទៅវិញទៅមក គូភាគីត្រូវពិចារណាលើកិច្ចសហប្រតិបត្តិការជាមួយនិងការរួមចំណែកពីភាគីដទៃ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីការងារប្រចាំឆ្នាំ។

**មាត្រា១៣.៦ _ មធ្យោបាយនៃកិច្ចសហប្រតិបត្តិការ**

១- គូភាគីត្រូវប្រឹងប្រែងជំរុញកិច្ចសហប្រតិបត្តិការបច្ចេកទេស បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងសេដ្ឋកិច្ចតាមរយៈមធ្យោបាយដូចខាងក្រោម៖

(ក) ការរៀបចំរួមគ្នានូវសន្និសិទ សិក្ខាសិលា កិច្ចប្រជុំ វគ្គបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ ការតាំងពិព័ណ៌ពាណិជ្ជកម្ម និងកម្មវិធីអប់រំ

(ខ) ការផ្លាស់ប្តូរនៃប្រតិភូ អ្នកជំនាញ អ្នកបច្ចេសទេស និងជំនាញការ មកពីវិស័យអប់រំ ខ្សោស្ថានស្រាវជ្រាវ វិស័យឯកជន និងភ្នាក់ងាររដ្ឋាភិបាល រួមទាំងទស្សនកិច្ចសិក្សានិង កម្មវិធីកម្មសិក្សាសម្រាប់ការបណ្តុះបណ្តាលជំនាញ

(គ) ការសន្ទនា និងការផ្លាស់ប្តូរបទពិសោធរវាងវិស័យឯកជននិងភ្នាក់ងារឯកជនដែលពាក់ ព័ន្ធនឹងការជំរុញពាណិជ្ជកម្មរបស់គូភាគី

(ឃ) ការផ្តួចផ្តើមនៃថ្នាលចែករំលែកចំណេះដឹង ដែលមានគោលដៅផ្ទេរបទពិសោធ និង ឧត្តមានុវត្តន៍ នៅក្នុងកិច្ចការអភិវឌ្ឍន៍និងធ្វើទំនើបកម្មវិស័យសាធារណៈទៅកាន់ប្រទេស ដទៃទៀត តាមរយៈកម្មវិធីផ្លាស់ប្តូរបទពិសោធរបស់រដ្ឋាភិបាលរបស់អេមីរ៉ាតអារ៉ាប់រួម

(ង) ជំរុញគំនិតផ្តួចផ្តើមអាជីវកម្មរួមគ្នារវាងសហគ្រិន រួមទាំងសហគ្រាសធុនតូចនិងមធ្យម របស់គូភាគី និង

(ច) ទម្រង់នៃកិច្ចសហប្រតិបត្តិការផ្សេងៗទៀតតាមការព្រមព្រៀងរបស់គូភាគី។

## មាត្រា១៣.៧ _ ការអភិវឌ្ឍសមត្ថភាពនិងជំនួយបច្ចេកទេស

ដោយទទួលស្គាល់អំពីគម្លាតនៃការអភិវឌ្ឍនិងសមត្ថភាពរវាងគូភាគី និងសារៈសំខាន់នៃការអភិវឌ្ឍ សមត្ថភាពសម្រាប់ការបង្កើនពាណិជ្ជកម្ម វិនិយោគ និងការជំរុញកំណើនសេដ្ឋកិច្ច គូភាគីត្រូវខិតខំអភិវឌ្ឍ ការកសាងសមត្ថភាពនិងសកម្មភាពជំនួយបច្ចេកទេស ដោយមានការព្រមព្រៀងពីគូភាគី ដើម្បីគាំទ្រដល់ ការអនុវត្តកិច្ចព្រមព្រៀងនេះនិងវិស័យផ្សេងៗទៀតតាមការព្រមព្រៀងគ្នាទៅវិញទៅមក។

## មាត្រា១៣.៨ _ គណៈកម្មការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស

១- ដើម្បីគោលបំណងក្នុងការសម្រេចបានការអនុវត្តនិងប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព គូភាគី ចាំបាច់ត្រូវបង្កើតគណៈកម្មាធិការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស (តទៅនេះហៅ កាត់ថា "គណៈកម្មាធិការ")។

២- គណៈកម្មាធិការត្រូវអនុវត្តមុខងារដូចខាងក្រោម៖

(ក) តាមដាននិងពិនិត្យមើលការអនុវត្តនៃជំពូកនេះ

(ខ) កំណត់កាលានុវត្តភាពថ្មីៗ និងឯកភាពលើគំនិតថ្មីៗសម្រាប់កិច្ចសហប្រតិបត្តិការ ឬ សកម្មភាពអភិវឌ្ឍសមត្ថភាព

(គ) រៀបចំនិងអភិវឌ្ឍសំណើកម្មវិធីការងារប្រចាំឆ្នាំនិងយន្តការអនុវត្ត

(ឃ) សម្របសម្រួល តាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃកម្មវិធីការងារប្រចាំឆ្នាំ ដើម្បីពិនិត្យ មើលប្រសិទ្ធិភាពជារួមនិងការរួមចំណែកក្នុងការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ

(ង) លើកសំណើធ្វើវិសោធនកម្មកម្មវិធីការងារប្រចាំឆ្នាំ តាមរយៈការវាយតម្លៃជាប្រចាំ

(ច) សហការជាមួយអនុគណៈកម្មាធិការផ្សេងទៀតនិង/ឬសាខាអង្គភាព ដែលបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ដើម្បីអនុវត្តការប្រមូលព័ត៌មាន តាមដាន និងកំណត់ជាគោលលើបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តនិងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និង

(ឆ) ក្នុងករណីចាំបាច់ រាយការណ៍ជូននិងពិភាក្សាជាមួយគណៈកម្មាធិការចម្រុះ ដែលពាក់ព័ន្ធនឹងការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ។

**មាត្រា១៣.៩ _ ការមិនអនុវត្តជំពូកទី១៤(ការដោះស្រាយវិវាទ)**

ជំពូកទី១៤(ការដោះស្រាយវិវាទ) មិនត្រូវបានអនុវត្តសម្រាប់បញ្ហាណាក៏ដោយ ដែលកើតឡើងក្រោមជំពូកនេះ។

# ជំពូកទី១៤
# ការដោះស្រាយវិវាទ

## មាត្រា១៤.១ _ គោលបំណង

គោលបំណងនៃជំពូកនេះ គឺដើម្បីបង្កើតយន្តការដ៏មានប្រសិទ្ធភាពនិងប្រសិទ្ធផលមួយ សម្រាប់ការចៀសវាងនិងការដោះស្រាយជម្លោះរវាងគូភាគី ទាក់ទងនឹងការបកស្រាយនិងការអនុវត្តកិច្ចព្រមព្រៀងនេះ ក្នុងគោលបំណងឈានទៅរកដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង តាមលទ្ធភាពដែលអាចធ្វើទៅបាន។

## មាត្រា១៤.២ _ វិសាលភាពនៃការអនុវត្ត

១- លើកលែងតែមានចែងក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តចំពោះការដោះស្រាយវិវាទណាមួយរវាងគូភាគីទាក់ទងនឹងការបកស្រាយ ការប្រតិបត្តិ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ (តទៅនេះហៅថា "បទប្បញ្ញត្តិដែលគ្របដណ្តប់") នៅពេលដែលភាគីណាមួយពិចារណាថា៖

(ក) វិធានការដែលបានអនុម័តដោយភាគីសមាជិកម្ខាងទៀត គឺមិនសមស្របនឹងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ខ) ភាគីសមាជិកម្ខាងទៀតបានខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ។

២- ជំពូកនេះមិនត្រូវគ្របដណ្តប់លើបណ្តឹងតវ៉ា ដែលគ្មានការរំលោភបំពាននិងស្ថានភាពបណ្តឹងដទៃទៀត។

## មាត្រា១៤.៣ _ ចំណុចទំនាក់ទំនង

១- ភាគីនីមួយៗត្រូវចាត់តាំងចំណុចទាក់ទង ដើម្បីជួយសម្រួលដល់ទំនាក់ទំនងរវាងគូភាគីទាក់ទងនឹងវិវាទណាមួយដែលបានផ្តួចផ្តើមនៅក្រោមជំពូកនេះ។

២- រាល់សំណើ ការជូនដំណឹង សារណាជាលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងទៀតដែលធ្វើឡើងដោយអនុលោមតាមជំពូកនេះ នឹងត្រូវបញ្ជូនទៅភាគីសមាជិកម្ខាងទៀត តាមរយៈចំណុចទាក់ទងដែលបានចាត់តាំងរបស់ខ្លួន។

## មាត្រា១៤.៤ _ សំណើសុំព័ត៌មាន

មុនពេលនឹងស្នើសុំការពិគ្រោះយោបល់ ការសម្របសម្រួល ការផ្សះផ្សា ឬសន្ធានកម្មត្រូវបានធ្វើឡើងដោយអនុលោមតាមមាត្រា១៤.៥ ឬមាត្រា១៤.៦ បន្តបន្ទាប់ ភាគីសមាជិកអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវព័ត៌មានពាក់ព័ន្ធណាមួយទាក់ទងនឹងវិធានការដែលចោទជាបញ្ហា។ ភាគីដែលទទួលសំណើនោះត្រូវខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីផ្តល់ព័ត៌មានដែលបានស្នើសុំដោយឆ្លើយតបជាលាយលក្ខណ៍អក្សរ ដែលត្រូវជាក់ជូនមិនលើសពី២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

**មាត្រា១៤.៥ _ ការពិគ្រោះយោបល់**

១- គូភាគីត្រូវខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទណាមួយ ដូចមានចែងក្នុងមាត្រា១៤.២ ដោយចូលរួមក្នុងការពិគ្រោះយោបល់ដោយសុចរិតនិងស្មោះត្រង់ ក្នុងគោលបំណងឈានទៅរកដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង។

២- ភាគីសមាជិកត្រូវស្នើសុំការពិគ្រោះយោបល់ តាមរយៈសំណើជាលាយលក្ខណ៍អក្សរដែលត្រូវធ្វើទៅភាគីសមាជិកម្ខាងទៀត ដើម្បីបញ្ជាក់ពីមូលហេតុនៃសំណើ រួមទាំងវិធានការដែលចោទជាបញ្ហានិងការពិពណ៌នាអំពីមូលដ្ឋាននៃអង្គហេតុនិងអង្គច្បាប់ ដែលបញ្ជាក់ពីបទប្បញ្ញត្តិគ្របដណ្តប់ដែលខ្លួនចាត់ទុកថាអាចអនុវត្តបាន។

៣- ភាគីដែលទទួលសំណើសុំការពិគ្រោះយោបល់ត្រូវឆ្លើយតបនឹងសំណើនេះភ្លាមៗ ប៉ុន្តែមិនត្រូវលើសពី១០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើឡើយ។ ការពិគ្រោះយោបល់ត្រូវធ្វើឡើងក្នុងកំឡុងពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើ។ ការពិគ្រោះយោបល់ត្រូវចាត់ទុកថាត្រូវបានបញ្ចប់ក្នុងកំឡុងពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

៤- ការពិគ្រោះយោបល់លើបញ្ហាបន្ទាន់ រួមមានទំនិញដែលងាយខូចគុណភាព ត្រូវធ្វើឡើងក្នុងកំឡុងពេល១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើ។ ការពិគ្រោះយោបល់ត្រូវចាត់ទុកថាត្រូវបានបញ្ចប់ក្នុងកំឡុងពេល១៥ថ្ងៃនោះ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

៥- ក្នុងកំឡុងពេលពិគ្រោះយោបល់ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានដែលគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមានការពិនិត្យពេញលេញអំពីវិធានការដែលចោទជាបញ្ហា រួមទាំងលក្ខណៈដែលវិធានការនោះកំពុងប៉ះពាល់ដល់ប្រតិបត្តិការនិងការអនុវត្តកិច្ចព្រមព្រៀងនេះផងដែរ។

៦- ការពិគ្រោះយោបល់ រួមទាំងព័ត៌មានទាំងអស់ដែលបានបង្ហាញនិងជំហរនៃគូភាគីក្នុងកំឡុងពេលពិគ្រោះយោបល់ ត្រូវទុកជាការសម្ងាត់ និងមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយនៅក្នុងដំណើរការបន្តបន្ទាប់ទៀតឡើយ ។

៧- ការពិគ្រោះយោបល់អាចធ្វើឡើងជាលក្ខណៈរូបវន្ត ឬដោយមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលឯកភាពដោយគូភាគី។ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ការពិគ្រោះយោបល់នឹងត្រូវធ្វើឡើងនៅលើដែនដីនៃភាគីម្ចាស់សំណើ ប្រសិនបើធ្វើឡើងជាលក្ខណៈរូបវន្ត។

៨- ប្រសិនបើភាគីទទួលសំណើមិនឆ្លើយតបនឹងសំណើសុំពិគ្រោះយោបល់ក្នុងកំឡុងពេល១០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបានទទួលឬប្រសិនបើការពិគ្រោះយោបល់មិនត្រូវបានធ្វើឡើងក្នុងកំឡុងពេលដូចមានចែងនៅក្នុងកថាខណ្ឌ៣ ឬនៅក្នុងកថាខណ្ឌ៤ រៀងគ្នា ឬប្រសិនបើគូភាគីយល់ព្រមមិនមានការពិគ្រោះយោបល់ ឬប្រសិនបើការពិគ្រោះយោបល់ត្រូវបានបញ្ចប់ ហើយមិនទាន់មានដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង ភាគីដែលស្នើសុំការពិគ្រោះយោបល់មានសិទ្ធិប្រើប្រាស់យន្តការដោះស្រាយវិវាទដូចមានចែងក្នុងមាត្រា១៤.៧។

**មាត្រា១៤.៦ _ អន្តរកាល ការផ្សះផ្សា ឬសន្ធានកម្ម**

១- គូភាគីអាចយល់ព្រមចាប់ផ្តើមនីតិវិធីសម្រាប់អន្តរកាល ការផ្សះផ្សា ឬសន្ធានកម្មនៅពេលណាក៏បាន។ គូភាគីអាចចាប់ផ្តើមនិងបញ្ចប់ដោយភាគីសមាជិកណាមួយ នៅពេលណាក៏បាន។

២- នីតិវិធីបណ្តឹងដែលទាក់ទងនឹងអន្តរកាល ការផ្សះផ្សា ឬសន្ធានកម្ម និងជំហរជាក់លាក់នៃគូភាគី នៅក្នុងនីតិវិធីបណ្តឹងទាំងនេះនឹងត្រូវរក្សាជាការសម្ងាត់ និងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយនៅក្នុងនីតិវិធីបណ្តឹងបន្តក្រោមដំពូកនេះ ឬនីតិវិធីបណ្តឹងផ្សេងទៀតណាមួយ មុនពេលវេទិកាត្រូវបានជ្រើសរើសដោយគូភាគី។

៣- ប្រសិនបើគូភាគីឯកភាព នីតិវិធីសម្រាប់អន្តរកាល ការផ្សះផ្សា ឬសន្ធានកម្មអាចនៅដំណើរការបន្ត ខណៈពេលដែលនីតិវិធីរបស់ក្រុមប្រឹក្សាជំនុំជម្រះដំណើរការ។

**មាត្រា១៤.៧ _ ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះ**

១- ភាគីប្តឹងតវ៉ាអាចស្នើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ប្រសិនបើ៖

(ក) ភាគីឆ្លើយតបពុំឆ្លើយតបទៅនឹងសំណើសម្រាប់ការពិគ្រោះយោបល់ដោយអនុលោមតាមពេលវេលាដែលយោងនៅក្នុងមាត្រា១៤.៥ ឬ

(ខ) ការពិគ្រោះយោបល់ដែលមានចែងក្នុងមាត្រា១៤.៥ មិនត្រូវបានធ្វើឡើងឬខកខានក្នុងការដោះស្រាយវិវាទក្នុងកំឡុងពេល៣០ថ្ងៃ ឬ១៥ថ្ងៃ ទាក់ទងនឹងបញ្ហាបន្ទាន់ រួមទាំងបញ្ហាទាក់ទងនឹងទំនិញងាយខូចគុណភាព បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើសម្រាប់ការពិគ្រោះយោបល់ដោយភាគីឆ្លើយតប។

២- សំណើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ត្រូវធ្វើតាមមធ្យោបាយនៃសំណើជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីសមាជិកម្ខាងទៀត ហើយត្រូវកំណត់វិធានការដែលចោទជាបញ្ហានិងបង្ហាញពីមូលដ្ឋានអង្គហេតុនៃបណ្តឹងនិងអង្គច្បាប់ដែលបញ្ជាក់ពីបទប្បញ្ញត្តិគ្របដណ្តប់ដែលពាក់ព័ន្ធក្នុងលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញពីលក្ខណៈដែលវិធានការណ៍នេះមានអសង្គតិភាពទៅនឹងបទប្បញ្ញត្តិទាំងនោះ។

៣- នៅពេលដែលការស្នើសុំត្រូវបានធ្វើឡើងដោយភាគីប្តឹងតវ៉ា ដោយអនុលោមតាមកថាខណ្ឌ១ ក្រុមប្រឹក្សាជំនុំជម្រះមួយនឹងត្រូវបានបង្កើតឡើង។

**មាត្រា១៤.៨ _ សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ**

១- លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះមួយត្រូវមានសមាជិកចំនួនបីរូប។

២- ក្នុងកំឡុងពេល២០ថ្ងៃ បន្ទាប់ពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ភាគីនីមួយៗត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះម្នាក់។ គូភាគីត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះទីបីដែលត្រូវធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះដោយកិច្ចព្រមព្រៀងរួម ក្នុងកំឡុងពេល៤០ថ្ងៃ បន្ទាប់ពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះ។

៣- ប្រសិនបើភាគីណាមួយខកខានក្នុងការតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ក្នុងកំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌ២ ក្នុងកំឡុងពេល២០ថ្ងៃ បន្ថែមទៀត ភាគីសមាជិកម្ខាងទៀតនៃវិវាទអាចស្នើសុំឱ្យអគ្គនាយកWTO តែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះដែលនៅសេសសល់ក្នុងកំឡុងពេល២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសំណើ។

៤- ប្រសិនបើអគ្គនាយកWTO ជូនដំណឹងដល់គូភាគីថា គាត់មិនអាចចូលរួមឬមិនអាចតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះដែលនៅសេសសល់ក្នុងកំឡុងពេល២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ

ទទួលបានសំណើដូចមានចែងក្នុងកថាខណ្ឌ៣បានទេ ភាគីសមាជិកណាមួយនៃវិាទអាចស្នើសុំអគ្គលេខាធិការតុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តកម្ម ឱ្យតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ដែលនៅសេសសល់ ក្នុងកំឡុងពេល២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសំណើនេះ។

៥- ប្រសិនបើគូភាគីមិនយល់ព្រមលើការតែងតាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងកំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ២ ពួកគេអាចផ្លាស់ប្តូរបញ្ជីឈ្មោះរៀងៗខ្លួន ដែលរួមមានបេក្ខភាពបីនាក់ ដែលម្នាក់ៗមិនមានសញ្ជាតិនៃភាគីសមាជិកណាមួយឡើយ។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាត្រូវតែងតាំងដោយការចាប់ឆ្នោតចេញពីបញ្ជីឈ្មោះក្នុងកំឡុងពេល១០ថ្ងៃ បន្ទាប់ពីការផុតកំណត់នៃរយៈពេលដែលគូភាគីត្រូវផ្លាស់ប្តូរបញ្ជីឈ្មោះបេក្ខភាពរៀងៗខ្លួន។ ការជ្រើសរើសប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើឡើងដោយគណៈកម្មាធិការចម្រុះ។

៦- ប្រសិនបើភាគីសមាជិកម្ខាងខកខានក្នុងការដាក់បញ្ជីឈ្មោះបេក្ខជនបីរូបរបស់ខ្លួន ក្នុងកំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌ៤ ប្រធានក្រុមប្រឹក្សាត្រូវតែងតាំងដោយការចាប់ឆ្នោតចេញពីបញ្ជីឈ្មោះដែលបានដាក់ជូនដោយភាគីសមាជិកម្ខាងទៀត។

៧- កាលបរិច្ឆេទតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ គឺជាកាលបរិច្ឆេទដែលសមាជិកចុងក្រោយក្នុងចំណោមសមាជិកទាំងបីរូប ដែលត្រូវបានជ្រើសរើសបានជូនដំណឹងដល់គូភាគីអំពីការទទួលយកការតែងតាំងរបស់គាត់។

**មាត្រា១៤.៩ _ សេចក្តីសម្រេចលើភាពបន្ទាន់**

ប្រសិនបើភាគីសមាជិកណាមួយស្នើសុំដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចក្នុងកំឡុងពេល១៥ថ្ងៃ នៃសមាសភាពរបស់ខ្លួន ថាតើវិាទទាក់ទងនឹងបញ្ហាបន្ទាន់ដែរឬទេ។

**មាត្រា១៤.១០ _ តម្រូវការសម្រាប់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ**

១- សមាជិកក្រុមប្រឹក្សាជំនុំជម្រះនីមួយៗត្រូវ៖

(ក) បានបង្ហាញពីជំនាញផ្នែកច្បាប់ ពាណិជ្ជកម្មអន្តរជាតិ និងផ្នែកផ្សេងៗទៀត ដែលគ្របដណ្តប់ក្នុងកិច្ចព្រមព្រៀងនេះ

(ខ) មានឯករាជ្យភាព និងមិនជាប់ពាក់ព័ន្ធជាមួយ ឬទទួលសេចក្តីបង្គាប់ពីភាគីសមាជិកណាមួយឡើយ

(គ) បំពេញមុខងារតាមសមត្ថភាពរបស់ខ្លួន និងមិនត្រូវទទួលសេចក្តីបង្គាប់ពីអង្គការ ឬរដ្ឋាភិបាលណាមួយលើបញ្ហាដែលទាក់ទងនឹងជម្លោះ

(ឃ) អនុលោមតាមក្រមប្រតិបត្តិសម្រាប់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១៤ខ (ក្រមប្រតិបត្តិសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ) និង

(ង) ត្រូវបានជ្រើសរើសយ៉ាងតឹងរ៉ឹងផ្អែកលើកត្តាសត្យានុម័ត ភាពអាចជឿទុកចិត្តបាន និងការវិនិច្ឆ័យដ៏ត្រឹមត្រូវ។

២- ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវមានបទពិសោធក្នុងដំណើរការនីតិវិធីដោះស្រាយវិាទផងដែរ។

៣- បុគ្គលដែលផ្តល់អន្តរការី ការផ្សះផ្សា ឬសន្ធានកម្មទៅកាន់គូភាគី ដោយអនុលោមតាមមាត្រា ១៤.៦ ទាក់ទងនឹងបញ្ហាដូចគ្នាឬបញ្ហាសមមូលជាសារវន្ត មិនត្រូវមានសិទ្ធិតែងតាំងជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះក្នុងបញ្ហានោះទេ។

**មាត្រា១៤.១១ _ ការជំនួសសមាជិកក្រុមប្រឹក្សាជំនុំជម្រះ**

ប្រសិនបើសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាមួយនៃក្រុមប្រឹក្សាជំនុំជម្រះដើមមិនអាចធ្វើសកម្មភាព ដកចេញ ឬត្រូវការជំនួស ដោយសារសមាជិកក្រុមប្រឹក្សាជំនុំជម្រះនោះមិនគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមប្រតិបត្តិនោះ បុគ្គលដែលត្រូវទទួលតំណែងជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះបន្តនឹងត្រូវតែងតាំងតាមរបៀបដូចគ្នា ដូចបានកំណត់សម្រាប់ការតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះដើម ហើយបុគ្គលដែលត្រូវទទួលតំណែងបន្តនោះត្រូវមានសិទ្ធិអំណាច និងការកិច្ចទាំងអស់ដូចសមាជិកក្រុមប្រឹក្សាជំនុំជម្រះដើមផងដែរ។ កិច្ចការរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវបានព្យួរទុកក្នុងកំឡុងពេលតែងតាំងបុគ្គលដែលត្រូវស្នងតំណែងជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ។

**មាត្រា១៤.១២ _ មុខងាររបស់ក្រុមប្រឹក្សាជំនុំជម្រះ**

លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះ៖

(ក) ត្រូវធ្វើការវាយតម្លៃបែបសត្យានុម័តលើរឿងក្តី រួមទាំងការវាយតម្លៃបែបសត្យានុម័តលើអង្គហេតុនៃសំណុំរឿងនោះ និងភាពដែលអាចយកមកអនុវត្តបាន និងអនុលោមភាពតាមវិធានការដែលចោទជាបញ្ហា ជាមួយនឹងបទប្បញ្ញត្តិគ្របដណ្តប់។

(ខ) ត្រូវបញ្ចូលក្នុងសេចក្តីសម្រេច និងរបាយការណ៍របស់ខ្លួន សេចក្តីសម្រេចលើការជំនុំជម្រះនៃអង្គហេតុនិងអង្គច្បាប់ និងហេតុផលនៅពីក្រោយសេចក្តីសម្រេចរបស់តុលាការ និងការសន្និដ្ឋានណាមួយដែលខ្លួនធ្វើ និង

(គ) ត្រូវពិគ្រោះយោបល់ជាមួយគូភាគីជាប្រចាំ និងផ្តល់ឱកាសឱ្យបានគ្រប់គ្រាន់សម្រាប់ការស្វែងរកដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង។

**មាត្រា១៤.១៣ _ លក្ខខណ្ឌយោង**

១- លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្នុងកំឡុងពេល១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបង្កើតក្រុមប្រឹក្សាជំនុំជម្រះ លក្ខខណ្ឌយោងរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

"ដោយពិចារណាលើបទប្បញ្ញត្តិគ្រប់ដណ្តប់ពាក់ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះដែលបានលើកឡើងដោយគូភាគី ពិនិត្យលើបញ្ហាដូចមានក្នុងសំណើបង្កើតក្រុមប្រឹក្សាជំនុំជម្រះដើម្បីស្រាវជ្រាវលើអនុលោមភាពនៃវិធានការ ដែលចោទជាបញ្ហាជាមួយនឹងបទប្បញ្ញត្តិគ្របដណ្តប់ដែលពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាអនុសាសន៍លើមធ្យោបាយដោះស្រាយវិវាទ និងដើម្បីផ្តល់របាយការណ៍ដោយអនុលោមតាមមាត្រា១៤.១៧ និង ១៤.១៨ ប្រសិនបើមាន។"

២- ប្រសិនបើគូភាគីឯកភាពលើលក្ខខណ្ឌយោងលើសពីអ្វីដែលបានលើកឡើងក្នុងកថាខណ្ឌ១ នោះ គូភាគីត្រូវជូនដំណឹងអំពីលក្ខខណ្ឌយោងដែលបានព្រមព្រៀងទៅក្រុមប្រឹក្សាជំនុំជម្រះ មិនឱ្យលើសពី៥ថ្ងៃ បន្ទាប់ពីការព្រមព្រៀងរបស់ខ្លួន។

**មាត្រា១៤.១៤ _ ទិដ្ឋានៃការបកស្រាយ**

១- ក្រុមប្រឹក្សាជំនុំជម្រះត្រូវបកស្រាយបទប្បញ្ញត្តិគ្រប់ដណ្តប់ ដោយយោងទៅតាមវិធានទំនៀមទម្លាប់នៃការបកស្រាយក្នុងច្បាប់អន្តរជាតិសាធារណៈ។

២- ក្រុមប្រឹក្សាជំនុំជម្រះក៏អាចពិចារណាលើការបកស្រាយដែលពាក់ព័ន្ធ នៅក្នុងរបាយការណ៍ពីមុនរបស់ក្រុមប្រឹក្សាជំនុំជម្រះដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និងរបាយការណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ និងអង្គឧទ្ធរណ៍ដែលត្រូវបានអនុម័តដោយស្ថាប័នដោះស្រាយវិវាទនៃWTO នៅពេលសមស្រប។

**មាត្រា១៤.១៥ _ នីតិវិធីរបស់ក្រុមប្រឹក្សាជំនុំជម្រះ**

១- លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើតាមគំរូវិធាននៃនីតិវិធីដូចមានចែងក្នុងឧបសម្ព័ន្ធ១៨ក(វិធាននៃនីតិវិធីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ)។

២- ក្រុមប្រឹក្សាជំនុំជម្រះអាចអនុម័តវិធានបន្ថែមនៃនីតិវិធីដែលមានអសង្គតិភាពនឹងគំរូវិធាននៃនីតិវិធីបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគូភាគី។

៣- មិនត្រូវមានការប្រាស្រ័យទាក់ទងជាមួយភាគីតែម្ខាងធ្វើឡើងជាមួយក្រុមប្រឹក្សាជំនុំជម្រះ ពាក់ព័ន្ធនឹងបញ្ហាដែលកំពុងស្ថិតនៅក្នុងការពិចារណាឡើយ។

៤- កិច្ចពិភាក្សាដេញដោលរបស់ក្រុមប្រឹក្សាជំនុំជម្រះ និងឯកសារដាក់ជូនទៅក្រុមប្រឹក្សាជំនុំជម្រះត្រូវរក្សាការសម្ងាត់។

៥- ភាគីសមាជិកដែលអះអាងថា វិធានការរបស់ភាគីសមាជិកម្ខាងទៀតមានអសង្គតិភាពនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវមានបន្ទុកក្នុងការអះអាងអំពីអសង្គតិភាពនេះ។ ភាគីសមាជិកដែលអះអាងថា វិធានការមួយស្ថិតក្រោមការលើកលែងនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវមានបន្ទុកក្នុងការបញ្ជាក់ពីការលើកលែង។

៦- ក្រុមប្រឹក្សាជំនុំជម្រះគួរពិគ្រោះយោបល់ជាមួយគូភាគីតាមភាពសមស្របនិងផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការសម្រេចបាននូវដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង។

៧- ក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើសេចក្តីសម្រេច រួមបញ្ចូលទាំងរបាយការណ៍ តាមរយៈការស្របមតិគ្នា ប៉ុន្តែប្រសិនបើមិនអាចស្របមតិគ្នាបានទេ នោះត្រូវសម្រេចតាមសមាជិកភាគច្រើនរបស់ខ្លួន។ សមាជិកណាម្នាក់អាចផ្តល់យោបល់ជាច់ដោយឡែកពីគ្នាលើបញ្ហា ដែលមិនត្រូវបានឯកភាពជាឯកច្ឆន្ទ ប៉ុន្តែមតិជំទាស់របស់សមាជិកមិនត្រូវលាតត្រដាងក្នុងកាលៈទេសៈណាមួយឡើយ។

**មាត្រា១៤.១៦ _ ការឧទ្ធរណ៍ព័ត៌មាន**

១- តាមសំណើរបស់ភាគីណាមួយឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្រុមប្រឹក្សាជំនុំជម្រះអាចស្វែងរកព័ត៌មានពាក់ព័ន្ធពីគូភាគីដែលខ្លួនចាត់ទុកថាចាំបាច់និងសមស្រប។ គូភាគីត្រូវឆ្លើយតបភ្លាមៗ និងមានលក្ខណៈពេញលេញទៅលើសំណើណាមួយរបស់ក្រុមប្រឹក្សាជំនុំជម្រះសម្រាប់ព័ត៌មាន។

២- តាមការស្នើសុំរបស់ភាគីឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្រុមប្រឹក្សាជំនុំជម្រះអាចស្វែងរកព័ត៌មានពីប្រភពណាមួយដែលខ្លួនចាត់ទុកថាសមស្រប។ ក្រុមប្រឹក្សាជំនុំជម្រះក៏មានសិទ្ធិស្វែងរកយោបល់ពីអ្នកជំនាញផងដែរ ដែលចាត់ទុកថាសមស្រប និងជាកម្មវត្ថុនៃលក្ខខណ្ឌណាមួយដែលបានឯកភាពដោយគូភាគី ដែលជាចំណុចដែលអាចអនុវត្តបាន។

៣- តាមសំណើរបស់ភាគីឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្រុមប្រឹក្សាជំនុំជម្រះអាចស្វែងរកព័ត៌មាននិងការប្រឹក្សាបច្ចេកទេសពីបុគ្គលឬស្ថាប័នណាមួយ ដែលខ្លួនយល់ថាសមស្របសម្រាប់ដែលគូភាគីឯកភាព និងគោរពតាមលក្ខខណ្ឌនិងស្ថានភាពដូចដែលគូភាគីឯកភាព។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្តល់ឱ្យគូភាគីនូវព័ត៌មានណាមួយដែលទទួលបានដើម្បីជាមតិយោបល់។

៤- ពាល់ព័ត៌មានដែលទទួលបានដោយក្រុមប្រឹក្សាជំនុំជម្រះក្រោមមាត្រានេះ ត្រូវផ្តល់ជូនគូភាគី ហើយគូភាគីអាចផ្តល់មតិយោបល់លើព័ត៌មាននោះ។

**មាត្រា១៤.១៧ _ របាយការណ៍បណ្តោះអាសន្ន**

១- ក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ជូនរបាយការណ៍បណ្តោះអាសន្នមួយទៅគូភាគីក្នុងកំឡុងពេល៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ។ នៅពេលក្រុមប្រឹក្សាជំនុំជម្រះពិចារណាថា មិនអាចបំពេញតាមកាលកំណត់នេះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវជូនដំណឹងដល់គូភាគីជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការពន្យារពេលនិងកាលបរិច្ឆេទដែលក្រុមប្រឹក្សាជំនុំជម្រះគ្រោងនឹងបញ្ជូនរបាយការណ៍បណ្តោះអាសន្នរបស់ខ្លួន។ ទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ ការពន្យារពេលមិនត្រូវលើសពី៣០ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់។

២- របាយការណ៍បណ្តោះអាសន្នត្រូវកំណត់ពីផ្នែកពិពណ៌នា និងសេចក្តីសម្រេចនិងការសន្និដ្ឋានរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

៣- ភាគីនីមួយៗអាចដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះនូវមតិយោបល់ និងសំណើជាលាយលក្ខណ៍អក្សរដើម្បីពិនិត្យមើលទិដ្ឋភាពជាក់ស្តែងនៃរបាយការណ៍បណ្តោះអាសន្ននោះក្នុងកំឡុងពេល១៥ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍បណ្តោះអាសន្ន។ ភាគីសមាជិកអាចផ្តល់មតិយោបល់លើសំណើរបស់ភាគីសមាជិកម្ខាងទៀតក្នុងកំឡុងពេល៦ថ្ងៃបន្ទាប់ពីការបញ្ជូនសំណើ។

៤- បន្ទាប់ពីបានពិចារណាលើមតិយោបល់និងសំណើជាលាយលក្ខណ៍អក្សររបស់ភាគីនីមួយៗលើរបាយការណ៍បណ្តោះអាសន្ន ក្រុមប្រឹក្សាជំនុំជម្រះអាចកែសម្រួលរបាយការណ៍បណ្តោះអាសន្ននិងធ្វើការពិនិត្យបន្ថែមទៀត ដែលខ្លួនចាត់ទុកថាសមស្រប។

**មាត្រា១៤.១៨ _ របាយការណ៍ស្ថាពរ**

១- ក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ជូនរបាយការណ៍ស្ថាពររបស់ខ្លួនទៅគូភាគី ក្នុងកំឡុងពេល១២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ។ នៅពេលក្រុមប្រឹក្សាជំនុំជម្រះពិចារណាថាមិនអាចបំពេញតាមកាលកំណត់នេះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវជូនដំណឹងដល់គូភាគីជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុនៃការពន្យារពេលនិងកាលបរិច្ឆេទដែលក្រុមប្រឹក្សានេះគ្រោងនឹងបញ្ជូនរបាយការណ៍ស្ថាពររបស់ខ្លួន។ ទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ ការពន្យារពេលមិនត្រូវ លើសពី៣០ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់។

២- របាយការណ៍ស្ថាពរ ត្រូវរួមបញ្ចូលការពិភាក្សាអំពីមតិយោបល់និងសំណើជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយភាគីនីមួយៗលើរបាយការណ៍បណ្តោះអាសន្ន។ នៅក្នុងរបាយការណ៍ស្ថាពរ ក្រុមប្រឹក្សាជំនុំជម្រះអាចស្នើពីវិធីដែលរបាយការណ៍ចុងក្រោយអាចត្រូវបានអនុវត្ត។

៣- របាយការណ៍ស្ថាពរត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងកំឡុងពេល១៥ថ្ងៃ បន្ទាប់ពីការបញ្ជូនទៅគូភាគី លើកលែងតែគូភាគីឯកភាពក្នុងការបោះពុម្ពរបាយការណ៍ស្ថាពរជាផ្នែកៗឬមិនបោះពុម្ពរបាយការណ៍ស្ថាពរ។

**មាត្រា១៤.១៩ _ ការអនុវត្តរបាយការណ៍ស្ថាពរ**

១- នៅពេលដែលក្រុមប្រឹក្សាជំនុំជម្រះរកឃើញថា ភាគីឆ្លើយតបបានធ្វើសកម្មភាពមិនស្របនឹងបទប្បញ្ញត្តិគ្របដណ្តប់ ភាគីឆ្លើយតបត្រូវចាត់វិធានការណាមួយដែលចាំបាច់ដើម្បីអនុវត្តតាមភ្លាមៗ និងដោយសុចរិតនិងស្មោះត្រង់ ជាមួយនឹងសេចក្តីសម្រេចនៃការជំនុំជម្រះនិងការសន្និដ្ឋាននៅក្នុងរបាយការណ៍ស្ថាពរ។

២- ភាគីឆ្លើយតបត្រូវគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះភ្លាមៗ។ ប្រសិនបើសេចក្តីសម្រេចនោះមានលក្ខណៈមិនអាចអនុវត្តបានភ្លាមៗទេ ភាគីឆ្លើយតប មិនយូរជាង៣០ថ្ងៃ បន្ទាប់ពីការបញ្ជូនរបាយការណ៍ស្ថាពរ ត្រូវជូនដំណឹងដល់ភាគីតវ៉ាអំពីកំឡុងពេលសមហេតុផលដែលចាំបាច់សម្រាប់ការអនុលោមតាមរបាយការណ៍ស្ថាពរ ហើយគូភាគីត្រូវព្យាយាមក្នុងការឯកភាពលើកំឡុងពេលសមហេតុផលដែលត្រូវការសម្រាប់ការអនុលោមតាមរបាយការណ៍ស្ថាពរ។

**មាត្រា១៤.២០ _ កំឡុងពេលសមរម្យនៃពេលវេលាសម្រាប់ការអនុលោម**

១- ប្រសិនបើគូភាគីមិនបានឯកភាពលើកំឡុងពេលសមរម្យនោះ ភាគីប្តឹងតវ៉ាអាចស្នើសុំជាលាយលក្ខណ៍អក្សរលើក្រុមប្រឹក្សាជំនុំជម្រះដើម ដើម្បីកំណត់កំឡុងពេលសមហេតុផល មិនឱ្យលើសពី២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលសេចក្តីជូនដំណឹងដែលធ្វើឡើងដោយភាគីឆ្លើយតបអនុលោមតាមមាត្រា១៤.១៩។ សំណើបែបនេះត្រូវជូនដំណឹងក្នុងពេលដំណាលគ្នាទៅភាគីឆ្លើយតប។ កំឡុងពេល២០ថ្ងៃ ដែលត្រូវបានចែងនៅក្នុងកថាខណ្ឌនេះអាចត្រូវបានពន្យារដោយការឯកភាពទៅវិញទៅមកនៃគូភាគី។

២- ក្រុមប្រឹក្សាជំនុំជម្រះដើម ត្រូវបញ្ជូនសេចក្តីសម្រេចរបស់ខ្លួនទៅគូភាគីក្នុងកំឡុងពេល២០ថ្ងៃ ចាប់ពីការស្នើសុំដែលពាក់ព័ន្ធ។

៣- រយៈពេលនៃកំឡុងពេលសមរម្យសម្រាប់ការអនុលោមតាមបាយការណ៍ស្ថាពរ អាចត្រូវបានពន្យារដោយមានការឯកភាពទាំងសងខាងរបស់គូភាគី។

**មាត្រា១៤.២១ _ ការពិនិត្យអនុលោមភាព**

១- ភាគីឆ្លើយតប ត្រូវបញ្ជូនសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីវឌ្ឍនភាពរបស់ខ្លួនក្នុងការអនុលោមតាមបាយការណ៍ស្ថាពរទៅភាគីដែលប្តឹងតវ៉ា យ៉ាងហោចណាស់មួយខែមុនពេលផុតកំណត់នៃរយៈពេលសមស្របសម្រាប់ការអនុលោមតាមបាយការណ៍ស្ថាពរ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

២- មិនយូរជាងកាលបរិច្ឆេទផុតកំណត់នៃកំឡុងពេលសមហេតុផល ភាគីឆ្លើយតបត្រូវបញ្ជូនសេចក្តីជូនដំណឹងដល់ភាគីដែលប្តឹងតវ៉ាអំពីវិធានការណាមួយ ដែលខ្លួនបានយកទៅអនុវត្តតាមបាយការណ៍ស្ថាពរ រួមជាមួយនឹងការពិពណ៌នាអំពីរបៀបដែលវិធានការធានាបាននូវអនុលោមភាពគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យភាគីប្តឹងតវ៉ាវាយតម្លៃវិធានការមុនពេលផុតកំណត់នៃកំឡុងពេលសមស្រប។

៣- នៅពេលដែលគូភាគីមិនឯកភាពលើអត្ថិភាពនៃវិធានការដើម្បីអនុវត្តតាមបាយការណ៍ស្ថាពរ ឬសង្គតិភាពជាមួយនឹងបទប្បញ្ញត្តិដែលគ្របដណ្តប់ ភាគីដែលប្តឹងតវ៉ាអាចស្នើសុំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាជំនុំជម្រះដើម ដើម្បីសម្រេចលើបញ្ហានេះមុនពេលសំណងអាចត្រូវបានស្នើសុំឬការព្យួរអត្ថប្រយោជន៍អាចត្រូវបានអនុវត្ត ដោយអនុលោមតាមមាត្រា១៤.២២.១(គ)។ សំណើបែបនេះ ត្រូវជូនដំណឹងក្នុងពេលដំណាលគ្នាទៅភាគីឆ្លើយតប។

៤- សំណើត្រូវផ្តល់មូលដ្ឋានជាក់ស្តែងនិងផ្លូវច្បាប់សម្រាប់ពាក្យបណ្តឹង រួមទាំងការកំណត់អត្តសញ្ញាណនៃវិធានការជាក់លាក់ដែលមានបញ្ហា និងការបង្ហាញអំពីមូលហេតុដែលវិធានការណាមួយដែលធ្វើឡើងដោយអ្នកឆ្លើយតបមិនគោរពតាមបាយការណ៍ស្ថាពរ ឬមានអសង្គតិភាពនឹងបទប្បញ្ញត្តិដែលគ្របដណ្តប់។

៥- ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបញ្ជូនសេចក្តីសម្រេចរបស់ខ្លួនទៅឱ្យគូភាគី ក្នុងកំឡុងពេល៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបញ្ជូនសំណើ។

**មាត្រា១៤.២២ _ ឧបាស្រ័យបណ្តោះអាសន្នក្នុងករណីមិនមានអនុលោមភាព**

១- ប្រសិនបើភាគីឆ្លើយតប៖

(ក) ខកខានក្នុងការជូនដំណឹងអំពីវិធានការណាមួយ ដែលអនុលោមតាមបាយការណ៍ស្ថាពរមុនពេលផុតកំណត់នៃកំឡុងពេលសមរម្យ

(ខ) ជូនដំណឹងដល់ភាគីដែលប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរថា មិនអាចអនុវត្តតាមបាយការណ៍ស្ថាពរក្នុងកំឡុងពេលសមហេតុផល ឬ

(គ) ក្រុមប្រឹក្សាជំនុំជម្រះដើមរកឃើញថា គ្មានវិធានការណាមួយដែលត្រូវអនុវត្តតាម ឬថាវិធានការដែលធ្វើឡើងដើម្បីអនុវត្តតាមបាយការណ៍ស្ថាពរ ដូចដែលបានជូនដំណឹងដោយភាគីដែលបានតវ៉ា គឺមានអសង្គតិភាពនឹងបទប្បញ្ញត្តិដែលគ្របដណ្តប់នោះទេ។

ភាគីឆ្លើយតប ត្រូវចូលរួមក្នុងការពិគ្រោះយោបល់ក្នុងគោលបំណងសម្រេចបាននូវកិច្ចព្រមព្រៀងដែលពេញចិត្តទាំងសងខាងឬសំណងចាំបាច់ណាមួយលើសំណើរបស់ភាគីប្តឹងតវ៉ា។

២- ប្រសិនបើគូភាគីមិនអាចឈានដល់ការឯកភាពដែលពេញចិត្តទាំងសងខាង ឬឯកភាពលើសំណងក្នុងកំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានសំណើដែលបានធ្វើឡើងដោយអនុលោមតាមកថាខណ្ឌ១ ភាគីប្តឹងតវ៉ាអាចបញ្ជូនសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីឆ្លើយតបថាខ្លួនមានបំណងផ្តាកការស្នើសុំទៅភាគីនៃអត្ថប្រយោជន៍ ឬភាគពាក់ព័ន្ធផ្សេងទៀតក្រោមកិច្ចព្រមព្រៀងនេះ។ សេចក្តីជូនដំណឹង ត្រូវបញ្ជាក់កម្រិតនៃបំណងក្នុងការលួរអត្ថប្រយោជន៍ឬភាគពាក់ព័ន្ធផ្សេងទៀត។

៣- ភាគីប្តឹងតវ៉ាអាចចាប់ផ្តើមការលួរអត្ថប្រយោជន៍ឬភាគពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌមុន៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនផ្តល់សេចក្តីជូនដំណឹងដល់ភាគីតវ៉ា លើកលែងតែភាគីឆ្លើយតបបានស្នើសុំក្រោមកថាខណ្ឌ៧។

៤- ការលួរអត្ថប្រយោជន៍ឬភាគពាក់ព័ន្ធផ្សេងទៀត៖

(ក) ត្រូវស្ថិតក្នុងកម្រិតមួយស្មើនឹងមោយភាពឬវិការៈ ដែលបណ្តាលមកពីការខកខានរបស់ភាគីឆ្លើយតបក្នុងការអនុវត្តតាមរបាយការណ៍ស្តាពរ និង

(ខ) ត្រូវដាក់កម្រិតចំពោះអត្ថប្រយោជន៍ ដែលទទួលបានដល់ភាគីឆ្លើយតបក្រោមកិច្ចព្រមព្រៀងនេះ។

៥- ក្នុងការពិចារណាអំពីអត្ថប្រយោជន៍អ្វីខ្លះដែលត្រូវលួរស្របតាមកថាខណ្ឌ២ ភាគីដែលប្តឹងតវ៉ាត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

(ក) ភាគីដែលតវ៉ា គួរតែស្នើសុំការលួរអត្ថប្រយោជន៍នៅក្នុងវិស័យដូចគ្នាជាមុនសិន ឬវិស័យដែលរងផលប៉ះពាល់ដោយវិធានការ ដែលក្រុមប្រឹក្សាជំនុំជម្រះបានរកឃើញថាមិនស្របនឹងកិច្ចព្រមព្រៀងនេះ ឬបានបណ្តាលឱ្យមានមោយៈភាពឬវិការៈ[1]។

(ខ) ភាគីដែលតវ៉ា អាចលួរអត្ថប្រយោជន៍ក្នុងវិស័យផ្សេងទៀត ប្រសិនបើខ្លួនចាត់ទុកថាមិនអាចអនុវត្តបាន ឬមានប្រសិទ្ធភាពក្នុងការលួរអត្ថប្រយោជន៍ឬភាគពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិស័យតែមួយ និង

(គ) ក្នុងការជ្រើសរើសអត្ថប្រយោជន៍ដែលត្រូវលួរ ភាគីដែលប្តឹងតវ៉ាត្រូវព្យាយាមក្នុងការពិចារណាលើផ្នែកណាដែលរំខានដល់ការអនុវត្តកិច្ចព្រមព្រៀងនេះតិចបំផុត។

៦- ការលួរអត្ថប្រយោជន៍ឬភាគពាក់ព័ន្ធផ្សេងទៀត គឺបណ្តោះអាសន្ន ហើយត្រូវអនុវត្តរហូតដល់អសង្គតិភាពនៃវិធានការជាមួយនឹងបទប្បញ្ញត្តិដែលគ្របដណ្តប់ពាក់ព័ន្ធ ត្រូវបានរកឃើញនៅក្នុងរបាយការណ៍ស្តាពរថាត្រូវបានដកចេញ ឬរហូតដល់គូភាគីបានឯកភាពដោយការពេញចិត្តទាំងសងខាង ឬសំណងចាំបាច់ណាមួយ។

---

[1] សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "វិស័យ" មានន័យថា៖ (i) ទាក់ទងនឹងទំនិញ មានន័យថា ទំនិញទាំងអស់ (ii) ទាក់ទងនឹងសេវាកម្ម មានន័យថា វិស័យចម្បងដូចដែលបានកំណត់នៅក្នុង "បញ្ជីចំណាត់ថ្នាក់ផ្នែកសេវាកម្ម" បច្ចុប្បន្ន ដែលកំណត់ផ្នែកទាំងនោះ។

៧. ប្រសិនបើភាគីឆ្លើយតប ចាត់ទុកថាការលួរអត្ថប្រយោជន៍មិនអនុលោមតាមកថាខណ្ឌ៤និង៥ នោះភាគីនោះអាចស្នើសុំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាជំនុំជម្រះដើម ដើម្បីពិនិត្យបញ្ហានេះ មិនលើសពី១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី២។ សំណើនោះ ត្រូវជូនដំណឹងក្នុងពេលដំណាលគ្នាទៅភាគីដែលប្តឹងតវ៉ា។ ក្រុមប្រឹក្សាជំនុំជម្រះដើម ត្រូវជូនដំណឹងទៅគូភាគី ពីសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះមិនលើសពី ៣០ថ្ងៃ នៃការទទួលបានសំណើពីភាគីដែលឆ្លើយតប។ អត្ថប្រយោជន៍ ឬកាតព្វកិច្ចផ្សេងទៀត មិនត្រូវផ្អាកឡើយ រហូតទាល់តែក្រុមប្រឹក្សាជំនុំជម្រះដើមបានចេញសេចក្តីសម្រេចរបស់ខ្លួន។ ការលួរអត្ថប្រយោជន៍ឬកាតព្វកិច្ចផ្សេងទៀត ត្រូវមានសង្គតិភាពតាមសេចក្តីសម្រេចនេះ។

**មាត្រា១៤.២៣ _ ការពិនិត្យឡើងវិញនូវវិធានការណ៍ណាមួយដែលត្រូវអនុវត្តតាម បន្ទាប់ពីការអនុម័តនៃឧបាស្រ័យបណ្តោះអាសន្ន**

១- តាមសេចក្តីជូនដំណឹងរបស់ភាគីឆ្លើយតបទៅភាគីដែលប្តឹងតវ៉ាអំពីវិធានការដែលបានធ្វើឡើងដើម្បីអនុវត្តតាមរបាយការណ៍ស្ថាពរ៖

(ក) ក្នុងស្ថានភាពដែលសិទ្ធិក្នុងការលួរអត្ថប្រយោជន៍ឬកាតព្វកិច្ចផ្សេងទៀត ត្រូវបានអនុវត្តដោយភាគីតវ៉ាស្របតាមមាត្រា១៤.២២ ភាគីប្តឹងតវ៉ាត្រូវបញ្ចប់ការលួរអត្ថប្រយោជន៍ឬកាតព្វកិច្ចផ្សេងទៀត មិនលើសពី៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹង លើកលែងតែករណីដែលបានចែងក្នុងកថាខណ្ឌ២ ឬ

(ខ) ក្នុងស្ថានភាពដែលសំណងចាំបាច់ត្រូវបានឯកភាពគ្នា ភាគីឆ្លើយតបអាចបញ្ចប់ការអនុវត្តសំណងបែបនេះ មិនលើសពី៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹង លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ២។

២- ប្រសិនបើគូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើថាតើវិធានការដែលបានជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ១ ស្របនឹងបទប្បញ្ញត្តិដែលមានការគ្របដណ្តប់ដែលពាក់ព័ន្ធ ក្នុងកំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹងនោះ ភាគីដែលប្តឹងតវ៉ាត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះដើម ដើម្បីពិនិត្យលើបញ្ហានោះ។ សំណើនោះត្រូវជូនដំណឹងក្នុងពេលដំណាលគ្នាទៅភាគីឆ្លើយតប។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវជូនដំណឹងដល់គូភាគីមិនលើសពី៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដោក់សំណើ។ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះសម្រេចថា វិធានការដែលបានជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ១ គឺមានសង្គតិភាពជាមួយនឹងបទប្បញ្ញត្តិដែលបានគ្របដណ្តប់ពាក់ព័ន្ធ ការលួរអត្ថប្រយោជន៍ ឬកាតព្វកិច្ចផ្សេងទៀត ឬការអនុវត្តសំណង នឹងត្រូវបញ្ចប់មិនលើសពី១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច។ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះកំណត់ថាវិធានការដែលបានជូនដំណឹងសម្រេចបានតែការអនុលោមតាមផ្នែកនៃបទប្បញ្ញត្តិ ដែលបានគ្របដណ្តប់នោះ កម្រិតនៃការលួរអត្ថប្រយោជន៍ ឬកាតព្វកិច្ចផ្សេងទៀត ឬនៃប្រាក់សំណង នឹងត្រូវកែសម្រួលទៅតាមការសេម្រេចចិត្តរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

**មាត្រា១៤.២៤ _ ការផ្សះផ្សានិងការបញ្ចប់នៃនីតិវិធីបណ្តឹង**

ប្រសិនបើភាគីទាំងពីរស្នើសុំដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្សះក្នុងរយៈពេលដែលបានឯកភាពដោយគូភាគី ហើយមិនលើសពី១២ខែ ជាប់ៗគ្នា។ ក្នុងករណីមានការផ្សះការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះ នោះរយៈពេលដែលពាក់ព័ន្ធនៅក្រោមផ្នែកនេះត្រូវពន្យារដោយរយៈពេលស្មើគ្នា ដែលការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវបានផ្សះ។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវបន្តការងាររបស់ខ្លួនឡើងវិញមុនការបញ្ចប់រយៈពេលនៃការផ្សះតាមសំណើជាលាយលក្ខណ៍អក្សររបស់គូភាគី។ ប្រសិនបើការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវបានផ្សះលើសពី១២ខែ ជាប់ៗគ្នា អាជ្ញាធរនៃក្រុមប្រឹក្សាជំនុំជម្រះនឹងត្រូវផុតរលត់ ហើយនីតិវិធីដោះស្រាយវិវាទនឹងត្រូវបញ្ចប់។

**មាត្រា១៤.២៥ _ ការជ្រើសរើសវេទិកា**

១- លើកលែងតែមានចែងក្នុងមាត្រានេះ ដំពូកនេះមិនមានការប៉ះពាល់ដល់សិទ្ធិរបស់ភាគីក្នុងការទាមទារនីតិវិធីដោះស្រាយវិវាទ ដែលមាននៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិផ្សេងទៀតដែលពួកគេជាគូភាគីទាំងពីរ។

២- នៅពេលដែលវិវាទកើតឡើងទាក់ទងនឹងអសង្គតិភាពនៃវិធានការជាក់លាក់ណាមួយ ជាមួយនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ និងកាតព្វកិច្ចសមមូលយ៉ាងសំខាន់នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិផ្សេងទៀតដែលភាគីទាំងពីរជាភាគីសមាជិក រួមទាំងកិច្ចព្រមព្រៀងWTO ភាគីប្តឹងតវ៉ាអាចជ្រើសរើសវេទិកាដើម្បីដោះស្រាយវិវាទ។

៣- នៅពេលដែលភាគីសមាជិកបានជ្រើសរើសវេទិកា និងចាប់ផ្តើមដំណើរការដោះស្រាយវិវាទក្រោមដំពូកនេះឬក្រោមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតទាក់ទងនឹងវិធានការជាក់លាក់ ដូចមានចែងក្នុងកថាខណ្ឌ២ ភាគីនោះមិនត្រូវចាប់ផ្តើមដំណើរការដោះស្រាយវិវាទនៅក្នុងវេទិកាផ្សេងទៀតទាក់ទងនឹងវិធានការជាក់លាក់នោះ លុះត្រាតែវេទិកាដែលបានជ្រើសរើសដំបូងមិនអាចស្វែងរកបញ្ហាដែលមានជម្លោះសម្រាប់ហេតុផលយុត្តាធិការឬហេតុផលនៃនីតិវិធី។

៤- សម្រាប់គោលបំណងនៃកថាខណ្ឌ៣៖

(ក) ដំណើរការដោះស្រាយវិវាទក្រោមដំពូកនេះ ត្រូវបានចាត់ទុកថា ត្រូវបានចាប់ផ្តើមនៅពេលដែលភាគីមួយស្នើសុំឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយស្របតាមមាត្រា១៤.៧

(ខ) ដំណើរការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងWTO ត្រូវបានចាត់ទុកថា ត្រូវបានចាប់ផ្តើមនៅពេលដែលភាគីសមាជិកស្នើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយ អនុលោមតាមមាត្រា៦ នៃការព្រមព្រៀងស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងការដោះស្រាយវិវាទ(DSU) និង

(គ) ដំណើរការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងផ្សេងទៀត ត្រូវបានចាត់ទុកថា ត្រូវបានចាប់ផ្តើមនៅពេលដែលភាគីសមាជិកស្នើសុំបង្កើតក្រុមដោះស្រាយវិវាទ ដោយអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនោះ។

**មាត្រា១៤.២៦ _ ការចំណាយ**

១- លើកលែងតែភាគីយល់ព្រមផ្សេងពីនេះ ការចំណាយរបស់ក្រុមប្រឹក្សាជំនុំជម្រះ និងការចំណាយផ្សេងទៀតដែលទាក់ទងនឹងដំណើរការនីតិវិធី ត្រូវទទួលបន្ទុកស្មើគ្នាដោយភាគីទាំងពីរ។

២- ភាគីនីមួយៗត្រូវទទួលខុសត្រូវលើការចំណាយរបស់ខ្លួន និងការចំណាយផ្លូវច្បាប់នៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

**មាត្រា១៤.២៧ _ ដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង**

១- គូភាគីអាចឈានដល់ដំណោះស្រាយ ដែលឯកភាពគ្នាទាំងសងខាងនៅពេលណាក៏ដោយទាក់ទងនឹងវិវាទណាមួយដូចមានចែងក្នុងមាត្រា១៤.២។

២- ប្រសិនបើដំណោះស្រាយត្រូវបានឯកភាពគ្នាទាំងសងខាង ក្នុងកំឡុងពេលនៃដំណើរការនៃក្រុមប្រឹក្សាជំនុំជម្រះ គូភាគីត្រូវជូនដំណឹងរួមគ្នាអំពីដំណោះស្រាយនោះទៅកាន់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ បន្ទាប់ពីសេចក្តីជូនដំណឹងនេះ ក្រុមប្រឹក្សាជំនុំជម្រះនឹងត្រូវបញ្ចប់។

៣- ភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីអនុវត្តដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាងក្នុងកំឡុងពេលដែលបានព្រមព្រៀងគ្នា។

៤- ភាគីអនុវត្តត្រូវជូនដំណឹងទៅភាគីសមាជិកម្ខាងទៀតជាលាយលក្ខណ៍អក្សរ អំពីវិធានការណាមួយដែលខ្លួនបានលើកយកមកអនុវត្តដំណោះស្រាយដែលបានព្រមព្រៀងគ្នានោះ មិនឱ្យរជាងពេលផុតកំណត់នៃកំឡុងពេលដែលបានឯកភាពគ្នា ។

**មាត្រា១៤.២៨ _ រយៈពេលកំណត់**

១- រយៈពេលកំណត់ទាំងអស់ដូចមានចែងក្នុងជំពូកនេះ ត្រូវគប់ជាថ្ងៃតាមប្រតិទិន ចាប់ពីថ្ងៃបន្ទាប់ពីសកម្មភាពដែលពួកគេសំដៅលើ។

២- រយៈពេលកំណត់ណាមួយដូចមានចែងនៅក្នុងជំពូកនេះ អាចត្រូវបានកែប្រែដោយកិច្ចព្រមព្រៀងទាំងសងខាងនៃគូភាគី។

**មាត្រា១៤.២៩ _ ឧបសម្ព័ន្ធ**

គណៈកម្មាធិការចម្រុះអាចកែសម្រួលឧបសម្ព័ន្ធ១៤ក(វិធាននៃនីតិវិធី) និង១៤ខ(ក្រមប្រតិបត្តិសម្រាប់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ)។

**មាត្រា១៤.៣០ _ កិច្ចសហប្រតិបត្តិការ**

គូភាគីត្រូវខិតខំខ្នះខ្នែងដើម្បីឯកភាពលើការបកស្រាយនិងការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយត្រូវខំប្រឹងប្រែងតាមរយៈកិច្ចសហប្រតិបត្តិការ ដើម្បីសម្រេចបាននូវដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាងលើបញ្ហាណាមួយដែលអាចប៉ះពាល់ដល់ប្រតិបត្តិការរបស់ខ្លួន។

## ឧបសម្ព័ន្ធ១៤ក
## វិធានដែនីតិវិធីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ

### កាលវិភាគ

១- បន្ទាប់ពីបានពិគ្រោះជាមួយគូភាគី ក្រុមប្រឹក្សាជំនុំជម្រះត្រូវរៀបចំកាលវិភាគសម្រាប់ដំណើរការក្រុមប្រឹក្សាជំនុំជម្រះ នៅពេលណាមួយដែលអាចធ្វើទៅបានក្នុងកំឡុងពេល៧ថ្ងៃ បន្ទាប់ពីការតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះចុងក្រោយ។ កាលវិភាគជាក់លាក់ដែលភ្ជាប់ទៅនឹងដំណូកនេះគួរតែត្រូវបានប្រើជាគោលការណ៍ណែនាំ។

២- ជាវិធានទូទៅ ដំណើរការរបស់ក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវលើសពី១២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបង្កើតក្រុមប្រឹក្សាជំនុំជម្រះរហូតដល់កាលបរិច្ឆេទនៃបាយការណ៍ស្ថាពរ លើកលែងតែគូភាគីយល់ព្រមផ្សេងពីនេះ។

៣- ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះពិចារណាថា មានភាពចាំបាច់ក្នុងការកែសម្រួលតារាងពេលវេលា ក្រុមប្រឹក្សាជំនុំជម្រះត្រូវជូនដំណឹងដល់គូភាគីជាលាយលក្ខណ៍អក្សរអំពីការកែសម្រួលដែលបានដាក់ស្នើនិងហេតុផលនៃសំណើនេះ។

### សារណាជាលាយលក្ខណ៍អក្សរនិងឯកសារផ្សេងៗទៀត

៤- លើកលែងតែក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្សេងពីនេះ ភាគីដែលប្តឹងតវ៉ាត្រូវបញ្ជូនសារណាជាលាយលក្ខណ៍អក្សរលើកដំបូងរបស់ខ្លួនទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះ ក្នុងរយៈពេលមិនឱ្យលើសពី ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះចុងក្រោយ។ ភាគីរងបណ្តឹង ត្រូវបញ្ជូនសារណាជាលាយលក្ខណ៍អក្សរលើកដំបូងរបស់ខ្លួនទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះ ក្នុងរយៈពេលមិនឱ្យលើសពី២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសារណាជាលាយលក្ខណ៍អក្សរលើកដំបូងរបស់ភាគីប្តឹងតវ៉ា។ ច្បាប់ថតចម្លងត្រូវផ្តល់ជូនសម្រាប់សមាជិកក្រុមប្រឹក្សាជំនុំជម្រះនីមួយៗ។

៥- ភាគីនីមួយៗក៏ត្រូវផ្តល់ច្បាប់ថតចម្លងនៃសារណាជាលាយលក្ខណ៍អក្សរលើកដំបូងរបស់ខ្លួនទៅកាន់ភាគីសមាជិកម្ខាងទៀត ក្នុងពេលដំណាលគ្នាដែលបញ្ជូនទៅក្រុមប្រឹក្សាជំនុំជម្រះ។

៦- ក្នុងកំឡុងពេល២០ថ្ងៃ បន្ទាប់ពីការបញ្ចប់សវនាការ ភាគីនីមួយៗអាចបញ្ជូនទៅក្រុមប្រឹក្សាជំនុំជម្រះនិងភាគីសមាជិកម្ខាងទៀតនូវសារណាជាលាយលក្ខណ៍អក្សរបន្ថែម ដើម្បីឆ្លើយតបទៅនឹងបញ្ហាណាមួយដែលកើតឡើងក្នុងកំឡុងពេលសវនាការ។

៧- គូភាគីត្រូវបញ្ជូនព័ត៌មានទាំងអស់ឬសារណាជាលាយលក្ខណ៍អក្សរ ឯកសារជាលាយលក្ខណ៍អក្សរនៃសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងការឆ្លើយតបចំពោះសំណួរដែលដាក់ដោយក្រុមប្រឹក្សាជំនុំជម្រះ ទៅភាគីសមាជិកម្ខាងទៀតនៃវិវាទ ក្នុងពេលដំណាលគ្នាដែលត្រូវបានដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះ។

៨- រាល់ឯកសារជាលាយលក្ខណ៍អក្សរដែលផ្តល់ទៅឱ្យក្រុមប្រឹក្សាជំនុំជម្រះ ឬដោយភាគីសមាជិកម្ខាងទៅភាគីសមាជិកម្ខាងទៀត ក៏ត្រូវផ្តល់ជាទម្រង់អេឡិចត្រូនិកផងដែរ។

៩- កំហុសឆ្គងគួចតាចរបស់ការងារស្មៀនលើសំណើ សេចក្តីដួនដំណឹង សារណាជាលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងទៀតទាក់ទងនឹងដំណើរការរបស់ក្រុមប្រឹក្សាជំនុំជម្រះ អាចត្រូវបានកែតម្រូវដោយការបញ្ជូនឯកសារថ្មីជំនួសដោយមានការបញ្ជាក់ច្បាស់ពីកំណែប្រែនោះ។

## ប្រតិបត្តិការនៃក្រុមប្រឹក្សាជំនុំជម្រះ

១០- ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវចូលរួមដឹកនាំគ្រប់កិច្ចប្រជុំទាំងអស់។ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើប្រតិភូកម្មជូនប្រធានក្រុមប្រឹក្សានូវសិទ្ធិអំណាចក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងផ្នែករដ្ឋបាលនិងនីតិវិធី។

១១- ការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែរក្សាជាការសម្ងាត់។ មានតែក្រុមប្រឹក្សាជំនុំជម្រះប៉ុណ្ណោះដែលអាចចូលរួមក្នុងការពិភាក្សារបស់ក្រុមប្រឹក្សាជំនុំជម្រះនេះ។ របាយការណ៍នៃក្រុមប្រឹក្សាជំនុំជម្រះ នឹងត្រូវបានព្រាងផ្អែកតាមព័ត៌មានដែលបានផ្តល់និងសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយគ្មានវត្តមានរបស់គូភាគី។

១២- មតិដែលបានបង្ហាញនៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ ដោយសមាជិកក្រុមប្រឹក្សាជំនុំជម្រះនីមួយៗ ត្រូវមានលក្ខណៈអនាមិក។

## សវនាការ

១៣- គូភាគីត្រូវបានផ្តល់ឱកាសឱ្យចូលរួមសវនាការ និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

១៤- កាលវិភាគដែលបានរៀបចំឡើងដោយអនុលោមតាមវិធានទី១ ត្រូវផ្តល់សម្រាប់សវនាការយ៉ាងហោចណាស់មួយសម្រាប់គូភាគីដើម្បីបង្ហាញករណីរបស់ខ្លួនទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះ។

១៥- ក្រុមប្រឹក្សាជំនុំជម្រះអាចបើកសវនាការបន្ថែម ប្រសិនបើគូភាគីឯកភាពដូច្នេះ។

១៦- សមាជិកក្រុមប្រឹក្សាជំនុំជម្រះទាំងអស់ត្រូវមានវត្តមាននៅក្នុងសវនាការ។ សវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើឡើងក្នុងសម័យប្រជុំបិទ ដែលមានតែការចូលរួមពីសមាជិកក្រុមប្រឹក្សាជំនុំជម្រះនិងគូភាគីប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការពិគ្រោះយោបល់ជាមួយគូភាគី ជំនួយការ អ្នកបកប្រែ ឬអ្នកកត់ត្រាដែលបានកំណត់ ក៏អាចមានវត្តមាននៅក្នុងសវនាការ ដើម្បីជួយក្រុមប្រឹក្សាជំនុំជម្រះក្នុងការងាររបស់ខ្លួន។ រាល់ការរៀបចំដែលបង្កើតឡើងដោយក្រុមប្រឹក្សាជំនុំជម្រះអាចត្រូវបានកែប្រែជាមួយនឹងកិច្ចព្រមព្រៀងរបស់គូភាគី។

១៧- សវនាការត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះក្នុងលក្ខណៈមួយដែលធានាបានថា ភាគីប្តឹងតវ៉ា និងភាគីឆ្លើយតបមានពេលវេលាស្មើគ្នាក្នុងការធ្វើបទបង្ហាញលើករណីរបស់ខ្លួន។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវបើកសវនាការតាមវិធីដូចតទៅ អំណះអំណាងរបស់ភាគីប្តឹងតវ៉ា អំណះអំណាងរបស់ភាគីឆ្លើយតប ការឆ្លើយតបរបស់ភាគីប្តឹងតវ៉ា ការឆ្លើយតបរបស់ភាគីឆ្លើយតប សេចក្តីថ្លែងការណ៍បិទរបស់ភាគីប្តឹងតវ៉ា និងសេចក្តីថ្លែងការណ៍បិទរបស់ភាគីឆ្លើយតប។ ប្រធានក្រុមប្រឹក្សាអាចកំណត់ពេលវេលាសម្រាប់អំណះអំណាងផ្ទាល់មាត់ ដើម្បីធានាថាភាគីនីមួយៗត្រូវបានផ្តល់ពេលវេលាស្មើគ្នា។

**សំណួរ**

១៨- ក្រុមប្រឹក្សាជំនុំជម្រះអាចចោទជាសំណួរទៅកាន់ភាគីសមាជិកណាមួយដោយផ្ទាល់ នៅពេលណាក៏ដោយក្នុងកំឡុងនីតិវិធីបណ្តឹង។ គូភាគីត្រូវឆ្លើយតបភ្លាមៗនិងពេញលេញចំពោះសំណើណាមួយរបស់ក្រុមប្រឹក្សាជំនុំជម្រះ សម្រាប់ព័ត៌មានដូចដែលក្រុមប្រឹក្សាជំនុំជម្រះចាត់ទុកថាចាំបាច់និងសមស្រប។

១៩- នៅពេលដែលសំណួរសរសេរជាលាយលក្ខណ៍អក្សរ ភាគីនីមួយៗក៏ត្រូវផ្តល់ច្បាប់ថតចម្លងនៃការឆ្លើយតបរបស់ខ្លួនចំពោះសំណួរនេះទៅភាគីម្ខាងទៀតក្នុងពេលដំណាលគ្នា នៅពេលដែលបញ្ជូនទៅក្រុមប្រឹក្សាជំនុំជម្រះ។ ភាគីនីមួយៗត្រូវផ្តល់ឱកាសឱ្យផ្តល់យោបល់ជាលាយលក្ខណ៍អក្សរលើការឆ្លើយតបរបស់ភាគីសមាជិកម្ខាងទៀត។

**ការសម្ងាត់**

២០- សវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះនិងឯកសារដែលបានដាក់ជូននោះ ត្រូវរក្សាជាការសម្ងាត់។ ភាគីនីមួយៗត្រូវចាត់ទុកនូវរាល់ព័ត៌មាន ដែលផ្តល់ជូនក្រុមប្រឹក្សាជំនុំជម្រះដោយភាគីម្ខាងទៀតជាការសម្ងាត់ នៅពេលដែលភាគីនោះកំណត់ជាការសម្ងាត់។

២១- នៅពេលដែលភាគីណាមួយ កំណត់ថាជាការសម្ងាត់នូវការដាក់សំណើជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅកាន់ក្រុមប្រឹក្សា តាមការស្នើសុំរបស់ភាគីម្ខាងទៀត ត្រូវផ្តល់ឱ្យក្រុមប្រឹក្សាជំនុំជម្រះនិងភាគីម្ខាងទៀតនូវសេចក្តីសង្ខេបដែលមិនមែនជាការសម្ងាត់នៃព័ត៌មាន ដែលមាននៅក្នុងការដាក់សំណើជាលាយលក្ខណ៍អក្សររបស់ខ្លួនដែលអាចត្រូវបានបង្ហាញ ដល់សាធារណជនមិនលើសពី១០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំ។ ពុំមានអ្វីនៅក្នុងវិធានទាំងនេះអាចរារាំងភាគីមិនឱ្យបង្ហាញសេចក្តីថ្លែងការណ៍អំពីជំហររបស់ខ្លួនជាសាធារណៈបានឡើយ។

**តាសាការដារ**

២២- តាសាការដារនៃនីតិវិធីរបស់ក្រុមប្រឹក្សាជំនុំជម្រះ រួមទាំងសារណាជាលាយលក្ខណ៍អក្សរ បទបង្ហាញឬអំណះអំណាងផ្ទាល់មាត់ របាយការណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ និងការទំនាក់ទំនងជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់ទាំងអស់រវាងគូភាគី និងជាមួយក្រុមប្រឹក្សាជំនុំជម្រះត្រូវតែជាភាសាអង់គ្លេស។

**ទីកន្លែង**

២៣- ទីកន្លែងសម្រាប់សវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសម្រេចដោយការព្រមព្រៀងរវាងគូភាគី។ ប្រសិនបើមិនមានការព្រមព្រៀងទេ សវនាការដំបូងនឹងត្រូវធ្វើឡើងនៅលើដែនដីនៃភាគីរងបណ្តឹង ហើយសវនាការបន្តែមណាមួយត្រូវធ្វើឡើងឆ្លាស់គ្នារវាងដែនដីនៃគូភាគី។

**ការចំណាយ**

២៤- ក្រុមប្រឹក្សាជំនុំជម្រះត្រូវរក្សាកំណត់ត្រា និងបង្ហាញគណនីចុងក្រោយនៃការចំណាយទូទៅទាំងអស់ដែលកើតឡើងទាក់ទងនឹងដំណើរការនីតិវិធី រួមទាំងការចំណាយលើជំនួយការរបស់ខ្លួន អ្នកកត់ត្រាដែលបានជ្រើសរើសឬបុគ្គលផ្សេងទៀតដែលខ្លួនជួល។

**កាលវិភាគជាក់លាក់សម្រាប់ក្រុមប្រឹក្សាដំនុំជម្រះ**

ក្រុមប្រឹក្សាដំនុំជម្រះត្រូវបានបង្កើតឡើងនៅថ្ងៃទី...ខែ....ឆ្នាំ.....។

២៥- ការទទួលការដាក់សំណើជាលាយលក្ខណ៍អក្សរលើកដំបូងរបស់គូភាគី៖

(ក) ភាគីប្តឹងតវ៉ា៖ ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតែងតាំងសមាជិកក្រុមប្រឹក្សាដំនុំជម្រះចុងក្រោយ។

(ខ) ភាគីឆ្លើយតប៖ ២០ថ្ងៃ បន្ទាប់ពី (ក)។

២៦- កាលបរិច្ឆេទនៃសវនាការដំបូងជាមួយគូភាគី៖ ២០ថ្ងៃ បន្ទាប់ពីបានទទួលសារណាលើកដំបូងរបស់ភាគីរងបណ្តឹង។

២៧- ការទទួលសារណាជាលាយលក្ខណ៍អក្សរបន្ថែមរបស់គូភាគី៖ ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសវនាការដំបូង។

២៨- ការចេញរបាយការណ៍ដំបូងដល់គូភាគី៖ ៩០ថ្ងៃនៃកាលបរិច្ឆេទនៃការតែងតាំងសមាសភាពក្រុមប្រឹក្សាដំនុំជម្រះ។

២៩- ថ្ងៃផុតកំណត់សម្រាប់គូភាគីក្នុងការផ្តល់មតិជាលាយលក្ខណ៍អក្សរលើរបាយការណ៍ដំបូង៖ ១៥ ថ្ងៃ បន្ទាប់ពីការចេញរបាយការណ៍ដំបូង។

៣០- ការចេញរបាយការណ៍ស្ថាពរដល់គូភាគី៖ ក្នុងរយៈពេល១២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទតែងតាំងសមាសភាពនៃក្រុមប្រឹក្សាដំនុំជម្រះ។

## ឧបសម្ព័ន្ធ១៤ខ
## ក្រមប្រតិបត្តិសម្រាប់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ

### និយមន័យ

១- សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

(ក) **ជំនួយការ** សំដៅដល់បុគ្គលធ្វើការស្រាវជ្រាវឬផ្តល់ការគាំទ្រដល់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ដែលស្ថិតនៅក្រោមលក្ខខណ្ឌនៃការតែងតាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះ

(ខ) **សមាជិកក្រុមប្រឹក្សាជំនុំជម្រះ** សំដៅដល់សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះដែលបានបង្កើតឡើងក្រោមមាត្រា១៤.៧

(គ) **នីតិវិធីបណ្តឹង** សំដៅដល់នីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះស្ថិតនៅក្រោមជំពូកនេះ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ និង

(ឃ) **បុគ្គលិក** ពាក់ព័ន្ធនឹងសមាជិកក្រុមប្រឹក្សាជំនុំជម្រះ សំដៅដល់បុគ្គលដែលស្ថិតក្រោមការចង្អុលបង្ហាញនិងការគ្រប់គ្រងរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ក្រៅពីជំនួយការ។

### ទំនួលខុសត្រូវក្នុងដំណើរការ

២- រាល់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចៀសវាងនូវការប្រព្រឹត្តមិនត្រឹមត្រូវ និងការស្តែងឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវ ត្រូវមានឯករាជ្យភាពនិងមិនលម្អៀង ត្រូវចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់និងដោយប្រយោល ហើយត្រូវគោរពតាមបទដ្ឋានប្រតិបត្តិខ្ពស់ ដើម្បីរក្សាសុចរិតភាពនិងភាពមិនលម្អៀងនៃដំណើរការដោះស្រាយវិវាទ។ អតីតសមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវតែអនុលោមតាមកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌ១៨ ដល់២១។

### កាតព្វកិច្ចលាតត្រដាង

៣- មុនពេលបញ្ជាក់អំពីការជ្រើសរើសរបស់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះនៅក្រោមកិច្ចព្រមព្រៀងនេះ បេក្ខជនត្រូវលាតត្រដាងផលប្រយោជន៍ ទំនាក់ទំនង ឬបញ្ហាដែលទំនងជាប៉ះពាល់ដល់ឯករាជ្យភាពឬភាពមិនលម្អៀង ឬដែលអាចបង្កើតឱ្យមានការស្តែងឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវឬភាពលម្អៀងនៅក្នុងនីតិវិធីបណ្តឹង។ ក្នុងន័យនេះ បេក្ខជនត្រូវព្យាយាមប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យបានដឹងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហាដែលអាចកើតឡើងទាំងនេះ។

៤- នៅពេលត្រូវបានជ្រើសរើស សមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវបន្តព្យាយាមប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យបានដឹងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហានានាដែលអាចកើតឡើង ដូចមានចែងក្នុងកថាខណ្ឌ៣ ហើយត្រូវលាតត្រដាងបញ្ហាទាំងនោះ ដោយទំនាក់ទំនងជាលាយលក្ខណ៍អក្សរទៅកាន់គណៈកម្មាធិការចម្រុះ ដើម្បីធ្វើការពិនិត្យដោយគូភាគី។ កាតព្វកិច្ចក្នុងការលាតត្រដាង គឺជាកាតព្វកិច្ចនៅបន្តមាន ដែលតម្រូវឱ្យសមាជិកក្រុមប្រឹក្សាជំនុំជម្រះលាតត្រដាងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហានានាដែលអាចកើតឡើងក្នុងដំណាក់កាលណាមួយនៃនីតិវិធីបណ្តឹង។

**ការអនុវត្តភាតព្វកិច្ចដោយសមាជិកក្រុមប្រឹក្សាជំនុំជម្រះ**

៥- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះនិងវិធាននៃនីតិវិធីដែលអាចអនុវត្តបានក្នុងឧបសម្ព័ន្ធ១៤ក(វិធាននៃនីតិវិធី)។

៦- នៅពេលជ្រើសរើស សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបំពេញការកិច្ចរបស់ខ្លួនឱ្យបានហ្មត់ចត់និងឆាប់រហ័សក្នុងរយៈពេលនៃនីតិវិធីបណ្តឹងដោយយុត្តិធម៌និងយកចិត្តទុកដាក់។

៧- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវបដិសេធសមាជិកក្រុមប្រឹក្សាជំនុំជម្រះផ្សេងទៀត ចំពោះឱកាសចូលរួមក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃនីតិវិធីបណ្តឹង។

៨- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវពិចារណាចំពោះតែបញ្ហាណាដែលបានលើកឡើងក្នុងនីតិវិធីបណ្តឹង និងចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេច ហើយមិនត្រូវប្រគល់ការកិច្ចក្នុងការសម្រេចចិត្តទៅឱ្យបុគ្គលណាម្នាក់ឡើយ។

៩- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់វិធានការដែលសមស្រប ដើម្បីធានាថាជំនួយការនិងបុគ្គលិករបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ យល់ដឹងនិងអនុលោមតាមកថាខណ្ឌ២ ៣ ៤ ១៩ ២០ និង២១។

១០- សមាជិកក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវពាក់ព័ន្ធក្នុងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង ក្នុងនីតិវិធីបណ្តឹងទេ។

១១- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវផ្សព្វផ្សាយរាល់បញ្ហារបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះផ្សេងទៀត ចំពោះការរំលោភជាក់ស្តែងឬដែលអាចកើតមានក្រោមឧបសម្ព័ន្ធនេះ លុះត្រាតែការផ្សព្វផ្សាយធ្វើឡើងរវាងភាគីសមាជិកទាំងពីរ ឬជាការចាំបាច់ដើម្បីបញ្ជាក់ថាសមាជិកក្រុមប្រឹក្សាជំនុំជម្រះនោះបានបំពានឬអាចបំពានឧបសម្ព័ន្ធនេះ។

**ឯករាជ្យភាពនិងភាពមិនលម្អៀងនៃសមាជិកក្រុមប្រឹក្សាជំនុំជម្រះ**

១២- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវតែឯករាជ្យនិងមិនលម្អៀង។ សមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវអនុវត្តការងារដោយយុត្តិធម៌ និងចៀសវាងការប្រព្រឹត្តមិនត្រឹមត្រូវឬលម្អៀង។

១៣- សមាជិកក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវទទួលឥទ្ធិពលពីផលប្រយោជន៍ផ្ទាល់ខ្លួន សម្ពាធពីខាងក្រៅ ថ្នូរនយោបាយ ការតវ៉ាជាសាធារណៈ ភាពស្មោះត្រង់ចំពោះភាគីសមាជិកណាមួយ ឬការភ័យខ្លាចចំពោះការរិះគន់។

១៤- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវទទួលភាតព្វកិច្ចណាមួយឬទទួលយកអត្ថប្រយោជន៍ណាមួយ ដែលនឹងជ្រៀតជ្រែកឬហាក់ដូចជាជ្រៀតជ្រែក ដោយផ្ទាល់ឬដោយប្រយោលទៅនឹងការបំពេញការកិច្ចយ៉ាងត្រឹមត្រូវរបស់សមាជិកក្រុមប្រឹក្សានោះទេ។

១៥- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវប្រើតួនាទីរបស់ខ្លួនក្នុងក្រុមប្រឹក្សាជំនុំជម្រះដើម្បីពង្រីកផលប្រយោជន៍ផ្ទាល់ខ្លួនឬឯកជនណាមួយឡើយ។ សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវជៀសវាងសកម្មភាពដែលអាចបង្កើតចំណាប់អារម្មណ៍ថា បុគ្គលផ្សេងទៀតស្ថិតនៅក្នុងមុខតំណែងពិសេសមួយមានឥទ្ធិពលដល់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ។ សមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រឹងប្រែង

គ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់ឬបង្ហាក់បុគ្គលនោះពីការបង្ហាញខ្លួនថាស្ថិតក្នុងមុខតំណែងពិសេសនោះ។

១៦- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវអនុញ្ញាតឱ្យហិរញ្ញវត្ថុ អាជីវកម្ម វិជ្ជាជីវៈ ទំនាក់ទំនងគ្រួសារ ឬសង្គម ឬទំនួលខុសត្រូវ ពីអតីតកាលឬដែលកំពុងមានស្រាប់ មានឥទ្ធិពលលើការប្រព្រឹត្តឬការវិនិច្ឆ័យរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះឡើយ។

១៧- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចៀសវាងការចូលទៅក្នុងទំនាក់ទំនងណាមួយ ឬការទទួលយកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុណាមួយ ដែលទំនងជាប៉ះពាល់ដល់ភាពលម្អៀងរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ឬដែលអាចបង្កើតឱ្យមានការប្រព្រឹត្តមិនត្រឹមត្រូវឬលម្អៀង។

**ភាពឯកិច្ចក្នុងស្ថានភាពជាអំណាត់**

១៨- សមាជិកក្រុមប្រឹក្សាជំនុំជម្រះឬអតីតសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចៀសវាងសកម្មភាពដែលអាចបង្កើតការបង្ហាញថា សមាជិកក្រុមប្រឹក្សាជំនុំជម្រះមានភាពលម្អៀងក្នុងការបំពេញភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ឬនឹងទទួលបានអត្ថប្រយោជន៍ពីសេចក្តីសម្រេចឬរបាយការណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ។

**ការរក្សាការសម្ងាត់**

១៩- សមាជិកក្រុមប្រឹក្សាជំនុំជម្រះឬអតីតសមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវលាតត្រដាងឬប្រើប្រាស់ព័ត៌មានមិនមែនជាសាធារណៈក្នុងពេលណាក៏ដោយ ទាក់ទងនឹងនីតិវិធីបណ្តឹង ឬបានទទួលក្នុងកំឡុងពេល លើកលែងតែសម្រាប់គោលបំណងរបស់នីតិវិធីបណ្តឹង ហើយក្នុងករណីណាក៏ដោយ មិនត្រូវលាតត្រដាង ឬប្រើប្រាស់ព័ត៌មាននោះ ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនឬផលប្រយោជន៍សម្រាប់អ្នកដទៃ ឬប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ។

២០- សមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវលាតត្រដាងរបាយការណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ ឬផ្នែកណាមួយនៃរបាយការណ៍ មុនពេលការបោះពុម្ពផ្សាយនោះទេ។

២១- សមាជិកក្រុមប្រឹក្សាជំនុំជម្រះឬអតីតសមាជិកក្រុមប្រឹក្សាជំនុំជម្រះ នៅពេលណាក៏ដោយ មិនត្រូវលាតត្រដាងការពិភាក្សារបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬទស្សនៈរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះណាមួយ លើកលែងតែមានការតម្រូវដោយច្បាប់ឬដំណើរមន្តញ្ញ។

# ជំពូកទី១៥
# ការលើកលែង

## មាត្រា១៥.១ _ ការលើកលែងទូទៅ

១- សម្រាប់គោលបំណងនៃជំពូកទី២(ពាណិជ្ជកម្មទំនិញ) ទី៣(វិធានដើមកំណើតទំនិញ) ទី៤ (នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម) ទី៥(វិធានការអនាម័យនិងកូតតាមអនាម័យ) ទី៦ (របាំងបច្ចេកទេសពាណិជ្ជកម្ម) មាត្រា XX របស់ GATT ១៩៩៤ រួមទាំងកំណត់បកស្រាយនានា ត្រូវបានដាក់បញ្ចូលនិងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដោយ*ត្រូវយកមកអនុវត្តដូចគ្នា*។

២- សម្រាប់គោលបំណងនៃជំពូកទី៨(ពាណិជ្ជកម្មសេវាកម្ម)និងជំពូកទី៩(ពាណិជ្ជកម្មឌីជីថល)[1] មាត្រាXIV របស់GATT ១៩៩៤ រួមទាំងកំណត់យោងត្រូវបានដាក់បញ្ចូលនិងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដោយ*ត្រូវយកមកអនុវត្តដូចគ្នា*។

## មាត្រា១៥.២ _ ការលើកលែងដោយមូលហេតុសន្តិសុខ

មិនមានបទប្បញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បី៖

(ក) តម្រូវឱ្យភាគីសមាជិកម្នាងផ្តល់ព័ត៌មានណាក៏ដោយ ដែលការលាតត្រដាងព័ត៌មានទាំងនោះត្រូវបានភាគីនោះចាត់ទុកថាផ្ទុយនឹងផលប្រយោជន៍ សន្តិសុខដ៏ចាំបាច់របស់ខ្លួន ឬ

(ខ) រារាំងភាគីសមាជិកម្នាងពីការធ្វើសកម្មភាពដែលខ្លួនចាត់ទុកថាចាំបាច់ សម្រាប់ការការពារផលប្រយោជន៍សន្តិសុខរបស់ខ្លួន៖

(i) ពាក់ព័ន្ធនឹងសារធាតុដែលអាចបំផ្ទុះបាន និងបញ្ចូលគ្នាបាន ឬវត្ថុធាតុដែលផលិតចេញពីវត្ថុធាតុទាំងនោះ

(ii) ពាក់ព័ន្ធនឹងចរាចរណ៍សព្វាវុធ គ្រាប់រំសេវ និងយុទ្ធភណ្ឌសង្គ្រាម និងពាក់ព័ន្ធនឹងចរាចរណ៍ទំនិញនិងសម្ភារៈផ្សេងទៀត ដែលប្រព្រឹត្តដោយផ្ទាល់ឬដោយប្រយោលសម្រាប់គោលបំណងផ្គត់ផ្គង់ដល់អង្គភាពយោធា

(iii) ពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មដែលប្រព្រឹត្តដោយផ្ទាល់ឬដោយប្រយោលសម្រាប់គោលបំណងរៀបចំអង្គភាពយោធា

(iv) ពាក់ព័ន្ធនឹងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ រួមមានហេដ្ឋារចនាសម្ព័ន្ធប្រាស្រ័យទាក់ទងសំខាន់ៗ ហេដ្ឋារចនាសម្ព័ន្ធថាមពល និងហេដ្ឋារចនាសម្ព័ន្ធទឹក ពីការប៉ុនប៉ងដោយចេតនាធ្វើឱ្យបញ្ឈប់ដំណើរការឬធ្វើឱ្យខូចខាតគុណភាពហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(v) នៅពេលប្រទេសជាតិត្រូវបានដាក់ក្នុងភាពអាសន្ន ឬសង្គ្រាម ឬភាពអាសន្នផ្សេងៗទៀតក្នុងទំនាក់ទំនងអន្តរជាតិ ឬ

---

[1] កថាខណ្ឌនេះមិនប៉ះពាល់ចំពោះថាតើភាគីសមាជិកម្នាងចាត់ទុកផលិតផលឌីជីថលថាជាទំនិញឬសេវាឡើយ។

(គ) ដើម្បីទប់ស្កាត់ភាគីសមាជិកម្ខាងពីការធ្វើសកម្មភាពណាមួយក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សម្រាប់ការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

**មាត្រា១៥.៣ _ ពន្ធដារ**

១- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះវិធានការដាក់ពន្ធដារណាមួយឡើយ[2]។

២- មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីសមាជិកក្រោមអនុសញ្ញាពន្ធដារណាមួយឡើយ។ ក្នុងករណីមានអសង្គតិភាពណាមួយរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញាពន្ធដារទាំងនោះ អនុសញ្ញាពន្ធដារនោះនឹងត្រូវយកជាគោលត្រឹមចំនុចអសង្គតិភាពទាំងនោះ។

[2] ដើម្បីបញ្ជៀសភាពមិនច្បាស់លាស់ បទប្បញ្ញត្តិដែលសិទ្ធិនិងកាតព្វកិច្ចដែលត្រូវធ្វើកំ ត្រូវបានផ្តល់ឱ្យឬកំណត់ក្រោមកិច្ចព្រមព្រៀងWTO ត្រូវអនុវត្តចំពោះវិធានការពន្ធដារ។

## ជំពូកទី១៦
## រដ្ឋបាលនៃកិច្ចព្រមព្រៀង

**មាត្រា១៦.១ _ គណៈកម្មាធិការចម្រុះ**

១- គូភាគីតទៅនេះព្រមព្រៀងគ្នាបង្កើតគណៈកម្មាធិការចម្រុះមួយ។

២- គណៈកម្មាធិការចម្រុះ៖

(ក) ត្រូវមានសមាសភាពពីតំណាងកម្ពុជានិងអេមីរ៉ាតអារ៉ាប់រួម និង

(ខ) អាចបង្កើតអនុគណៈកម្មាធិការអេចវ៉ែន្ត្រយ៍ឬចំពោះកិច្ច ឬក្រុមការងារ ហើយប្រគល់សិទ្ធិនូវអំណាចណាមួយរបស់ខ្លួននោះ។

៣- គណៈកម្មាធិការចម្រុះត្រូវរៀបចំប្រជុំ ក្នុងកំឡុងរយៈពេលមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់មក គណៈកម្មាធិការចម្រុះនឹងត្រូវប្រជុំរៀងរាល់ពីរឆ្នាំម្តង ដើម្បីពិចារណាលើបញ្ហាណាមួយដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។ សម័យប្រជុំទៀងទាត់នៃគណៈកម្មាធិការចម្រុះ ត្រូវធ្វើឡើងឆ្លាស់គ្នាក្នុងដែនដីរបស់គូភាគី។

៤- គណៈកម្មាធិការចម្រុះក៏ត្រូវរៀបចំសម័យប្រជុំពិសេស ដោយមិនមានការពន្យារពេល ចាប់ពីកាលបរិច្ឆេទនៃសំណើពីភាគីសមាជិកណាមួយ។

៥- មុខងាររបស់គណៈកម្មាធិការចម្រុះមានដូចខាងក្រោម៖

(ក) ពិនិត្យនិងវាយតម្លៃលទ្ធផលនិងប្រតិបត្តិការរួមនៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកតាមបទពិសោធនដែលទទួលបានក្នុងកំឡុងពេលអនុវត្តនិងគោលបំណងរបស់ខ្លួន

(ខ) ពិចារណាលើវិសោធនកម្មណាមួយលើកិច្ចព្រមព្រៀងនេះ ដែលអាចត្រូវបានស្នើឡើងដោយភាគីណាមួយ រួមទាំងការកែប្រែសម្បទានដែលធ្វើឡើងក្រោមកិច្ចព្រមព្រៀងនេះ

(គ) ខិតខំដោះស្រាយវិវាទដោយមិត្តភាពរវាងគូភាគីដែលកើតចេញពីការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ

(ឃ) ត្រួតពិនិត្យ និងសម្របសម្រួលការងាររបស់អនុគណៈកម្មាធិការនិងក្រុមការងារទាំងអស់ដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ

(ង) ពិចារណាលើបញ្ហាផ្សេងទៀតដែលអាចប៉ះពាល់ដល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ

(ច) ស្នើសុំការបកស្រាយដែលបានព្រមព្រៀងគ្នាទៅវិញទៅមក ចំពោះបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ប្រសិនបើត្រូវបានស្នើសុំដោយភាគីណាមួយ

(ឆ) អនុម័តសេចក្តីសម្រេច ឬផ្តល់អនុសាសន៍តាមការព្រមព្រៀងដោយកិច្ចព្រមព្រៀងនេះ និង

(ជ) អនុវត្តមុខងារផ្សេងទៀតតាមការព្រមព្រៀងដោយគូភាគី។

៦- គណៈកម្មាធិការចម្រុះត្រូវបង្កើតនីតិវិធីការងាររបស់ខ្លួន ដែលនឹងត្រូវក្លាយជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ។

៧- កិច្ចប្រជុំនៃគណៈកម្មាធិការចម្រុះនិងអនុគណៈកម្មាធិការអេចវ៉ែន្ត្រយ៍ឬចំពោះកិច្ច ឬក្រុមការងារអាចរៀបចំឡើងជាលក្ខណៈរូបវន្តឬក្នុងទម្រង់ផ្សេងទៀតដែលកំណត់ដោយគូភាគី។

**មាត្រា១៦.២ _ ការប្រាស្រ័យទាក់ទង**

១- ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការចូលជាធរមាន ភាគីនីមួយៗត្រូវតែតាំងចំណុចទាក់ទងមួយរូប ដើម្បីទទួលនិងសម្រួលការប្រាស្រ័យទាក់ទងផ្លូវការរវាងគូភាគី លើបញ្ហាទាំងឡាយដែលទាក់ទង នឹងកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗត្រូវជូនដំណឹងដល់ភាគីម្ខាងទៀតឱ្យបានឆាប់តាមដែល អាចធ្វើបានអំពីការផ្លាស់ប្តូរណាមួយចំពោះចំនុចទំនាក់ទំនងនោះ។

២- រាល់ការប្រាស្រ័យទាក់ទងផ្លូវការទាំងអស់ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ត្រូវតែធ្វើឡើងជា ភាសាអង់គ្លេស។

# ជំពូកទី១៧
# អវសានប្បញ្ញត្តិ

## មាត្រា១៧.១ _ឧបសម្ព័ន្ធ លិខិតភ្ជាប់ និងកំណត់សម្គាល់

ឧបសម្ព័ន្ធ លិខិតភ្ជាប់ និងលេខយោងនៃកិច្ចព្រមព្រៀងនេះ ត្រូវក្លាយជាផ្នែកដែលមិនអាចខ្វះបាននៃកិច្ចព្រមព្រៀងនេះទាំងមូល។

## មាត្រា១៧.២ _ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

១. គូភាគីបញ្ជាក់ឡើងវិញពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ដែលមាននៅក្រោមកិច្ចព្រមព្រៀងWTO និងកិច្ចព្រមព្រៀងដទៃទៀតដែលគូភាគីជាភាគីសមាជិក។

២. ប្រសិនបើភាគីម្ខាងពិចារណាថា បទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងមានអសង្គតិភាពជាមួយនឹងបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងដ៏ទៃទៀតដែលគូភាគីជាសមាជិក នៅពេលមានការស្នើសុំ គូភាគីត្រូវពិគ្រោះយោបល់ក្នុងគោលបំណងស្វែងរកដំណោះស្រាយ ដែលមានការពេញចិត្តទាំងសងខាង។ កថាខណ្ឌនេះមិនត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគី ក្រោមជំពូកទី១៤(ការដោះស្រាយវិវាទ) ឡើយ។

៣. សម្រាប់គោលបំណងនៃការអនុវត្តកិច្ចព្រមព្រៀងនេះ គូភាគីឯកភាពគ្នាថា ករណីដែលកិច្ចព្រមព្រៀងមួយផ្តល់នូវប្រព្រឹត្តកម្មដែលអនុគ្រោះចំពោះទំនិញ សេវាកម្ម វិនិយោគ ឬបុគ្គល ជាងដែលផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងនេះ ពុំសំដៅដល់អសង្គតិភាពជាមួយនឹងខ្លឹមសារនៃកថាខណ្ឌ២ ឡើយ។

## មាត្រា១៧.៣ _វិសោធនកម្ម

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយឬបទប្បញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនោះ ដែលត្រូវបានយោងឬត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើវិសោធនកម្ម ឬកិច្ចព្រមព្រៀងអន្តរជាតិនោះត្រូវបានជំនួសដោយកិច្ចព្រមព្រៀងអន្តរជាតិមួយផ្សេងទៀត គូភាគីត្រូវពិគ្រោះយោបល់និងឯកភាពគ្នា ផ្អែកលើការស្នើសុំនៃភាគីណាមួយ ថាតើមានការចាំបាច់ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះដែរឬទេ។

២. ភាគីទាំងសងខាងអាចដាក់សំណើសុំការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះទៅគណៈកម្មាធិការចម្រុះ សម្រាប់សេចក្តីសម្រេចនិងអនុសាសន៍។

៣. បន្ទាប់ពីការផ្តល់អនុសាសន៍ដោយគណៈកម្មាធិការចម្រុះ ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះនឹងត្រូវបានដាក់ជូនគូភាគីសម្រាប់ការអនុម័តឬការផ្តល់សច្ចាប័ន ស្របទៅតាមនីតិវិធីតម្រូវដោយរដ្ឋធម្មនុញ្ញឬនីតិវិធីច្បាប់ផ្ទៃក្នុងរៀងៗខ្លួន។

៤. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងបែបបទដូចគ្នា ដូចមានចែងនៅក្នុងមាត្រា១៧.៣ នៃដំពូកនេះ។

## មាត្រា១៧.៤ _ ការត្រួតពិនិត្យទៅឡើងវិញ

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ គូភាគីត្រូវធ្វើការពិនិត្យឡើងវិញលើការប្តេជ្ញាចិត្តរបស់ខ្លួន ក្រោមពាណិជ្ជកម្មសេវាកម្ម ក្នុងគោលបំណងបង្កើនពាណិជ្ជកម្មរវាងគូភាគី ក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២. គូភាគីត្រូវត្រួតពិនិត្យទូទៅឡើងវិញ នូវកិច្ចព្រមព្រៀងនេះជារៀងរាល់ប្រាំឆ្នាំម្តងបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ក្នុងគោលបំណងធ្វើបច្ចុប្បន្នកម្មនិងធ្វើឱ្យមានភាពប្រសើរឡើង ដើម្បីជានាថាកិច្ចព្រមព្រៀងនេះនៅតែពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មនិងវិនិយោគ រួមទាំងបញ្ហាប្រឈមនានាដែលគូភាគីជួបប្រទះ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

៣. ក្នុងការត្រួតពិនិត្យឡើងវិញដោយអនុលោមតាមមាត្រានេះ គូភាគីត្រូវ៖

(ក) ពិចារណាលើមធ្យោបាយនានា ដើម្បីលើកកម្ពស់បន្ថែមទៀតនូវទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងគូភាគី និង

(ខ) ពិចារណាចំពោះ៖

(i) កិច្ចការរបស់គណៈកម្មាធិការចម្រុះ អនុគណៈកម្មាធិការ និងអង្គភាពក្រោមឱវាទទាំងអស់ ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមជំពូកទី១៦(រដ្ឋបាលនៃកិច្ចព្រមព្រៀង) និង

(ii) ការអភិវឌ្ឍពាក់ព័ន្ធនានានៅលើវេទិកាអន្តរជាតិ។

## មាត្រា១៧.៥ _ ការចូលជាសមាជិក

១. កិច្ចព្រមព្រៀងនេះ ត្រូវបើកចំហសម្រាប់ការចូលជាសមាជិកដោយប្រទេសឬដោយក្រុមប្រទេសណាមួយ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ ប្រទេសឬក្រុមប្រទេសណាមួយអាចយល់ព្រមលើកិច្ចព្រមព្រៀងនេះ ផ្អែកលើបញ្ញត្តិនិងលក្ខខណ្ឌនានា ដូចដែលអាចឯកភាពគ្នារវាងបណ្តាប្រទេសឬក្រុមប្រទេស និងគូភាគី។

២. ប្រទេសឬក្រុមប្រទេសអាចស្នើសុំចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ដោយការដាក់ជូននូវសំណើជាលាយលក្ខណ៍អក្សរតាមរយៈការទូតទៅគូភាគី។

៣. ផ្អែកលើបញ្ញត្តិនិងលក្ខខណ្ឌដែលបានឯកភាពគ្នាដោយអនុលោមតាមកថាខណ្ឌ១ ប្រទេសឬក្រុមប្រទេសត្រូវក្លាយជាភាគីសមាជិកនៃកិច្ចព្រមព្រៀងនេះ ក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលភាគីទាំងអស់ដែលស្នើសុំចូលជាសមាជិក បានជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈការទូត អំពីការបំពេញនីតិវិធីផ្ទៃក្នុងរៀងៗខ្លួនរួចរាល់។

៤. បន្ថែមលើមាត្រានេះ នីតិវិធីការចូលជាសមាជិក ត្រូវបានអនុវត្ត ដោយអនុលោមទៅតាមនីតិវិធីសម្រាប់ការចូលជាសមាជិក ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការចម្រុះ។

៥. ទោះបីជាចែងក្នុងកថាខណ្ឌខាងលើក៏ដោយ មាត្រានេះ ពុំត្រូវបានបកស្រាយ ដើម្បីរាំងភាគីណាមួយនៃកិច្ចព្រមព្រៀងនេះ ពីការចូលរួមក្នុងការចរចាទ្វេភាគី ឬការចរចាពហុភាគីជាមួយប្រទេស ឬក្រុមប្រទេសណាមួយ ដែលស្វែងរកការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះទេ។

**មាត្រា ១៧.៦៖ ថេរវេលា និងការបញ្ចប់**

១. កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពសម្រាប់រយៈពេលមិនកំណត់។

២. ភាគីទាំងសងខាងអាចបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ តាមរយៈផ្លូវការទូតទៅភាគីម្ខាងទៀត ហើយការបញ្ចប់នេះ ត្រូវចូលជាធរមានរយៈពេលប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

**មាត្រា ១៧.៧ ការចូលជាធរមាន**

កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃកំណត់ទូតផ្លូវការចុងក្រោយ ដែលគូភាគីជូនដំណឹងគ្នាទៅវិញទៅមកថា ខ្លួនបានបំពេញនូវតម្រូវការ និងនីតិវិធីផ្លូវច្បាប់ផ្ទៃក្នុងចាំបាច់ទាំងអស់ សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះរួចរាល់ហើយ ឬកាលបរិច្ឆេទណាមួយបន្ទាប់ពីការផ្លាស់ប្តូរកំណត់ទូត ដូចដែលត្រូវបានព្រមព្រៀងគ្នាដោយគូភាគី។

**មាត្រា ១៧.៨ អត្ថបទយថាភូត**

កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងជាខេមរភាសា ភាសាអារ៉ាប់ និងភាសាអង់គ្លេស ។ អត្ថបទទាំងអស់មានតម្លៃ និងយថាភូតភាពដូចគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេសត្រូវយកជាគោល។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

**ធ្វើ**នៅរាជធានីភ្នំពេញ, ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣។

| **សម្រាប់រាជរដ្ឋាភិបាល<br>នៃព្រះរាជាណាចក្រកម្ពុជា** | **សម្រាប់រដ្ឋាភិបាល<br>នៃអេមីរ៉ាតអារ៉ាប់រួម** |
|---|---|